រកទទួលទានជាជនសាមញ្ញ ។ ក្រោយរបបប្រល័យពូជសាសន៍ **ប៉ុល-ពត** នាចុងឆ្នាំ ១៩៧៩ ខ្ញុំបានភៀសខ្លួន ចូលមកនៅជំរំខាវអ៊ីដាង នៅក្នុងទឹកដីនៃប្រទេសថៃ ។ នៅខែសីហា ១៩៨១ ត្រូវបានរដ្ឋាភិបាលអាមេរិកកាំង អនុញ្ញាតឲ្យចូលមករស់នៅ ក្នុងទឹកដីនៃសហរដ្ឋអាមេរិក ក្នុងនាមជាជនភៀសខ្លួន នៅក្រុងឡុងប៊ិច (Long Beach) រដ្ឋកាលីហ្វ័រញ៉ា (California) ។

ជីវិតក្នុងទឹកដីថ្មីនេះ ខ្ញុំឆ្លៀតឱកាស បន្តវិជ្ជា នៅមហាវិទ្យាល័យ ទីក្រុងឡុងប៊ិច អស់រយៈពេលបីឆ្នាំ ។ នៅថ្ងៃទី ៨ ខែមិថុនា ១៩៨៤ (June 08, 1984) ខ្ញុំបានទទួលអនុបរិញ្ញាបត្រផ្នែកអេលិចត្រូនិច (The Degree of Associate in Science majoring Electronic Technology) ។

ឆាកជីវិតរបស់ខ្ញុំ ថ្វីបើខ្ញុំពុំបានសិក្សាខ្ពង់ខ្ពស់វែងឆ្ងាយ ប៉ុន្តែដោយខ្ញុំជឿជាក់លើព្រះពុទ្ធសាសនា ដើរតាមគន្លងព្រះពុទ្ធោវាទ ប្រកាន់យកមាគ៌ាខ្លះនៃមាគ៌ាទាំង ៨ គឺប្រកាន់នូវ សម្មាវាយាមៈ (ការប្រឹងប្រែងព្យាយាមត្រូវ) សម្មាកម្មន្តៈ (ការងារត្រឹមត្រូវ) និង សម្មាអាជីវៈ(ការចិញ្ចឹមជីវិតត្រឹមត្រូវ) ខ្សែជីវិតខ្ញុំបានជួបប្រទះនូវសេចក្តីសុខចំរើន មានជីវភាពសមរម្យ ក្នុងទឹកដីថ្មី ។



# អារម្ភកថា

សៀវភៅ **ព្រះពុទ្ធដីកា** នេះ គឺជាវណ្ណកម្មទីពីរ របស់ខ្ញុំបន្ទាប់អំពីសៀវភៅ **ត្រីស្តីកម្មផល** ដែលបានទទួលការគាំទ្រយ៉ាងច្រើនបន្តូរ ពីសំណាក់សប្បុរសជនលោកអ្នកអាន ពីគ្រប់មជ្ឈដ្ឋាន ជាហេតុជម្រុញទឹកចិត្តខ្ញុំ ឲ្យកាន់តែមានសេចក្តីក្លាហានមានវិរិយភាព និង មោទនភាព ក្នុងកិច្ចការប្រមូលចងក្រង ជាសៀវភៅផ្នែកពុទ្ធសាសនា តទៅអនាគតទៀត ។

ខ្ញុំខំប្រឹងប្រែង ពុះពារឧបសគ្គគ្រប់យ៉ាង ចងក្រងសៀវភៅ **ព្រះពុទ្ធដីកា** នេះ ហើយចាត់ការបោះពុម្ពផ្សាយ ចែកចាយជាធម្មទាន លុះត្រាតែបានសម្រេចជាស្ថាពរ ក្នុងគោលបំណងបណ្តុះឧបនិស្ស័យរបស់ខ្ញុំ ក្នុងថ្នាលព្រះពុទ្ធសាសនា និង ពង្រឹងពង្រីកចំណេះដឹងផ្ទាល់ខ្លួនរបស់ខ្ញុំ ក្នុងវិស័យព្រះធម៌ ដែលមាន **បរិយត្តិ បដិបត្តិ** និង **បដិវេធ** ។ ជាពិសេស ខ្ញុំមានបំណងឲ្យសប្បុរសជនអស់លោកមិត្តអ្នកអាន បានជ្រួតជ្រាបនូវអត្ថន័យពិត នៃ **ព្រះពុទ្ធដីកា** របស់ព្រះពុទ្ធទាំងឡាយថា ៖

១- **សព្វបាបស្ស អករណំ** ការមិនធ្វើបាបទាំងពួង,

២- **កុសលស្សូបសម្បទា** ការបំពេញកុសល,

៣- **សចិត្តបរិយោទបនំ** ការធ្វើចិត្តរបស់ខ្លួនឲ្យស្អាតផូរផង់។

ដោយសារខ្ញុំបាទ ពុំមែនជាធម្មាចារ្យផ្នែកបរិយត្តិ និង ផ្នែកវិបស្សនា ក្នុងការអធិប្បាយព្រះពុទ្ធដីកាខាងលើនេះ ខ្ញុំពុំបានបរិយាយឲ្យអស់អាថ៌សេចក្តី ពន្យល់ន័យឲ្យល្អិតសុខុមឡើយ ។ ម៉្យាងទៀត ពុទ្ធវចនៈ **សចិត្តបរិយោទបនំ** (ការធ្វើចិត្តរបស់ខ្លួនឲ្យស្អាតផូរផង់) មានទាក់ទងដល់វិបស្សនាកម្មដ្ឋាន ឬ សតិបដ្ឋាន នោះ ក៏ខ្ញុំបាទ ពុំបានសរសេរជារបៀបបង្ហាត់បច្ចេកទេសចម្រើនកម្មដ្ឋានទាំងឡាយនោះផងដែរ ព្រោះកិច្ចការនេះ វាហួសពីសមត្ថភាពរបស់ខ្ញុំ ។

ប្រសិនបើសប្បុរសជន ចាប់អារម្មណ៍នឹងវិបស្សនាកម្មដ្ឋាន ឬ សតិបដ្ឋាន គួរស្រាវជ្រាវអានព្រះត្រៃបិដក ភាគទី ១៧ ទំព័រ ២៤៤ បន្ថែមទៀត នឹងបានជ្រាបច្បាស់មិនខាន ។ មួយប្រការទៀត ប្រសិនបើសប្បុរសជន មានឧបនិស្ស័យចង់ចំរើនវិបស្សនាភាវនា វត្តចម្បង គួរជ្រើសរើសរកគ្រូ ដែលមានគុណសម្បត្តិចរិយាសម្បត្តិ និង សមត្ថភាពគ្រប់គ្រាន់ទាំងផ្នែកបច្ចេកទេសទាំងផ្នែកបរិយត្តិ និង បដិបត្តិ ទើបអាចនាំសប្បុរសជនដើរលើមាគ៌ាត្រឹមត្រូវឆ្ពោះទៅរកបរមសុខ ពោលគឺព្រះនិព្វាន បើពុំដូច្នោះទេសប្បុរសជននឹងខាតបង់ពេលវេលាឥតប្រយោជន៍ សមដូចពាក្យចាស់លោកពោលថា ដំរីខ្វាក់ ទ្រមាក់ភ្លើ ពុំខាន ។



ខ្ញុំសង្ឃឹមទុកជាមុនថា ទោះបីយ៉ាងណា ស្នាដៃរបស់ខ្ញុំនេះគង់អាចបានជាប្រទីបតូចមួយ ជួយបំភ្លឺសប្បុរសជនមិត្តអ្នកអានឲ្យបានយល់ជាបណ្តើរៗ នូវព្រះពុទ្ធដីកា និង ព្រះបំណាងនៃព្រះពុទ្ធទាំងឡាយ ចំពោះសត្វលោក ដែលរស់នៅក្រោមនឹមអវិជ្ជា តណ្ហា ឧបាទាន ... ។

ខ្ញុំសូមអភ័យទោសទុកជាមុន ពីសំណាក់អ្នកប្រាជ្ញ រាជបណ្ឌិត អត្ថកោវិទ ខាងព្រះពុទ្ធសាសនា ប្រសិនបើអស់លោកជួបប្រទះឃើញកំហុសឆ្គាំឆ្គង ផ្នែកនិយមន័យ ពាក្យពេចន៍ ឃ្លាប្រយោគ ឬ អក្ខរាវិរុទ្ធ ដូចម្តេចក្តី សូមមេត្តាកែលំអ ដោយសន្តានចិត្ត អនុគ្រោះឲ្យទានខ្ញុំបាទផង ខ្ញុំបាទរង់ចាំទទួលការរិះគន់ស្ថាបនា ដោយចិត្តស្មោះសរីករាយជាទីបំផុត ។

ឆ្លៀតឱកាសនេះ ខ្ញុំសូមរៀបរាប់ពីប្រវត្តិសង្ខេបរបស់ខ្ញុំ ។ ខ្ញុំបាទ កើតនៅឆ្នាំ ១៩៤៦ (ថ្ងៃខែមិនប្រាកដ) នៅភូមិជ្រៃ ឃុំជ្រៃ ស្រុកមោងឫស្សី ខេត្តបាត់ដំបង ។ លោកឪពុកឈ្មោះ **ឈុន-ហួយ** អ្នកម្តាយឈ្មោះ **ពៅ-លន់** ។ ខ្ញុំមានបងប្អូនប្រាំនាក់ ប្រុសពីរនាក់ និង ស្រីបីនាក់ ហើយខ្ញុំជាកូនប្រុសច្បង ។

ជីវិតនៅមាតុភូមិក្នុងយុវវ័យ ការរៀនសូត្ររបស់ខ្ញុំបានត្រឹមមធ្យមសិក្សា ហើយខ្ញុំបានលាចាកការសិក្សា នៅឆ្នាំ ១៩៦៦ មក

## ព្រះរាជនិពន្ធ សម្ដេចព្រះសង្ឃរាជ ជ.ណ. ជោតញ្ញាណោ

### បទកាកគតិ

វីបុណ្យនិងបាប    វែងមានសភាព    កើតពីការធ្វើ
គឺខ្លួនរាល់ខ្លួន    សម្រេចអំពើ    បើជនណាធ្វើ
ជននោះរងផល ។

ផលសុខផលទុក្ខ    វែងតែងចេញមុខ    តាមពេលត្រូវផ្ដល់
ចេញតាមលំអាន    កុសលាកុសល    ឥតអ្វីណាផ្ដល់
ក្រៅពីនោះទេ ។

ស្អាតនិងមិនស្អាត    ជាក់ច្បាស់ពេញខ្នាត    នៃកម្មបុព្វេ
ឥតអ្នកដទៃ    ក្រៅពីខ្លួនទេ    ជនខ្វះធ្វេសទ្វេ
មិនជឿកម្មផល ។

ទោះកម្មចេញមុខ    ឲ្យសុខឲ្យទុក្ខ    ក៏ដឹងមិនដល់
ពុំដឹងថាកម្ម    ទេតើផ្ដល់ផល    ពុំគួរឆ្ងៃឆ្ងល់
ពុំយល់ច្នោះឡើយ ។

ព្រះពុទ្ធទ្រង់ប្រាប់    គួរតាំងចិត្តស្ដាប់    កុំធ្វើតោះតើយ
ត្រូវប្រើការគិត    ពិនិត្យរឿយៗ    ចិត្តស្ងៀមព្រងើយ
ធ្វើម្ដេចនឹងយល់ ។៚

វត្តឧណ្ណាលោម ក្រុងភ្នំពេញ, ថ្ងៃអង្គារ ទី២៣ កក្កដា ព. ស. ២៥១២ គ. ស. ១៩៦៨



## សេចក្ដីថ្លែងអំណរព្រះគុណ និង អរគុណ

ខ្ញុំសូមថ្លែងអំណរព្រះគុណ និង អរគុណយ៉ាងជ្រាលជ្រៅចំពោះ ៖

-ភិក្ខុឥន្ទប្បញ្ញោ **ខិន-តេន** គង់នៅវត្តពោធិវង្សប្រទេសបារាំង ដែលព្រះអង្គបានប្រទានសៀវភៅធម៌មួយចំនួនដល់ខ្ញុំបាទកាលខ្ញុំបាទបានទៅថ្វាយបង្គំព្រះអង្គដល់វត្តពោធិវង្ស។ សៀវភៅធម៌ទាំងនោះ មានសារៈសំខាន់ណាស់ សម្រាប់ខ្ញុំដកស្រង់បញ្ចូលទៅក្នុងស្នាដៃខ្ញុំនេះ ។

-ភិក្ខុវិនយធរោ **មហាឃិន-នឿន** ប្រធានពុទ្ធិកសមាគមខ្មែរ នៅទីក្រុងសាន់តាអាណា (Santa Ana, California) ដែលព្រះអង្គបានជួយវាយអក្សរកុមព្យូទ័រនិងបានជួយកែសម្រួលវាក្យស័ព្ទ ភាសាបាលី និង អត្ថន័យ ព្រមទាំងជួយផ្ដល់នូវក្បួនច្បាប់ផ្សេងៗ សម្រាប់ដកស្រង់មកបញ្ចូលក្នុងសៀវភៅនេះ ។

-លោក **អោក-ឈឿន** ដែលបានចំណាយពេលវេលាដ៏មានតម្លៃ ជួយពិនិត្យកែសម្រួលពាក្យពេចន៍ និង អត្ថន័យផ្សេងៗ ព្រមទាំងអក្ខរាវិរុទ្ធ ។

-លោកព្រឹទ្ធាចារ្យ **សោម-ខន** ដែលលោកបានជួយផ្ទៀងផ្ទាត់ យ៉ាងយកចិត្តទុកដាក់ កែសម្រួលអត្ថន័យ ឃ្លាល្បះ អក្ខរា-

វិរុទ្ធ និង ផ្តល់នូវគំនិតដ៏ល្អៗ ធ្វើឲ្យសៀវភៅនេះ មានអត្ថរូប អត្ថរស និង អត្ថន័យ អាចទទួលយកបាន ។

-លោកស្រី **ឡោ-កែវម្លិះ** ភរិយារបស់ព្រឹទ្ធាចារ្យ សោម-ផន ដែលបានជួយពិនិត្យពាក្យពេចន៍អក្ខរាវិរុទ្ធ និង ជួយផ្តល់គំនិតល្អៗ ដើម្បីធ្វើឲ្យសៀវភៅនេះ បានល្អប្រសើរឡើង មួយកម្រិតទៀត ។

ប្រសិនបើគ្មានការឧបត្ថម្ភ ជួយជ្រោមជ្រែង ពីសំណាក់ព្រះសង្ឃ និង អស់លោក អ្នកស្រី ដូចបានជម្រាបខាងលើនេះទេ សៀវភៅ **ព្រះពុទ្ធដីកា** នេះ ប្រាកដជាពុំបានលេចចេញជារូបរាង ជាសមិទ្ធិកម្មដ៏ថ្លៃថ្លា សម្រាប់ព្រះពុទ្ធសាសនាឡើយ ។

## ឧទ្ទិសកថា

ខ្ញុំសូមឧទ្ទិសបុណ្យកុសល ដែលកើតឡើងអំពីសេចក្តីព្យាយាមអត់ធន់ ដកស្រង់ ប្រមូលរៀបរៀងសៀវភៅនេះ ជូនចំពោះមាតាបិតាគុណគ្រូ ឧបជ្ឈាយាចារ្យ ញាតិកា ៧ សន្តាន ដែលមានជីវិតរស់នៅសព្វថ្ងៃក្តី ដែលបានចែកស្ថានទៅហើយក្តី សូមអនុមោទនាកុសលផលបុណ្យ នៃធម្មទាននេះ ដោយចិត្តជ្រះថ្លា ហើយសូមឲ្យបានសម្រេចនូវសម្បត្តិទាំងឡាយបីប្រការ គឺ



សម្បត្តិមនុស្ស សម្បត្តិទេវតា និង សម្បត្តិព្រះនិព្វាន កុំបីឃ្លៀងឃ្លាតឡើយ ។

ម៉្យាងទៀត ខ្ញុំសូមឲ្យអស់លោកមិត្តអ្នកអាន បានជួបប្រទះនូវពុទ្ធពរទាំងឡាយបួនប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។

សូមសាសនាព្រះសមណគោតមព្រះបរមគ្រូ មានអាយុយឺនយូរ គ្រប់កំណត់ ៥០០០ ព្រះវស្សា ដើម្បីជាម្លប់សាខា ដ៏ត្រជាក់ត្រជុំ ដល់សត្វលោកទាំងឡាយក្នុងត្រៃភព ។

សូមឲ្យសេចក្តីបរិសុទ្ធិ ស្ថិតនៅក្នុងសន្តានចិត្តសត្តនិករ ជានិច្ចនិរន្តរ៍ ។

ឡុងប៊ិច រដ្ឋកាលីហ្វ័រញ៉ា សហរដ្ឋអាមេរិក
ថ្ងៃ ៦ រោច ខែភទ្របទ ព.ស.២៥៥៣
ត្រូវនឹងថ្ងៃទី ១០ ខែកញ្ញា គ.ស. ២០០៩

**ឈុន-គីមអៀត**

# មាតិកា

| ឈ្មោះអត្ថបទ | ទំព័រ |
|---|---|
| អារម្ភកថា របស់អ្នករៀបរៀង | ក |
| ព្រះពុទ្ធដីកា | ១ |
| សព្វបាបស្ស អករណំ (មិនត្រូវធ្វើបាបទាំងពួង) | ១០ |
| កុសលស្សូបសម្បទា (ត្រូវបំពេញកុសល) | ១៨ |
| បាប និង បុណ្យ | ២៤ |
| កម្មឲ្យផលតាមកិច្ច ៤ យ៉ាង | ៣១ |
| កម្មឲ្យផលតាមលំដាប់មុនក្រោយ ៤ យ៉ាង | ៣៣ |
| កម្មឲ្យផលតាមលំដាប់ ៤ យ៉ាង | ៣៥ |
| ជំនឿបីយ៉ាង នៃលទ្ធិអន្យតិ្ថយ៍ | ៤០ |
| បដិសន្ធិ | ៤៥ |
| ចុតិចិត្ត និង និមិត្ត ៣ យ៉ាង | ៥៣ |
| សចិត្តបរិយោទបនំ (ត្រូវជម្រះចិត្តរបស់ខ្លួនឲ្យស្អាត) | ៥៦ |
| សីល | ៧៣ |
| សមាធិ | ៨៧ |
| ឈាន | ៩៩ |
| បញ្ញា | ១០៦ |
| ធម៌ជាតួជាសរីរៈ របស់វិបស្សនា | ១១៣ |
| វិបស្សនាញ្ញាណ | ១១៧ |
| បុថុជ្ជន និង អរិយជន | ១២៦ |

| ឈ្មោះអត្ថបទ | ទំព័រ |
| --- | --- |
| លោកុត្តរកុសលចិត្ត | ១២៩ |
| និព្វាន និង បរិនិព្វាន | ១៣២ |
| សតិបដ្ឋាន | ១៣៩ |
| កាយានុបស្សនា | ១៤៣ |
| វេទនានុបស្សនា | ១៥៨ |
| ចិត្តានុបស្សនា | ១៦៥ |
| ធម្មានុបស្សនា | ១៦៩ |
| អរិយសច្ចបួនៈ ទុក្ខសច្ច | ១៨០ |
| ទុក្ខសមុទយសច្ច | ១៨៩ |
| ទុក្ខនិរោធសច្ច | ១៩៣ |
| មគ្គសច្ច | ១៩៧ |
| សតិបដ្ឋានការនៅនិសង្ស | ២០៣ |
| អវសានកថា | ២០៦ |
| ឈ្មោះសៀវភៅដែលខ្ញុំបានដកស្រង់ | ២២១ |
| សេចក្តីជូនដំណឹង | ២២២ |
| បញ្ជីរាយនាមសប្បុរសជន | ២២៣ |

ពិតជាសាកល (Universal truth) ជាធម៌សំរាប់រំដោះមនុស្សសត្វដែលប្រតិបត្តិតាម ឲ្យរួចចាកទុក្ខ ជានិយ្យានិកធម៌ ជាធម៌ស្រោចស្រង់ខ្លួនឯង ។ ម្យ៉ាងទៀត ព្រះអង្គទ្រង់បានអប់រំព្រះទ័យព្រះអង្គដល់នូវភាពបរិសុទ្ធិ ឈ្នះអស់មន្ទិលទាំងឡាយ មានកិលេសតណ្ហាជាដើម ទើបព្រះអង្គទេសនាទូន្មាន ប្រៀនប្រដៅមនុស្សសត្វជាក្រោយ ។

តាមការវែកញែកដ៏សង្ខេបខាងលើនេះ ពាក្យថា **ព្រះធម៌** របស់ព្រះពុទ្ធ ពិតជាមានន័យឧត្តុង្គឧត្តម មានគម្ពីរភាពជាងពាក្យថា **ទស្សនវិជ្ជា** ។ ប៉ុន្តែបើយើងថែមពាក្យថា **ញាណ** នៅពីមុខពាក្យទស្សនវិជ្ជា បានជាពាក្យថា **ញាណទស្សនវិជ្ជា** នោះ ទើបសមរម្យ ហើយស៊ីជំរៅជាង ព្រោះព្រះពុទ្ធបានត្រាស់ដឹងព្រះធម៌ដោយ **ញាណ** និង **ទស្សនៈ** ។ ម្យ៉ាងទៀត ដែលពួកលោកខាងលិច ហៅព្រះអង្គថា ទស្សនវិទូ ក៏រិតតែពុំគួរសមណាស់ទៅទៀត ព្រោះព្រះពុទ្ធជាអរិយបុគ្គល មានព្រះនាម ១០ គឺ **អរហំ** (ព្រះអង្គឃ្លាតឆ្ងាយស្រឡះអំពីកិលេស) **សម្មាសម្ពុទ្ធោ** (ព្រះអង្គត្រាស់ដឹងដោយប្រពៃចំពោះព្រះអង្គ) **វិជ្ជាចរណសម្បន្នោ** (ព្រះអង្គបរិបូណ៌ដោយវិជ្ជានិងចរណៈ) **សុគតោ** (ព្រះអង្គមានព្រះដំណើរល្អមានព្រះបន្ទូលពិរោះ) **លោកវិទូ** (ព្រះអង្គជ្រាបច្បាស់



# ព្រះពុទ្ធដីកា

ពុទ្ធបរិស័ទធ្លាប់បានអានបានស្តាប់ចេះចាំរឿងរ៉ាវជីវិតនៃព្រះពុទ្ធបរមគ្រូនៃយើងស្ទើរគ្រប់ៗគ្នា ។ តាមរយៈពុទ្ធប្រវត្តិ យើងអាចអះអាងបានថា ព្រះពុទ្ធជាមនុស្សសុទ្ធសាធ ចាប់បដិសន្ធិក្នុងត្រកូលអភិជន។ ព្រះអង្គពុំមែនជាអាទិទេព ពុំមែនជាតួអង្គអវតា (Incarnation) ពុំមែនជាព្រះព្រហ្ម ព្រះឥសូរ ព្រះវិស្ណុ ឬ ជាបរមទេព្តា មិនចេះស្លាប់នោះឡើយ ។ ព្រះអង្គជាមនុស្សរស់នៅក្នុងសង្គមមនុស្ស ហើយបានប្រើវិរិយភាពយ៉ាងខ្លាំងក្លា រហូតបានត្រាស់ដឹងសព្វនូវបញ្ហាមនុស្ស ហើយបានអប់រំណែនាំមនុស្ស ឲ្យស្គាល់ល្អ អាក្រក់ សុខ ទុក្ខ បុណ្យ បាប គ្រប់បែបយ៉ាង ។ ព្រះពុទ្ធបរិនិព្វានទៅមែនពិត ប៉ុន្តែ ទស្សនៈ ទ្រឹស្តី ឬ ព្រះធម៌ របស់ព្រះអង្គនៅគង់វង់ ស្ថិតស្ថេរ ហើយត្រូវបានអនុវត្ត រហូតមកដល់សព្វថ្ងៃនេះ ។

**ព្រះធម៌** ឬ **ធម្មៈ** (Dharma or Dhamma) ដែលព្រះពុទ្ធបានត្រាស់សំដែងក្នុងពោធិសម័យ ត្រូវបានព្រះអរិយសាវក ប្រមូលចងក្រង (Collection) បានចំនួនប្រាំបីម៉ឺនបួនពាន់ (៨៤,០០០) ព្រះធម្មក្ខន្ធ ។ ក្នុងបណ្តាធម៌ទាំងឡាយនេះ ព្រះបរមសាស្តា ទ្រង់ជ្រើសយក “**អរិយសច្ចធម៌**” មកសំដែងប្រោសបញ្ចវគ្គីយ៍មុនគេ

នៅព្រៃឥសិបតនមិគទាយវ័ន សព្វថ្ងៃនេះ ឈ្មោះទីក្រុងសារនាថ (Saranat) មានចម្ងាយ ១០ គ. ម. ស្ថិតនៅខាងជើងនៃទីក្រុងពារាណសី បច្ចុប្បន្ន មានឈ្មោះថា វ៉ារ៉ាណាស៊ី (Varanashi) ឬ ទីក្រុងបេណារ៉េស (Benares) ឬ ហៅថា ទីក្រុង កាសី (Kashi) ស្ថិតនៅក្នុងរដ្ឋឧត្តរប្រទេស (Utthar Pradesh) ប្រទេសឥណ្ឌា ។ **អរិយសច្ចធម៌** ឬ **ចតុរារិយសច្ចធម៌** ជាបេះដូងនៃព្រះពុទ្ធសាសនា ។

ព្រះពុទ្ធទ្រង់ទតឃើញថា សត្វលោកទាំងអស់កំពុងរស់នៅក្រោមក្រញាំទុក្ខ ពុំអាចរើបំរះបាន។ ពាក្យថា **ទុក្ខ** មកពីពាក្យថា **ទុ** + **ខមៈ** ។ **ទុ** ប្រែថា លំបាក ឯ **ខមៈ** ប្រែថា ទ្រាំទ្រ សរុបមកបានជាលំបាកទ្រាំទ្រ ឬ ប្រព្រឹត្តទៅដោយលំបាក ដែលជាពាក្យផ្ទុយនឹងពាក្យថា **សុខ** ៗ មកពីពាក្យថា **សុ** + **ខមៈ** បានសេចក្តីថា ងាយទ្រាំទ្រ ឬ ប្រព្រឹត្តទៅ ដោយស្រួល ។ បញ្ហាទុក្ខនេះ ពួកមេសាសនាធំៗ ដទៃទៀត បានចាប់អារម្មណ៍ខ្លាំងណាស់ដែរ ប៉ុន្តែពួកគេគ្មានលទ្ធភាពដោះស្រាយ មានតែព្រះពុទ្ធមួយអង្គប៉ុណ្ណោះ បានត្រាស់ដឹងរកឃើញច្បាស់នូវធម្មជាតិនៃទុក្ខរបស់សត្វលោក ដែលហៅថា **ទុក្ខអរិយសច្ចៈ** (The Dukkha) រកឃើញឫសកំណើតរបស់ទុក្ខដែលហៅថា **ទុក្ខសមុទយអរិយសច្ចៈ**





(the Rising of Dukkha) រកឃើញកន្លែងផុតរលត់ទុក្ខ ដែលហៅថា **ទុក្ខនិរោធអរិយសច្ចៈ** (The Cessation of Dukkha) ហើយនិងរកឃើញផ្លូវរំដោះទុក្ខ ដែលហៅថា **មគ្គអរិយសច្ចៈ** (the Path) ។

ពួកសាសនាវិទូបស្ចិមប្រទេសហៅ **ព្រះធម៌** ជាពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធថា **ទស្សនវិជ្ជា** (Philosophy) ហើយហៅព្រះពុទ្ធថា **ទស្សនវិទូ** (Philosopher) ។ ការឲ្យន័យព្រះធម៌ ស្មើនឹងទស្សនវិជ្ជា ពិតជាពុំស៊ីជំរៅគ្នាទេ ។ ពាក្យថា **ទស្សនវិជ្ជា** មានពីរបទ គឺ **ទស្សនៈ** និង **វិជ្ជា** ប្រែថា វិជ្ជាអំពីទស្សនៈ គឺជាវិជ្ជាសិក្សាអំពីទស្សនៈ ឬ មតិយោបល់ផ្សេងៗ របស់អ្នកប្រាជ្ញទាំងឡាយ ជាទស្សនវិទូ ក្នុងលោក ។ អស់លោកទាំងនោះ លោកខ្លះមានគំនិតជាទេវនិយម ខ្លះជាសម្ភារនិយម បានត្រឹមតែបញ្ចេញជាទ្រឹស្តី តាមការយល់ឃើញរបស់ខ្លួន ដោយពុំបានអប់រំកាយវាចា ចិត្ត ឲ្យបានបរិសុទ្ធឡើយ ។ ទស្សនវិជ្ជា របស់លោកកាលម៉ាក់ (Karl Max) មេបង្កើតទ្រឹស្តីកុម្មុយនិស្ត បានធ្វើឲ្យពិភពលោកឈ្លោះគ្នា បង្កើតសង្គ្រាម បង្ហូរឈាមគ្នា ស្លាប់មនុស្សរាប់រយលាននាក់ ដោយសារទស្សនវិជ្ជាមិច្ឆាទិដ្ឋិនេះឯង ។ ចំណែកព្រះពុទ្ធ ព្រះអង្គត្រាស់ដឹង ដោយប្រាជ្ញាញាណ (Enlightenment) នូវអរិយសច្ច (Noble Truth) ជាធម៌ពិត តាមសភាវធម្មជាតិ ជាធម៌

រឭក ព្រោះយល់ឃើញថា ព្រះពុទ្ធជាបរមសាស្ដា ជាមហាសមណៈ អ្នកត្រាស់ដឹងនូវលោកុត្តរធម៌ មានព្រះទ័យប្រកបដោយវិសុទ្ធិគុណ បញ្ញាគុណនិងករុណាគុណ ព្រមទាំងទ្រង់បានបង្ហាញផ្លូវសត្វលោក ឲ្យឈានទៅរកបរមសុខ គឺព្រះនិព្វាន ។ ម្យ៉ាងទៀត ពុទ្ធបរិស័ទធ្លាប់បានសូត្រនមស្សការព្រះរតនត្រ័យថា **នត្ថិ មេ សរណំ អញ្ញំ** វត្ថុដទៃជាទីពឹងទីរឭកនៃខ្ញុំព្រះករុណាមិនមានឡើយ **ពុទ្ធោ មេ សរណំ វរំ** មានតែព្រះពុទ្ធជាម្ចាស់ជាទីពឹងទីរឭកដ៏ប្រសើររបស់ខ្ញុំព្រះករុណា **ឯតេន សច្ចវជ្ជេន ហោតុ មេ ជយមង្គលំ** សូមសិរីសួស្ដីជ័យមង្គល ចូរមានដល់ខ្ញុំព្រះករុណា ដោយកិរិយាពោលនូវពាក្យសច្ចៈនេះ ។

បំណាច់ហ៊ានថ្វាយខ្លួន ចំពោះព្រះពុទ្ធបែបនេះហើយ ពុទ្ធបរិស័ទ គួរមានភក្ដីភាពចំពោះព្រះពុទ្ធ គួរសិក្សាអត្ថន័យនិងគួរខំប្រតិបត្តិឲ្យបានសុក្រឹតនូវព្រះពុទ្ធឱវាទ គឺព្រះធម៌និងវិន័យ។ ព្រះពុទ្ធមិនសូវជាពេញព្រះទ័យនឹងអាមិសបូជាមានទៀនផ្កាភ្ញីជាដើម ប៉ុន្ដែ ព្រះអង្គទ្រង់ពេញព្រះទ័យនឹងបដិបត្តិបូជា គឺការប្រព្រឹត្តិត្រឹមត្រូវតាមធម៌វិន័យព្រះអង្គ ។ ទ្រង់ត្រាស់ថា "អ្នកណា បូជាតថាគត ដោយបដិបត្តិបូជា អ្នកនោះ ឈ្មោះថា គោរពរាប់អានតថាគត ដោយការបូជាដ៏ប្រសើរលើសលប់" ។





នូវលោក) **អនុត្តរោ** (ព្រះអង្គប្រសើរវិសេស រកបុគ្គលណាប្រសើរជាងគ្មាន) **បុរិសទម្មសារថិ** (ព្រះអង្គជាអ្នកទូន្មាននូវបុរសដែលមានឧបនិស្ស័យគួរនឹងទូន្មានបាន) **សត្ថា ទេវមនុស្សានំ** (ព្រះអង្គជាគ្រូ នៃទេវតានិងមនុស្សទាំងឡាយ) **ពុទ្ធោ** (ព្រះអង្គជាអ្នកភ្ញាក់រឭក ត្រាស់ដឹងនូវចតុរារិយសច្ច ហើយញ៉ាំងអ្នកដទៃឲ្យត្រាស់ដឹងផង) **ភគវា** (ព្រះអង្គមានព្រះភាគ, ព្រះអង្គជាអ្នកចែក, ព្រះអង្គមានជោគ, ព្រះអង្គមានព្រះដំណើរទៅកាន់ត្រៃភពខ្ជាក់ចោលហើយ) ។ បើនិយាយឲ្យងាយស្ដាប់ ព្រះពុទ្ធជាលោកុត្តរបុគ្គល ព្រោះព្រះអង្គហួសចាកឆ្ងាយលោកទាំងបី គឺកាមលោក រូបលោក និង អរូបលោក ។ ចំណែកទស្សនវិទូដទៃទៀត ជាបុថុជ្ជនបុគ្គលវិលវល់ក្នុងកាមភព តាមរយៈកាមាវចរចិត្ត ជំពាក់ស្អិតតែក្នុងកាមគុណ ពុំអាចប្រៀបធៀបជាមួយព្រះពុទ្ធបានទេ ។ ដូចនេះ ពួកទស្សនវិទូ បស្ចិមប្រទេសគួរថ្វាយព្រះនាមព្រះអង្គថា **ញាណទស្សនវិទូ** ឬ **មហាបុរស បេះដូងពេញ ដោយប្រាជ្ញាញាណ** (The Intelligent Heart) ដែលមានន័យថា ព្រះពុទ្ធជាលោកវិទូ ទ្រង់ជ្រាបនូវលោកដោយ **ញាណ** និង **ទស្សនៈ** ទើបត្រឹមត្រូវជាង ។

ព្រះសព្វញ្ញុពុទ្ធ ក្នុងពុទ្ធកាល ព្រះអង្គទ្រង់សំដែងនូវធម្-

ទេសនាប្រោសសត្វលោក ដោយពុំប្រកាន់វណ្ណៈឡើយ។ មនុស្សគ្រប់វណ្ណៈ មានវណ្ណៈស្តេច, វណ្ណៈព្រាហ្មណ៍, វណ្ណៈវេស្សៈ, វណ្ណៈសុទ្ទ ឬ សូទ្រ ជាច្រើននាក់មានប្រុស មានស្រីបានចូលទៅសុំបួសរៀន ក្នុងសំណាក់ព្រះពុទ្ធ ។ ពាក្យប្រៀនប្រដៅដែលព្រះសក្យមុនី ទ្រង់បានប្រោសប្រទាន ដល់ពុទ្ធបរិស័ទគ្រប់ប្រភេទមានច្រើនជាអនេក រហូតដល់ប្រាំបីម៉ឺនបួនពាន់ព្រះធម្មក្ខន្ធ។ ប៉ុន្តែបើសារុបដោយសង្ខេប មានត្រឹមតែបីប្រការ គឺ ៖

១- **សព្វបាបស្ស អករណំ** មិនត្រូវធ្វើបាបគ្រប់យ៉ាង,

២- **កុសលស្សូបសម្បទា** ត្រូវបំពេញបុណ្យកុសល,

៣- **សចិត្តបរិយោទបនំ** ត្រូវជុះខាត់ជម្រះចិត្តរបស់ខ្លួន ឲ្យស្អាត ។

ពាក្យថាប្រៀនប្រដៅនេះ អាចហៅថា **ព្រះពុទ្ធវចនៈ. ព្រះពុទ្ធោវាទ. ព្រះពុទ្ធសាសន៍** ឬ **ព្រះពុទ្ធដីកា** ក៏បាន ។ ព្រះពុទ្ធសាសន៍ទាំងបីប្រការនេះ ពុំមែនជាព្រះពុទ្ធដីកា របស់ព្រះពុទ្ធសមណគោត្តមតែមួយព្រះអង្គឯងនោះទេ គឺជាព្រះពុទ្ធវចនៈរបស់ព្រះពុទ្ធគ្រប់ៗព្រះអង្គ ។ ព្រះពុទ្ធ មានបីប្រភេទ គឺ ៖

១- **ព្រះសម្មាសម្ពុទ្ធ** ឬ **សព្វញ្ញុពុទ្ធ** គឺអ្នករកធម៌ឃើញត្រាស់ដឹង ដោយខ្លួនឯង ព្រមទាំងមានសមត្ថភាព សម្តែងធម៌





ប្រៀនប្រដៅសត្វលោកឲ្យរួចរដោះចាកទុក្ខ ។

២- **ព្រះបច្ចេកពុទ្ធ** គឺអ្នករកធម៌ឃើញ ត្រាស់ដឹងដោយខ្លួនឯង ប៉ុន្តែគ្មានសមត្ថភាពសម្តែងធម៌ប្រៀនប្រដៅអ្នកដទៃបានទេ។

៣- **ព្រះសុតពុទ្ធ** ឬ **សាវកពុទ្ធ** គឺអ្នកមិនបានរកធម៌ឃើញខ្លួនឯងទេ ជាពុទ្ធសាវក ត្រូវស្តាប់តពីព្រះសម្មាសម្ពុទ្ធមកហើយទើបចាប់បតិបត្តិ ដោយខ្លួនឯង រហូតដល់បានសម្រេចមគ្គផលដល់ទីបំផុត ។

ព្រះពុទ្ធគ្រប់ៗព្រះអង្គ ទ្រង់ប្រទានឱវាទទាំងបីខាងលើនេះ ដោយហេតុព្រះអង្គមានទឹកព្រះទ័យប្រកបដោយមហាករុណាទិគុណ ចំពោះសត្វនិករទូទៅ ហើយមានព្រះពុទ្ធបំណងចង់ឲ្យសត្វលោករួចរដោះផុតចាកសេចក្តីទុក្ខ ឲ្យបានជួបប្រទះសេចក្តីសុខ ។ ព្រះអង្គជ្រាបច្បាស់ថា “**បាបតែងឱ្យផលជាទុក្ខ បុណ្យកុសលតែងឱ្យផលជាសុខ ឯការជម្រះចិត្តរបស់ខ្លួនឱ្យស្អាតនោះ តែងផ្តល់នូវសេចក្តីសុខដ៏លើសលប់ គឺព្រះនិព្វាន** ។ **ចិត្តេន នីយតិ លោកោ** សត្វលោកត្រូវចិត្តដឹកនាំ។ គឺចិត្តនេះហើយដែលបុគ្គលទូន្មានបានដោយកម្រ។ **ចិត្តំ គុត្តំ សុខាវហំ** ចិត្តដែលគេគ្រប់គ្រងបានល្អហើយតែងបានសុខ” ។

ពុទ្ធសាសនិកជន យកព្រះពុទ្ធជាសរណគមន៍ជាទីពឹង ជាទី

៣- **កាមេសុមិច្ឆាចារ** កិរិយាប្រព្រឹត្តិខុស ក្នុងកាមទាំងឡាយ មានការលួចប្រពន្ធកូនអ្នកដទៃ,

៤- **មុសាវាទ** កិរិយាពោលនូវពាក្យកុហក,

៥- **សុរាមេរយមជ្ជប្បមាទដ្ឋាន** ការផឹកសុរា និង មេរ័យ។

## អកុសលកម្ម

អកុសលកម្ម មានកម្មបថដប់ ហៅថា "អកុសលកម្មបថដប់" គឺ **កាយទុច្ចរិច** ៣, **វចីទុច្ចរិត** ៤, **មនោទុច្ចរិត** ៣ ។

ពាក្យថា **កម្មបថ** មានពីរបទគឺ **កម្ម** = ទង្វើ ឬ អំពើ + **បថ** = គន្លងឬផ្លូវ រួមជា **កម្មបថ** ប្រែថាគន្លងឬផ្លូវនៃអំពើដែលគេធ្វើ ។ អំពើអាក្រក់ដែលប្រព្រឹត្តតាមផ្លូវកាយ ហៅថា **កាយទុច្ចរិត** មាន ៣ យ៉ាង គឺ ៖

១- **បាណាតិបាតោ** កិរិយាសម្លាប់បំបាត់ជីវិតសត្វ,

២- **អទិន្នាទានំ** កិរិយាលួចលាក់ឆក់ដណ្តើមទ្រព្យគេ,

៣- **កាមេសុមិច្ឆាចារោ** កិរិយាប្រព្រឹត្តិខុសក្នុងកាមទាំងឡាយគឺលួចសេពមេថុនទឹងស្រីដែលមានគេហួងហែង ។

អំពើអាក្រក់ដែលគេប្រព្រឹត្តតាមផ្លូវវាចា ហៅថា **វចីទុច្ចរិត** មាន ៤ យ៉ាង គឺ ៖

១- **មុសាវាទោ** កិរិយាពោលនូវពាក្យកុហកកូតករ,





បំណាច់មានសទ្ធាមុតមាំ តំកល់ខ្លួនស៊ប់ក្នុងព្រះពុទ្ធសាសនា ពុទ្ធសាសនិកជន គួរប្រើងប្រែងចំរើនប្រាជ្ញាបីយ៉ាង គឺ សុតមយ-បញ្ញា ប្រាជ្ញា កើតឡើង ដោយការសិក្សាត្រងត្រាប់ស្តាប់ ១, ចិន្តមយបញ្ញា ប្រាជ្ញា កើតអំពីការប្រើងរិះគិតពិចារណា ១, ភាវនាមយបញ្ញា ប្រាជ្ញាកើតពីការប្រព្រឹត្តិចំរើនសមាធិកម្មដ្ឋាន ឬសមថកម្មដ្ឋាន និង វិបស្សនាកម្មដ្ឋាន ១ ។

ពាក្យថា **សទ្ធា** មានន័យថា ការជឿឬជំនឿ មាន៤ យ៉ាងគឺ

១- **កម្មសទ្ធា** ការជឿលើកម្ម ការជឿនូវអំពើដែលសត្វធ្វើ,

២- **វិបាកសទ្ធា** ការជឿផល គឺជឿផលនៃកុសលកម្ម និង អកុសលកម្ម,

៣- **កម្មស្សកតាសទ្ធា** ការជឿថាសត្វទាំងឡាយ មានកម្មដែលខ្លួនធ្វើហើយជារបស់ខ្លួន,

៤- **តថាគតសទ្ធា** ជឿការត្រាស់ដឹងរបស់ព្រះតថាគត ។

អាស្រ័យហេតុនេះ សាធុជនដែលមានសទ្ធាជ្រះថ្លា ក្នុងព្រះពុទ្ធសាសនា ជឿកម្មផល បាបបុណ្យ គួរស្វែងយល់អត្ថន័យនៃពាក្យបាបបុណ្យ ឲ្យបានទូលំទូលាយ ញែកបាបនិងបុណ្យឲ្យបានដាច់ស្រឡះ ដើម្បីជាការងាយស្រួលទឹងអនុវត្តខ្លួន រចនាជីវិតខ្លួនឲ្យបានប្រសើរក្នុងសង្គមបច្ចុប្បន្ននិងទៅអនាគតជាតិ ។

# សព្វបាបស្ស អករណំ
## មិនត្រូវធ្វើបាបទាំងពួង

ពាក្យថា **បាប** ជាភាសាបាលីផង ជាភាសាសំស្រ្កឹតផង ។ បើប្រែតាមអត្ថានុរូបថា “កម្មដែលញ៉ាំងសត្វឲ្យដល់នូវសេចក្តីទុក្ខលំបាក វិនាសហិនហោច ។ បើប្រែតាមអត្ថប្បដិរូប អាចប្រែបានច្រើនយ៉ាង គឺ ប្រែថា សេចក្តីខុស, អំពើអាក្រក់, អំពើខិលខូច, អំពើខុសច្បាប់ និង អំពើឈ្លានពានជាដើម ។ ប៉ុន្តែ ពាក្យនេះសព្វថ្ងៃត្រឡប់ទៅជាភាសាសម្រាប់ជាតិខ្មែរទៅហើយ គឺជាតិខ្មែរទាំងប្រទេស អាចនិយាយបានគ្រប់គ្នា ថា “**បាប**” ប៉ុន្តែ ត្រង់ការយល់ដឹងចំពោះពាក្យថា “**បាប**” នេះ មិនស្មើគ្នាទេ ។ អ្នកខ្លះបានសិក្សាច្រើន ក៏អាចយល់អត្ថន័យ នៃពាក្យនេះបានជ្រាលជ្រៅទៅ អ្នកខ្លះ មិនបានសិក្សា ឬ បានសិក្សាតិច ក៏យល់សេចក្តីរាក់ៗ មិនបានទូលំទូលាយ ដូចជាអ្នកសិក្សាច្រើនឡើយ ។

គួរជ្រាបថា អ្នកដែលអាចប្រព្រឹត្តអំពើបាបឃោរឃៅ យង់ឃ្នងបាន អាស្រ័យដោយហេតុមានអកុសលចិត្ត ឬ អកុសលចេតនា ជាសមុដ្ឋាន ។ អកុសលចិត្ត ជាចិត្តដែលប្រកបដោយ **លោភៈ ទោសៈ** និង **មោហៈ** ដែលហៅថា **អកុសលមូល** ឬ





ឫសគល់នៃអកុសល ។ គឺអកុសលចេតនា នេះហើយ ដែលបណ្តាលឲ្យមនុស្សទាំងឡាយប្រាសចាកអំពីហិរិឱត្តប្បៈ (ការខ្មាសរអែង ខ្លាសអៀនអំពើបាប) ហ៊ានប្រព្រឹត្តអកុសលកម្ម ដោយឥតញញើត ។

វេវចនសព្ទ ឬពាក្យគេនិយមប្រើមានលំនាំន័យដូចគ្នា អាចប្រើជំនួសពាក្យ “**បាប**” បាន មានច្រើនណាស់ ដូចជា **អកុសល ទុច្ចរិត អធម៌ ទណ្ឌកម្ម តបនីយកម្ម លាមកធម៌ អធម្មធិម កាឡធម៌** (ធម៌ខ្មៅ) **អយុត្តិធម៌**...។ រីឯអ្នកប្រព្រឹត្តអំពើបាបព្រៃផ្សៃយង់ឃ្នង ក៏អាចហៅបានច្រើនយ៉ាងដែរ ដូចជាថា **បាបជន** ឬ **បាបការី, អកុសលជន, ជនទុច្ចរិត, ជនតិរច្ឆាន, ជនកាឡកិណី, ជនអមនុស្សធម៌** និង **ជនពាលអន្ធការ** ជាដើម ។

កំហុសធ្ងន់ធ្ងរ ទង្វើបំពានខុសច្បាប់រដ្ឋ និង ច្បាប់សាសនា ដែលបាបការីប្រព្រឹត្ត ក្រោមអំណាចអកុសលចិត្ត បើរាប់រៀបមានច្រើនប្រការណាស់ គឺ ៖

-**វេរកម្ម** គឺទង្វើនាំឲ្យមានពៀរ ហើយដែលគួរវៀរ មាន ៥ យ៉ាង ហៅថា **បញ្ចវេរា** គឺ ៖

១- **បាណាតិបាត** កិរិយាបៀតបៀនសម្លាប់សត្វមានជីវិត,

២- **អទិន្នាទាន** កិរិយាបន្លំលួចទ្រព្យអ្នកដទៃ,

**បាបស្ស ថោកំ ថោកំបិ អាចិនំ** សូម្បីក្អមទឹកគង់ពេញដោយតំណក់ទឹក ដែលធ្លាក់ចុះមកយ៉ាងណា ជនពាល សន្សំបាបបន្តិចម្តងៗ គង់ពេញដោយបាបក៏យ៉ាងនោះដែរ” ។ ដើម្បីជាជំនួយដល់សតិ បញ្ញា ក្នុងការស្វែងយល់អំពីទោសនៃបាបកម្ម ខ្ញុំសូមលើកយកពុទ្ធភាសិតមួយចំនួន មកធ្វើអត្ថាធិប្បាយ ដូចតទៅ ៖

១- **ឥធ សោចតិ បេច្ច សោចតិ**
**បាបការី ឧភយត្ថ សោចតិ**
**សោ សោចតិ សោ វិហញ្ញតិ**
**ទិស្វា កម្មកិលិដ្ឋមត្តនោ** ។

អ្នកធ្វើបាប រមែងសោកស្តាយក្នុងលោកនេះ ទៅខាងមុខក៏សោកស្តាយទៀត ឈ្មោះថា សោកស្តាយក្នុងលោកទាំងពីរ អ្នកនោះ រមែងសោកស្តាយក្តៅក្រហាយ ព្រោះឃើញកម្មដ៏សៅហ្មងរបស់ខ្លួន” ។

២- **មធុវា មញ្ញតី ពាលោ យាវ បាបំ ន បច្ចតិ**
**យទា ច បច្ចតី បាបំ អថ ទុក្ខំ និគច្ឆតិ** ។

បាបមិនទាន់ឲ្យផលត្រឹមណា ជនពាលរមែងចូលចិត្តថា ដូចជាវត្ថុមានរសផ្អែមត្រឹមនោះ តែកាលណាបាបឲ្យផល កាលនោះជនពាល ទើបជួបនូវសេចក្តីទុក្ខ” ។

៣- **សចេ ភាយថ ទុក្ខស្ស សចេ វោ ទុក្ខមប្បិយំ**





២- **បិសុណាវាចា** កិរិយាពោលនូវពាក្យញុះញង់ ស៊កសៀតបំបាក់បំបែកអ្នកដទៃ,

៣- **ផរុសវាចា** កិរិយាពោលនូវពាក្យទ្រគោះបោះបោកជេរប្រទេចអ្នកដទៃ,

៤- **សម្ផប្បលាបោ** កិរិយាពោលនូវពាក្យរោយរាយ ឥតប្រយោជន៍ ។

អំពើអាក្រក់ដែលប្រព្រឹត្តតាមផ្លូវចិត្ត ហៅថា **មនោទុច្ចរិត** មានបីយ៉ាង គឺ ៖

១- **អភិជ្ឈា** ចិត្តសំឡឹងរំពៃចំពោះទ្រព្យអ្នកដទៃដោយបំរុងនឹងឲ្យបានជារបស់ខ្លួន,

២- **ព្យាបាទោ** ចិត្តបង់គំនុំគុំកួន គឺប៉ងនឹងឲ្យអ្នកដទៃដល់នូវក្តីវិនាស,

៣- **មិច្ឆាទិដ្ឋិ** គំនិតយល់ខុសហើយប្រកាន់ឡើងថាជាត្រូវ។

## មិច្ឆាជីវៈ

សម្មាអាជីវៈ (Right Livelihood) ជាការចិញ្ចឹមជីវិតត្រឹមត្រូវតាមគន្លងធម៌ និង តាមច្បាប់រដ្ឋ ។ ផ្ទុយគ្នានឹងពាក្យសម្មាអាជីវៈ គឺ មិច្ឆាជីវៈ ជាការចិញ្ចឹមជីវិតខុស មាន ៥ យ៉ាង គឺ ៖

១- **សត្ថវណិជ្ជា** ជួញគ្រឿងសស្ត្រាវុធសំរាប់ប្រហារ គឺ

ធ្វើគ្រឿងសស្ត្រាវុធ ដោយខ្លួនឯង ឬ បានមកដោយហេតុឯណាមួយហើយលក់ដូរនូវគ្រឿងសស្ត្រាវុធនោះៗ,

២- **សត្តវណិជ្ជា** ជួញដូរមនុស្ស,

៣- **មំសវណិជ្ជា** ជួញសាច់គឺចិញ្ចឹមនូវសត្វទាំងឡាយមានជ្រូកជាដើមលុះដល់សត្វទាំងនោះធំឡើងក៏សម្លាប់យកសាច់លក់,

៤- **មជ្ជវណិជ្ជា** ជួញទឹកស្រវឹង គឺផ្សំគ្រឿងណាមួយ ឲ្យកើតឡើងជាទឹកស្រវឹង ដោយខ្លួនឯង ឬ ទិញគេយកមក ហើយលក់នូវគ្រឿងស្រវឹងនោះ,

៥- **វិសវណិជ្ជា** ជួញថ្នាំពិស គឺចាត់ចែងនូវថ្នាំពិស ឲ្យកើតឡើងដោយខ្លួនឯង ឬ ឲ្យគេផ្សំឲ្យ ឬ បានមកដោយហេតុណាមួយ ហើយលក់នូវថ្នាំពិសនោះ ។

ទង្វើបាប មានប្រការប៉ុណ្ណេះជាដើម ជនទុច្ចរិតអាចធ្វើបានដោយរីករាយឥតញញើត ព្រោះជនអន្ធពាលខ្វះវិចារណញ្ញាណលង់ក្នុងមិច្ឆាទិដ្ឋិ យល់ខុសថា គ្មានបុណ្យបាប គុណទោស នរកសួគ៌... ។ ច្បាប់នៃកម្ម (The law of Kamma) ចែងថា បើមានកម្មត្រូវតែមានផល ។ កម្ម (Action) គឺអំពើដែលបុគ្គលម្នាក់ៗ ធ្វើដោយកាយ វាចា និង ចិត្ត ហើយមានចេតនាជាដើមចម ។ ចេតនានេះឯង គឺជាតួកម្ម ដូចជាពុទ្ធវចនៈថា "**ចេតនាហំ ភិក្ខវេ**





**កម្មំ វទាមិ** ប្រែថា ម្នាលភិក្ខុទាំងឡាយ តថាគត ហៅចេតនាថាជាតួកម្ម" ។ ចំណែកពាក្យថា **ផល** បានន័យថា ផ្លែផ្កាដែលលេចចេញអំពីកម្ម ។ កម្មល្អឲ្យផលល្អ កម្មអាក្រក់ឲ្យផលអាក្រក់ ។ មនុស្សជាអ្នកសាងកម្មខ្លួនឯង ហើយត្រូវទទួលយកផល នៃកម្មនោះ ដោយខ្លួនឯងដែរ ។ ព្រះទសពល ទ្រង់សម្តែងថា ៖

**អត្តនា វ កតំ បាបំ  អត្តនា សង្កិលិស្សតិ**<br>
**អត្តនា អកតំ បាបំ  អត្តនា វ វិសុជ្ឈតិ**<br>
**សុទ្ធិ អសុទ្ធិ បច្ចត្តំ  នាញ្ញោ អញ្ញំ វិសោធយេ** ។

អ្នកណា ធ្វើបាបដោយខ្លួនឯង អ្នកនោះនឹងសៅហ្មង ដោយខ្លួនឯង, អ្នកណា មិនធ្វើបាបដោយខ្លួនឯង អ្នកនោះ នឹងបរិសុទ្ធស្អាតដោយខ្លួនឯង, សេចក្តីបរិសុទ្ធិ និង មិនបរិសុទ្ធិ ស្រេចតែនឹងខ្លួនឯង ឥតមានអ្នកដទៃណា ធ្វើអ្នកដទៃឲ្យបរិសុទ្ធបានឡើយ ។ ព្រះជិនស្រី ទ្រង់ត្រាស់បន្ថែមទៀតថា "**ទុក្ខោ បាបស្ស ឧច្ចយោ** ការសន្សំបាប តែងបាននូវសេចក្តីទុក្ខ" ។ ឥតមានបាបជនណាម្នាក់ គេចខ្លួនរួចពីផលអាក្រក់ឡើយ ។ ជនអន្ធពាល ច្រើនធ្វេសប្រហែស មើលងាយបាបថា បាបបន្តិចបន្តួច ដែលបានប្រព្រឹត្តហើយ មានទោសស្រាល នឹងមិនឲ្យផលឡើយ ។ ចំពោះការភ័ន្តច្រឡំនេះ ព្រះភគវា ទ្រង់បានបំភ្លឺដោយវចនៈថា "**បូរតិ ពាលោ**

-**រក្សានិច្ចសីល** គឺសីល ៥ ឬ បញ្ចសីល,

-**រក្សាឧបោសថសីល** គឺសីល ៨,

-**រក្សាអតិរេកសីល** គឺសីល ១០,

-**រក្សាកុសលកម្មបថ** ១០ គឺកាយសុចរិត ៣ វចីសុចរិត ៤ និង មនោសុចរិត ៣ ។ កុសលកម្មបថ ១០ នេះ ផ្ទុយគ្នានឹង អកុសលកម្មបថ ១០ ដូចដែលបានជម្រាបនៅទំព័រខាងដើម ។

-**ហាត់អប់រំចិត្តឱ្យស្អាតល្អ** គឺចំរើនសមាធិភាវនា,

សេចក្តីខាងដើមនេះ ជាវត្ថុសំរាប់ធ្វើឲ្យកើតបុណ្យ ហៅថា **បុញ្ញកិរិយាវត្ថុ** ។ បុញ្ញកិរិយាវត្ថុនេះ បើនិយាយដោយសង្ខេប មានតែ ៣ យ៉ាង គឺ ៖

១- **ទានមយៈ** បុណ្យកើតអំពីការធ្វើទាន,

២- **សីលមយៈ** បុណ្យកើតអំពីការរក្សាសីល,

៣- **ភាវនាមយៈ** បុណ្យកើតអំពីការចំរើនភាវនា,

បុញ្ញកិរិយាវត្ថុនេះ បើចែកដោយពិស្តារមាន ១០ យ៉ាង គឺ៖

១- **ទានមយៈ** បុណ្យសម្រេចដោយការធ្វើទាន,

២- **សីលមយៈ** បុណ្យសម្រេចដោយការរក្សាសីល,

៣- **ភាវនាមយៈ** បុណ្យសម្រេចដោយការចំរើនភាវនា,

៤- **អបចាយនមយៈ** បុណ្យសម្រេចដោយការគោរពក្រែង



ព្រះពុទ្ធដីកា

**មាកត្ថ បាបកំ កម្មំ អាវី វា យទិ វា រហោ** ។

បើអ្នកទាំងឡាយខ្លាចទុក្ខ បើអ្នកទាំងឡាយមិនស្រឡាញ់ទុក្ខទេ អ្នកកុំធ្វើបាបកម្ម ទាំងក្នុងទីវាល ទាំងក្នុងទីកំបាំងឡើយ"។

៤- **ន ជច្ចា វសលោ ហោតិ ន ជច្ចា ហោតិ ព្រាហ្មណោ កម្មុនា វសលោ ហោតិ កម្មុនា ហោតិ ព្រាហ្មណោ** ។

បុគ្គលមិនមែនជាអ្នកថោកទាបព្រោះជាតិទេ មិនមែនជាអ្នកប្រសើរព្រោះជាតិទេ ជាអ្នកថោកទាបព្រោះកម្ម ជាអ្នកប្រសើរក៏ព្រោះកម្ម" ។

សរុបសេចក្តីមក សកម្មភាពអាក្រក់ជួរជាតិគ្រប់យ៉ាងដែលពួកជនអមនុស្សធម៌បានចាត់ចែងធ្វើទោះបីក្នុងទីស្ងាត់កំបាំងក្តី ក្នុងទីចំពោះមុខសាធារណជនក្តី រមែងផ្តល់ផលអាក្រក់ដូចត់ ឥតត្រាប្រណី ដល់ខ្លួនអ្នកប្រព្រឹត្តជានិច្ច ពុំអាចគេចវេះបាន ទាំងក្នុងបច្ចុប្បន្នកាល ទាំងអនាគតកាល ។ ព្រះពុទ្ធគ្រប់ៗព្រះអង្គ ត្រាស់ដឹងច្បាស់ច្បាប់កម្មផលថា "សេចក្តីសុខទុក្ខ ចំរើនវិនាស កើតចេញមកអំពីអំពើរបស់ខ្លួន សត្វទាំងឡាយ មានកម្មជារបស់ខ្លួន (**កម្មស្សកោម្ហិ**) ទើបទ្រង់ប្រទានឱវាទថា "**សព្វបាបស្ស អករណំ** មិនត្រូវធ្វើបាបទាំងពួង" ។

# កុសលសម្បូរសម្បទា
## ត្រូវបំពេញកុសល

ពាក្យថា **កុសល** ជាភាសាបាលី ។ បើប្រែតាមអត្ថានុរូបថា "កម្មដែលកាត់ផ្តាច់នូវសេចក្តីអាក្រក់គ្រោតគ្រាតដូចស្បូវភ្លាំង" ។ បើប្រែតាមអត្ថបដិរូប អាចប្រែបានច្រើនយ៉ាងដូចជាថា អំពើត្រឹមត្រូវ, អំពើល្អ អំពើទៀងត្រង់ជាដើម ។ ប៉ុន្តែពាក្យថា "**កុសល**" នេះគេច្រើននិយាយជាប់គ្នានឹងពាក្យ **បុណ្យ** ថា"**បុណ្យកុសល**" ។ ដូចនេះសូមលើកយកពាក្យបុណ្យមកអធិប្បាយវិញដើម្បីឲ្យស្រប នឹងពុទ្ធឱវាទទី១ ថា "មិនត្រូវធ្វើបាប" ត្រូវបំពេញបុណ្យកុសល។ រីឯ **បុណ្យ** និង **កុសល** នេះ មានអត្ថន័យដូចគ្នា **បុណ្យ** គឺ **កុសល** **កុសល** គឺ **បុណ្យ** ។

ពាក្យថា **បុណ្យ** ជាភាសាសំស្ក្រឹត, ភាសាបាលីថា **បុញ្ញៈ** ប៉ុន្តែ ខ្មែរយើង តែងនិយាយតាមភាសាសំស្ក្រឹត ថា **បុណ្យ** ៗ ។ ពាក្យថា "**បុញ្ញៈ**" បើប្រែតាមអត្ថានុរូបថា "ធម្មជាតិជំរះនូវចិត្ត(ឲ្យស្អាត)"។ ថា "អំពើដែលសម្រេចអំពីកាយ វាចា ចិត្ត ដ៏ស្អាតបរិសុទ្ធ" ។ ធម្មជាតិឯណា ដែលជំរះសំអាតសន្តានចិត្តរបស់ខ្លួនឲ្យស្អាតបរិសុទ្ធផូរផង់ ប្រាសចាកមន្ទិល គឺសេចក្តីសៅហ្មងចិត្តមាន **លោភៈ** **ទោសៈ** **មោហៈ** ជាដើមហៅថា **បុណ្យ** ។ បើប្រែ





តាមអត្ថបដិរូប អាចប្រែបានច្រើនយ៉ាងដូចពាក្យថា **កុសល** ដែរ

វេវចនសព្ទ ឬ ពាក្យដែលមានសេចក្តីដូចគ្នានឹងបុណ្យមានច្រើនគឺ **បុញ្ញកម្ម**, **កុសល** ឬ **កុសលកម្ម**, **សុចរិត**, **កល្យាណធម៌**, **ធម្មកម្ម**, **សុក្កធម៌**, **អតប្បនីយធម៌** ជាដើម ។ ឯមនុស្សអ្នកធ្វើបុណ្យក៏គេអាចហៅបានច្រើនយ៉ាងដែរគឺហៅថា **មនុស្សបុណ្យ**, **មនុស្សកុសល**, **មនុស្សសុចរិត**, **មនុស្សល្អ**, **មនុស្សធម្មិក**, **កល្យាណការី** ជាដើម ។

គួរជ្រាបថា អ្នកដែលអាចធ្វើបុណ្យសុន្ទរទានបាន អាស្រ័យដោយហេតុមាន **កុសលចិត្ត** ឬ **កុសលចេតនា** ជាសមុដ្ឋាន ។ កុសលចិត្តជាចិត្តប្រកបដោយ អលោភៈ អទោសៈ និងអមោហៈ ដែលហៅថា **កុសលមូល** (ឫសគល់នៃកុសល) ។ កុសលចេតនានេះហើយដែលដឹកនាំមនុស្សទាំងឡាយ ឲ្យមានសទ្ធាជ្រះថ្លាប្រាថ្នាវាងវៃ អាចធ្វើបុណ្យកុសលផ្សេងៗ បាន ។

មនុស្សដែលមានចិត្តជាកុសល ហើយប្រព្រឹត្តធ្វើបុណ្យទានគឺអំពើល្អអំពើដែលចំរើន មានគុណធម៌ មានសារប្រយោជន៍ដល់ខ្លួនឯង និង ដល់អ្នកដទៃ មានច្រើនប្រការណាស់ គឺ ៖

-**បរិច្ចាគទ្រព្យ** កំចាត់បង់មច្ឆរិយៈ (សេចក្តីកំណាញ់) លះបង់ទ្រព្យសម្បត្តិទៅជាទាន,

# **បាប** និង **បុណ្យ**

កុសលកម្ម (បុណ្យ) និង អកុសលកម្ម(បាប) ដែលបុគ្គលណាបានប្រព្រឹត្តលាយឡំគ្នា កើតបានជាផលមួយ លោកហៅថា **កម្មផល** ។ លុះផលនោះ រួមគ្នាច្រើនទៅ ទើបលោកឲ្យឈ្មោះថា **វិបាក** ។ វិបាកនេះគឺជាផលដែរ ប៉ុន្តែផលរួមគ្នាច្រើន លោកហៅថា វិបាករបស់ផល ។ ដូច្នេះពាក្យថា **វិបាក** ឬក៏រួមពាក្យទាំងពីរ គឺ **ផលវិបាក** ប្រែមកថា វិបាករបស់ផលនេះឯង ។ វិបាកនេះលោកច្រើននិយាយ នៅពេលបុគ្គលជិតធ្វើមរណភាព ជិតធ្វើដំណើរទៅមុខដែលកើតអំពីកម្មមួយ លោកហៅថា **ជនកកម្ម** ក្នុងកម្ម១២ យ៉ាង (នឹងមានពណ៌នានៅខាងមុខ)។ ជនកកម្មនេះហើយជាកម្មមួយបែប ដែលសំរាប់បដិសន្ធិវិញ្ញាណរបស់សត្វ សំរាប់ជម្រុញសត្វឲ្យកើតជាវិបាក ឲ្យកើតជាជាតិ ជាភពតទៅទៀត ។

បើយើងនិយាយពីភព ក្នុងជាតិបច្ចុប្បន្ន ចាប់តាំងអំពីតូចមកយើងធ្វើបាបខ្លះ ធ្វើបុណ្យខ្លះជាធម្មតា ។ បាបបុណ្យនេះបង្កើតជាផលរួមគ្នាច្រើនទៅ លោកហៅថា វិបាក ឬ វិបាកវិញ្ញាណ ។ វិបាកវិញ្ញាណហ្នឹងឯង ជាតួបដិសន្ធិរបស់សត្វ ប៉ុន្តែមិនមែនជាតួវិញ្ញាណទេ គឺគ្រាន់តែជាកម្លាំងដែលរុញច្រានទៅភពមួយទៀតតែប៉ុណ្ណោះ ។ ពាក្យថា **បដិសន្ធិ** មានពីរបទ គឺ **បដិ** + **សន្ធិ**, **បដិ**





ចាស់ព្រឹទ្ធាចារ្យ ឬ ជនដែលគួរគោរព,

៥- **បត្តិទានមយៈ** បុណ្យសម្រេច ដោយការចែករំលែកបុណ្យដល់គ្នា,

៦- **បត្តានុមោទនាមយៈ** បុណ្យសម្រេចដោយការត្រេកអរចំពោះចំណែកបុណ្យដែលអ្នកដទៃឲ្យ,

៧- **វេយ្យាវច្ចមយៈ** បុណ្យសម្រេច ដោយការខ្វល់ខ្វាយជួយខ្នះខ្នែង ក្នុងពិធីបុណ្យអ្នកដទៃ,

៨- **ធម្មស្សវនមយៈ** បុណ្យសម្រេចដោយការស្តាប់ធម៌,

៩- **ធម្មទេសនាមយៈ** បុណ្យសម្រេចដោយការសំដែងធម៌,

១០- **ទិដ្ឋុជុកម្ម** ការធ្វើទិដ្ឋិឲ្យត្រង់ (សម្មាទិដ្ឋិ) ។

## បុណ្យមានហេតុ ឬ លក្ខណៈ ៣ យ៉ាង គឺ

១-**បសាទៈ** មានចិត្តជ្រះថ្លា,

២-**សំវេគៈ** មានចិត្តសង្វេគតក់ស្លុត,

៣-**តេសុចរិតា** មានចិត្តស្អាតបរិសុទ្ធដោយកាយវាចាចិត្ត ។

បុណ្យផ្តល់នូវសម្បទា ៥ យ៉ាង ហៅថា **បុញ្ញសម្បទា** គឺៈ

១- **ញាតិសម្បទា** បរិបូណ៌ដោយញាតិ,

២- **អារោគ្យសម្បទា** បរិបូណ៌ដោយសុខភាព គ្មានរោគ,

៣- **ភោគសម្បទា** បរិបូណ៌ដោយទ្រព្យសម្បត្តិ,

៤- **សីលសម្បទា** បរិបូណ៌ដោយសីល,

៥- **ទិដ្ឋិសម្បទា** បរិបូណ៌ដោយសម្មាទិដ្ឋិ គឺប្រាជ្ញាយល់ឃើញត្រឹមត្រូវ ។

ទ្រឹស្តីពុទ្ធសាសនាបញ្ជាក់ថា បុណ្យនីមួយៗដែលយើងបានធ្វើ យើងរមែងបានទទួលជានិច្ចនូវផល ឬផ្លែផ្កានៃបុណ្យ ហៅថា **ផលានិសង្ស** គឺ **អានិសង្សនៃបុណ្យ** ។ អានិសង្សបុណ្យ មាន ៥ យ៉ាង គឺ ៖

១- **តិក្ខបញ្ញាវិសារទោ** ប្រាជ្ញាក្លៀវក្លាមុះមុត,

២- **សុវណ្ណតា** មានពណ៌សម្បុរល្អ,

៣- **សុរូបតា** មានរូបល្អ,

៤- **សុសណ្ឋានា** មានសណ្ឋានទ្រង់ទ្រាយល្អ,

៥- **ចក្កវត្តិរាជា ហោតិ** នឹងបានទៅជាស្តេចចក្រពត្តិ ក្នុងជាតិណាមួយមិនខានឡើយ ។

ព្រះសម្មាសម្ពុទ្ធ ទ្រង់សរសើរអានិសង្សបុណ្យណាស់ព្រោះបុគ្គលណា ស្រឡាញ់ចូលចិត្តបុណ្យ យូរ ឬ ឆាប់ បុគ្គលនោះនឹងបានសម្រេចលោកុត្តរធម៌ ទើបទ្រង់ត្រាស់សម្តែង ថា ៖

**សុខោ បុញ្ញស្ស ឧច្ចយោ**





ការសន្សំបុណ្យ រមែងនាំមកនូវសេចក្តីសុខ

**ឥធ មោទតិ បេច្ច មោទតិ**

**កតបុញ្ញោ ឧភយត្ថ មោទតិ**

អ្នកបានធ្វើបុណ្យ រមែងរីករាយសប្បាយ ក្នុងលោកទាំងពីរ គឺ រីករាយសប្បាយ ក្នុងលោកនេះ លុះទៅកាន់លោកខាងមុខ រមែងរីករាយសប្បាយទៀត ។

ព្រះពុទ្ធអង្គទ្រង់ជ្រាបច្បាស់ដោយបញ្ញាញាណថា បុណ្យជាអំពើល្អ អ្នកណាមួយបានធ្វើ បានសន្សំហើយ រមែងញុំាងអ្នកនោះ ឲ្យទទួលផលបុណ្យ (អានិសង្សបុណ្យ) គឺសេចក្តីសុខចំរើនឥតមានអ្វីរាំងខាំងបានឡើយ បានជាព្រះអង្គទ្រង់ប្រទាននូវឱវាទថា **កុសលស្សូបសម្បទា** ត្រូវបំពេញបុណ្យកុសល ។

❈ ✤ ❈

ជាដើម ។ ប៉ុន្តែមតិកគឺកម្មដែលគេធ្វើហើយ គេត្រូវតែទទួលផលនៃកម្មនោះ ដោយខ្លួនឯងជាទៀងទាត់ នឹងឲ្យបុគ្គលឯទៀតទទួលជំនួសពុំបានឡើយ។ ឧទាហរណ៍ ដោយសារកម្មអាក្រក់របស់គេ គេកើតមក ជាមនុស្សមានរោគាព្យាធិច្រើន គេត្រូវរងទុក្ខវេទនាយ៉ាងខ្លោចផ្សា តែគ្មានអ្នកណា សូម្បីតែប្រពន្ធ ឬ កូនអាចជួយទទួលរំលែកទុក្ខនោះបានឡើយ ព្រោះគេជាទាយាទនៃកម្មនោះ ។

**កម្មយោនី** មានកម្មជាកំណើត គឺកម្មជាអ្នកបង្កើតសត្វលោក បានសេចក្តីថា បើមានកម្ម ត្រូវតែមានវិបាក ដែលជាតួបដិសន្ធិ របស់សត្វ ។ បើអស់កម្ម អស់វិបាក បដិសន្ធិ ក៏អស់ដែរ ។ ព្រះអរហន្ត លោកលះកិលេសអស់ហើយ លោកធ្វើអ្វីមិនរាប់ថាជាកម្មបានទេគ្រាន់តែកិរិយាប៉ុណ្ណោះ លោកអស់កម្មហើយ ដូចនេះ គ្មានវិបាក គ្មានបដិសន្ធិកើតឡើងទៀតបានទេ។ ផ្លូវលោកគេនិយាយថា មាតាបិតា ជាអ្នកបង្កើតសត្វលោក ប៉ុន្តែ ផ្លូវធម៌លោកនិយាយថា កម្មជាអ្នកបង្កើតសត្វលោក តែអាស្រ័យមាតាបិតា ជាទីកើត ។

**កម្មពន្ធុ** មានកម្មជាផៅពង្ស (ញាតិសន្តាន) ។ ធម្មតាញាតិសន្តានជាមិត្រនឹងគ្នាខ្លះ ជាសត្រូវនឹងគ្នាខ្លះ ជួយគ្នាបានខ្លះ ជួយគ្នាមិនបានខ្លះ សូម្បីជួយគ្នាបាន ពេលខ្លះនៅឆ្ងាយពីគ្នាពេក រកតែ





ប្រែថា ឆ្ពោះទៅ ឬ ចំពោះទៅ, **សន្ធិ** ប្រែថា ត, ដូច្នេះ ពាក្យថា **បដិសន្ធិ** ប្រែថា ការតជាតិភពទៅមុខទៀត ។

ពុទ្ធសាសនិកជនគ្រប់រូប បានយល់ដឹងហើយថា ទ្រឹស្តីកម្មផល ជាមូលដ្ឋាននៃព្រះពុទ្ធសាសនា ។ ដូចនេះ យើងអាចហៅព្រះពុទ្ធសាសនាជាលទ្ធិកម្មនិយម (លទ្ធិស្តីពីកម្ម) វិញក៏បាន ឥតទាស់ខុសទេ ។ ទ្រឹស្តីកម្មផលនេះ ស្មុគស្មាញណាស់ បុគ្គលអ្នកមិនបានសិក្សារឿងកម្មផលនេះ ឲ្យបានម៉ត់ចត់ មើលមិនចប់ចុងចប់ដើម មិនគ្រប់ជ្រុងជ្រោយ ច្រើនក័ន្តច្រឡំថា ធ្វើបុណ្យមិនឃើញបានបុណ្យ ធ្វើបាបមិនឃើញបានបាប ឬក៏ច្រឡំថា កម្មមិនជាហេតុឲ្យមានកំណើត កម្មមិនអាចចាត់ចែងសត្វលោក ឲ្យខុសប្លែកគ្នា ។

មនុស្សយើងកើតមក មិនដូចគ្នាទេ អ្នកខ្លះ កើតក្នុងវិមានក្នុងប្រាសាទ អ្នកខ្លះកើតក្នុងផ្ទះថ្ម ផ្ទះឈើ ឬ ខ្ទមស្បូវ ។ សូម្បីតែកើតក្នុងប្រាសាទដូចគ្នា រូបរាងក៏មិនដូចគ្នា ចិត្តថ្លើមចរិយាមារយាទ ក៏មិនដូចគ្នាទៀត តើអ្នកណាធ្វើឲ្យសត្វលោកខុសប្លែកគ្នាយ៉ាងនេះ? ។ ព្រះសព្វញ្ញុពុទ្ធ ទ្រង់បានត្រាស់ដឹងរឿងអាថ៌កំបាំងនេះ ទ្រង់មានបន្ទូលថា **កម្មំ សត្តេ វិភជតិ យទិទំ ហីនប្បណីតតាយ** កម្មតែងចែកសត្វទាំងឡាយឲ្យថោកទាបនិងថ្លៃថ្លា ។

គម្ពីរសុត្តន្តបិដក មជ្ឈិមនិកាយ ឧបរិបណ្ណាសក ភាគ ២៨ ទំព័រទី ៥៥ បរិយាយបញ្ជាក់ទៀតថា **សុភមាណព** បានទូលសួរព្រះមានព្រះភាគថា "បពិត្រព្រះអង្គដ៏ចំរើន អ្វីជាហេតុធ្វើឲ្យសត្វលោកប្លែកគ្នា អ្នកខ្លះមានអ្នកខ្លះក្រ អ្នកខ្លះល្អ អ្នកខ្លះអាក្រក់ អ្នកខ្លះមានអាយុវែង អ្នកខ្លះមានអាយុខ្លី..." ។ ព្រះពុទ្ធទ្រង់ត្រាស់ថា "**កម្មស្សកា មាណវ សត្តា កម្មទាយាទា កម្មយោនី កម្មពន្ធូ កម្មប្បដិសរណា កម្មំ សត្តេ វិភជតិ យទិទំ ហីនប្បណីតតាយ** ម្នាលមាណព សត្វទាំងឡាយ មានកម្មជារបស់ខ្លួន ជាទាយាទនៃកម្ម (គឺជាអ្នកទទួលមត៌កនៃកម្ម) មានកម្មជាកំណើត មានកម្មជាផៅពង្ស (ញាតិសន្តាន) មានកម្មជាទីពឹងអាស្រ័យកម្ម ជាអ្នកចាត់ចែងសត្វលោកឲ្យអាក្រក់ល្អ" ។

តាមរយៈការត្រាស់ដឹង នៃព្រះសម្មាសម្ពុទ្ធនេះ បញ្ជាក់ថា មិនមានតួអង្គអាទិទេព ឥន្ទ ព្រហ្ម អង្គណាជាអ្នកសាងលោកទេ គឺពិតជាកម្មនេះឯង ជាអ្នកកសាងសត្វលោក ។ រឿងនេះ យើងអាចសង្កេតមើល ក្នុងជីវិតប្រចាំថ្ងៃរបស់យើងបាន ។ ខ្ទិល និង ឧសព្វាហ៍ តើឲ្យផលខុសគ្នាដូចម្ដេច ។ កាច និង ស្លូត តើឲ្យផលខុសគ្នាដូចម្ដេច ។ អ្នកផងគេស្អប់យើង តើមកពីអ្វី? គេរាប់អានយើង តើមកពីអ្វី? មកពីព្រះឥន្ទ ព្រះព្រហ្ម ទេវតា ឬ មកពីកម្ម





គឺកុសលកម្ម អកុសលកម្ម របស់យើង គិតតែប៉ុណ្ណឹងទៅ គង់យល់បានហើយ។ **កល្យាណការី កល្យាណំ បាបការី ច បាបកំ** អ្នកធ្វើកម្មល្អបានផលល្អ អ្នកធ្វើកម្មអាក្រក់បានផលអាក្រក់ ។

ព្រះដ៏មានព្រះភាគទ្រង់សម្ដែងថា **កម្មស្សកា** មានកម្មជារបស់ខ្លួន ។ ប៉ុន្តែ មនុស្សលោក យល់ថា ខ្លួនរបស់ខ្លួន ទ្រព្យសម្បត្តិរបស់ខ្លួន ប្រពន្ធ ឬ ប្ដីរបស់ខ្លួន កូនចៅរបស់ខ្លួន... ។ មនុស្សលោក យល់ដូចនេះ ត្រូវតាមការសន្មត ប៉ុន្តែមិនត្រូវតាមការពិតទេ ព្រោះដល់ពេលស្លាប់ទៅ គ្មានយកអ្វីដែលគេសម្គាល់ថាជារបស់គេនោះទៅជាមួយបានទេ។ ព្រះពុទ្ធសម្ដែងថា កម្ម ពិតជារបស់ខ្លួនព្រោះវាជាប់ទៅជាមួយខ្លួនរហូត ទៅទីកន្លែងណា កម្មទៅតាមជាមួយរហូត សូម្បីតែស្លាប់ចាកលោកនេះ ក៏តាមទៅជាប់ជាមួយដែរ នេះបានពិតជារបស់ខ្លួនមែន ។

**កម្មទាយាទា** ជាទាយាទនៃកម្ម គឺជាអ្នកទទួលមត៌កនៃកម្ម។ កេរមត៌ក ដែលជីដូនជីតា មាតាបិតា បម្រុងចែកឲ្យក្ដី ឬ ញាតិមិត្រ បម្រុងចែកឲ្យក្ដី កេរមត៌កនេះ មិនទៀងទាត់ទេ ជួនក៏បានទទួល ជួនកាលក៏មិនបានទទួល សូម្បីបានទទួលហើយ ក៏អាចត្រូវបាត់បង់ទៅវិញបានដោយហេតុផ្សេងៗ មានចោរលួចចោរប្លន់

៣- **ឧបបីឡកកម្ម** កម្មមានកិច្ចបៀតបៀន គឺបន្ថយផលនៃជនកកម្ម ។ បើជនកកម្ម នាំកើតក្នុងកន្លែងសុខច្រើន បន្ថយឲ្យមានសុខតិច ។ បើជនកកម្ម នាំឲ្យកើតក្នុងកន្លែងទុក្ខច្រើន បន្ថយឲ្យមានទុក្ខតិច ។

៤- **ឧបឃាតកកម្ម** កម្មមានកិច្ចផ្ដាច់បង់នូវជនកកម្ម និងកម្មដទៃ ហើយឲ្យផលខ្លួនឯងជំនួស ។ ឧទាហរណ៍ សម្លាប់សត្វផង សម្លាប់មនុស្សផង កម្មគឺការសម្លាប់មនុស្ស ផ្ដាច់បង់នូវផល នៃកម្មគឺការសម្លាប់សត្វ ហើយឲ្យផលខ្លួនឯងជំនួសវិញ ។ បើចំរើនឈាន បានសម្រេចចាប់តាំងពីបឋមជ្ឈាន រហូតដល់ចតុជ្ឈាន ចតុជ្ឈាន ផ្ដាច់បង់នូវផលនៃឈានខាងដើម ហើយឲ្យផលខ្លួនឯងជំនួសវិញ ។

អធិប្បាយបន្ថែម: ជនកកម្ម ដែលល្អ នាំឲ្យទៅកើត ក្នុងត្រកូលខ្ពង់ខ្ពស់មានទ្រព្យសម្បត្តិច្រើន កើតហើយ មិនប្រមាទ ខំយកចិត្តទុកដាក់ ខំធ្វើការងារល្អតទៅទៀត (នេះជាឧបត្ថម្ភកកម្ម) គេរឹតតែមានទ្រព្យច្រើនទៀត ។ កើតហើយ ប្រហែសធ្វេស ខ្ជិលធ្វើការងារ (នេះជា ឧបបីឡកកម្ម) ទ្រព្យសម្បត្តិក៏អន់ថយចុះមក ។ កើតហើយ ប្រមាទ គិតតែលេងល្បែងអបាយមុខ (នេះជា ឧបឃាតកកម្ម) ទ្រព្យសម្បត្តិក៏វិនាសអស់រលីង ។ ជនកកម្ម



ព្រះពុទ្ធដីកា

ជួយគ្នាមិនទាន់ ហើយក្នុងវិស័យខ្លះទៀត ជួយគ្នាមិនបានតែម្ដង ដូចជានៅពេលប្រឡងជាដើម ។ ចំណែកកម្ម ដែលគេបានសាងទុក គឺជាញាតិយ៉ាងជិតស្និទ្ធបំផុត ហើយអាចជួយបាន គ្រប់កាលៈទេសៈទាំងអស់ ។

**កម្មប្បដិសរណា** មានកម្មជាទីពឹងអាស្រ័យ ។ បងប្អូនញាតិមិត្រ យើងពឹងគេបានមួយដងមួយកាល ពឹងគេរហូតមិនបានទេ សូម្បីមាតាបិតា យើងពឹងលោករហូត ក៏មិនសូវល្អដែរ គេទិចទៀន ថា កូនអ្វីចិញ្ចឹមមិនចេះធំ... ។ ចំណែកកម្ម ដែលគេបានកសាងហើយ តែងជាទីពឹងអាស្រ័យរបស់គេបាន គ្រប់ពេលវេលា គ្រប់ទីកន្លែង និង តទៅរហូតគ្រប់ៗ ជាតិ ។

ពន្យល់ជូនត្រួសៗ មកប៉ុណ្ណេះ សឲ្យឃើញថា កម្ម មានតួនាទីសំខាន់ណាស់ ដែលពុទ្ធបរិស័ទទាំងឡាយ ត្រូវខំប្រឹងប្រែងកសាងឲ្យបានល្អ ។

គម្ពីរសុត្តន្តបិដក អង្គុត្តរនិកាយ ចតុក្កនិបាត ភាគ ៤៣ ទំព័រទី ២២៩ ចែងអំពីកម្ម ៤ យ៉ាង គឺ ៖

១- **កម្មំ កណ្ហំ កណ្ហវិបាកំ** កម្មខ្មៅ មានវិបាកខ្មៅ,

២- **កម្មំ សុក្កំ សុក្កវិបាកំ** កម្មស មានវិបាកស,

៣- **កម្មំ កណ្ហំ សុក្កំ កណ្ហសុក្កវិបាកំ** កម្មខ្មៅខ្លះ សខ្លះ

មានវិបាកខ្មៅខ្លះ សខ្លះ,

៤-**កម្មំ អកណ្ហំ អសុក្កំ អកណ្ហំអសុក្កំវិបាកំ កម្មក្ខយាយ សំវត្តតិ** កម្មមិនខ្មៅ មិនស មានវិបាកមិនខ្មៅ មិនស ប្រព្រឹត្តទៅ ដើម្បីអស់កម្ម ។

កម្មក្នុងព្រះសូត្រនេះ ព្រះសម្មាសម្ពុទ្ធ ទ្រង់យកពណ៌ជាគ្រឿងប្រៀបធៀប ។ ពណ៌ខ្មៅ ជាតំណាងសេចក្តីអាក្រក់សេចក្តីទុក្ខក្តៅក្រហាយ ។ ពណ៌ស ជាតំណាងសេចក្តីល្អ សេចក្តីស្ងប់សុខត្រជាក់ ។ កម្មខ្មៅ បានដល់អកុសលកម្ម កម្មស បានដល់កុសលកម្ម ។ បើគេធ្វើកម្មខ្មៅ គេត្រូវបានទទួលវិបាកខ្មៅ ។ បើគេធ្វើកម្មស គេត្រូវបានទទួលវិបាកស ។ បើគេធ្វើកម្មខ្មៅខ្លះ សខ្លះ លាយគ្នា គេត្រូវទទួលផលលាយគ្នាដែរ គឺៈ ទុក្ខខ្លះ សុខខ្លះ សើចខ្លះ យំខ្លះ ផ្លាស់ប្តូរគ្នារឿយៗ តាមអំពើដែលគេបានធ្វើ ។ សត្វដែលនៅមានកម្ម ត្រូវតែអន្ទោលវិលវល់ក្នុងវដ្តសង្សារ លិចអណ្តែត កើតស្លាប់ៗ ពីខ្ពស់មកទាប ពីទាបទៅខ្ពស់ ពីមនុស្សទៅនរក... ពីមនុស្សទៅទេវតា... សាចុះសាឡើងដូចជាគ្រាប់អង្ករនៅក្នុងឆ្នាំង ដែលគេដាក់ទឹកដាំឲ្យពុះ វាកញ្ជ្រោលចុះឡើងៗ ដូចនោះដែរ ។

ទ្រឹស្តីកម្មផល ស្មុគស្មាញណាស់ មានស្រាលមានធ្ងន់ មាន





មុន មានក្រោយ មានជួយគ្នា មានប្រឆាំងគ្នា មានទាមទារពេលវេលាឲ្យផល មិនមែនត្រឹមតែមួយជីវិតទេ ច្រើនជីវិតច្រើនជាតិណាស់ ។ បើយើងគិតពិចារណាខ្លីៗ ប្រើពេលវេលាខ្លីៗ កម្មឲ្យផលមិនទាន់សព្វគ្រប់ទេ ។ រឿងកម្មផល ជាវិស័យរបស់ព្រះពុទ្ធ មិនមែនជាវិស័យរបស់យើងទេ ប៉ុន្តែបើយើងខំសិក្សា យើងនឹងកើតបញ្ញាភ្លឺស្វាងគ្រាន់បើដែរ ល្មមជឿកម្មផល និង បដិបត្តិទៅបានប្រយោជន៍ បានសុខយ៉ាងសមរម្យ ។

បន្ទាប់ទៅនេះ សូមពណ៌នាយ៉ាងសង្ខេបនូវកម្ម ១២ យ៉ាង ដែលមានកម្ម ឲ្យផលតាមកិច្ច ៤ យ៉ាង, កម្ម ឲ្យផលតាមលំដាប់មុនក្រោយ ៤ យ៉ាង និង កម្ម ឲ្យផលតាមលំដាប់ពេលវេលា ៤ យ៉ាង ។

## កម្មឱ្យផលតាមកិច្ច ៤ យ៉ាង គឺ ៖

១- **ជនកកម្ម** កម្មមានកិច្ចជាអ្នកបង្កើត ជាតួបដិសន្ធិនាំសត្វឲ្យកើត ក្នុងកាមភព រូបភព និង អរូបភព ។

២- **ឧបត្ថម្ភកកម្ម** កម្មមានកិច្ចជួយជ្រោមជ្រែង បើជនកកម្មនាំឲ្យកើតក្នុងកន្លែងល្អ ជួយជ្រោមជ្រែងឲ្យរឹតតែល្អឡើង ។ បើជនកកម្ម នាំឲ្យកើតក្នុងកន្លែងអាក្រក់ ជួយជ្រោមជ្រែង ឲ្យរឹតតែអាក្រក់ថែមទៀត ។

**អហោសិកម្ម** កម្មដែលមិនឲ្យផល ។ កម្មដែលគេធ្វើដោយឥតចេតនា ឬ មានចេតនាខ្សោយ បើកម្មដទៃឲ្យផលហើយ វាក៏ទៅជា អហោសិកម្ម ។ កម្មជាអកុសល ស្រាលខ្លះ ធ្ងន់ខ្លះ ដូចជាសម្លាប់សត្វផង សម្លាប់មនុស្សផង កាលបើការសម្លាប់មនុស្សវាឲ្យផលហើយ ការសម្លាប់សត្វ វាទៅជា អហោសិកម្ម មិនអាចឲ្យផល ក្នុងបដិសន្ធិកាលបានទេ ប៉ុន្តែ វាឲ្យផល ក្នុងបវត្តិកាល (កាលបន្ទាប់ពីស្លាប់) បាន ។ ចំណែកកម្មជាកុសល ស្រាលខ្លះ ធ្ងន់ខ្លះ ក៏មានទំនងដូចគ្នាដែរ ។ កម្មជាកុសលប្រកបដោយចេតនា តែមានឥន្ទ្រីយ៍ ៥ (គឺ សទ្ធា វិរិយៈ សតិ សមាធិ បញ្ញា) ខ្សោយ ហើយមាន តណ្ហា មានះ ទិដ្ឋិ ខ្លាំង បើមានកម្មដទៃឲ្យផលហើយ វាក៏ទៅជា អហោសិកម្មដែរ ។ បុគ្គលធ្វើកម្មជាអកុសល បើមានការភ្ញាក់រឭកប្រកបដោយធម៌ ៥ យ៉ាងគឺ **បដិរូបទេសវាស** ការនៅក្នុងប្រទេសប្រកបដោយសីលធម៌, **សប្បុរិសូបសំសេវ** ការបានសេពគប់នឹងសប្បុរស, **អត្តសម្មាបណិធិ** ការតាំងខ្លួនទុកដោយប្រពៃ, **បុព្វេកតបុញ្ញតា** ការបានសាងបុណ្យទុក ក្នុងកាលមុន និង **សទ្ធម្មស្សវន** ការបានស្តាប់ព្រះសទ្ធម្ម ក៏អាចញ៉ាំងកម្មជាអកុសលនោះឲ្យទៅជាអហោសិកម្មបានដែរ។ កម្មរបស់បុគ្គលអ្នកបានសម្រេចព្រះនិព្វាន មិនមានបុគ្គលណាត្រូវទទួលផល នៃ





ផ្នែកអាក្រក់ នាំឲ្យទៅកើត ក្នុងត្រកូលទន់ទាប ក្រទ្រព្យសម្បត្តិ កើតហើយ ខ្ជិលធ្វើការងារ គិតតែលេងល្បែងអបាយមុខ (នេះជា ឧបត្ថម្ភកកម្ម) រឹតតែហិនហោចលិចលង់តទៅទៀត ។ កើតហើយ មិនសូវខ្ជិល ខិតខំធ្វើការងារ (នេះជាឧបបីឡកកម្ម) គេក៏បានទ្រព្យសម្បត្តិ យ៉ាងមធ្យម ប្រឡំគេប្រឡំឯងបាន ។ កើតមកហើយ ខំរៀនសូត្រ មានការចេះដឹងច្រើន ហើយខំយកចិត្តទុកដាក់ ធ្វើការងារថែមទៀត (នេះជា ឧបឃាតកកម្ម) គេក៏បានទទួលតំណែងខ្ពង់ខ្ពស់ ហើយមានទ្រព្យសម្បត្តិថែមទៀត ។ អ្នកជឿកម្មផល ត្រូវយល់ និង អនុវត្តតាមទ្រឹស្តីនេះ ។

## កម្មឱ្យផលតាមលំដាប់មុនក្រោយ ៤ យ៉ាងគឺ

១- **គរុកម្ម** កម្មមានទម្ងន់ ផ្នែកអកុសល បានដល់អនន្តរិយកម្ម សម្លាប់មាតាបិតា សម្លាប់ព្រះអរហន្ត ញ៉ាំងព្រះលោហិតព្រះពុទ្ធឲ្យកើតឡើង និងធ្វើការបំបែកសង្ឃ ។ ផ្នែកកុសល បានដល់មហគ្គតកម្ម គឺ សមាបត្តិ ៨ រូបឈាន ៤ អរូបឈាន ៤ ។ គរុកម្ម ឲ្យផលមុនកម្មឯទៀតទាំងអស់ ។

២- **អាសន្នកម្ម** កម្មដែលគេធ្វើជិតពេលស្លាប់ដូចជាកូនចៅ ឬ ញាតិមិត្រ គេជួយចាត់ចែងរៀបចំ ជាកិច្ចបុណ្យជូនក្តី ឬ នឹកដល់កម្មចាស់ ដែលធ្លាប់បានធ្វើហើយក្តី ហៅថា អាសន្នកម្ម ។

បើគ្មាន គរុកម្ម ទេ អាសន្នកម្ម ត្រូវឲ្យផលមុន ។

៣- **អាចិណ្ណកម្ម** (ឬពហុលកម្ម) កម្មដែលគេធ្វើហើយ ធ្វើទៀតរឿយៗ ទៅជាទម្លាប់ជាផ្នត់គំនិតក្ដី ឬ កម្មដែលគេធ្វើតែម្ដងទេ ប៉ុន្តែ ចិត្តនៅតែចងចាំ នឹកមិនភ្លេចក្ដី ហៅថា អាចិណ្ណកម្ម ។ បើគរុកម្ម និងអាសន្នកម្មមិនឲ្យផលទេ អាចិណ្ណកម្ម ត្រូវឲ្យផល។

៤- **កដត្តាកម្ម** កម្មដែលគេធ្វើដោយឥតចេតនា ឬ ដោយចេតនាទន់ខ្សោយ ឬ ដោយចេតនាបម្រុងធ្វើកម្មដទៃ ប៉ុន្តែ វាប៉ះប្រទ្បមកលើបុគ្គលដទៃទៅវិញ ឬក៏ សេសសល់ផលនៃកម្មចាស់រង់ចាំឱកាសនឹងឲ្យផល ហៅថា កដត្តាកម្ម ។ បើកម្មទាំងបីខាងដើមមិនមានទេ កដត្តាកម្ម ត្រូវឲ្យផល ។

ការគួរសង្កេត: គរុកម្ម មានទម្ងន់ធ្ងន់ណាស់ អាចកាត់ផ្ដាច់ឧបនិស្ស័យនៃកម្មចាស់ចេញបាន។ អាសន្នកម្ម ប្រៀបដូចជាគោចាស់ មានកម្លាំងខ្សោយ ឈរក្បែរទ្វារក្រោល បើគេបើកទ្វារក្រោល ត្រូវតែបានចេញមុនគេ ប៉ុន្តែ បើអាសន្នកម្ម មានកម្លាំងខ្សោយពេក អាចិណ្ណកម្ម ប្រៀបដូចជាគោមានកម្លាំងមធ្យម នៅឆ្ងាយបន្តិចនោះ អាចចេញមកបានមុនអាសន្នកម្មដែរ ។ ទោះបីអាសន្នកម្ម ឲ្យផលមុនអាចិណ្ណកម្មក៏ដោយ ក៏មានផលស្រាលនិងរយៈពេលខ្លីជាងអាចិណ្ណកម្មដែរ ។ ឯកដត្តាកម្ម សូម្បីឥតចេតនា





ក៏គង់ឲ្យផលដែរ ។

## កម្មឱ្យផលតាមលំដាប់ពេលវេលា ៤ យ៉ាងគឺ

១- **ទិដ្ឋធម្មវេទនីយកម្ម** កម្ម ឲ្យផលក្នុងបច្ចុប្បន្នជាតិនេះ,

២- **ឧបបជ្ជវេទនីយកម្ម** កម្ម ឲ្យផលបន្ទាប់ពីជាតិបច្ចុប្បន្ន គឺ ក្នុងជាតិទី ២,

៣- **អបរាបរិយវេទនីយកម្ម** កម្ម ឲ្យផលបន្ទាប់ពីជាតិ ទី២ គឺ រាប់តាំងពីជាតិ ទី៣ រហូតទៅ មានឱកាស ពេលណា ឲ្យផលពេលនោះ,

៤- **អហោសិកម្ម** កម្មដែលមិនឲ្យផល ។

**ទិដ្ឋធម្មវេទនីយកម្ម** កម្ម ឲ្យផលក្នុងបច្ចុប្បន្នជាតិនេះ មានទាំងល្អមានទាំងអាក្រក់ ។ ផ្នែកល្អដូចជាអ្នកធ្វើបុណ្យកុសលប្រកបដោយសម្បទា ៤ គឺ **ចេតនាសម្បទា** ការតាំងចិត្តយ៉ាងខ្ជាប់ខ្ជួនក្លាដាច់ខាត១, **បច្ចយសម្បទា** បច្ច័យដែលយកមកធ្វើបុណ្យកុសលនោះស្អាតបរិសុទ្ធ ១, **វត្ថុសម្បទា** អ្នកទទួលបច្ច័យនោះជាព្រះអរហន្ត ឬ យ៉ាងទាបត្រឹម ព្រះអនាគាមី ១, **គុណាតិរេកសម្បទា** អ្នកទទួលបច្ច័យនោះ ប្រកបដោយគុណវិសេស គឺទើបនឹងចេញពីសមាបត្តិ ១ ។ ផ្នែកអាក្រក់ ដូចជាអ្នកធ្វើអនន្តរិយកម្មជាដើម ។

**ទី៖** ព្រោះពេលនោះ គេត្រូវការតែមនុស្សក្លាហាន ។ ឯអ្នកចេះដឹងច្រើន ហើយមិនក្លាហាន ក៏ខកខានទៅ ព្រោះកាលវេលាមិនផ្តល់ឲ្យ ឬ ព្រោះកាលវិបត្តិ ។

**បយោគវិបត្តិ :** នាយ **ក** មានសតិបញ្ញា និង ចំណេះវិជ្ជាច្រើន តែគេមិនបានយកទៅប្រើការ ក្នុងផ្លូវសុចរិតទេ គេប្រព្រឹត្តតែរឿងទុច្ចរិតខុសច្បាប់ ម្ល៉ោះហើយ ក៏ធ្លាក់ខ្លួនមានទោសជាប់គុកជាប់ច្រវាក់ ខានបានទទួលនូវប្រយោជន៍ពីចំណេះវិជ្ជាទៅ ព្រោះបយោគវិបត្តិ ។

ទ្រឹស្តីកម្មផល ជាទ្រឹស្តីធំមួយ ក្នុងព្រះពុទ្ធសាសនា ។ បើគ្មានកម្មផល ព្រះពុទ្ធសាសនា ក៏គ្មានដែរ ។ បុគ្គលអ្នកមិនជឿកម្មផល ជាជនពាលអន្យតិរ្ថិយ៍ បុគ្គលអ្នកជឿកម្មផល សើៗ ឬជឿជ្រុលពេក ឈ្មោះថា ជាមនុស្សដែលខ្វះវិចារណញ្ញាណ ។ សាសនាអន្យតិរ្ថិយ៍មានទ្រឹស្តីស្រដៀងគ្នានេះដែរ ដែលនិយាយតែអំពី "**កម្មចាស់**" ខុសស្រឡះពីព្រះពុទ្ធសាសនាដែលនិយាយអំពី **កម្មចាស់** ផង **កម្មថ្មី** ផង ។

គម្ពីរសុត្តន្តបិដក អង្គុត្តរនិកាយ តិកនិបាត ភាគ ៤១ ទំព័រទី ១៧៩ ចែងថា លទ្ធិអន្យតិរ្ថិយ៍ គេមានជំនឿបីយ៉ាង គឺ ៖

១- **បុព្វេកតហេតុ** បុរសបុគ្គលទទួលសេចក្តីសុខក្តី ទុក្ខក្តី





កម្មនោះតទៅទៀត ហៅថា អហោសិកម្ម ដែរ ។

ច្បាប់របស់កម្ម ជាច្បាប់មួយមានលក្ខណៈស្មុគស្មាញពិបាកយល់ឲ្យបានច្បាស់លាស់ណាស់ មិនមែនជាវិស័យរបស់យើងទេ ជាពុទ្ធវិស័យ ប៉ុន្តែ យើងត្រូវខំសិក្សាឲ្យបានយល់ខ្លះ ដើម្បីងាយស្រួលដល់ការបដិបត្តិ ។ កម្មមិនមែនគេធ្វើថ្ងៃហ្នឹង ទទួលផលថ្ងៃហ្នឹងទាំងអស់ទេ គេទទួលផលថ្ងៃហ្នឹងផង ថ្ងៃតៗ ទៅផង ដូចជាដើមស្វាយអីចឹង មិនឲ្យផ្លែតែម្តងទាំងអស់ទេ ត្រូវឲ្យផលតៗ ទៅទៀតផង ។ កម្ម មិនមែនកម្មណា គេធ្វើមុន ឲ្យផលមុន កម្មណាគេធ្វើក្រោយ ត្រូវឲ្យផលក្រោយទេ ដូចជាគេដាំរុក្ខជាតិអីចឹងដែរ មិនមែនគេដាំរុក្ខជាតិណាមុន រុក្ខជាតិនោះ ឲ្យផលមុន គេដាំរុក្ខជាតិណាក្រោយ រុក្ខជាតិនោះ ឲ្យផលក្រោយដូចនោះទេ ។ ត្រូវអាស្រ័យទៅតាមពូជធ្ងន់ស្រាល នៃរុក្ខជាតិនោះៗ ផង អាស្រ័យអាកាសធាតុជាដើមរួមផ្សំផង ។ កម្ម មិនមែនគេធ្វើ ក្នុងបច្ចុប្បន្នជាតិនេះ ហើយទទួលផល ក្នុងជាតិនេះទាំងអស់ទេ ត្រូវទទួលជាតិតៗទៅមុខទៀតផង ។ រឿងកម្មវែងឆ្ងាយដូចនេះហើយ បានជាធ្វើឲ្យអ្នកបញ្ញាខ្ចី ដូចយើងពិបាកយល់ ។

កម្ម ឬ អំពើដែលបុគ្គលណាមួយ បានធ្វើហើយ ជារឿងរបស់បុគ្គលនោះម្នាក់ៗ ។ **កម្មស្សកោម្ហិ** មានកម្មជារបស់ខ្លួន...។

អ្នកណាធ្វើបុណ្យ បានបុណ្យ អ្នកណាធ្វើបាប បានបាប ។ សូមជ្រាបថា បុណ្យបាបមិនបាត់បង់ទៅណាទេ សូម្បីធ្លាក់ក្នុងទឹកក៏មិនរលាយរលេះ ធ្លាក់ទៅក្នុងភ្លើងក៏មិនឆេះ វារង់ចាំឲ្យផលដល់យើងជាដរាប ប៉ុន្តែវាមិនទាន់មានឱកាសល្អ នឹងឲ្យផលបាននៅឡើយ។ បុណ្យបាប ដែលនឹងអាចឲ្យផលបានស្រួល ត្រូវអាស្រ័យដោយសម្បត្តិ ៤ ឬ វិបត្តិ ៤ ជាអង្គប្រកបរួមផ្សំដែរ ។ បើប្រកបដោយសម្បត្តិ ៤ បុណ្យងាយនឹងឲ្យផល បើប្រកបដោយវិបត្តិ ៤ វិញ បុណ្យឲ្យផលពុំសូវបានពេញលេញទេ ។

**សម្បត្តិ ៤ យ៉ាង គឺ ៖**

១- **គតិសម្បត្តិ** ទីកន្លែងល្អ,

២- **ឧបធិសម្បត្តិ** រូបរាងល្អ,

៣- **កាលសម្បត្តិ** ពេលវេលាល្អ,

៤- **បយោគសម្បត្តិ** ការប្រកប ឬ ធ្វើការល្អ ។

**វិបត្តិ ៤ យ៉ាង គឺ ៖**

១- **គតិវិបត្តិ** ទីកន្លែងមិនល្អ,

២- **ឧបធិវិបត្តិ** រូបរាងកាយមិនល្អ,

៣- **កាលវិបត្តិ** ពេលវេលាមិនល្អ,

៤- **បយោគវិបត្តិ** ការប្រកប ឬ ធ្វើការមិនល្អ ។





អធិប្បាយបន្ថែមដោយមានឧទាហរណ៍ ៖

**គតិវិបត្តិ** : នាយ **ក** មានសតិបញ្ញា តែទៅកើត ក្នុងទីកន្លែងមិនល្អ ម្ល៉ោះហើយអត់បានទៅជាអ្នកប្រាជ្ញធំដុំអ្វីទេ គ្រាន់តែបានល្មម ។ នាយ **ក** បានធ្វើបុណ្យទុកច្រើន ប៉ុន្តែ ពេលដែលព្រះពុទ្ធទ្រង់ត្រាស់ អាសន្នកម្ម បាននាំនាយ **ក** ទៅកើតក្នុងអបាយភូមិ ម្ល៉ោះហើយអត់មានឱកាសបានសម្រេចធម៌អ្វីទេ ។

**ឧបធិវិបត្តិ** : នាយ **ក** និង នាយ **ខ** មានចំណេះវិជ្ជាដូចគ្នា មានចរិយាប្រហែលគ្នា ប៉ុន្តែ នាយ **ក** មានរាងកាយមាំមួន នាយ **ខ** មានរោគព្យាធិយ៉ាងច្រើន ដល់ពេលគេជ្រើសរើសយកមនុស្សធ្វើការ គេយកនាយ **ក** គេមិនយកនាយ **ខ** ទេ ព្រោះឧបធិវិបត្តិ ។ នាង **ក** មានចំណេះវិជ្ជាច្រើនជាងនាង **ខ** ប៉ុន្តែនាង **ខ** មានរូបរាងទ្រង់ទ្រាយល្អជាងនាង **ក** ដល់ពេលគេជ្រើសរើសយកមនុស្សធ្វើការផ្នែកទទួលភ្ញៀវ គេយកនាង **ខ** មិនយកនាង **ក** ទេ ព្រោះឧបធិវិបត្តិ ។

**កាលវិបត្តិ** នាយ **ធីរៈ** មិនសូវមានចំណេះវិជ្ជាប៉ុន្មានទេ តែជាអ្នកក្លាហានតស៊ូ ចំណែកនាយ **ខឡុនៈ** ជាអ្នកមានចំណេះវិជ្ជាច្រើនតែជាមនុស្សមិនក្លាហានតស៊ូ ពេលនោះ ជាពេលស្រុកកើតសង្គ្រាម គេត្រូវការយកមនុស្សធ្វើការ គេសម្រេចយកនាយ

មកនូវសេចក្តីសុខចំរើន ដល់ជាតិ និង សាសនា ឬ ដល់បុគ្គលណាទេ អ្នកណា បដិបត្តិតាម អ្នកនោះ ឈ្មោះថា ជាមនុស្ស**ក្រៅពុទ្ធសាសនា** ។

សព្វថ្ងៃនេះ នៅប្រទេសខ្មែរយើង មានអ្នកកាន់ពុទ្ធសាសនាមួយចំនួន កំពុងធ្លាក់ខ្លួនចូលក្នុងលទ្ធិអន្យតីរ្ថិយ៍ គេនិយាយតែពីកម្មចាស់ ពីឧបនិស្ស័យ ពីហេតុបច្ច័យ គេអត់គិតរឿងកម្មថ្មី អត់គិតរឿងអប់រំអ្វីទេ ។ គេតាំងខ្លួនជាពុទ្ធបរិស័ទ ប៉ុន្តែគ្មានភក្តីចំពោះព្រះពុទ្ធទេ គេពូកែខាងសូត្រធម៌មិនមស្សការ ឯខាងសទ្ធាវិញ ដូចទឹកលើស្លឹកឈូក ជឿព្រះផង ជឿព្រាហ្មណ៍ផង ជឿមន្តលក្ខាក់ផ្អើលផង ។ បើមានមិច្ឆាទិដ្ឋិផង ល្ងង់ផង ចចេសផង ខ្ជិលផង តើព្រះពុទ្ធឯណាព្រះអង្គជួយបាន សូម្បីតែ ព្រះអង្គគង់ព្រះជន្មជាធរមានក៏ដោយចុះ ។

ទ្រឹស្តីកម្មផល ស្តីអំពីទំនាក់ទំនងនៃជីវិតចាស់ទៅនឹងជីវិតថ្មី គឺ ស្លាប់កើត កើតស្លាប់ ក្នុងវាលវដ្តសង្សារ បង្កើតជាចម្ងល់មួយថា មនុស្សស្លាប់ទៅ តើមានសភាព មានលក្ខណៈ យ៉ាងណា ? កើតទៀត ឬ មិនកើតទៀត ? តើកម្មនៃជីវិតចាស់ ឆ្លងទៅជីវិតថ្មីរបៀបណា? ។

ត្រង់ចំណុចនេះ សូមអស់លោកអ្នកជ្រាបតាមសេចក្តី នៅ





មិនសុខមិនទុក្ខក្តី ទាំងអស់នោះ ព្រោះហេតុតែអំពើដែលគេបានធ្វើហើយក្នុងកាលមុន (កម្មចាស់) ។

២- **ឥស្សរនិម្មានហេតុ** បុរសបុគ្គល ទទួលសេចក្តីសុខក្តី ទុក្ខក្តី មិនសុខ មិនទុក្ខក្តី ទាំងអស់នោះ ព្រោះហេតុតែទេវតាដ៏ធំបណ្តាលឲ្យ ។

៣- **អហេតុអប្បច្ចយា** បុរសបុគ្គល ទទួលសេចក្តីសុខក្តី ទុក្ខក្តី មិនសុខ មិនទុក្ខក្តី ទាំងអស់នោះ ព្រោះមិនមានហេតុ មិនមានបច្ច័យ ។

លទ្ធិទីមួយ "**បុព្វេកតហេតុ** " ជឿលើកម្មចាស់ ។ លទ្ធិនេះបើគេមើលសើៗ ស្រដៀងគ្នានឹងព្រះពុទ្ធសាសនាដែរ ព្រោះពុទ្ធសាសនា **មានបុព្វេកតបុញ្ញតា** ការបានធ្វើបុណ្យទុកពីជាតិមុន ។ ប៉ុន្តែបើគេពិនិត្យឲ្យស៊ីជំរៅ ឃើញខុសគ្នាស្រឡះ ព្រោះលទ្ធិអន្យតីរ្ថិយ៍ ប្រកាន់មាំថា អ្វីៗ ទាំងអស់នោះសុទ្ធតែកើតមកពីផល នៃកម្មចាស់ កម្មចាស់កំណត់ទុកស្រេចហើយ មិនអាចកែប្រែបាន។ ជាពួក **អកិរិយវាទ** ធ្វើឲ្យមនុស្សអស់ **ឆន្ទៈ** និង **វីរិយៈ** មើលងាយអត្តភាពរបស់ខ្លួនជាដើម ម្លោះហើយគ្មានចំណង់ គ្មានប្រឹងប្រែងកសាង ឬ រើបម្រះអ្វីទាំងអស់។ ឯព្រះពុទ្ធសាសនាមានរឿងកម្មចាស់ដែរ តែមិនប្រកាន់មាំថា អ្វីៗ ទាំងអស់នោះ សុទ្ធតែជា

ផលនៃកម្មចាស់ទេ កម្មចាស់មិនអាចកំណត់ទុកទាំងស្រុង ដោយមិនឲ្យមានការប្រែអ្វីបានសោះនោះទេ។ ពាក្យប្រៀនប្រដៅព្រះអង្គជា **កិរិយវាទ** ដឹកនាំឲ្យមានឆន្ទៈ វីរិយៈ ខំកែលំអកសាងខ្លួនរំដោះខ្លួន ដោយខ្លួនឯង ។ ព្រះអង្គទ្រង់សម្តែងថា **សុខ ទុក្ខ មិនមែនសុទ្ធតែជាផលនៃកម្មចាស់ទាំងអស់នោះទេ** ។ ឧទាហរណ៍ ពេលណា គេប្រឹងប្រែងប្រើកម្លាំងហួស ពេលនោះ គេមានទុក្ខវេទនាខ្លាំង ពេលណា គេបន្ធូរបន្ថយការប្រឹងប្រែង ទុក្ខវេទនា ក៏ធូរស្រាល ពេលណា គេឈប់ប្រឹងប្រែង ពេលនោះ ទុក្ខវេទនា ក៏រលត់ ។ ពេលណា គេជាប់ចិត្តនឹងស្ត្រីម្នាក់ ហើយស្ត្រីនោះទៅទាក់ទងនឹងបុរសដទៃ ពេលនោះគេកើតទុក្ខ។ ពេលណា គេឈប់ជាប់ចិត្តនឹងស្ត្រីនោះ ទោះបីស្ត្រីនោះ ទៅទាក់ទងនឹងបុរសដទៃ ពេលនោះ គេក៏មិនកើតទុក្ខដែរ ។

ម្យ៉ាងទៀត ក្នុងពេលដែល **សុភមាណព** ទូលសួរថា អ្វីជាហេតុបច្ច័យ ធ្វើឲ្យបុគ្គលខ្លះមានអាយុខ្លី បុគ្គលខ្លះមានអាយុវែង, ព្រះអង្គទ្រង់សម្តែងថា ការសម្លាប់សត្វជាហេតុធ្វើឲ្យមានអាយុខ្លី។ ការមិនសម្លាប់សត្វ ជាហេតុធ្វើឲ្យមានអាយុវែង ។ នេះគឺជារឿងកម្មចាស់ ។ ដល់មករឿងកម្មថ្មី ព្រះអង្គសម្តែងថា ហេតុដែលនាំឲ្យអាយុខ្លី មាន ៥ យ៉ាង គឺ ៖





១- មិនចេះធ្វើខ្លួនឲ្យសប្បាយ,

២- មិនស្គាល់ប្រមាណក្នុងការសប្បាយ,

៣- បរិភោគភោជនាហារស្ទែងដល់សុខភាព,

៤- ត្រាច់ចរមិនស្គាល់កាលៈទេសៈ,

៥- មិនប្រព្រឹត្តព្រហ្មចារ្យ គឺសេពកាមហួសប្រមាណ ។

បើប្រព្រឹត្តផ្ទុយគ្នាពីនេះ នឹងទៅជាហេតុនាំឲ្យមានអាយុវែង។ បើកម្មចាស់កំណត់ទុកស្រេចហើយ នឹងចាំបាច់មានកម្មថ្មីនេះ ធ្វើអ្វីទៀត? ។

លទ្ធិទីពីរ **ឥស្សរនិម្មានហេតុ**... អ្វីៗទាំងអស់សុទ្ធតែទេវតាដ៏ជាធំបណ្តាលឲ្យ ។ លទ្ធិនេះ ពឹងផ្អែកលើវត្ថុខាងក្រៅ លើព្រះជាម្ចាស់ បដិសេធសមត្ថភាពរបស់មនុស្ស។ បញ្ញាស្មារតីសេចក្តីព្យាយាមជាដើម ត្រូវគាំងអស់ ព្រោះទេវតាដ៏ជាធំលោកសម្រេចឲ្យទាំងអស់ហើយ ។

លទ្ធិទីបី **អហេតុអប្បច្ចយា** ... អ្វីៗទាំងអស់ មិនមានហេតុ មិនមានបច្ច័យ។ លទ្ធិនេះ គ្មានអ្វីជាគោលទេ សុខក៏សុខឯង មានក៏មានឯង ក្រក៏ក្រឯង សុទ្ធតែជារឿងចៃដន្យទាំងអស់ មិនបាច់ខំប្រឹងប្រែងទេ ដេកចាំយកតែម្តង ។

លទ្ធិទាំងបីនេះ ព្រះសម្មាសម្ពុទ្ធ ចាត់ទុកជា **លទ្ធិខុស** មិននាំ

**ខណៈចិត្ត ។**

*ភវង្គៈ ភវង្គចលនៈ និង ភវង្គុប្បច្ឆេទៈ ជាខណៈចិត្ត ឬចិត្តប្រាសចាកវិថី ឬ ផុតវិថី ។ បន្ទាប់មកបានកើត* **បញ្ចទ្វារាវជ្ជនៈ**ៗ *បើកើតក្នុងភ្នែក លោកហៅថា* **ចក្ខុទ្វារាវជ្ជនៈ** *គឺការនឹកគិត ក្នុងទ្វារចក្ខុ ។ ត្រង់នេះ ពុំទាន់កើតចិត្តវិញ្ញាណនៅឡើយ ប៉ុន្តែ មានតួមនោ វារេទៅរកអារម្មណ៍ ដូចជាប៉ះរូបជាដើម បើប៉ះអ្វី កើតតាមអាយតនៈណា លោកឲ្យឈ្មោះថា បញ្ចទ្វារាវជ្ជនៈ ។ ពាក្យថា* **បញ្ចទ្វារាវជ្ជនៈ** *បែកជា ៣ បទ គឺ* **បញ្ច** + **ទ្វារ** + **អាវជ្ជនៈ** *ជា* **បញ្ចទ្វារាវជ្ជនៈ** **បញ្ចៈ** *ប្រែថា ៥ (ចំនួន៥)* **ទ្វារ** *ប្រែថា ប្រឡោះប្រហោង* **អាវជ្ជនៈ** *ប្រែថា រាវរក សរុបសេចក្តីមក ប្រែថារាវរកអារម្មណ៍ក្នុងទ្វារទាំង ៥ ។ បន្ទាប់មក ទើបកើត* **ចក្ខុវិញ្ញាណ** ៗ *គឺការដឹងតាមចក្ខុទ្វារ ពុំមែនដឹងតាមត្រចៀក ឬ ច្រមុះឡើយ ។ បន្ទាប់មកទៀត ទើបកើត* **សម្បដិច្ឆន្នៈ** ៗ *គឺការទទួលអារម្មណ៍ បន្ទាប់មកទៀត កើត* **សន្តីរណចិត្ត** ៗ *គឺ ពិចារណានូវអារម្មណ៍ ទើបកើតជា* **វោដ្ឋព្វនៈ** *គឺការកត់សំគាល់នូវអារម្មណ៍ ។*

*គួរជ្រាបថា ការធ្វើអត្ថាធិប្បាយ ការរៀបរាប់ជាតួបរិយត្តិ ហាក់ដូចជាយឺតៗ ប៉ុន្តែខណៈចិត្តនេះ ដើរលឿនរហ័សណាស់ ។ បើកើតត្រឹមតែ* **វោដ្ឋព្វនៈ** *គឺសំគាល់ថា អារម្មណ៍នេះ ជារូប ជា*





*ក្នុងគម្ពីរសុត្តន្តបិដក លោកមិនបាននិយាយ មិនបានរៀបរាប់ ថាសត្វស្លាប់ទៅ កើតទៀត ឬ មិនកើតទៀតនោះទេ ប៉ុន្តែព្រះពុទ្ធជាម្ចាស់ទ្រង់លើកយកមូលដ្ឋានមួយសំខាន់ គឺព្រះអង្គទ្រង់បញ្ជាក់ថា កើតទៀត ឬ មិនកើតទៀតនោះ វាអាស្រ័យទៅលើហេតុ ទៅលើបច្ច័យរបស់ធម៌។ បើកាលណាមនុស្ស ឬ សត្វណានៅមានអវិជ្ជា តណ្ហា ឧបាទាន កម្ម ដែលជាហេតុជាបច្ច័យ សត្វនោះ នៅកើតទៀត បើអស់ហេតុអស់បច្ច័យ ត្រូវឈប់កើត ។ ត្រង់ចំណុចនេះ គឺព្រះពុទ្ធទ្រង់សំដែងអំពីហេតុ ហើយឲ្យមនុស្សសត្វទាំងអស់គ្នាសន្និដ្ឋានទៅរកផល ។*

*ដើម្បីឲ្យយល់រឿងនេះ សូមជ្រាបពីខណៈចិត្តបច្ចុប្បន្នជាមុនសិន ទើបយល់អំពីខណៈចិត្ត ដែលត្រូវបន្តទៅកត ទៅជាតិមួយទៀត តើបន្តរបៀបណា? ការប្រព្រឹត្តិទៅនៃចិត្ត ក្នុងបញ្ចទ្វារ មាន ១៧ ខណៈ គឺ ៖*

១- **អតីតភវង្គ** *ឬ* **ភវង្គ**,

២- **ភវង្គចលន** *កំរើកតួភវង្គ*,

៣- **ភវង្គុបច្ឆេទ** *ដាច់ចាកភវង្គ*,

៤- **បញ្ចទ្វារាវជ្ជន** *ឬ* **អាវជ្ជនៈ** *រាវរកអារម្មណ៍តាមបញ្ចទ្វារ*,

៥- **បញ្ចវិញ្ញាណ** *ដឹងនូវអារម្មណ៍តាមទ្វារទាំង ៥*,

៦- **សម្បដិច្ឆន្ន** ទទួលអារម្មណ៍,

៧- **សន្តីរណ** ពិចារណានូវអារម្មណ៍,

៨- **វោដ្ឋវន** កត់សំគាល់នូវអារម្មណ៍,

៩- **ជវន** (៧ ដង) សោយនូវអារម្មណ៍,

១០- **តទាលម្ពណ** (២ ដង) តោងទាញនូវអារម្មណ៍ដែលជវនចិត្តសោយ ។

ចិត្ត ឬ វិញ្ញាណ កើតឡើងអាស្រ័យអាយតនៈ ខាងក្នុង ៦ គឺ ភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ និង មនោ ប៉ះទង្គិចគ្នា (ផស្សៈ) នឹងអាយតនៈខាងក្រៅ ៦ គឺ រូប សម្លេង ក្លិន រសផោដ្ឋព្វៈ និង ធម្មារម្មណ៍ ។ កាលណា ប៉ះទង្គិចគ្នា ទើប ចក្ខុ-វិញ្ញាណ សោតវិញ្ញាណ ឃានវិញ្ញាណ ជីវ្ហាវិញ្ញាណ កាយ-វិញ្ញាណ និង មនោវិញ្ញាណ កើតឡើង។ គឺកាលណាបើភ្នែកមានបសាទរូបពុំខូច គឺនៅមានចលនា ជាតួភវង្គ ស្ថិតនៅ ក្នុងភ្នែកជាចក្ខុបសាទ បានសេចក្តីថា ភ្នែកនោះ មិនវិកលវិការ មិនខូចមិនងងឹត មិនខ្វាក់ គឺនៅមានសមត្ថភាពអាចនឹងទទួលរូបបានភ្នែកនោះ លោក សន្មតថា ជាតួភវង្គ ។ ពាក្យថា **ភវង្គ** នេះមកពី **ភវៈ** ប្រែថា ចេតនា និង **អង្គ** ប្រែថា ប្រដាប់ ដូច្នេះ **ភវង្គ** ប្រែថា ប្រដាប់ សំរាប់បង្កើតចេតនា ជាតួភវង្គៗ នេះ គឺ





ស្ថិតនៅជាធម្មតា ។ កាលណាបើអារម្មណ៍វាមិនទាន់ប៉ះទេ ភវង្គក៏នៅតែដើរធម្មតា ដូចជានាឡិកាដែលដើរជាតួភវង្គ ប៉ុន្តែ លោកមិនទាន់ឲ្យឈ្មោះថា **ចិត្ត** នៅឡើយ ព្រោះមិនទាន់ឡើងទៅកាន់**វិថីចិត្ត** ពីព្រោះអាយតនៈខាងក្នុង និង ខាងក្រៅ មិនទាន់ប៉ះទង្គិចគ្នា ដែលលោកហៅថា ផស្សៈ ឬ ផស្សាយតនៈហ្នឹងឯង ។ នេះជាកត្តា ទី១ គឺកាលណា បើចក្ខុបសាទ នៅមានលក្ខណៈល្អ ។ ខាងក្រៅគឺមានរូបពិតប្រាកដ ទោះបីរូបនោះជាអ្វីក៏ដោយ។ កត្តាមួយទៀត គឺមានពន្លឺ សំរាប់ឲ្យភ្នែកនោះ មើលឃើញផង ។ បើមានកត្តាទាំងនេះផ្សំគ្នា ទើបខណៈចិត្ត អាចឡើងរហូតដល់**វិញ្ញាណ** បាន **ចក្ខុវិញ្ញាណ** ក៏កើតឡើងក្នុងពេលនោះ ។

ក្នុងគម្ពីរអភិធម្មត្ថសង្គហៈ លោកសំដែងថា **បញ្ចទ្វារវជ្ជនៈ** មានវិថីចិត្ត ៧ មានខណៈចិត្ត ១៧ គឺភវង្គ តែងមានចលនាតាមប្រក្រតីរបស់វា ។ កាលណាអារម្មណ៍មកប៉ះ លោកហៅថា **ភវង្គចលនៈ**ៗ គឺកំរើកតួភវង្គ បានសេចក្តីថា មិនមែនជាភវង្គធម្មតាទេ វាកំរើកដោយសារមានអារម្មណ៍មកប៉ះ ។ បន្ទាប់មកទៀត ទៅជា**ភវង្គុបច្ឆេទៈ** គឺដាច់ចាក ភវង្គ បានសេចក្តីថា វាជិតមានសមត្ថភាព នឹងដឹងថារូបហើយ ប៉ុន្តែត្រឹមភវង្គុបច្ឆេទៈនេះ លោកមិនទាន់ឲ្យឈ្មោះថា **វិថីចិត្ត** នៅឡើយ លោកឲ្យឈ្មោះត្រឹមតែ

អស់លោកអ្នក យល់អំពីខណៈចិត្តបច្ចុប្បន្ន ជាមុនសិន ពីព្រោះ លោកបានបញ្ជាក់ថា ខណៈចិត្តទៅមុខទៀត ក៏មិនខុសគ្នាពីខណៈ ចិត្តបច្ចុប្បន្នដែរ ។ ខណៈចិត្តបច្ចុប្បន្នយ៉ាងណា ខណៈចិត្តរបស់ បុគ្គលដែលចាប់បដិសន្ធិ ក្នុងភពមួយទៀត ក៏មិនខុសគ្នាដែរ ។

ពាក្យថា ស្លាប់ មួយម៉ាត់ តាមអត្ថន័យនៃពុទ្ធសាសនា សំ ដៅយកអ្នកអស់ដង្ហើមចេញចូល អស់ភ្លើងធាតុ អស់វិញ្ញាណ គឺ ស្លាប់លែងដឹង លោកសន្មតថា អ្នកនោះស្លាប់ហើយ។ គេបានធ្វើ ការពិសោធន៍គ្រប់បែបយ៉ាង ដោយចង់ដឹងថា តើអ្នកនោះទៅកើត ទៀត តើទៅកើតក្នុងលក្ខណៈណា ចេញតាមណាទៅកើត? មាន អ្វីទៅកើត?។ បើក្នុងខន្ធ ៥ គ្មានខន្ធណាមួយចេញទៅទេ ខន្ធទាំង នោះ ត្រូវរលត់ទៅហើយ ។ បើរូបរលាយ នាមក៏ត្រូវរលត់ ក្នុង ពេលនោះដែរ តើអ្វីទៅកើតទៀត? ។ នេះជាសំណួរមួយ ដែល អ្នកកាន់សាសនាទាំងអស់ តែងតែលើកយកមកដោះស្រាយ ។

តាមន័យពុទ្ធសាសនា ខណៈចិត្តរបស់យើង ក្នុងបច្ចុប្បន្ន តែងតែកើតរលត់ៗទៅតាមអារម្មណ៍ផ្សេងៗ ។ ចំណែកអ្នកដែល ស្លាប់ទៅនោះ ក៏បន្តខណៈចិត្តនេះតភពជាតិទៅទៀតមិនមែនរលត់ ត្រឹមនេះទេ ។ ពេលបុគ្គលមានជម្ងឺឈឺធ្ងន់ ជិតដល់មរណភាព ខណៈចិត្ត ទី១៧ ខាងចុង (តទាលម្ពណៈ) តោងយកបដិសន្ធិចិត្ត





សំឡេង ជាក្លិន ជារស ជាសម្ផស្ស ជាធម្មារម្មណ៍នៅឡើយ លោកមិនចាត់ថា បុណ្យ ថា បាប នៅឡើយទេ ព្រោះមិនទាន់ មានហេតុជាសោមនស្ស ទោមនស្ស គ្រាន់តែកត់សំគាល់នូវ អារម្មណ៍ ជូនកាលធ្លាក់មកកាន់ភវង្គវិញ នៅជាតួចលនា ជាតួ មនោធម្មតា ។ ចិត្តដែលកើតត្រឹមវោដ្ឋព្វនៈ ហៅថា **អហេតុកចិត្ត** គឺចិត្តមិនប្រកបដោយហេតុទាំង ៦ គឺ លោភៈ ទោសៈ មោហៈ អលោភៈ អទោសៈ អមោហៈ ។ បន្ទាប់មកទៀត បើចិត្តនោះ មានកម្លាំងខ្លាំង រមែងកើតដល់ **ជវន** ដែលប្រែថា ចិត្តសោយ នូវអារម្មណ៍ ។ បើខាងបាប ក៏កើតអកុសលចិត្តឡើង បើខាង បុណ្យក៏កើតកុសលចិត្តឡើង ។ **ជវនចិត្ត** នេះ ទើបលោកចាត់ ទុក ថា បុណ្យ ថា បាប ហៅថា **សហេតុកចិត្ត** គឺ ចិត្តប្រកប ដោយហេតុទាំង ៦ ។ ជវន កើត ៧ ដង ចិត្តធ្លាក់កាន់ភវង្គវិញ ។

បន្ទាប់មកទៀត **តទាលម្ពណចិត្ត** កើតឡើង គឺបន្ទាប់ពីជវន ចិត្ត បានសោយនូវអារម្មណ៍នោះហើយ ក្លាយទៅជាតួវិបាក ស្ថិត នៅក្នុងចិត្តហៅថា **តទាលម្ពណៈ**ៗ នេះជាផលរបស់ **ជវនចិត្ត** ។ តទាលម្ពណៈ កើតយ៉ាងច្រើន ត្រឹមពីរដង ក៏ធ្លាក់កាន់ភវង្គវិញ ។ តទាលម្ពណៈ ដែលជាតួផលនោះ លុះធ្លាក់មកកាន់ភវង្គដើមវិញ ក្លាយជា **ហេតុ** នៅក្នុង **មនោ** ។ ត្រង់នេះហើយដែលលោកចាត់

ទុកថា អ្នកដែលបានបំពេញបុណ្យ និង បាប តែងប្រមូលមកនៅក្នុងចិត្តដែលជាតួ **មនោ** ។ ហ្នឹងឯងជាតួចលនាធម្មតា ដែលស្ថិតនៅក្នុងភវង្គ ។

ដូច្នេះ បាបបុណ្យ របស់បុគ្គលដែលបានសាង បានធ្វើនោះ មិនបាត់ទៅណាទេ គឺ ស្ថិតនៅ ក្នុងមនោ ជាតួហេតុ ពេលណាឱកាសដែលវាមិនទាន់ឲ្យផល បាបបុណ្យនោះ តែងស្ថិតនៅក្នុងមនោ ជាតួភវង្គជានិច្ច ។ ក្នុងភវង្គចិត្ត លោករាប់ចាប់តាំងអំពី **បញ្ចទ្វារាវជ្ជនៈ បញ្ចវិញ្ញាណ សម្បដិច្ឆន្នៈ សន្តីរណៈ វោដ្ឋព្វនៈ ជវន តទាលម្ពណៈ** ៧ នេះលោកហៅថា វិថីចិត្ត គឺដំណើរចិត្តដែលវាប្រព្រឹត្តទៅ ។ ឯខណៈចិត្ត មាន ១៧ គឺ រាប់តាំងពី **ភវង្គ ភវង្គចលនៈ ភវង្គុបច្ឆេទៈ បញ្ចទ្វារាវជ្ជនៈ បញ្ចវិញ្ញាណ សម្បដិច្ឆន្នៈ សន្តីរណៈ វោដ្ឋព្វនៈ ជវន តទាលម្ពណៈ** ។ ជវន មាន៧ តទាលម្ពណៈ មាន២ ទាំងអស់បូករួមជា ១៧ ខណៈចិត្ត។ នៅក្នុងខណៈចិត្ត ១៧ បើលោកបែងចែកឲ្យល្អិតទៅទៀត នៅក្នុងខណៈចិត្តនីមួយៗ មានខណៈចិត្តតូចៗ ៣ ទៀត គឺ **ឧប្បាទៈ ឋិតិ ភង្គៈ** ។ ឧប្បាទៈ ឋិតិ ភង្គៈ ៣ នេះគុណនឹង ១៧ ដង ត្រូវជា៥១ ។ ដូច្នេះហើយបានជាលោកបញ្ជាក់ថា រូបធម៌របស់យើងដែលជាតួអនិច្ចតាធម៌ប្រព្រឹត្តទៅបានតែម្តង





ខណៈចិត្តរបស់យើងប្រព្រឹត្តទៅបាន ៥១ ដង ។ ដូច្នេះសេចក្តីទុក្ខក្នុងរូប ឬ រូបធម៌មានតែម្តង សេចក្តីទុក្ខក្នុងផ្លូវចិត្ត ឬ នាមធម៌មានរហូត ៥១ ដង ។

ដូច្នេះ បញ្ជាក់ឲ្យឃើញថា យើងដែលអាចរស់នៅបាននេះដោយសារចលនាតួអនិច្ចតាធម៌ គឺមានចលនាជានិច្ច ទាំងរូបធម៌ទាំងនាមធម៌ ។ សូមជម្រាបអំពីន័យផ្សេងគ្នារវាង **វិញ្ញាណ ចិត្ត** និង **មនោ** ។ ពាក្យថា **វិញ្ញាណ** ប្រែថា ការស្ទុះទៅរកអារម្មណ៍ គឺមានសេចក្តីថា បើអាយតនៈខាងក្រៅ មកប៉ះអាយតនៈខាងក្នុងឈាមនេះ វាប្រាលឡើង វាបណ្តាលឡើង ដើម្បីជំរុញឲ្យមានសមត្ថភាពអាចនឹងទទួលអារម្មណ៍ណាមួយបាន ។ ពាក្យថា **ចិត្ត** ប្រែថា ការនឹកគិត ការសន្សំនូវអារម្មណ៍ផ្សេងៗ ទោះជាអារម្មណ៍បែបណាក៏ដោយ ទៅតាមលក្ខណៈរបស់បុគ្គល របស់មនុស្សសត្វនីមួយៗ ហ្នឹងឯង ។ ពាក្យថា **មនោ** ប្រែថា ការរទៅ ការអោនទៅរកអារម្មណ៍ ការបេះទោរទន់ទៅរកអារម្មណ៍ ។ នាមធម៌មានលក្ខណៈរទៅរកអារម្មណ៍ ចំណែករូបជាសភាវៈ ដែលកើតមកហើយវិនាសទៅវិញ ។ លោកបញ្ញត្តិថា រូបមិនបេះរដូចនាមឡើយ ។

ដូច្នេះដើម្បីយល់អំពីសេចក្តីស្លាប់ ទៅជាយ៉ាងណានោះ គួរ

# សចិត្តបរិយោទបនំ

## ត្រូវជុសខាត់ជម្រះចិត្តរបស់ខ្លួនឱ្យស្អាត ។

ពាក្យថា **ចិត្ត** មានវចនត្ថៈ ថា **អារម្មណំ ចិន្តេតីតិ ចិត្តំ** ប្រែថាធម្មជាតិណា រមែងគិត គឺដឹងនូវអារម្មណ៍ ព្រោះហេតុនោះ ធម្មជាតិនោះ ឈ្មោះថា ចិត្ត ។ ចិត្តនេះ ជានាមធម៌ គ្មានរូប អាស្រ័យនៅ ក្នុងរូបរាងកាយនៃមនុស្សសត្វទាំងឡាយ មានការៈ សោយ ឬ ទទួលអារម្មណ៍ ៦ គឺ រូបារម្មណ៍ (រូប) សទ្ទារម្មណ៍ (សំលេង) គន្ធារម្មណ៍ (ក្លិន) រសារម្មណ៍(រស) ផោដ្ឋព្វារម្មណ៍ (ប៉ះផ្ទប់នឹងកាយ) ធម្មារម្មណ៍ (ធម៌) តាមទ្វារទាំង ៦ គឺ ចក្ខុទ្វារ (ភ្នែក) សោតទ្វារ(ត្រចៀក) ឃានទ្វារ (ច្រមុះ) ជិវ្ហាទ្វារ(អណ្តាត) កាយទ្វារ (កាយ) និង មនោទ្វារ (មនោ)។ បើអារម្មណ៍ទាំងនោះ អាក្រក់ ក៏នាំបណ្តាលចិត្តនោះឲ្យអាក្រក់ទៅជាមួយ។ បើអារម្មណ៍ នោះល្អ ក៏អាចនាំចិត្តនោះឲ្យល្អទៅផង ។ ចិត្តនេះ បើតាមធម្មតា ជាចិត្តភ្លឺ ស្អាតផូរផង់ ពន្លឺត្រចះត្រចង់ណាស់ ប៉ុន្តែ ដែលត្រឡប់ ទៅជាចិត្តអាក្រក់ ឬ សៅហ្មង ជាចិត្តអាប់អួរ ឥតពន្លឺវិញនោះ ក៏ដោយសារតែអារម្មណ៍ចូលមកអំពីខាងក្រៅ ។ អារម្មណ៍ដែល ធ្វើចិត្តឲ្យសៅហ្មងនោះ ហៅថា **កិលេស** ឬ **ឧបក្កិលេស** ។

កិលេស ឬ ឧបក្កិលេស ដែលចូលមកធ្វើឲ្យចិត្តសៅហ្មង





គឺមាន **ឧប្បាទៈ** កើតឡើង **ឋិតិ** តាំងនៅ ទើបមាន **ភង្គ** ។ ខណៈចិត្តនោះ ត្រូវរលត់ទៅ ពេលនោះបុគ្គលនោះបានតោងយក បដិសន្ធិចិត្ត ហើយពេលនោះ រូបរាងកាយក៏រលត់ទៅ ប៉ុន្តែពេល នោះ មិនអាចឲ្យបុគ្គលនោះដឹងខ្លួនថា ទៅកើតទីណាកន្លែងណាទេ គឺស្រេចតែអំណាចកម្មដែលឲ្យកម្លាំងពីជាតិនេះទៅ ។

ចិត្តជាន់ក្រោយបំផុតនៃជីវិត ឈ្មោះថា **ចុតិចិត្ត** ក្នុងពេល នោះ ក្រសែជីវិតនៅពុំទាន់សាបសូន្យទេ អំណាចកម្មនឹងរុញច្រាន ឲ្យរអិលឃ្លាតចាកចិត្តនៃភពចាស់ឲ្យទៅចាប់ភពថ្មី ដោយអំណាច បដិសន្ធិចិត្ត ដែលជាចិត្តភ្ជាប់ពីអតីតទៅបច្ចុប្បន្នជាប្រកពនៃជីវិត ថ្មី ។ ចុតិចិត្ត ឬ ចុតិវិញ្ញាណដែលជាចិត្តចុងក្រោយនៃមនុស្សជិត ដាច់ខ្យល់ស្លាប់ តែងតែឃើញនូវអារម្មណ៍ទាំង ៣ គឺ **កម្មារម្មណ៍ កម្មនិមិត្តារម្មណ៍ គតិនិមិត្តារម្មណ៍** ឬ ហៅខ្លីថា **កម្ម កម្មនិមិត្ត គតិនិមិត្ត** ឯណានីមួយ លុះឃើញហើយ ក៏ចាប់អារម្មណ៍នោះ ជាប់ ។ មុននឹងចុតិវិញ្ញាណរលត់ទៅ វាបានប្រគល់អារម្មណ៍នោះ ព្រមទាំងសំណុំរឿង នៃកម្មចាស់ទាំងអស់ ឲ្យទៅបដិសន្ធិចិត្ត ឬ បដិសន្ធិវិញ្ញាណ បដិសន្ធិវិញ្ញាណនេះហើយ ដែលមានតួនាទីទៅ ចាប់ភពថ្មីទៀត ។ អារម្មណ៍ ៣ យ៉ាង គឺ ៖

១- **កម្មារម្មណ៍** អារម្មណ៍គឺការងារដែលខ្លួនធ្លាប់ធ្វើ ។ បើ

ខាងកុសល គឺឃើញខ្លួនឯង កំពុងធ្វើទាន រក្សាសីល ។ល។ បើខាងអកុសល គឺឃើញខ្លួនដែលកំពុងសម្លាប់សត្វ លួចទ្រព្យគេជាដើម មិនមែនឃើញដោយភ្នែកទេ គឺឃើញដោយមនោទ្វារ (ចិត្ត) ។

២- **កម្មនិមិត្តារម្មណ៍** អារម្មណ៍ គឺគ្រឿងប្រដាប់សម្រាប់ធ្វើការងារ បើខាងកុសល គឺ ឃើញត្រៃចីវរ កុដិ សាលា ព្រះវិហារ ។ល។ បើខាងអកុសល គឺឃើញដាវលំពែង សំណាញ់មង ជាដើម ។ កម្មនិមិត្ត មាន ២ គឺ អតីតកម្មនិមិត្ត ឃើញតាមមនោទ្វារ (ចិត្ត) បច្ចុប្បន្នកម្មនិមិត្ត ឃើញតាមបញ្ចទ្វារ ភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ ។

៣- **គតិនិមិត្តារម្មណ៍** អារម្មណ៍ គឺកន្លែងដែលគេត្រូវធ្វើដំណើរទៅ ។ បើខាងកុសល គឺឃើញប្រាសាទ រាជវាំង ស្ថានសួគ៌ ។ល។ បើខាងអកុសល គឺឃើញទីកន្លែងគួរឲ្យភ័យខ្លាច ឃើញស្ថាននរកជាដើម គឺឃើញតាមមនោទ្វារ (ចិត្ត) ។

កម្ម ដែលមកប្រាកដជាអារម្មណ៍នោះ មិនបានកំណត់ដាច់ខាតថា កម្មថ្មី ឬ កម្មចាស់នោះទេ ។ បើមានគរុកម្មៗ នោះ ត្រូវតែមកប្រាកដជាអារម្មណ៍ឲ្យឃើញ បើមិនមានគរុកម្មទេ អាសន្នកម្ម ឬ អាចិណ្ណកម្ម ត្រូវមកប្រាកដជាអារម្មណ៍ ។ ក៏ប៉ុន្តែ បើ





អាសន្នកម្ម ឬ អាចិណ្ណកម្ម មានកម្លាំងខ្សោយ កម្មចាស់ដែលរង់ចាំពេលវេលាមក អស់កាលដ៏យូរហើយនោះ មានកម្លាំងជាងវាត្រូវតែចេញមក ប្រាកដជាអារម្មណ៍ជំនួសវិញ ។ ចុតិវិញ្ញាណចាប់យកអារម្មណ៍នោះហើយ ប្រគល់ឲ្យទៅបដិសន្ធិវិញ្ញាណ យកទៅចាប់កពថ្មីទៀត ។ បើគេឃើញអារម្មណ៍ជាកុសល គេនឹងទៅកើតក្នុងសុគតិ បើគេឃើញអារម្មណ៍ជាអកុសល គេនឹងទៅកើតក្នុងអបាយភូមិ ។ ហេតុនេះ យើងគួរតែព្យាយាមលះអកុសលកម្ម ហើយកសាងសន្សំកុសលកម្មឲ្យបានច្រើនឡើងៗ ដើម្បីជួយឲ្យមានអារម្មណ៍ល្អៗកើតឡើង ក្នុងពេលជិតស្លាប់ ទើបជាការប្រសើរ ។ ព្រះពុទ្ធទ្រង់សំដែងថា **នត្ថិ កម្មសមំ ពលំ** គ្មានកម្លាំងអ្វីខ្លាំងស្មើនឹងកម្លាំងកម្មទេ ។

ព្រះពុទ្ធគ្រប់ព្រះអង្គ ទ្រង់ត្រាស់ដឹងច្បាស់ណាស់ថា អ្នកដែលធ្វើបាប និង បុណ្យ មិនមែនធ្វើដោយហេតុដទៃក្រៅពីចិត្តទេ គឺអកុសលចិត្ត នាំឲ្យធ្វើបាប កុសលចិត្ត នាំឲ្យធ្វើបុណ្យ ទើបព្រះអង្គប្រទានឱវាទ ទី៣ ថា **សចិត្តបរិយោទបនំ** ត្រូវជុសខាត់ជម្រះចិត្តរបស់ខ្លួនឲ្យស្អាត ។

១៣- **មានៈ** សេចក្តីប្រកាន់ខ្លួន មានអស្មិមានះ,

១៤- **អតិមានៈ** សេចក្តីប្រកាន់ខ្លួនហួសពេកគឺមើលងាយគេ,

១៥- **មទៈ** ស្រវឹងស៊ប់ងប់ចិត្តក្នុងសេចក្តីស្រវឹងទាំងបី,

១៦- **បមាទៈ** ការធ្វេសប្រហែស ឬការបណ្តែតបណ្តោយ ។

## សំយោជនកិលេស

សំយោជនកិលេស គឺកិលេសដែលចងភ្ជាប់សត្វលោក ឲ្យជាប់នឹងសេចក្តីទុក្ខ ដូចជាជាតិទុក្ខ ជរាទុក្ខ ព្យាធិទុក្ខ មរណទុក្ខជាដើម ។ សំយោជនកិលេស មាន ១០ យ៉ាង គឺ ៖

១- **សក្កាយទិដ្ឋិ** សេចក្តីឃើញថា មានខ្លួន តួអញ យល់ឃើញថា បញ្ចក្ខន្ធ ជារបស់ខ្លួន,

២- **វិចិកិច្ឆា** សេចក្តីមន្ទិលសង្ស័យជាប់ជានិច្ច,

៣- **សីលព្វតបរាមាសៈ** ការប្រកាន់ជាប់នូវសីលព្វតបដិបត្តិដោយធ្វើតាមគ្នា យ៉ាងងងឹតងងល់ ហើយជឿថា អាចជួយឲ្យរួច ចាកទុក្ខបាន,

៤- **កាមច្ឆន្ទៈ** សេចក្តីត្រេកត្រអាលក្នុងកាមារម្មណ៍,

៥- **បដិឃៈ** ការថ្នាំងថ្នាក់ចិត្ត ការរង្គោសចង្អៀតចង្អល់ចិត្ត,

៦- **រូបរាគៈ** សេចក្តីជំពាក់ក្នុងរូបស្អាតរូបល្អ,

៧- **អរូបរាគៈ** ការជំពាក់លើអបិយវត្ថុ,





នោះ មាន ៣ ប្រភេទ គឺ **វិតក្កកិលេស** កិលេសគ្រោតគ្រាត **បរិយុដ្ឋានកិលេស** កិលេសថ្នាក់កណ្តាល និង **អនុសយកិលេស** កិលេសល្អិតសុខុមដេកត្រាំក្នុងសន្តានចិត្តសត្វលោក ។ បើពោលដោយសង្ខេប មាន កិលេស ៣ យ៉ាង កិលេស ៦ យ៉ាង កិលេស ១០ យ៉ាង កិលេសធម៌ ១០ យ៉ាង ឧបក្កិលេស ១៦ យ៉ាង សំយោជនកិលេស ១០ យ៉ាង មន្ទិល ៩ ប្រការ អនុសយកិលេស ៧ យ៉ាង អាសវៈ ៤ បើពោលដោយពិស្តារ មានច្រើនជាអនេក ។

## កិលេស ៣ យ៉ាង គឺ ៖

១- **រាគៈ** សេចក្តីរីករាយ ត្រេកត្រអាលក្នុងកាមារម្មណ៍,

២- **ទោសៈ** កំហឹង សេចក្តីក្រេវក្រោធពិរោធគុំកួនព្យាបាទ,

៣- **មោហៈ** ការវង្វេងភ័ន្តច្រឡំ មិនដឹងខុសត្រូវ,

## កិលេស ៦ យ៉ាង គឺ ៖

១- **រាគៈ** សេចក្តីរីករាយ ត្រេកត្រអាលក្នុងកាមារម្មណ៍,

២- **លោភៈ** លោភ សេចក្តីជំពាក់ចិត្តក្នុងអារម្មណ៍,

៣- **ឥច្ឆា** សេចក្តីប្រាថ្នាចង់បាន ចង់មានមិនចេះស្កប់,

៤- **ឥស្សា** សេចក្តីប្រណែនឈ្នានីស,

៥- **អរតិ** សេចក្តីមិនត្រេកអរក្នុងកុសល,

៦- **អសន្តុដ្ឋី** សេចក្តីមិនសន្តោស ។

## កិលេស ១០ យ៉ាង គឺ

១- **លោភៈ** ល្មោភ សេចក្តីជំពាក់ក្នុងអារម្មណ៍,

២- **ទោសៈ** កំហឹង សេចក្តីក្រេវក្រោធពិរោធគុំគួនព្យាបាទ,

៣- **មោហៈ** ការវង្វេងភ័ន្តច្រឡំ មិនដឹងខុសត្រូវ,

៤- **មានៈ** សេចក្តីប្រកាន់ខ្លួន,

៥- **ទិដ្ឋិ** ការយល់ខុស ការឃើញខុស,

៦- **វិចិកិច្ឆា** សេចក្តីមន្ទិលសង្ស័យជាប់ជានិច្ច,

៧- **ថីនៈ** សេចក្តីខ្ជិលច្រអូសងោកងុយជាប់ជានិច្ច,

៨- **ឧទ្ធច្ចៈ** សេចក្តីរាយមាយអន្ទះអន្ទែងក្នុងកាយចិត្ត,

៩- **អហិរិកៈ** ការមិនខ្មាសអៀននឹងទង្វើបាប,

១០- **អនោត្តប្បៈ** ការមិនខ្លាចនឹងទង្វើបាប ។

## កិលេសធម៌ ១០ យ៉ាង គឺ

១- **លោភៈ** ល្មោភ សេចក្តីជំពាក់ក្នុងអារម្មណ៍,

២- **ទោសៈ** កំហឹង សេចក្តីក្រេវក្រោធពិរោធគុំគួនព្យាបាទ,

៣- **មោហៈ** ការវង្វេងភ័ន្តច្រឡំ មិនដឹងខុសត្រូវ,

៤- **កោធៈ** សេចក្តីក្រេវក្រោធប្រឡោតតោតតូង,

៥- **ឧបនាហៈ** ការចងកំហឹងទុក,





៦- **មក្ខៈ** ការលុបគុណអ្នកមានឧបការគុណ,

៧- **បឡាសៈ** ការវាយឫកប្រៀបផ្ទឹម ឬ ប្រណាំងវាសនា,

៨- **ឥស្សា** សេចក្តីប្រណែនឈ្នានីស,

៩- **មច្ឆរិយៈ** សេចក្តីកំណាញ់,

១០- **មានៈ** សេចក្តីប្រកាន់ខ្លួន មានអស្មិមានះ ។

## ឧបក្កិលេស ១៦ យ៉ាង គឺ

១- **អភិជ្ឈាវិសមលោភៈ** ល្មោភ គឺចង់បានឥតព្រំដែន,

២- **ព្យាបាទៈ** គំនុំ គឺចងចិត្តបម្រុងនឹងធ្វើឲ្យគេវិនាស,

៣- **កោធៈ** សេចក្តីក្រេវក្រោធប្រឡោតតោតតូង,

៤- **ឧបនាហៈ** ការចងកំហឹងទុក,

៥- **មក្ខៈ** ការលុបគុណអ្នកមានឧបការគុណ,

៦- **បឡាសៈ** ការវាយឫកប្រៀបផ្ទឹម ឬ ប្រណាំងវាសនា,

៧- **ឥស្សា** សេចក្តីប្រណែនឈ្នានីស,

៨- **មច្ឆរិយៈ** សេចក្តីកំណាញ់,

៩- **មាយា** ការប្រព្រឹត្តិលាក់ពុតបិទបាំងទោស,

១០- **សាឋេយ្យៈ** ការអួតអាង ឬ អែបអប,

១១- **ថម្ភៈ** សេចក្តីរឹងត្អឹង,

១២- **សារម្ភៈ** ប្រណាំងប្រជែង,

មួយចូល មិនមានឱកាសទំនេរសោះ ។ ចិត្តនោះ ចេះតែប្រឡាក់ ចេះតែសៅហ្មងជានិច្ចរហូតទៅ អស់កាលដរាបណា ដរាបនោះ ចិត្តដែលសៅហ្មងនោះ ក៏ចេះតែដឹកនាំឲ្យប្រព្រឹត្តធ្វើបាបកម្ម អំពើព្រៃផ្សៃ ខុសឆ្គាំឆ្គង ជាដរាបទៅ ។

ព្រះពុទ្ធគ្រប់ព្រះអង្គ ទ្រង់ជ្រាបច្បាស់ដូច្នេះហើយ ទើបព្រះអង្គប្រទានឱវាទ ទីបី ថា **សចិត្តបរិយោទបនំ** ត្រូវជុសខាត់ជម្រះចិត្តរបស់ខ្លួនឲ្យស្អាត ។

ធម្មជាតិរបស់ចិត្ត តែងតែប្រព្រឹត្តទៅតាមអំណាចកិលេសនានា ដែលចូលមករួបរឹតធ្វើឲ្យកករល្អក់ ។ ចិត្តនេះ កាលដំបូងមិនទាន់មានការអប់រំនៅឡើយ ជាចិត្តផ្ទេងផ្ទុង អណ្ដែតអណ្ដូង (**ផន្ទនំ**) ជាចិត្តកំរើកញាប់ញ័រ (**ចបលំ**) ពិបាករក្សា (**ទុរក្ខំ**) ផ្ចាញ់ផ្ចាលបានដោយកម្រ (**ទុន្និគ្គហំ**) ។ ព្រះភគវា ទ្រង់ត្រាស់បន្ថែមទៀតថា :

**ទុន្និគ្គហស្ស លហុនោ យត្ថ កាមនិបាតិនោ**
**ចិត្តស្ស ទមថោ សាធុ ចិត្តំ ទន្តំ សុខាវហំ ។**

ការទូន្មានចិត្ត ដែលគេផ្ចាញ់ផ្ចាលបានដោយលំបាក ជាចិត្តស្រាល ច្រើនធ្លាក់ទៅក្នុងអារម្មណ៍ដែលគេតែងប្រាថ្នា (យ៉ាងនេះ) ជាការល្អ (ព្រោះថា) ចិត្តដែលគេទូន្មានហើយ នាំឲ្យបានសុខ ។





៨- **មានៈ** សេចក្ដីប្រកាន់ខ្លួន មានអស្មិមានះ,

៩- **ឧទ្ធច្ចៈ** សេចក្ដីរាយមាយអន្ទះអន្ទែងក្នុងកាយចិត្ត,

១០- **អវិជ្ជា** ការមិនដឹង មិនស្គាល់នូវវត្ថុ ៨ យ៉ាង គឺ អរិយសច្ច ៤ អតីតក្ខន្ធ ១ អនាគតក្ខន្ធ ១ អតីតអនាគតក្ខន្ធ និង បដិសន្ធិក្ខន្ធ ១ ។

## មន្ទិល

កិលេស ដែលធ្វើឲ្យចិត្តសៅហ្មង ដូចវត្ថុពណ៌ខ្មៅមានធ្យូងជាដើម ដែលធ្វើរបស់ស្អាតឲ្យប្រឡាក់ខូចទៅ លោកហៅថា **មន្ទិល** ។ មន្ទិល នោះមាន ៩ ប្រការ គឺ :

១- **កោធៈ** សេចក្ដីក្រេវក្រោធប្រឡោតតោតតូង,

២- **មក្ខៈ** ការលុបគុណអ្នកមានឧបការគុណ,

៣- **ឥស្សា** សេចក្ដីប្រណែនឈ្នានីស,

៤- **មច្ឆរិយៈ** សេចក្ដីកំណាញ់,

៥- **មាយា** ការប្រព្រឹត្តិពុតបិទបាំងទោស,

៦- **សាថេយ្យៈ** ការអួតអាង ឬ អែបអប,

៧- **មុសា** ការកុហកបោកប្រាស់ ។

៨- **បាបិច្ឆៈ** សេចក្ដីប្រាថ្នាលាមក,

៩- **មិច្ឆាទិដ្ឋិ** ការយល់ខ្វេងពីការពិតថា គ្មានបាបបុណ្យ ។

បណ្ដាអកុសលទាំង ៩ នេះ កាលបើអកុសលឯណាមួយ កើតឡើងហើយ ក៏ធ្វើចិត្តឲ្យកករល្អក់ មិនជ្រះថ្លា ។ ព្រោះហេតុដូច្នេះ បានជាលោកហៅថា មន្ទិល គ្រឿងសៅហ្មងចិត្ត ។

## អនុសយកិលេស

អនុសយកិលេស គឺសេចក្ដីសៅហ្មងចិត្ត ដែលដេកត្រាំក្នុងសន្ដានមនុស្សសត្វគ្រប់រូប។ អនុសយកិលេស មាន ៧ យ៉ាង គឺ

១- **កាមរាគានុសយ** អនុស័យគឺសេចក្ដីរីករាយត្រេកត្រអាលក្នុងកាមារម្មណ៍,

២- **បដិឃានុសយ** អនុស័យ គឺសេចក្ដីថ្នាក់ថ្នាំងចិត្ត,

៣- **ទិដ្ឋានុសយ** អនុស័យ គឺទិដ្ឋិការយល់ឃើញខុស,

៤- **វិចិកិច្ឆានុសយ** អនុស័យ គឺសេចក្ដីសង្ស័យ,

៥- **មានានុសយ** អនុស័យ គឺមានះប្រកាន់ខ្លួន,

៦- **ភវរាគានុសយ** អនុស័យ គឺការត្រេកត្រអាលក្នុងភព,

៧- **អវិជ្ជានុសយ** អនុស័យ គឺអវិជ្ជា ។

## អាសវៈ

អាសវៈ ឬ អាសវក្កិលេស គឺកិលេសដែលជាគ្រឿងដេកត្រាំ កិលេសធម៌ ដែលត្រាំក្នុងសន្ដានចិត្ត ឬ សភាវៈដែលហូរជ្រាបចូលទៅ ឬ ត្រាំនៅក្នុងសន្ដានចិត្ត ។ មាន ៤ យ៉ាង គឺ :





១- **កាមាសវៈ** អាសវៈ គឺកាម,

២- **ភវាសវៈ** អាសវៈ គឺភព,

៣- **ទិដ្ឋាសវៈ** អាសវៈ គឺទិដ្ឋិ,

៤- **អវិជ្ជាសវៈ** អាសវៈ គឺអវិជ្ជា ។

កិលេស ឧបក្កិលេស អនុសយកិលេស ដែលបានរៀបរាប់ចំនួនដោយសង្ខេបខាងលើនេះ សុទ្ធតែចូលមកធ្វើចិត្ត ឲ្យប្រឡាក់សៅហ្មង ។ កាលបើចិត្តសៅហ្មងហើយ ចិត្តនោះ ល្អក់ខ្វល់ ឥតមានរស្មីភ្លឺថ្លាទេ ជាចិត្តអាប់អួរមួហ្មង ឆេងឆោងក័ន្តប្រឡំ លែងយល់ការខុសត្រូវ ។ ចិត្តដែលសៅហ្មងហើយនោះ តែងដឹកនាំមនុស្សសត្វ ឲ្យហ៊ានធ្វើបំពានទៅលើអំពើខុស អំពើអាក្រក់គ្រប់យ៉ាង តាមទ្វារទាំង ៣ គឺ កាយទ្វារ (ផ្លូវកាយ) វចីទ្វារ (ផ្លូវវាចា) មនោទ្វារ (ផ្លូវចិត្ត) ។

សូមជ្រាបថា កិលេសដែលមានចំនួនច្រើនយ៉ាងនេះ កាលដែលចូលមកធ្វើចិត្តឲ្យសៅហ្មងនោះ មិនមែនចូលមកព្រមគ្នាទេ បើកិលេសណាមួយចូលមកហើយ កិលេសឯទៀតទាំងអស់មិនអាចចូលមកបានទេ ព្រោះចិត្តមានកន្លែងសម្រាប់ទទួលអារម្មណ៍តែមួយៗ ។ ប៉ុន្តែ កិលេសដែលមានចំនួនច្រើនទាំងនោះ ចេញចូលមិនចេះឈប់ មានអាការៈដូចជាផ្លាស់វេនគ្នា គឺ មួយចេញ

-**សីល សមាធិ បញ្ញា**,

-**ការពិចារណានូវត្រៃលក្ខណធម៌** ៣ អនិច្ចំ ទុក្ខំ អនត្តា,

-**សតិប្បដ្ឋាន** ៤,

-**ពោជ្ឈង្គ** ៧,

-**សមថភាវនា** ឬ **សមាធិភាវនា**,

-**វិបស្សនាភាវនា** ឬ **បញ្ញាភាវនា** ។

ធម៌ ដែលបានរៀបរាប់មកនេះ សុទ្ធតែមានអានុភាព អាចកំចាត់បង់កិលេសធម៌ក្នុងចិត្តបានដោយលំដាប់ ។ កាលបើបុគ្គលណាបានដុសខាត់ជម្រះចិត្តឲ្យបានស្អាតបរិសុទ្ធហើយ បុគ្គលនោះនឹងអាចសម្រេចប្រយោជន៍ គឺសេចក្តីសុខចំរើន ទាំងក្នុងបច្ចុប្បន្នជាតិ ទាំងក្នុងអនាគតជាតិ រហូតដល់បានបរមសុខគឺព្រះនិព្វាន ។ ក្នុងវត្ថូបមសូត្រ មជ្ឈិមនិកាយ មូលបណ្ណាសកៈ មានពុទ្ធភាសិតថា :

**ចិត្តេ បរិសុទ្ធេ សុគតិ បាដិកង្ខា** ។

កាលបើចិត្តបរិសុទ្ធហើយ សុគតិ គួរគប្បីប្រាថ្នាចុះ ។

អ្នកឯណាមួយ ទោះជាបព្វជិតក្តី គ្រហស្ថក្តី កាលបើបានធ្វើចិត្តរបស់ខ្លួន ឲ្យស្អាតបរិសុទ្ធហើយ អ្នកនោះ នឹងត្រូវបាននូវសុគតិ ។ ពាក្យថា សុគតិ មានពីរបទ គឺ **សុ** = ល្អ **គតិ** =





**យថា អគារំ ទុច្ឆន្នំ វុដ្ឋិ សមតិវិជ្ឈតិ**

**ឯវំ អភាវិតំ ចិត្តំ រាគោ សមតិវិជ្ឈតិ** ។

ភ្លៀង រមែងលេចស្រោចផ្ទះ ដែលប្រក់មិនជិត យ៉ាងណា រាគៈរមែងលេចស្រោចចិត្តដែលគេមិនបានអប់រំក៏យ៉ាងនោះដែរ។

**ចិត្តេ សង្កិលិដ្ឋេ ទុគ្គតិ បាដិកង្ខា** ។

កាលបើចិត្តសៅហ្មងហើយ ទុគ្គតិ ក៏កើតប្រាកដ (បើទុកជាមិនចង់បាន ក៏គង់តែនឹងបានពុំខាន) ។

**ចិត្តេ អសង្កិលិដ្ឋេ សុគតិ បាដិកង្ខា** ។

កាលបើចិត្តមិនសៅហ្មងហើយ សុគតិ ក៏កើតប្រាកដ (បើទុកជាមិនចង់បាន ក៏គង់តែនឹងបានពុំខាន) ។

រូបរាងកាយមនុស្សជារូបធម៌ អាចមើលឃើញ ប៉ះ និងចាប់កាន់បាន ។ កាលបើប្រឡាក់ដោយគ្រឿងមិនស្អាតផ្សេងៗ ដូចជាធូលី ញើសក្អែល របស់បដិកូលជាដើម គេអាចយកទឹកសាប៊ូ ឬគ្រឿងផ្សំផ្សេងៗ មកដុសលាងជម្រះបានស្អាត គួរជាទីគាប់ចិត្ត ។ រីឯចិត្តវិញ ជានាមធម៌ជ្រកនៅក្នុងរាងកាយ គ្មានរូប មិនអាចចាប់កាន់ពាល់ ឬក៏ កាន់យកដោយអវយវៈបានទេ ។ កាលបើចិត្តប្រឡាក់ដោយគ្រឿងមន្ទិលសៅហ្មងផ្សេងៗ ដែលជានាមធម៌ ឥតរូប គេមិនអាចយកទឹក និង សាប៊ូ ដែលជារូបធម៌ទៅជម្រះបាន

ឡើយ គេត្រូវយកធម៌ដែលឥតរូប ដែលមិនមែនជាកិលេសធម៌មកកំចាត់បង់កិលេសនោះចេញពីចិត្ត ទើបចិត្តនោះ អាចត្រឡប់ទៅជាចិត្តស្អាតបរិសុទ្ធបាន ។ ឧទាហរណ៍ ដូចជា កិលេសគ្រោតគ្រាត គឺ **ទោសៈ** កំហឹងក្រេវក្រោធ កើតឡើង ធ្វើចិត្តឲ្យសៅហ្មង ។ បើត្រូវការចង់កំចាត់បង់ទោសៈ ត្រូវយក **មេត្តាធម៌** មកអប់រំចិត្ត ធ្វើចិត្តឲ្យមានមេត្តាករុណា ចំពោះអ្នកដទៃនោះ ទើបទោសៈ រលត់ទៅបាន ។ បើ **មោហៈ** សេចក្ដីវង្វេងល្ងិតល្ងង់កើតឡើង ធ្វើចិត្តឲ្យសៅហ្មង ត្រូវយកបញ្ញាមកអប់រំចិត្ត ឲ្យចេះគិតពិចារណា ទើបមោហៈនោះរលត់រលាយទៅបាន ។

ព្រះសម្មាសម្ពុទ្ធ ជាម្ចាស់ទ្រង់ជ្រាបថា កិលេសធម៌ដែលធ្វើចិត្តឲ្យសៅហ្មង មិនមែនមានតែមួយទេ គឺមានច្រើនណាស់ ទើបព្រះអង្គទ្រង់ត្រាស់សំដែងធម៌ ដែលជាវិធី ឬ ជាមធ្យោបាយដុសលាង ឬ ជម្រះចិត្តឲ្យជ្រះ ឬ ក៏សម្រាប់កំចាត់បង់កិលេសធម៌ទាំងនោះឲ្យមានច្រើនដូចគ្នា ។

វេជ្ជបណ្ឌិតក្នុងលោកនេះ ដែលជំនាញខាងពេទ្យវិទ្យា បានដឹងថា រោគដែលកើតឡើង ក្នុងសរីរាងកាយមនុស្ស សម្រាប់បំផ្លាញជីវិតមនុស្សមានច្រើនប្រភេទ ។ កាលបើបានពិនិត្យ ធ្វើរោគវិនិច្ឆ័យ ស្គាល់សមុដ្ឋានរបស់រោគទាំងនោះសព្វគ្រប់ហើយ





ទើបបានវេជ្ជបណ្ឌិតទាំងនោះ ផ្សំឱសថដ៏ច្រើនប្លែកៗ ពីគ្នា សំរាប់រម្ងាប់រោគទាំងនោះ ។ វេជ្ជបណ្ឌិតក្នុងលោកនេះ យ៉ាងណាមិញ ព្រះពុទ្ធបរមគ្រូ ក៏យ៉ាងនោះដែរ គឺព្រះអង្គជា **ញាណទស្សនវិទូ** ឬ **លោកវិទូ** ទ្រង់ជ្រាបនូវរោគដែលកើតក្នុងសន្ដានចិត្ត រោគនោះគឺកិលេសធម៌នេះឯង ជារោគមានពិសខ្លាំងជាង រោគកើតនៅលើរាងកាយ ។ រោគនេះអាចបំផ្លាញសេចក្ដីសុខ ជួយបណ្ដុះសេចក្ដីទុក្ខ ព្រមទាំងអាចបំផ្លាញជាតិត្រកូលខ្ពង់ខ្ពស់ឲ្យក្លាយទៅជាជាតិត្រកូលអន់ថយទៅវិញបាន ។ មិនតែប៉ុណ្ណោះ ព្រះអង្គជ្រាបទាំងសមុដ្ឋាន នៃកិលេសរោគទាំងនោះថែមទៀតផង ទើបទ្រង់បានប្រទានឱសថ គឺព្រះធម៌ច្រើនប្រភេទ តម្រូវតាមរោគ ឬ កិលេសទាំងនោះ ដើម្បីរម្ងាប់រោគ គឺកិលេសទាំងនោះ ឲ្យមានប្រសិទ្ធិភាពជាស្ថាពរ ។

ព្រះធម៌ ទុកដូចជាឱសថ ដែលព្រះពុទ្ធជាម្ចាស់ទ្រង់ប្រទានទុកមក សម្រាប់កំចាត់បង់កិលេសធម៌ ក្នុងចិត្តនោះ មានច្រើនជាអនេកប្បការ មានជាអាទិ៍ គឺ :

- **អប្បមាទធម៌** ការមិនធ្វេសប្រហែស, ការមិនភ្លេចស្មារតី,
- **អលោភៈ អទោសៈ អមោហៈ**
- **បុញ្ញកិរិយាវត្ថុ** ៣ យ៉ាង និង ១០ យ៉ាង,

ព្រះនិព្វាន ដូចជាព្រះអង្គដែរ ។ ព្រះពុទ្ធ ទ្រង់មានព្រះបន្ទូល ថា "នរណា បានប្រតិបត្តិត្រឹមត្រូវ ដោយប្រពៃ តាមព្រះធម្មវិន័យ តថាគត អ្នកនោះ ឈ្មោះថា បានជួបតថាគត" ។

ដូច្នេះ ដើម្បីបាននាមបញ្ញត្តិថា ពុទ្ធសាសនិកជន ដែលជាអ្នកជឿជាក់ កាន់តាមលំអានព្រះពុទ្ធសាសនានោះ សាធុជនទាំងឡាយ គួរមានស្វាមីភក្តិចំពោះព្រះពុទ្ធអង្គ ប្រតិបត្តិតាមមាគ៌ា ដែលព្រះអង្គទ្រង់បានបង្ហាញ ព្រោះមាគ៌ានោះ ជាមាគ៌ាដ៏ប្រសើរ ឧត្តុង្គឧត្តម អាចនាំសត្វលោកឲ្យដល់នូវលោកុត្តរធម៌ គឺធម៌រួចផុតកាមលោក រូបលោក និង អរូបលោកបាន ។ បូរាណាចារ្យលោកពោលថា : សីលជាស្ពាន ទានជាស្បៀង ភាវនាជាថ្នាំសំលៀង បញ្ញាជាអាវុធ ។

**នត្ថិ សន្តិ បរំ សុខំ**

សុខដទៃក្រៅពីសេចក្តីស្ងប់មិនមានឡើយ ។





ដំណើរ ប្រែថា ដំណើរល្អ មាន ២ យ៉ាង គឺ :

១- **បដិបត្តិសុគតិ** ដំណើរល្អក្នុងការប្រតិបត្តិ ។ មានន័យថា អ្នកដែលមានចិត្តស្អាតបរិសុទ្ធ តែងប្រព្រឹត្តធ្វើតែអំពើល្អ អំពើសុចរិត ។

២- **គតិសុគតិ** ដំណើរល្អក្នុងគតិ គឺកំណើត ។ បានន័យថា អ្នកដែលបានប្រតិបត្តិត្រឹមត្រូវ តាមសុចរិតធម៌ហើយ លុះធ្វើនូវមរណកាលទៅ នឹងបានទៅកើតក្នុងកំណើតមនុស្សខ្លះ កំណើតទេវតាខ្លះ ។ ចំណែកអ្នកដែលមានចិត្តសៅហ្មង នឹងត្រូវបាននូវទុគ្គតិ ផ្ទុយគ្នានឹងសុគតិ ។

គម្ពីរខុទ្ទកនិកាយ ធម្មបទ ត្រង់ចិត្តវគ្គ មានពុទ្ធភាសិត ថា:

**សុទុទ្ទសំ សុនិបុណំ យត្ថ កាមនិបាតិនំ**
**ចិត្តំ រក្ខេថ មេធាវី ចិត្តំ គុត្តំ សុខាវហំ ។**

អ្នកមានប្រាជ្ញា គួររក្សាចិត្តដែលឃើញដោយកម្រក្រៃពេក ដែលល្អិតពេកណាស់ មានប្រក្រតីធ្លាក់ចុះទៅតាមសេចក្តីប្រាថ្នា ក្នុងអារម្មណ៍ណាមួយ (ព្រោះថា) ចិត្តដែលគេរក្សាបានហើយ រមែងនាំមកនូវសេចក្តីសុខ ។

**ទូរង្គមំ ឯកចរំ អសរីរំ គុហាសយំ**
**យេ ចិត្តំ សញ្ញមេស្សន្តិ មោក្ខន្តិ មារពន្ធនា ។**

អ្នកទាំងឡាយណា នឹងសង្រួមចិត្តដែលទៅឆ្ងាយ ជាចិត្តត្រាច់ទៅតែឯង មិនមានសរីរៈ មានគូហា គឺមហាភូតរូប ៤ ជាទីអាស្រ័យនៅ អ្នកទាំងនោះ រមែងរួចចាកចំណងនៃមារ ។

**តេលបត្តំ យថា បរិហរេយ្យ ឯវំ សចិត្តមនុរក្ខេ** ។

បុគ្គល គប្បីរក្សាចិត្តរបស់ខ្លួន ដូចជាគេរក្សាភាជន៍ដែលពេញដោយប្រេង ។ បានន័យថា ចិត្តជាធម្មជាតិ ដែលគេពិបាកគ្រប់គ្រងរក្សាទូន្មានណាស់ លោកប្រៀប ចិត្តទៅនឹងមច្ឆា ។ ធម្មជាតិរបស់ត្រី ដែលធ្លាប់តែរស់នៅក្នុងទឹក កាលណាអ្នកនេសាទចាប់វាបោះទៅលើគោកវាតែងតែប្រឹងបម្រះនទៀលមករកទឹកវិញ យ៉ាងណាមិញ ចិត្តដែលធ្លាប់តែសោយកាមារម្មណ៍តាមទំនើង កាលបើគេយកវាទៅអប់រំ ឃុំខ្ចុះ ដោយសីល សមាធិ បញ្ញា យ៉ាងណា ចិត្តនេះ ក៏តែងតែកញ្ជ្រោលរើបម្រះរត់មករកកាមគុណវិញដដែល ។ អាស្រ័យហេតុនេះហើយ បានជាព្រះពុទ្ធទ្រង់ដាស់តឿនឲ្យបុគ្គលខំថែរក្សាចិត្តរបស់ខ្លួន ឲ្យដូចជាគេថែរក្សានូវចានដែលពេញដោយប្រេងអញ្ចឹង ។

ព្រះពុទ្ធសាសនា មានលំអ ៣ គឺ **សីល សមាធិ បញ្ញា** ។ សីល ចាត់ជាគុណល្អគួររាប់ ថ្នាក់ខាងដើម នៃព្រះពុទ្ធសាសនា ហៅថា **អាទិកល្យាណ** ។ សមាធិ ចាត់ជាគុណល្អគួររាប់ ថ្នាក់





កណ្តាល នៃព្រះពុទ្ធសាសនា ហៅថា **មជ្ឈេកល្យាណ** ។ បញ្ញា ចាត់ជាគុណល្អគួររាប់ ថ្នាក់ខាងចុងបំផុតនៃព្រះពុទ្ធសាសនា ហៅថា **បរិយោសានកល្យាណ** ។

សីល ញ៉ាំងបុគ្គលដែលប្រតិបត្តិតាម ឲ្យវៀរបង់នូវ **កាមសុខល្លិកានុយោគ** (ការប្រព្រឹត្តិជាប់ចិត្តចំពោះកាមសុខ) បាន ។ សមាធិ ញ៉ាំងបុគ្គលដែលប្រតិបត្តិតាម ឲ្យវៀរបង់នូវ **អត្តកិលមថានុយោគ** (ការប្រកបព្យាយាមតឹងហួសពេកឲ្យនឿយលំបាកខ្លួនឥតប្រយោជន៍)បាន ។ បញ្ញា ញ៉ាំងបុគ្គលដែលប្រតិបត្តិតាម ឲ្យសេពនូវ **មជ្ឈិមាបដិបទា** (ផ្លូវប្រដិបត្តិជាកណ្តាល) បាន ។

ព្រះពុទ្ធឃោសាចារ្យ ជាពុទ្ធសាសនបណ្ឌិត ដ៏ឆ្នើម ក៏បានបង្រួមព្រះត្រៃបិដក មកជាបីផ្នែក ហៅថា **ត្រៃសិក្ខា** (The three fold training) គឺ **សីលសិក្ខា** (Morality) **សមាធិសិក្ខា** (Concen tration) និង **បញ្ញាសិក្ខា** (Wisdom) ហើយឲ្យឈ្មោះថា **វិសុទ្ធិមគ្គ** (The Part of Purification) ។ **វិសុទ្ធិមគ្គ** ប្រែថា ផ្លូវ ឬមធ្យោបាយសម្រាប់ធ្វើចិត្តឲ្យបរិសុទ្ធ ។ ការអប់រំចិត្ត ឬ ការជម្រះចិត្តឲ្យស្អាតបរិសុទ្ធផូរផង់ គឺជាកម្មវត្ថុចម្បងដែលព្រះពុទ្ធគ្រប់ៗ ព្រះអង្គ ទ្រង់ចង់ឲ្យមនុស្សម្នាមហាជន ប្រតិបត្តិតាម ឲ្យបានសុក្រឹត ដើម្បីបានសេចក្តីសុខក្នុងបច្ចុប្បន្ន រហូតដល់បរមសុខ គឺ

ការគិត គំនិត ការចាត់ចែងរបស់បុគ្គល វៀរចាកបញ្ចវេរ ៥ ចេតនាវៀរចាកកាយទុច្ចរិត ៣ និង វចីទុច្ចរិត ៤ ចេតនានៃអ្នករក្សាឧបោសថសីល (សីល ៨) ក្តី ទសសីល (សីល១០) ក្តី ធ្វើវត្តប្រតិបត្តិឲ្យបានត្រឹមត្រូវបរិសុទ្ធ ហៅថា សីល ។

ខ- **ចេតសិកំ សីលំ** ចេតសិក ជាតួសីល ចេតសិកមានន័យថា ជាសភាវធម៌មួយប្រភេទដែលកើតរួមនឹងចិត្ត ដឹងសភាវៈជាមួយនឹងចិត្ត រលត់ព្រមជាមួយចិត្ត និង កើតត្រង់កន្លែងជាមួយចិត្ត ប៉ុន្តែក្នុងទីនេះ បានដល់ធម៌ ៣ យ៉ាង គឺ :

១- **អនភិជ្ឈា** ការមិនសំឡឹងរំពៃចង់បានទ្រព្យរបស់គេមកធ្វើជាទ្រព្យរបស់ខ្លួន ដែលជាអលោភចេតសិក,

២- **អព្យាបាទោ** ការមិនចងគំនុំឲ្យសត្វដទៃវិនាស ដែលជាអទោសចេតសិក,

៣-**សម្មាទិដ្ឋិ** ការយល់ឃើញត្រូវដែលជាអមោហចេតសិក ហៅថា សីល ដូចមានព្រះពុទ្ធដីកាជាដើម ថា “**ចេតសិកសីលំ នាម អភិជ្ឈំ បហាយ វិគតាភិជ្ឈេន ចេតសា វិហរតិ** បុគ្គលលះបង់នូវអភិជ្ឈា មានចេតនា ដែលមានអភិជ្ឈាទៅប្រាស ហើយ គង់នៅឈ្មោះថា ចេតសិកសីល” ។

គ- **សំវរោ សីលំ** សេចក្តីសង្រួមជាតួសីល សេចក្តី



# សីល

**សីល** ជាលំអថ្នាក់ដើមដំបូង នៃព្រះពុទ្ធសាសនា ហៅថា **អាទិកល្យាណ** បើមិនមានសីល ព្រះពុទ្ធសាសនាក៏មិនមានដែរ។ សីលជាធម្មចរិយា ជាគុណជាតិមួយ ជាគ្រឿងប្រក់ រក្សាទុកនូវកុសលថ្នាក់សមាធិ ឬ កុសលថ្នាក់វិបស្សនា ជាដើម ព្រោះហេតុថា កុសលទាំងអស់នោះ កាលបើគ្មានសីល ជាឫសគល់ ខាងដើមទេនោះ ក៏មិនអាចកើតឡើងបាន ។ កុសលធម៌ទាំងអស់មានសីលនេះឯង ជាគ្រឿងធ្វើឲ្យបរិសុទ្ធស្អាតផង ជារបងការពារកិលេស បីប្រភេទ គឺ **វិតិក្កមកិលេស** (កិលេសគ្រោតគ្រាត) **បរិយុដ្ឋានកិលេស** (កិលេសថ្នាក់កណ្តាល) និង **អនុសយកិលេស** (កិលេសថ្នាក់ល្អិតសម្ងំត្រាំនៅក្នុងសន្តានចិត្ត) ផង ។

ពាក្យថា **សីល** ជាភាសាបាលី ប្រែថា វិរតិចេតនា ដែលវៀរចាកអំពើអាក្រក់, ការកាន់ ឬ ប្រព្រឹត្តិល្អដោយកាយវាចាចិត្ត, ការមិនប្រព្រឹត្តិកន្លងសិក្ខាបទ ឬ វិនយប្បញ្ញត្តិ, ការកាន់ចរិយាល្អ, ការសង្រួម, អង្គនៃចរិយា, ចរិត, ចរិយា, មារយាទ, សេចក្តីល្អ, គតិ, លក្ខណៈ, និស្ស័យ, អធ្យាស្រ័យ, សភាព, ប្រក្រតី, ទម្លាប់, សណ្តាប់ធ្នាប់, ធម្មជាតិ, ធម្មតា ។ល។

**សីលមានន័យថាធម្លាប់ឬប្រក្រតីដោយសេចក្ដីពីរយ៉ាងគឺ**

១- **សមាធានៈ** កិរិយាតំកល់ដោយប្រពៃ,

២- **ឧបធារណៈ** កិរិយាចូលទៅទ្រទ្រង់ ។

**សមាធានៈ** កិរិយាតំកល់ដោយប្រពៃ បានសេចក្ដីថា ភាពមិនរាត់រាយ នៃកាយកម្ម វចីកម្ម មនោកម្ម ដោយអំណាចនៃខ្លួន ឬ ការទាញអារម្មណ៍ឲ្យតាំងនៅនឹង ជាអ្នកមានសីលល្អបរិសុទ្ធ ។

**ឧបធារណៈ** កិរិយាចូលទៅទ្រទ្រង់ បានសេចក្ដីថា ភាពទ្រទ្រង់ ដោយអំណាចនៃការតំកល់នូវធម៌ ជាកុសលទាំងឡាយ កុសលទាំងនោះ ទុកជាកាមាវចរកុសលក្ដី រូបាវចរកុសលក្ដី អរូបាវចរកុសលក្ដី លោកុត្តរកុសលក្ដី ដែលតាំងនៅស្ថិតស្ថេរបាន អាស្រ័យមានសីលជាឫសគល់ បើគ្មានសីលជាឫសគល់ទេ កុសលទាំងអស់នោះ ក៏រលត់រលាយបង់ទៅជាពុំខាន ។

សួរថា : អ្វីជាតួសីល? សីលជានាមធម៌ ជាគុណជាតិដែលមាននៅក្នុងសន្ដានចិត្ត កាលបើកុសលចិត្តមាន ទើបសីលមាន កាលបើកុសលចិត្តគ្មាន សីលក៏មិនមាន ។ សីល មានធម៌ ៤ យ៉ាង គឺ: **ចេតនា** ១ **ចេតសិក** ១ **សំវរៈ** ១ **អវិតិក្កមៈ** ១ ជាតួសីល ។ ធម៌ទាំង ៤ យ៉ាងនេះ សុទ្ធតែជានាមធម៌ទាំងអស់





ហើយកើតរលត់ជាមួយនឹងចិត្ត ។

ន័យក្នុង **បដិសម្ភិទា** (១) បានពោលថា **ចេតនា សីលំ ចេតសិកំ សីលំ សំវរោ សីលំ អវិតិក្កមោ សីលំ** ប្រែថា **ចេតនា** ជាតួសីល, **ចេតសិក** ជាតួសីល, **សេចក្ដីសង្រួម** ជាតួសីល, **ការមិនប្រព្រឹត្តិកន្លង** ជាតួសីល ។

ក- **ចេតនា សីលំ** ចេតនា ជាតួសីល ព្រះពុទ្ធដីកា ថា "**ចេតនាហំ ភិក្ខវេ សីលំ វទាមិ** ម្នាលភិក្ខុទាំងឡាយតថាគតហៅចេតនាថា ជាតួសីល" ។ ចេតនា មានន័យថា ធម្មជាតិអ្នកគិត, អ្នកចាត់ចែង អ្នកសន្សំ មានវិគ្រោះថា **អភិសន្ទហតីតិ ចេតនា** ធម្មជាតិណាចាត់ចែង ធម្មជាតិនោះ ឈ្មោះថា ចេតនា ។ បានសេចក្ដីថា ធម្មជាតិដែលញុំាងសម្បយុត្តធម៌ គឺ ចិត្ត និង ចេតសិក ដែលប្រកបជាមួយឲ្យហូរចុះទៅក្នុងសីល ។

---

(១) **បដិសម្ភិទា** : ការបែកប្រាជ្ញាយល់ច្បាស់, ប្រាជ្ញាដែលបែកអាចយល់ធ្លុះធ្លាយឥតទើសទាក់, ប្រាជ្ញាដែលភ្លឺស្វាងអាចពិចារណាយល់ជាក់ប្រាកដភ្លាមៗ នូវហេតុផលនៃកិច្ចការទាំងពួង ។ បដិសម្ភិទា មាន ៤ យ៉ាង គឺ : ១- អត្ថប្បដិសម្ភិទា ការបែកប្រាជ្ញាយល់ធ្លុះធ្លាយក្នុងអត្ថ, ២-ធម្មប្បដិសម្ភិទា ការបែកប្រាជ្ញាយល់ធ្លុះធ្លាយក្នុងធម៌, ៣-និរុត្តិប្បដិសម្ភិទា ការបែកប្រាជ្ញាយល់ធ្លុះធ្លាយក្នុងនិរុត្តិ, ៤-បដិភាណប្បដិសម្ភិទា ការបែកប្រាជ្ញាយល់ធ្លុះធ្លាយ ក្នុងបដិភាណ ។

ទ្រង់សម្តែងហើយ ដោយអំណាចនៃអដ្ឋឧបោសថជាដើម ។

ពាក្យថា **សីល** បានដល់ធម៌មាន វិរតិចេតនាជាដើមដែលប្រព្រឹត្តទៅតាមសិក្ខាបទដែលព្រះសម្មាសម្ពុទ្ធទ្រង់សម្តែងហើយ។

## និច្ចសីលមានសិក្ខាបទ ៥ គឺ

១- **បាណាតិបាតា វេរមណី** វៀរចាកការសម្លាប់សត្វមានជីវិត,

២- **អទិន្នាទានា វេរមណី** វៀរចាកការលួចទ្រព្យសម្បត្តិគេ,

៣- **កាមេសុមិច្ឆាចារា វេរមណី** វៀរចាកការប្រព្រឹត្តិខុសក្នុងផ្លូវកាមទាំងឡាយ,

៤- **មុសាវាទា វេរមណី** វៀរចាកការនិយាយកុហកភូតភរ,

៥- **សុរាមេរយមជ្ជប្បមាទដ្ឋានា វេរមណី** វៀរចាកការផឹកសុរា និង មេរ័យជាគ្រឿងស្រវឹង ។

## ឧបោសថសីល មានសិក្ខាបទ ៨ គឺ

១- **បាណាតិបាតា វេរមណី** វៀរចាកការសម្លាប់សត្វមានជីវិត,

២- **អទិន្នាទានា វេរមណី** វៀរចាកការលួចទ្រព្យសម្បត្តិគេ,





សង្រួមមាន ៥ យ៉ាង គឺ :

១- **បាតិមោក្ខសំវរោ** សេចក្តីសង្រួមនូវកាយវាចា ទៅតាមសិក្ខាបទ ដែលមាននៅក្នុងបាតិមោក្ខ និង សេចក្តីសង្រួមនូវកាយវាចា មិនប្រព្រឹត្តកន្លងនូវសិក្ខាបទ ដែលព្រះដ៏មានព្រះភាគទ្រង់បញ្ញត្តហើយ ខាងក្រៅបាតិមោក្ខ សីលនេះ ជា **បាតិមោក្ខ-សំវរសីល** ។

២- **សតិសំវរោ** សេចក្តីសង្រួមសតិ បានដល់ការសង្រួមក្នុងឥន្ទ្រីយ៍ទាំង៦ គឺចក្ខុន្ទ្រីយ៍ ១, សោតិន្ទ្រីយ៍ ១, ឃានិន្ទ្រីយ៍ ១, ជិវ្ហិន្ទ្រីយ៍ ១, កាយិន្ទ្រីយ៍ ១, មនិន្ទ្រីយ៍ ១ គឺ ជាការសង្រួមស្មារតីតាមផ្លូវភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ និង ចិត្ត ហាមឃាត់មិនឲ្យអកុសលធម៌គឺអភិជ្ឈា ទោមនស្ស និង បាបធម៌ កើតឡើងគ្របសង្កត់ចិត្តបាន ក្នុងខណៈដែលមានអារម្មណ៍ មានរូបារម្មណ៍ជាដើម មកប៉ះផ្ទប់នឹងទ្វារមានចក្ខុទ្វារជាដើម ។ សីលនេះជា **ឥន្ទ្រីយសំវរសីល** ។

៣- **ញាណសំវរោ** សេចក្តីសង្រួមញាណ (ការដឹង) បានដល់ប្រាជ្ញាដែលតម្កល់ដោយប្រពៃ ពិចារណាប្រើប្រាស់នូវបច្ច័យ ៤ គឺ ចីវរបច្ច័យ ១, បិណ្ឌបាតបច្ច័យ ១, សេនាសនបច្ច័យ ១, គិលានភេសជ្ជបច្ច័យ ១ តាមសមគួរដល់ធម៌ នៃការប្រើប្រាស់

បច្ច័យរបស់អ្នកបួស ។ សីលនេះជា **បច្ចយសន្និស្សិតសីល** ។

៤- **ខន្តិសំវរោ** សេចក្តីសង្រួម ក្នុងការអត់ទ្រាំគ្រប់យ៉ាង ចំពោះត្រជាក់ និង ក្តៅ លោកធម៌ ៨ គឺ លាភ ១, អលាភ ១, យស ១, អយស ១, និន្ទា ១, សរសើរ ១ សុខ ១, ទុក្ខ ១ ជាដើម ដែលកើតឡើងដល់ខ្លួន ។

៥- **វីរិយសំវរោ** សេចក្តីសង្រួមនូវការព្យាយាម បានដល់ការព្យាយាមអត់សង្កត់ កំចាត់បង់នូវអកុសលវិតក្កៈ ទាំង ៣ គឺ កាមវិតក្កៈ សេចក្តីត្រិះរិះពីកាម ១, ព្យាបាទវិតក្កៈ សេចក្តីត្រិះរិះពីព្យាបាទ ១, វិហិង្សាវិតក្កៈ សេចក្តីត្រិះរិះពីការបៀតបៀនសត្វ ដែលកើតឡើងគ្របសង្កត់ចិត្ត ១ ។

សេចក្តីសង្រួម ៥ យ៉ាង និង ចេតនាវៀរចាក ចំពោះវត្ថុ ដែលដល់ព្រមរបស់កុលបុត្រ ដែលជាអ្នកភ័យខ្លាច ក្នុងបាប ក៏ហៅថា **សំវរសីល** ទាំងអស់ ។

ឃ- **អវីតិក្កមោ សីលំ** ការមិនប្រព្រឹត្តិកន្លង ជាតួសីល គឺបានដល់ ការមិនប្រព្រឹត្តិកន្លង របស់បុគ្គលដែលបានសមាទានសីល មានសីល ៥, សីល ៨, សីល ១០, ហ្នឹងឯង ។ ឧបាសកឧបាសិកាដែលបានសមាទានសីលអំពីបុគ្គល ឬ គណៈ ឬ ព្រះសង្ឃហើយ ក៏ប្រឹងសង្រួមកាយ វាចា ដោយប្រពៃតាមសិក្ខាបទ





៥, ៨, ១០ ដែលខ្លួនបានសមាទានហើយ គឺមិនប្រព្រឹត្តកន្លងសិក្ខាបទណាមួយឡើយ ។ សីលរបស់ឧបាសកឧបាសិកា ដែលកើតឡើងនេះឯង ហៅថា **អវីតិក្កមសីល** ។

## សីល មាន ៤ ប្រការ គឺ

ក- **និច្ចសីល** (សីល ៥ ឬ បញ្ចសីលា) មាន ៥ សិក្ខាបទ,

ខ- **ឧបោសថសីល** (សីល ៨) មាន ៨ សិក្ខាបទ,

គ- **ទសសីល** (សីល ១០) មាន ១០ សិក្ខាបទ,

ឃ- **ចតុប្បារិសុទ្ធិសីល** (សីលរបស់ភិក្ខុ) មាន ៤ យ៉ាង ។

សីលទាំងបួនប្រការនេះ លោកចែកជាពីរប្រភេទ តាមភេទអ្នករក្សា គឺៈ

១- និច្ចសីល និង ឧបោសថសីល ជាសីលសំរាប់ឧបាសកឧបាសិការក្សា ហៅថា **អាគារិកសីល** (សីលរបស់ អ្នកមានផ្ទះ),

២- ទសសីល និង ចតុប្បារិសុទ្ធិសីល ហៅថា **អនាគារិកសីល** (សីលសម្រាប់អ្នកគ្មានផ្ទះ) ។

គួរកត់សំគាល់ពាក្យ **សិក្ខាបទ** និង **សីល** ព្រោះពាក្យទាំងពីរនេះមានន័យផ្សេងគ្នា ។ **សិក្ខាបទ** មានន័យថា វិនយបញ្ញត្តិ ដែលព្រះសម្មាសម្ពុទ្ធ លើកឡើងជាមាត្រាមួយៗ មានសិក្ខាបទ ៥ ដែលទ្រង់សម្តែងហើយ ដោយអំណាចនៃសីល ៥ សិក្ខាបទ ១០ ទ្រង់សម្តែងហើយ ដោយអំណាចនៃសីល ១០ សីល ៨

មានប្រយោជន៍ ឲ្យកើត **សមាធិ** (សេចក្តីតំកល់ចិត្តមាំទាំ ក្នុងកុសលធម៌) ។ សមាធិ មានប្រយោជន៍ឲ្យកើត **យថាភូតញ្ញាណទស្សនៈ** (សេចក្តីយល់ឃើញដឹងច្បាស់ នូវសភាវធម៌ទាំងពួងតាមសេចក្តីពិត) ។ យថាភូតញ្ញាណទស្សនៈ មានប្រយោជន៍ឲ្យកើត **និព្វិទា** (ការនឿយណាយ ក្នុងសត្វនិងសង្ខារ) ។ និព្វិទា មានប្រយោជន៍ឲ្យកើត **វិរាគៈ** (សេចក្តីប្រាសចាកតម្រេក) ។ វិរាគៈ មានប្រយោជន៍ឲ្យកើត **វិមុត្តិ** (សេចក្តីរួចស្រឡះចាកកិលេស) ។ វិមុត្តិ មានប្រយោជន៍ឲ្យមាន **វិមុត្តិញ្ញាណទស្សនៈ** (សេចក្តីយល់ឃើញ ដឹងច្បាស់ថា មានវិមុត្តិ) ។ វិមុត្តិញ្ញាណទស្សនៈ មានប្រយោជន៍ឲ្យបាន **អនុបាទានបរិនិព្វាន** (ការរលត់ទុក្ខ ដោយអស់សេចក្តីប្រកាន់មាំ) ។

សីល ដែលបុគ្គលបានរក្សា ឲ្យបរិសុទ្ធហើយ រមែងបានអានិសង្ស ៥ ប្រការដទៃទៀត គឺ :

១- **អប្បមាទាធិករណំ មហន្តំ ភោគក្ខន្ធំ អធិគច្ឆតិ** អ្នកមានសីល រមែងបានជួបប្រទះនូវគំនរភោគៈយ៉ាងច្រើន ព្រោះមានសេចក្តីមិនប្រមាទជាហេតុ,

២- **កល្យាណោ កិត្តិសទ្ទោ អព្ភុគ្គច្ឆតិ** កិត្តិស័ព្ទដ៏ល្អ រមែងលាន់ឮខ្ចរខ្ចាយ,

៣- **វិសារទោ ឧបសង្កមតិ អមង្កុភូតោ** អ្នកមានសីល





៣- **អព្រហ្មចរិយា វេរមណី** វៀរចាកការសេពមេថុនធម្ម, ផ្លូវកាមទាំងឡាយ,

៤- **មុសាវាទា វេរមណី** វៀរចាកការនិយាយកុហកភូតភរ,

៥- **សុរាមេរយមជ្ជប្បមាទដ្ឋានា វេរមណី** វៀរចាកការផឹកសុរា និង មេរ័យជាគ្រឿងស្រវឹង,

៦- **វិកាលភោជនា វេរមណី** វៀរចាកការបរិភោគ ក្នុងពេលខុស,

៧- **នច្ចគីតវាទិតវិសូកទស្សន មាលាគន្ធវិលេបនធារណមណ្ឌន វិភូសនដ្ឋានា វេរមណី** វៀរចាកការរាំ និង ច្រៀង និង ប្រគំ និង មើលនូវល្បែងដែលជាសត្រូវដល់កុសលធម៌ និង ការទ្រទ្រង់ និង ប្រដាប់ និង តាក់តែងស្អិតស្អាងរាងកាយ ដោយផ្កាកម្រង និង គ្រឿងក្រអូប និង គ្រឿងលាបផ្សេងៗ,

៨- **ឧច្ចាសយនមហាសយនា វេរមណី** វៀរចាកទីសេនាសនៈខ្ពស់ហួសប្រមាណ និង ទីសេនាសនៈដ៏ប្រសើរ ។

## ទសសីលមានសិក្ខាបទ ១០ គឺ

១- **បាណាតិបាតា វេរមណី** វៀរចាកការសម្លាប់សត្វមានជីវិត,

២- **អទិន្នាទានា វេរមណី** វៀរចាកការលួចទ្រព្យ

សម្បត្តិគេ,

៣- **អព្រហ្មចរិយា វេរមណី** វៀរចាកការសេពមេថុនធម្ម, ផ្លូវកាមទាំងឡាយ,

៤- **មុសាវាទា វេរមណី** វៀរចាកការនិយាយកុហក ភូតភរ,

៥- **សុរាមេរយមជ្ជប្បមាទដ្ឋានា វេរមណី** វៀរចាកការ ផឹកសុរា និង មេរ័យជាគ្រឿងស្រវឹង,

៦- **វិកាលភោជនា វេរមណី** វៀរចាកការបរិភោគ ក្នុងពេលខុស,

៧- **នច្ចគីតវាទិតវិសូកទស្សនា វេរមណី** វៀរចាកការ រាំ និង ច្រៀង និង ប្រគំ និង មើលនូវល្បែងដែលជាសត្រូវ ដល់កុសលធម៌,

៨-**មាលាគន្ធ វិលេបនធារណ មណ្ឌនវិភូសនដ្ឋានា វេរមណី** វៀរចាកការទ្រទ្រង់ និង ប្រដាប់ និង តាក់តែង ស្អិតស្អាងរាងកាយដោយផ្កាកម្រង និង គ្រឿងក្រអូប និង គ្រឿង លាបផ្សេងៗ,

៩- **ឧច្ចាសយនមហាសយនា វេរមណី** វៀរចាកទី សេនាសនៈ ខ្ពស់ហួសប្រមាណ និង ទីសេនាសនៈដ៏ប្រសើរ ។

១០- **ជាតរូបរជតប្បដិគ្គហណា វេរមណី** វៀរចាកការ



ព្រះពុទ្ធដីកា

ទទួលកាន់យកនូវមាស និង ប្រាក់ ដោយខ្លួនឯង ឬ ប្រើអ្នក ដទៃ ឲ្យទទួលកាន់យក ហើយត្រេកអរចំពោះមាស និង ប្រាក់ នោះ ។

## ចតុបារិសុទ្ធិសីល មាន ៤ គឺ

១- **បាតិមោក្ខសំវរសីល** សង្រួមក្នុងបាតិមោក្ខ,

២- **ឥន្ទ្រិយសំវរសីល** សង្រួមក្នុងឥន្ទ្រិយ៍,

៣- **អាជីវបារិសុទ្ធិសីល** ចិញ្ចឹមជីវិតដោយបរិសុទ្ធិ,

៤- **បច្ចយសន្និស្សិតសីល** អាស្រ័យបច្ច័យ ៤ ដោយការ ពិចារណា ។

សីលរបស់បុគ្គលដែលបានសមាទានហើយ ដុសខាត់ស្អាត ផូរផង់បរិសុទ្ធ នឹងនាំមកនូវអានិសង្សច្រើន ។ ក្នុងគម្ពីរវិសុទ្ធិមគ្គ ព្រះមានព្រះភាគ ទ្រង់ត្រាស់សរសើរអានិសង្សសីល ថា :

សីលមានប្រយោជន៍ឲ្យកើត **សំវរៈ** (ការសង្រួម) ។ ការ សង្រួម មានប្រយោជន៍មិនឲ្យមាន **វិប្បដិសារៈ** (សេចក្ដីក្ដៅ ក្រហាយចិត្ត) ។ ការមិនមានវិប្បដិសារៈ មានប្រយោជន៍ឲ្យ កើត **បាមោជ្ជៈ** (សេចក្ដីរីករាយចិត្ត) ។ បាមោជ្ជៈ មាន ប្រយោជន៍ឲ្យកើត **បីតិ** (សេចក្ដីឆ្អែតចិត្ត) ។ បីតិ មាន ប្រយោជន៍ឲ្យកើត **បស្សទ្ធិ** (សេចក្ដីស្ងប់រំងាប់ចិត្ត) ។ បស្សទ្ធិ មានប្រយោជន៍ឲ្យកើត **សុខៈ** (សេចក្ដីស្រួលចិត្ត) ។ សុខៈ

និង **កម្មដ្ឋាន**, **សមថៈ** ប្រែថា ចិត្តស្ងប់ **កម្មដ្ឋាន** ប្រែថា ហេតុជាទីតាំង នៃបរិកម្មភាវនា រួមមក បានន័យថា ហេតុជាទីតាំងតំកល់នៃបរិកម្ម សម្រាប់ធ្វើចិត្តឲ្យស្ងប់ គឺធ្វើចិត្តឲ្យឃ្លាតឆ្ងាយចាកនីវរណធម៌ដែលជាកិលេសធម៌ ។

**នីវរណធម៌** មានន័យថា ធម៌ជាគ្រឿងរារាំង មិនឲ្យកើតប្រាជ្ញាក្នុងការចំរើនវិបស្សនា ឬ ធម៌ដែលរាំងផ្លូវចិត្តមិនឲ្យកើតសមាធិចិត្ត មាន ៥ យ៉ាង គឺ :

១- **កាមច្ឆន្ទ** សេចក្តីប្រាថ្នាក្នុងកិលេសកាម និង វត្ថុកាម,

២- **ព្យាបាទ** សេចក្តីគំនុំអាឃាតចំពោះអារម្មណ៍ មិនជាទីប្រាថ្នា,

៣- **ថីនមិទ្ធ** សេចក្តីធុញទ្រាន់ និង ងងុយជ្រប់ ឬថា សេចក្តីប្រអូសកាយប្រអូសចិត្ត,

៤- **ឧទ្ធច្ចកុក្កុច្ច** សេចក្តីរាយមាយចិត្ត និង រំខានចិត្ត ឬថា សេចក្តីអណ្តែតអណ្តូងចិត្ត និង ក្តៅក្រហាយចិត្ត,

៥- **វិចិកិច្ឆា** សេចក្តីសង្ស័យមិនអស់មិនហើយក្នុងចិត្ត ។

កាលដែលបុគ្គលយកកម្មដ្ឋានណាមួយមកបរិកម្មភាវនា រហូតដល់ចិត្តស្ងប់នូវនីវរណធម៌នោះ លោកហៅថា **សមថៈ** ។ ដូច្នេះ ពាក្យថា **សមថ :** គឺជាឈ្មោះផលមួយដែលកើតចេញមកអំពីការបរិកម្ម ឬ ការភាវនា ។





ទោះបីចូលទៅកាន់ចំណោមបរិស័ទណា រមែងក្លៀវក្លា អង់អាចមិនមានមុខសំយុង,

៤- **អសម្មូឡ្ហោ កាលំ ករោតិ** អ្នកមានសីលរមែងមិនវង្វេងនៅពេលស្លាប់,

៥- **កាយស្ស ភេទា បរម្មរណា សុគតឹ សគ្គំ លោកំ គច្ឆតិ** បន្ទាប់ពីបែករាងកាយស្លាប់ទៅ រមែងទៅកាន់សុគតិសួគ៌ទេវលោក ។

សេចក្តីប្រាថ្នា ដែលតាំងនៅក្នុងចិត្តអ្នកមានសីលបរិសុទ្ធិ រមែងបានសម្រេចដូចបំណង ។ **សីលេន សុគតឹ យន្តិ** សត្វទាំងឡាយបានទៅដល់សុគតិ (ដំណើរល្អ) ក៏ព្រោះសីល ។ **សីលេន ភោគសម្បទា** សត្វទាំងឡាយ បានបរិបូណ៌ដោយភោគៈ ក៏ព្រោះសីល ។ **សីលេន និព្វុតឹ យន្តិ** សត្វទាំងឡាយ បានទៅកាន់ទីរំលត់ទុក្ខគឺព្រះនិព្វាន ក៏ព្រោះសីល ។ ពុទ្ធបរិស័ទទាំងឡាយ គប្បីរក្សាសីលជំរះចិត្ត ឲ្យបរិសុទ្ធផូរផង់ជាប់ជានិច្ច ។

**សីលសិក្ខា** មានអង្គមគ្គ ៣ នៃអដ្ឋង្គិកមគ្គ គឺ: **សម្មាវាចា** (វាចាត្រឹមត្រូវ) **សម្មាកម្មន្ត** (ការងារត្រឹមត្រូវ), **សម្មាអាជីវៈ** (ចិញ្ចឹមជីវិតត្រូវ) ។ ដរាបណា សាធុជន ប្រកបដោយអង្គមគ្គ ៣ នេះ ដោយប្រពៃ ដរាបនោះ សាធុជន រមែងបាននូវ

បរិសុទ្ធិសីល ដែលជាកត្តាចម្បង នាំឲ្យកើតសមាធិចិត្ត សមាធិ-ចិត្ត នាំឲ្យកើតបញ្ញា បញ្ញា នាំឲ្យឃើញធម៌ពិត គឺសច្ចធម៌ ។

ព្រះជិនស្រីទ្រង់ត្រាស់ថា ៖

**អាទិ សីលំ បតិដ្ឋា ច កល្យាណានញ្ច មាតុកំ**
**បមុខំ សព្វធម្មានំ សីលំ វិសោធយេ ។**

សីល ជាទីពឹងខាងដើម ជាមាតា របស់កល្យាណធម៌ទាំងឡាយ ជាប្រមុខនៃធម៌ទាំងពួង ព្រោះហេតុនោះ បុគ្គលគួរជម្រះសីលឲ្យស្អាត ។

**សីលំ ពលំ អប្បដិមំ សីលំ អាវុធមុត្តមំ**
**សីលំ អាភរណំ សេដ្ឋំ សីលំ កវចមព្ភុតំ ។**

សីល ជាកម្លាំង ឥតមានអ្វីផ្ទឹមបាន សីលជាអាវុធដ៏ខ្ពង់ខ្ពស់ សីល ជាគ្រឿងប្រដាប់ដ៏ប្រសើរ សីល ជាគ្រឿងក្រោះ យ៉ាងអស្ចារ្យ ។

**សីលំ សេតុ មហេសក្ខោ សីលំ គន្ធោ អនុត្តរោ**
**សីលំ វិលេបនំ សេដ្ឋំ យេន វាតិ ទិសោទិសំ ។**

សីល ជាស្ពានដ៏មានសក្តិធំ សីល ជាក្លិនដែលមិនមានក្លិនដទៃលើសជាង សីលជាគ្រឿងលាបលន យ៉ាងប្រសើរ ដែលខ្ចរខ្ចាយទៅគ្រប់ទិស ។



# សមាធិ

**សមាធិ** ជាលំអប្ផាក់កណ្តាលនៃព្រះពុទ្ធសាសនា ហៅថា **មជ្ឈេ កល្យាណ** ដែលមានសីលជាបទដ្ឋាន ។ សមាធិ ជាអធិចិត្តសិក្ខា ដែលក្នុងទីនេះ បានដល់ **សមាធិកម្មដ្ឋាន** ។

ពាក្យថា **កម្មដ្ឋាន** មានពីរបទគឺ **កម្ម** និង **ឋាន** ។ **កម្ម** ក្នុងទីនេះ បានន័យថា កិច្ចការងារខាងផ្លូវចិត្ត ។ ឯពាក្យថា **ឋាន** គឺកន្លែង ឬ ទីតាំង រួមមកប្រែថា កន្លែង ឬ ទីតាំងសំរាប់ធ្វើការងារខាងផ្លូវចិត្ត ឬ ការិយាល័យ របស់ចិត្ត ។ បើកន្លែង ឬ ទីតាំងសម្រាប់ធ្វើការងារខាងផ្លូវកាយ គេហៅថា **ការដ្ឋាន** ។

**កម្មដ្ឋាន** បើនិយាយឲ្យស្រួលស្តាប់ បានន័យថា ហេតុជាទីតាំងនៃភាវនាកម្ម គឺជាអារម្មណ៍សម្រាប់បរិកម្មភាវនា ឬម្យ៉ាងទៀតថា ហេតុជាទីតាំង នៃបរិកម្មភាវនា គឺបានដល់អារម្មណ៍ដែលបុគ្គលយកមកសំឡឹង យកមកគិតពិចារណា ។ ពាក្យថា **អារម្មណ៍** ប្រែថា ធម្មជាតិជាគ្រឿងតោងរបស់ចិត្ត ។ អារម្មណ៍ជាគ្រឿងតោងរបស់ចិត្ត មាន ៦ គឺ មាន ធម្មារម្មណ៍ (អារម្មណ៍គឺធម៌សម្រាប់ផ្លូវចិត្ត) ជាដើម ។

**កម្មដ្ឋាន** មាន ២ យ៉ាង គឺ **សមថកម្មដ្ឋាន** និង **វិបស្សនាកម្មដ្ឋាន** ។ **សមថកម្មដ្ឋាន** លោកឲ្យន័យស្មើគ្នា នឹងពាក្យថា **សមាធិកម្មដ្ឋាន** ដែរ ។ **សមថកម្មដ្ឋាន** បែកជាពីរបទ គឺ **សមថៈ**

៩- **គន្ថបលិពោធ** កង្វល់ដោយការរៀនព្រះបរិយត្តិ,

១០- **ឥទ្ធិបលិពោធ** កង្វល់ដោយការរក្សាទុកនូវឫទ្ធិ ជារបស់បុថុជ្ជន តែថា ឫទ្ធិនេះ ជាកង្វល់ដល់វិបស្សនា មិនមែនកង្វល់ដល់សមាធិឡើយ គឺត្រូវលោកអ្នកចំរើនវិបស្សនា ត្រូវតែផ្តាច់បង់ចេញ ។

វិធីដែលនឹងផ្តាច់បង់បលិពោធ ដោយហេតុ ២ យ៉ាង គឺៈ ដោយលះបង់ចេញម្យ៉ាង, ដោយធ្វើបង្អើយម្យ៉ាង (ណាដែលគួរលះបង់ចេញបាន ត្រូវលះបង់ចេញ ណាមិនគួរលះបង់ចេញបាន ត្រូវធ្វើបង្អើយ) ។

យោគាវចរ គប្បីសិក្សា **អាការៈ** ១០ យ៉ាង នៃកម្មដ្ឋាន ។ អាការៈ ១០ យ៉ាងនោះ គឺ ៖

១- **សង្ខាតនិទ្ទេស** ត្រូវដឹងអាការៈ ដែលលោកសំដែងចេញរាប់ចំនួន,

២- **ឧបចារប្បនាវហ** ត្រូវដឹងកម្មដ្ឋាន ដែលនាំមកនូវឧបចារជ្ឈាន និង កម្មដ្ឋានដែលនាំមកនូវអប្បនាឈាន,

៣- **ឈានប្បភេទ** ត្រូវដឹងប្រភេទរបស់ឈាន,

៤- **សមតិក្កមៈ** ត្រូវដឹងវិធីប្រព្រឹត្តិកន្លងរបស់កម្មដ្ឋាន,

៥- **វឌ្ឍនាវឌ្ឍន** ត្រូវដឹងកម្មដ្ឋានដែលគួរចំរើនថែម និង មិនគួរចំរើនថែម,



ព្រះពុទ្ធដីកា

**សមថកម្មដ្ឋាន** ប្រែថា អារម្មណ៍ ឬ ហេតុជាទីតាំង នៃភាវនាកម្ម ដើម្បីឲ្យកើត **សមថចិត្ត** នេះឯង ។

**សមាធិ** មានន័យថា ចិត្តដែលតាំងនៅ ក្នុងអារម្មណ៍តែមួយ ។ ក្នុងអដ្ឋកថា លោកបានពិគ្រោះថា **កុសលចិត្តេកគ្គតា សមាធិ** ប្រែថា ភាពរបស់ចិត្ត និង ចេតសិក ជាកុសលដែលតំកល់ស្មើល្អ ក្នុងអារម្មណ៍តែមួយ ហៅថា **សមាធិ** ។ ដូច្នេះ ចិត្តដែលអាចតំកល់នៅក្នុងអារម្មណ៍តែមួយបាន លុះត្រាតែស្ងប់នូវនីវរណធម៌ ។ កាលណាស្ងប់នីវរណធម៌ ទើបចិត្តទៅជា **ឯកគ្គតារម្មណ៍** ជាចិត្តសមាធិបាន ប្រសិនបើមិនទាន់ស្ងប់នីវរណធម៌ទាំង ៥ នេះទេ មិនអាចកើតសមាធិចិត្តបានឡើយ ។

ដូច្នេះ ពាក្យថា **សមថៈ** ស្ងប់នូវនីវរណធម៌ក្តី, ពាក្យថា **សមាធិ** ចិត្តដែលមានអារម្មណ៍តែមួយក្តី ជាពាក្យអាចប្រើផ្លាស់ប្តូរគ្នាបាន គឺ ចិត្តដែលស្ងប់ម្ងាប់ហ្នឹងឯង ជាចិត្តសមាធិ ឬក៏ចិត្តសមាធិហ្នឹងឯង ដែលហៅថា ចិត្តស្ងប់ ។

ពាក្យថា **សមាធិកម្មដ្ឋាន** ចែកជាពីរបទ គឺ **សមាធិ** និង **កម្មដ្ឋាន** រួមមកប្រែថា ហេតុជាទីតាំងនៃភាវនាកម្ម ដើម្បីឲ្យកើតជាសមាធិចិត្ត ។ ដូច្នេះ សមាធិ ជាផល កម្មដ្ឋាន ជាហេតុ ឬ កម្មដ្ឋាន ជាហេតុ សមាធិជាផល ។ កម្មដ្ឋាន ជាហេតុ សមថជាផល ។

ពាក្យថា **បរិកម្ម** បានន័យថា យកអារម្មណ៍របស់កម្មដ្ឋានមកគិត មកពិចារណា ដូចជាពិចារណានូវពុទ្ធានុស្សតិ មាននាមថា **អរហំ** ជាដើមក្តី ពិចារណានូវសីល ឲ្យឃើញភាពបរិសុទ្ធិ នៃសីលរបស់ខ្លួនក្តី ឬក៏ សំឡឹងដូចជាកសិណ មានអាបោកសិណជាដើម ដែលបុគ្គលយកចិត្តទៅដាក់សំឡឹងពិចារណាក្តី លោកហៅថា **បរិកម្ម** ។

ពាក្យថា **ភាវនា** បានន័យថា ការចំរើន, ការនឹកចំពោះត្រង់អារម្មណ៍ដ៏ល្អិតតែមួយដដែលៗ ឲ្យច្រើនៗ គឺនឹកហើយនឹកទៀតរឿយៗ ជាអនេក ។

រីឯពាក្យថា **វិបស្សនាកម្មដ្ឋាន** វិញ ប្រែថា ឧបាយអប់រំចិត្តឲ្យកើតបញ្ញា ។ **សមថកម្មដ្ឋាន** ជាកម្មដ្ឋានជាប់ដោយបរិកម្ម ។ រីឯ **វិបស្សនាកម្មដ្ឋាន** ជាកម្មដ្ឋានជាប់ដោយញាណទស្សនៈ ។ វិបស្សនាកម្មដ្ឋាន នឹងយកមកពណ៌នា នៅទំព័រខាងក្រោយ ។

សមថកម្មដ្ឋាន ដែលព្រះសម្មាសម្ពុទ្ធឲ្យបុគ្គលចំរើន ដើម្បីធ្វើចិត្តឲ្យស្ងប់ ជាចេតោវិមុត្តិ ការរួចចាកកិលេស គឺរួចចាកនីវរណធម៌បាន ដោយអាស្រ័យចិត្តស្ងប់ គឺចិត្តជាសមាធិ នឹងនៅក្នុងអារម្មណ៍ ព្រោះធម្មជាតិនៃចិត្តយើង មិននឹងនៅក្នុងអារម្មណ៍ទេ តែងតែឃ្លេងឃ្លោងកំរើក ញាប់ញ័រត្រេចចរទៅកាន់អារម្មណ៍ផ្សេងៗ ។ សមថកម្មដ្ឋាន ឬ សមាធិកម្មដ្ឋាន ត្រូវបាន





បុគ្គលចំរើនឡើង ដើម្បីស្ងប់នូវនីវរណធម៌ទាំង ៥ ហើយឲ្យចិត្តនៅនឹងនៅក្នុងអារម្មណ៍មួយដែលជាអារម្មណ៍កម្មដ្ឋានជាកុសល។ ប៉ុន្តែមិនមែនអស់កិលេសទេ គ្រាន់តែធ្វើឲ្យចិត្តស្ងប់តែប៉ុណ្ណោះ ។

មុននឹងចំរើន សមថកម្មដ្ឋាន ឬ សមាធិកម្មដ្ឋាន យោគាវចរ (អ្នកចំរើនភាវនាកម្មដ្ឋាន) ត្រូវលះបង់នូវ **បលិពោធិ** (ធម៌ជាគ្រឿងកង្វល់) ១០ យ៉ាង គឺ :

១- **អាវាសបលិពោធ** កង្វល់ដោយការគ្រប់គ្រងទីលំនៅ,

២- **កុលបលិពោធ** កង្វល់ដោយជាប់ជំពាក់ នៅក្នុងត្រកូលញាតិ ឬ ត្រកូលរបស់ឧបដ្ឋាក,

៣- **លាភបលិពោធ** កង្វល់ដោយការទទួលលាភ គឺកង្វល់ដោយការធ្វើអនុមោទនា ឬ សំដែងធម៌ ដល់ទាយកទាយិកា,

៤- **គណបលិពោធ** កង្វល់ដោយពួកអ្នករៀនព្រះសូត្រ ឬ ពួកលោករៀនអភិធម្ម គឺកង្វល់ដោយការបង្រៀន,

៥- **កម្មបលិពោធ** កង្វល់ដោយការងារ គឺកង្វល់ដោយការងារខ្លួនឯង ឬ ចាត់បង្គាប់ឲ្យគេធ្វើ,

៦- **អទ្ធានបលិពោធ** កង្វល់ដោយដើរដំណើរផ្លូវឆ្ងាយ,

៧- **ញាតិបលិពោធ** កង្វល់ថែទាំព្យាបាលជម្ងឺ របស់ញាតិ គឺ អាចារ្យ និង ឧបជ្ឈាយ៍,

៨- **អាពាធបលិពោធ** កង្វល់ដោយព្យាបាលរោគខ្លួនឯង,

១០- **អដ្ឋិក** អសុភមានតែរាងឆ្អឹងរាត់រាយខ្ចាត់ខ្ចាយ ទៅផ្សេងៗ ។

## អនុស្សតិ ១០

១- **ពុទ្ធានុស្សតិ** ការរលឹករឿយៗ មានពុទ្ធគុណ ជាអារម្មណ៍,

២- **ធម្មានុស្សតិ** ការរលឹករឿយៗ មានធម្មគុណ ជាអារម្មណ៍,

៣- **សង្ឃានុស្សតិ** ការរលឹករឿយៗ មានសង្ឃគុណ ជាអារម្មណ៍,

៤- **សីលានុស្សតិ** ការរលឹករឿយៗ មានសីលគុណ ជាអារម្មណ៍,

៥- **ចាគានុស្សតិ** ការរលឹករឿយៗ មានចាគគុណ ជាអារម្មណ៍,

៦- **ទេវតានុស្សតិ** ការរលឹករឿយៗ មានសទ្ធាទិគុណ របស់ទេវតា និង សទ្ធាទិគុណ របស់ខ្លួនជាអារម្មណ៍,

៧- **មរណានុស្សតិ** ការរលឹករឿយៗមានសេចក្ដីស្លាប់ ជាអារម្មណ៍,

៨- **កាយគតាសតិ** ការរលឹកក្នុងរាងកាយរបស់ខ្លួន និងរបស់អ្នកដទៃ ដែលប្រជុំដោយអាការៈ ៣២ មានសក់ រោម





៦- **អារម្មណ** ត្រូវដឹងអារម្មណ៍របស់កម្មដ្ឋាន,

៧- **ភូមិ** ត្រូវដឹងភូមិរបស់កម្មដ្ឋាន,

៨- **គហណ** ត្រូវដឹងកិច្ចដែលត្រូវរៀនយកនូវកម្មដ្ឋាន,

៩- **បច្ចយ** ត្រូវដឹងបច្ច័យរបស់កម្មដ្ឋាន,

១០- **ចរិយានុកូល** ត្រូវដឹងកម្មដ្ឋានដែលសមគួរដល់ចរិត ។

សមថកម្មដ្ឋាន ឬ សមាធិកម្មដ្ឋាន មានអារម្មណ៍ ៤០ ប្រភេទ បើចាត់ជាពួក មាន ៧ ពួក គឺ : អសុភ ១០, កសិណ ១០, អនុស្សតិ ១០, ព្រហ្មវិហារ ៤, អរូប ៤, អាហារេបដិកូលសញ្ញា ១, ចតុធាតុវវដ្ឋាន ១ រួមត្រូវជា ៧ ពួក និង ៤០ អារម្មណ៍ ។

អារម្មណ៍ របស់សមថកម្មដ្ឋានទាំង ៤០ ដែលបានចាត់ជាពួកៗ ដូច្នេះ ទុកដូចជាឱសថសម្រាប់រំងាប់រោគផង ទុកដូចជាអាហារសម្រាប់បរិភោគឲ្យមានកម្លាំងផង គឺចាត់តាមចរិត នៃបុគ្គល ។

ពាក្យថា **ចរិត** មានន័យថា លំនាំប្រព្រឹត្តជាប្រក្រតី ឬ សំណាមវាសនា ដែលធ្លាប់សន្សំអប់រំទុកមកពីអតីតជាតិហើយ មកផុសផុលឡើង ក្នុងសន្តានដោយច្រើនក្នុងបច្ចុប្បន្ននេះ ។ ចរិតចែកដោយសង្ខេប មាន ៦ យ៉ាង គឺ :

១- **រាគចរិត** លំនាំរាគៈ គឺច្រើនដោយសេចក្ដីតម្រេក,

២- **ទោសចរិត** លំនាំទោស គឺច្រើនដោយសេចក្តីប្រទូស,

៣- **មោហចរិត** លំនាំមោហៈ គឺច្រើនដោយសេចក្តីវង្វេង,

៤- **សទ្ធាចរិត** លំនាំសទ្ធា គឺច្រើនដោយសេចក្តីជឿ,

៥- **ពុទ្ធិចរិត** លំនាំប្រាជ្ញា គឺច្រើនដោយសេចក្តីចេះដឹង,

៦- **វិតក្កចរិត** លំនាំវិតក្កៈ គឺច្រើនដោយសេចក្តីត្រិះរិះ ។

បុគ្គលក្នុងលោក បំព្រួញមកមានតែ ៦ ពួក បានឈ្មោះតាមចរិតទាំង ៦ នេះឯង គឺតាមដោយចរិតណាមួយ ផុសផុលក្នុងសន្តានច្រើន ត្រូវសម្គាល់ដឹងបានថា បុគ្គលនេះ ជារាគចរិត ឬ ជាចរិតណាមួយនោះ ដោយពិនិត្យសង្កេតមើលឥរិយាបថ សង្កេតមើលស្នាដៃធ្វើការងារ សង្កេតមើលកិរិយាបរិភោគភោជន សង្កេតមើលកិរិយាក្រឡេកឃើញរូបជាដើម សង្កេតមើលធម៌ដែលប្រព្រឹត្តទៅក្នុងសន្តាន ។

## កសិណ ១០

១- **បថវីកសិណ** យកដីធ្វើជាវង់កសិណ,

២- **អាបោកសិណ** យកទឹកធ្វើជាវង់កសិណ,

៣- **តេជោកសិណ** យកភ្លើងធ្វើជាវង់កសិណ,

៤- **វាយោកសិណ** យកខ្យល់ធ្វើជាវង់កសិណ,

៥- **នីលកសិណ** យកវត្ថុមានពណ៌ខៀវជាកសិណ,

៦- **បីតកសិណ** យកវត្ថុមានពណ៌លឿងជាកសិណ,





៧- **លោហិតកសិណ** យកវត្ថុមានពណ៌ក្រហមជាកសិណ,

៨- **ឱទាតកសិណ** យកវត្ថុមានពណ៌-ស ជាកសិណ,

៩- **អាកាសកសិណ** យកអាកាសដែលកំណត់ទុកជាកសិណ,

១០- **អាលោកកសិណ** យកពន្លឺជាកសិណ ។

## អសុភ ១០

១- **ឧទ្ធុមាតក** អសុភហើមពោរពងឡើង,

២- **វិនីលក** អសុភហើមមានពណ៌ខៀវដោយច្រើន,

៣- **វិបុព្វក** អសុភហើមមានខ្ទុះហូរទៅក្នុងខាងលើ ខាងក្រោម,

៤- **វិច្ឆិទ្ទក** អសុភដែលគេកាត់ដាច់ពាក់កណ្តាលខ្លួន,

៥- **វិក្ខាយិតក** អសុភដែលសត្វខាំកកេរស៊ីមានសំណាមរលុះរលួយផ្សេងៗ,

៦- **វិក្ខិត្តក** អសុភដែលគេកាត់ដាច់ចេញពីគ្នាជាកំណាត់ៗរាត់រាយផ្សេងៗ,

៧- **ហតវិក្ខិត្តក** អសុភដែលគេកាប់សាប់មានស្នាមរវាម,

៨- **លោហិតក** អសុភត្រូវគេប្រហារ មានឈាមហូរស្រោចស្រព,

៩- **បុឡុវក** អសុភមានដង្កូវចោះហូរចេញតាមទ្វារទាំង៩,

# ឈាន មាន ២ យ៉ាង គឺ

១- **រូបជ្ឈាន** ឈានមានរូបធម៌ជាអារម្មណ៍ ឈានជារូបាវចរកុសល ឲ្យផលទៅកើតក្នុងរូបភព,

២- **អរូបជ្ឈាន** ឈានមានអរូបធម៌ជាអារម្មណ៍ ឈានជាអរូបាវចរកុសល ឲ្យផលទៅកើតក្នុងអរូបភព ។

# រូបជ្ឈាន មាន ៤ ថ្នាក់ គឺ

១- **បឋមជ្ឈាន** ឈានថ្នាក់ទី ១ មានអង្គ ៥ គឺ :

ក- **វិតក្កៈ** ការនឹកសំដៅទៅរកអារម្មណ៍ដែលកំពុងភាវនា,

ខ- **វិចារៈ** ការរំពឹងពិចារណាអារម្មណ៍ដែលកំពុងភាវនា,

គ- **បីតិ** សេចក្ដីឆ្អែតចិត្ត,

ឃ- **សុខៈ** សេចក្ដីសប្បាយចិត្ត,

ង- **ឯកគ្គតា** ដំណើរចូលចិត្តស្ដុងទៅក្នុងអារម្មណ៍តែមួយ ។

២- **ទុតិយជ្ឈាន** ឈានថ្នាក់ទី ២ មានអង្គ ៣ គឺ : លះ **វិតក្កៈ** និង **វិចារៈ** ចេញ នៅសល់តែ **បីតិ** និង **សុខៈ** ដែលជាប់មកអំពីសមាធិរបស់បឋមជ្ឈាន ហើយ និង **ឯកគ្គតា** ។

៣- **តតិយជ្ឈាន** ឈានថ្នាក់ទី ៣ មានអង្គ ២ គឺ : លះ **បីតិ** ចេញ នៅសល់តែ **សុខៈ** និង **ឯកគ្គតា** ។

៤- **ចតុត្ថជ្ឈាន** ឈានថ្នាក់ទី ៤ មានអង្គ ២ ដែរ គឺ : លះ **សុខៈ** ចេញ ចិត្តក្លាយទៅជា **ឧបេក្ខា** គឺព្រងើយកណ្ដើយ ជាពីរ





ក្រចកជាដើម,

៩- **អានាបានស្សតិ** ការរលឹកដល់ខ្យល់ដង្ហើមចេញចូលយកមកជាអារម្មណ៍ គឺយកសតិចងចិត្តទុកនឹងសសរបង្គោល គឺខ្យល់ដង្ហើមចេញចូលហ្នឹងឯង ។

១០- **ឧបសមានុស្សតិ** ការរលឹករឿយៗ មានគុណរបស់ព្រះនិព្វាន ដែលជាទីរម្ងាប់ទុក្ខទាំងពួងជាអារម្មណ៍ ។

# អាការៈទាំង ៣២

**កេសា** សក់ទាំងឡាយ, **លោមា** រោមទាំងឡាយ, **នខា** ក្រចកទាំងឡាយ, **ទន្តា** ធ្មេញទាំងឡាយ, **តចោ** ស្បែក, **មំសំ** សាច់, **នហារូ** សរសៃ, **អដ្ឋិ** ឆ្អឹង, **អដ្ឋិមិញ្ជំ** ខួរក្នុងឆ្អឹង, **វក្កំ** ទាច, (តម្រងបស្សាវៈ), **ហទយំ** បេះដូង, **យកនំ** ថ្លើម, **កិលោមកំ** វាវ, **បិហកំ** ក្រពះ, **បប្ផាសំ** សួត, **អន្តំ** ពោះវៀនធំ, **អន្តគុណំ** ពោះវៀនតូច, **ឧទរិយំ** អាហារថ្មី, **ករីសំ** អាហារចាស់, **មត្ថកេមត្ថលុង្គំ** ខួរក្នុងក្បាល, **បិត្តំ** ប្រមាត់, **សេម្ហំ** ស្លេស្ម, **បុព្វោ** ខ្ទុះ, **លោហិតំ** ឈាម, **សេទោ** ញើស, **មេទោ** ខ្លាញ់ខាប់, **អស្សុ** ទឹកភ្នែក, **វសា** ខ្លាញ់រាវ, **ខេឡោ** ទឹកមាត់, **សិង្ឃាណិកា** ទឹកសំបោរ, **លសិកា** ទឹករំអិល, **មុត្តំ** ទឹកមូត្រ ។

# ព្រហ្មវិហារ ៤

១- **មេត្តា** ផ្សាយមេត្តាដល់សព្វសត្វទាំងអស់,

២- **ករុណា** ផ្សាយករុណាដល់សព្វសត្វទាំងអស់,

៣- **មុទិតា** ផ្សាយមុទិតាដល់សព្វសត្វទាំងអស់,

៤- **ឧបេក្ខា** ផ្សាយឧបេក្ខាដល់សព្វសត្វទាំងអស់ ។

### អរូប ៤

១- **អាកាសានញ្ចាយតនៈ** យកអាកាសក្នុងបដិភាគនិមិត្ត ដែលកើតពីកសិណ ៩ លើកអាកាសកសិណចេញដែលមិនមាន ទីបំផុតជាអារម្មណ៍,

២- **វិញ្ញាណញ្ចាយតនៈ** ស្រាវយកអរូបវិញ្ញាណ ទី១ ដែលផ្សាយទៅមិនមានទីបំផុតជាអារម្មណ៍,

៣- **អាកិញ្ចញ្ញាណយតនៈ** កំណត់យកអរូបវិញ្ញាណ ទី ១ ដែលផ្សាយទៅ មិនមានកន្លល់តិចតួចមកជាអារម្មណ៍,

៤- **នេវសញ្ញានាសញ្ញាយតនៈ** កំណត់យកសេចក្ដីល្អិត របស់អរូបវិញ្ញាណ ទី៣ ដែលមានស្ទើរតែមិនមាន មកជា អារម្មណ៍ ។

## អាហារេបដិកូលសញ្ញា

**សញ្ញា** ដែលយោគាវចរពិចារណាអាហារដែលបដិកូល ។

## ចតុធាតុវវដ្ឋាន

**វវដ្ឋាន** ដែលព្រះយោគាវចរពិចារណាកំណត់ធាតុទាំង ៤ គឺ បឋវីធាតុ ធាតុដី, អាបោធាតុ ធាតុទឹក, តេជោធាតុ ធាតុភ្លើង,





វាយោធាតុ ធាតុខ្យល់ ។

រួមទាំងអស់ ជាកម្មដ្ឋាន ៤០ ។

អារម្មណ៍ របស់កម្មដ្ឋាន ៤០ ប្រភេទ ដែលបានរៀបរាប់សង្ខេបមកហើយនេះ បុគ្គលជ្រើសរើសយកអារម្មណ៍ណាមួយមកធ្វើបរិកម្មភាវនា តាមគន្លងអង្គមគ្គបី នៃអដ្ឋង្គិកមគ្គ មាន សម្មាវាយាម (ព្យាយាមត្រូវ) សម្មាសតិ (តាំងសតិត្រូវ) សម្មា-សមាធិ (សមាធិត្រូវ) បុគ្គលនោះ ប្រាកដជាបាននូវសមថចិត្ត ឬ សមាធិចិត្ត ដែលបណ្តុះបណ្តាលឲ្យកើតបញ្ញា ។

ក្នុងអដ្ឋង្គិកមគ្គ ពាក្យថា **សមាធិ** សំដៅយក **ឈាន** អ្នកបានអភិញ្ញា ត្រូវប្រើឈាន អ្នកចូលនិរោធសមាបត្តិ ត្រូវប្រើឈាន ព្រះអរហន្តចេតោវិមុត្តិ ត្រូវប្រើឈាន ព្រះពុទ្ធ មុននឹងចូលបរិនិព្វាន ទ្រង់ក៏បានប្រើឈានដែរ ។

ពាក្យថា **ឈាន** ជាភាសាបាលី ជានាមស័ព្ទ មានន័យថា ការសំឡឹងអារម្មណ៍ ដោយចិត្តជាសមាធិ (អប្បនាសមាធិ) ឬ ការដុតនូវនីវរណធម៌ឲ្យទ្រោមទៅ ។ ឯពាក្យថា **ឈាន** ជាកិរិយាស័ព្ទ ប្រែថា លើកជើងដើរ ឬ បោះជំហានឈានជើងទៅមុខ ។ អ្នកខ្លះយល់ស្មានថា ឈានលាភី (អ្នកបានឈាន) ឈានជើងឡើងកាំជណ្តើរទៅស្ថានសួគ៌ ស្ថានព្រហ្ម ស្ថាននិព្វាន ។ សូមកុំប្រឡំយល់ខុស ។

កសិណ ១០ អសុភ ១០ កាយគតាសតិ ១ អានាបានស្សតិ ១ ប៉ុណ្ណោះ ។ ឈាន កើតចេញពីបដិភាគនិមិត្តនេះឯង ។

## ភាវនា ៣ យ៉ាង

១- **បរិកម្មភាវនា** ភាវនាដែលចាប់ផ្តើមជាដំបូង រហូតជិតដល់ឧគ្គហនិមិត្តកើតឡើង,

២- **ឧបចារភាវនា** ភាវនាចាប់ត្រឹមឧគ្គហនិមិត្ត កើតឡើង រហូតដល់ជិតអប្បនាកើតឡើង,

៣- **អប្បនាភាវនា** ភាវនាក្នុងពេលដែលចិត្តស្ថិតនៅក្នុងបដិភាគនិមិត្ត ។ នីវរណក្កិលេស មានកាមច្ឆន្ទ ជាដើម ចាប់ស្ងប់រម្ងាប់ពីត្រឹមឧបចារភាវនានេះទៅ ព្រោះហេតុនោះ ទើបលោកហៅថា ឧបចារជ្ឈាន ចំណែកអប្បនាភាវនា លោកហៅថា អប្បនាឈាន ឈានចុះស៊ប់ ។

ព្រះយោគាវចរ កាលបានសំរេចបឋមជ្ឈានហើយ បើមានប្រាថ្នាឲ្យបានសំរេចទុតិយជ្ឈាន ឬ ឈានខ្ពស់ៗឡើងទៀត គប្បីហាត់បង្វឹកឈានជាន់ក្រោម ដែលខ្លួនបានហើយនោះ ឲ្យប្រឹក ដោយ **វសី** ទាំង ៥ ជាមុនសិន ដល់ពេលចេញចាកឈាននោះមកវិញ ត្រូវពិចារណាឲ្យឃើញទោស ក្នុងឈានជាន់ក្រោម ឃើញអានិសង្សក្នុងឈានជាន់លើ ហើយធ្វើទុកក្នុងចិត្តនូវឈានជាន់លើទៅ ដរាបដល់អប្បនាចិត្តកើតឡើង ។ **វសី** ៥ នោះ គឺ:





និង **ឯកគ្គតា** ។

ក្នុងអភិធម្ម លោកចែកជា ៥ ទៅជា **បញ្ចមជ្ឈាន** ដោយចែកត្រង់ **ទុតិយជ្ឈាន** ជា ២ (**ទុតិយ-តតិយ**) ឯ **តតិយ** ទៅជា **ចតុត្ថ ចតុត្ថ** ទៅជា **បញ្ចម** គ្រប់ជា ៥ ។ **រូបជ្ឈាន** ដែលមាន ៤ ថ្នាក់ លោករាប់ជា **ចតុក្កន័យ** (ឈានមានន័យ ៤) ។ រីឯ **រូបជ្ឈាន** ដែលមាន ៥ ថ្នាក់ លោករាប់ជា **បញ្ចកន័យ** (ឈានមានន័យ ៥) ។

## អរូបជ្ឈាន មាន ៤ គឺ

១- **អាកាសានញ្ចាយតនៈ** មានអារម្មណ៍ថា អាកាសមិនមានទីបំផុត,

២- **វិញ្ញាណញ្ចាយតនៈ** មានអារម្មណ៍ថា វិញ្ញាណមិនមានទីបំផុត,

៣- **អាកិញ្ចញ្ញាយតនៈ** មានអារម្មណ៍ថា វត្ថុតិចតួចមិនមាន,

៤- **នេវសញ្ញានាសញ្ញាយតនៈ** មានអារម្មណ៍ថា នេះជាធម្មជាតិស្ងប់សូន្យ ស្ងាប់ទៅលែងកើតទៀត ។

គួរកត់សំគាល់ថា រូបជ្ឈាន ឬ អារម្មណូបនិជ្ឈាន ជាឈានចូលទៅសំឡឹងអារម្មណ៍នៃសមថៈ យ៉ាងជិតស្និទ្ធ ។ ឯអរូបជ្ឈាន ឬ លក្ខណូបនិជ្ឈាន គឺឈានដែលចូលទៅសំឡឹងលក្ខណៈ អនិច្ចំ

ទុក្ខំ អនត្តា នៃវិបស្សនា យ៉ាងជាក់ច្បាស់ ។

ដើម្បីឲ្យបានសម្រេចបឋមជ្ឈាន គេត្រូវចំរើនសមថកម្មដ្ឋាន អប់រំចិត្តឲ្យស្ងប់ ឲ្យតាំងនៅស៊ប់មាំ (សមាធិ) ក្នុងអារម្មណ៍ ជាកុសល ដូចជា បឋវីកសិណ(ដី)ជាដើម រហូតដល់កើតបដិភាគ-និមិត្ត ។ បើចិត្តតាំងនៅស៊ប់ ក្នុងបដិភាគនិមិត្ត កំចាត់នីវរណូ-បក្កិលេសចេញបាន អង្គឈានទាំង ៥ គឺ វិតក្កៈ វិចារៈ បីតិ សុខ ឯកគ្គតា កើតឡើង ពេលនោះ ឈ្មោះថា បានសម្រេច បឋមជ្ឈាន ។

យោគាវចរត្រូវសិក្សាឲ្យស្គាល់ថា តើកម្មដ្ឋានណាខ្លះ ដែលអាចឲ្យសម្រេចឈាន ឲ្យបានសម្រេចត្រឹមឈានណា? កម្មដ្ឋាន ដែលអាចឲ្យសម្រេចឈាន មាន ៣០ គឺ :

អសុភ ១០ និង កាយគតាសតិ ១ ឲ្យសំរេចបានត្រឹម បឋមជ្ឈាន ។ ព្រហ្មវិហារ ៣ មេត្តា ករុណា មុទិតា ឲ្យ សំរេចបានត្រឹមតតិយជ្ឈាន ។

ព្រហ្មវិហារ ១ គឺ ឧបេក្ខា ឲ្យសំរេច រហូតដល់ចតុត្ថជ្ឈាន (បញ្ចមជ្ឈាន) ។

កសិណ ១០ និង អានាបានស្សតិ ១ ឲ្យសម្រេច រហូត ដល់ចតុត្ថជ្ឈាន (បញ្ចមជ្ឈាន) ។

អរូបកម្មដ្ឋាន ៤ ឲ្យសំរេចអរូបជ្ឈាន ៤ ។





## និមិត្ត

ពាក្យថា **និមិត្ត** ប្រែថា គ្រឿងសំគាល់ គ្រឿងចំណាំ បើនិយាយឲ្យងាយស្តាប់ គឺអារម្មណ៍របស់កម្មដ្ឋាននោះឯង ។ និមិត្ត មាន ៣ គឺ :

១- **បរិកម្មនិមិត្ត** អារម្មណ៍របស់កម្មដ្ឋាន ដែលគេលើក យកមកទុកជាទីតាំងនៃចិត្ត គឺជាបង្គោលដំបូង សំរាប់ចងក្រៀក ចិត្ត,

២- **ឧគ្គហនិមិត្ត** និមិត្តហាក់ដូចជាភាពចម្លងទាំងស្រុង នៃ បរិកម្មនិមិត្ត គឺដូចគ្នាបេះបិទ គ្មានខុសគ្នាត្រង់ចំណុចណា សោះ ឡើយ គ្រាន់តែ បរិកម្មនិមិត្តខ្លះ អាចមើលឃើញដោយភ្នែកបាន ចំណែកឧគ្គហនិមិត្ត មិនមែនមើលឃើញ ដោយភ្នែកបានទេ គឺ ឃើញដោយចិត្ត ហាក់ដូចជាជាប់នឹងភ្នែក ទៅទីកន្លែងណា ជាប់ តាមទៅជាមួយ ដូចជាស្រមោលអន្ទោលតាមប្រាណ ។

៣- **បដិភាគនិមិត្ត** និមិត្តបរិសុទ្ធថ្លាស្អាត ប្រាសចាកពណ៌ សណ្ឋានដើម ជានិមិត្តប្រហែលគ្នានឹងឧគ្គហនិមិត្ត ក៏ប៉ុន្តែ ជាភាព ម៉ត់ចត់បរិសុទ្ធ សូម្បីឧគ្គហនិមិត្ត មានចំណុចសៅហ្មង បដិភាគ-និមិត្ត ឥតមានចំណុចសៅហ្មងឡើយ ។

បរិកម្មនិមិត្ត និង ឧគ្គហនិមិត្ត មានទូទៅគ្រប់កម្មដ្ឋាន ទាំង អស់ ចំណែកឯបដិភាគនិមិត្ត មានចំពោះតែកម្មដ្ឋាន ២២ គឺ :

## វិបស្សនា មានធម៌ជាគោល ៣ យ៉ាង គឺ

១- **ធម៌ជាភូមិ** ជាអារម្មណ៍របស់វិបស្សនា,

២- **ធម៌ជាឫសគល់** ជាហេតុកើតឡើងតាំងនៅនៃវិបស្សនា,

៣- **ធម៌ជាតួរបស់វិបស្សនា** ។

## ធម៌ជាភូមិ ជាអារម្មណ៍របស់វិបស្សនា

**ភូមិ** ប្រែថាទីកន្លែង ឬ ជាន់ថ្នាក់, **អារម្មណ៍** ប្រែថា អ្វីៗដែលចិត្តតោង ចិត្តថ្ពក់ ចិត្តជាប់ជំពាក់ ។ ធម៌ជាភូមិជាអារម្មណ៍របស់វិបស្សនា បើនិយាយដោយសង្ខេប មានត្រឹមតែ ២ គឺៈ **នាម** និង **រូប** (បញ្ចក្ខន្ធ) ។ តែបើរួមឲ្យកាន់តែខ្លីទៅទៀត នៅត្រឹមតែមួយ គឺ **សង្ខារ** ។ បើនិយាយ ដោយពិស្ដារ បានដល់ធម៌ ៦ ពួក គឺ ខន្ធ ៥, អាយតនៈ ១២, ធាតុ ១៨, ឥន្ទ្រិយ៍ ២២, អរិយសច្ច ៤, បដិច្ចសមុប្បាទ ១២ រួមទាំងអស់ត្រូវជា ៧៣ ។

## ខន្ធ ៥

១- **រូបក្ខន្ធ** រូបដែលផ្សំផ្គុំឡើង ដោយធាតុខាងក្នុង ៤ ដី ទឹក ភ្លើង ខ្យល់,

២- **វេទនាខន្ធ** ធម្មជាតិសោយនូវអារម្មណ៍ ឬ ដឹងនូវអារម្មណ៍,

៣- **សញ្ញាខន្ធ** ធម្មជាតិចំណាំនូវអារម្មណ៍,

៤- **សង្ខារក្ខន្ធ** ធម្មជាតិតាក់តែងចិត្ត ប្រព្រឹត្តទៅ ក្នុង





១- **អាវជ្ជនវសី** ថ្មីកក្នុងការពិចារណាអង្គឈាន នៃមនោទ្វារាវជ្ជនៈ,

២- **សមាបជ្ជនវសី** ថ្មីកក្នុងការពិចារណាឈាន គឺចូលបានភ្លាមមិនយឺតយូរ,

៣- **អធិដ្ឋានវសី** ថ្មីកក្នុងការកំណត់ពេលចូល គឺចង់ចូលអស់ពេលប៉ុន្មាន បានប៉ុណ្ណឹង មិនតិចជាងពេលកំណត់,

៤- **វុដ្ឋានវសី** ថ្មីកក្នុងការកំណត់ពេលចេញ គឺចង់ចេញពេល ថ្មើម៉ាន បានស្មើណឹង មិនលើសពេលកំណត់,

៥- **បច្ចវេក្ខណវសី** ថ្មីកក្នុងការពិចារណាអង្គឈាន នៃជវនៈ ។

បើមិនទាន់ស្ទាត់ ឬ ថ្មីក ក្នុងវសីទាំង ៥ នេះទេ ចូលទុតិយជ្ឈាន និង ឈានថ្នាក់លើៗ មិនបានសំរេចទេ ។

សរុបសេចក្ដីមក ការចំរើនសមាធិកម្មដ្ឋាន ឬ សមថ-កម្មដ្ឋាន ពឹងផ្អែកទាំងស្រុងទៅលើការព្យាយាមត្រូវ សតិសម្ប-ជញ្ញៈត្រូវ ការតំកល់អារម្មណ៍ត្រូវ ទើបអាចសំរេចបឋមជ្ឈាន និង ឈានឯទៀតបាន ដែលជាហេតុនាំឲ្យកើតបញ្ញា ជាបដិវេធ-ធម៌ ចាក់ធ្លុះអវិជ្ជា តណ្ហា ឧបាទាន ។

# បញ្ញា

**បញ្ញា** ជាលំអឋ្នាក់ខាងចុងបំផុតនៃព្រះពុទ្ធសាសនា ហៅថា **បរិយោសានកល្យាណ** ដែលមានអង្គមគ្គ ២ នៃអដ្ឋង្គិកមគ្គ គឺ សម្មាទិដ្ឋិ និង សម្មាសង្កប្បៈ ។ បញ្ញានេះ លោកសំដៅទៅលើ វិបស្សនាបញ្ញា ឬ វិបស្សនាញាណ ដែលបានមកពីការបណ្តុះបណ្តាល ពិសោធន៍ផ្ទាល់ខ្លួន មិនមែនជាបញ្ញាចាស់ សំដៅយកបញ្ញា ដែលគេបានសន្សំពីបុព្វជាតិ ហើយជិតជាមជាប់ជាមួយនឹងវិបាកវិញ្ញាណ មកចាប់កំណើតក្នុងភពថ្មី ខ្លះមានតិច ខ្លះមានច្រើន តាមឧបនិស្ស័យរបស់ខ្លួនទេ ។ បញ្ញាបច្ចុប្បន្ន ដែលបុគ្គលម្នាក់ៗ អាចបណ្តុះបណ្តាលបាន មាន ៣ គឺ :

១- **សុតមយបញ្ញា** បញ្ញា បានមកពីការស្តាប់ធម្មទេសនា ស្តាប់បាឋកថា ស្តាប់គ្រូបង្រៀន អានសៀវភៅ សិក្សាបរិយត្តិ-ធម៌ជាដើម,

២- **ចិន្តាមយបញ្ញា** បញ្ញា បានមកពីការជញ្ជឹងគិត ការត្រិះរិះរកហេតុផល តាមធម្មតារបស់មនុស្ស ឬ ពិចារណាអ្វីៗ ដែលបានរៀន បានអាន បានស្តាប់ជាដើម,

៣- **ភាវនាមយបញ្ញា** បញ្ញា បានមកពីការចំរើន ការបដិបត្តិ ការយកបរិយត្តិធម៌ ដែលបានរៀន បានអាន បានត្រិះរិះ មកបដិបត្តិ(អនុវត្ត) ផ្ទាល់ខ្លួន មានជាអាទិ៍ គឺ: ការចំរើនភាវនា-





សមថកម្មដ្ឋាន ឬ វិបស្សនាកម្មដ្ឋាន ។

បញ្ញា ដែលគេអាចបណ្តុះបណ្តាលបានទាំងបីខាងលើនេះ បើរួមមក ចែកជាពីរប្រភេទ គឺ :

១- **លោកបញ្ញា** (លោកិយបញ្ញា) បញ្ញាផ្លូវលោក គឺបញ្ញា សំរាប់ច្នៃប្រឌិត បង្កើតផលិតផល សម្ភារៈផ្សេងៗ ឲ្យច្រើនឡើង ដើម្បីផ្តល់ផាសុខភាព សុខភាពដល់ពិភពលោក ដែលហៅថា លោកសម្ភារនិយម ។

២- **ធម្មបញ្ញា** (លោកុត្តរបញ្ញា) បញ្ញាផ្លូវធម៌ គឺបញ្ញា សំរាប់ចុះឲ្យឃើញសភាវធម៌ ទៅតាមសេចក្តីពិតរបស់វា ហើយបន្ថយនូវកិលេស លោភៈ ទោសៈ មោហៈ ។

ពាក្យថា **វិបស្សនាកម្មដ្ឋាន** មានពីរបទ គឺ **វិបស្សនា** + **កម្មដ្ឋាន** ។ **វិបស្សនា** ប្រែថា ប្រាជ្ញាពិចារណាឃើញច្បាស់នូវដំណើរសង្ខារធម៌តាមសេចក្តីពិត ។ រួមមកមានន័យថា អារម្មណ៍ ដែលបុគ្គលយកមកបរិកម្មភាវនា ដើម្បីឲ្យកើតបញ្ញា តាមផ្លូវចិត្ត ឃើញសភាវៈពិត នៅក្នុងសង្ខារទាំងឡាយ មានបញ្ចក្ខន្ធ (ខន្ធ៥) ជាដើមថាជា អនិច្ចំ ទុក្ខំ អនត្តា ។ បើនិយាយឲ្យស្រួលស្តាប់មានន័យថា ការអប់រំចិត្តឲ្យកើតបញ្ញាផ្លូវធម៌ ដែលកើតពីការបដិបត្តិ ជាភាវនាមយបញ្ញា ឬ ហៅម្យ៉ាងទៀតថា វិបស្សនាបញ្ញា ។

ដែលខ្លួនធ្លាប់ឃើញហើយ គឺ មគ្គចិត្តខាងលើបី និង ផលចិត្តខាងក្រោមបី,

២២- **អញ្ញាតាវិន្ទ្រីយ៍** ភាពជាធំ ក្នុងការឃើញច្បាស់អរិយសច្ច ៤ ចប់សព្វគ្រប់ហើយ គឺ អរហត្តផលចិត្ត ១ ។

## អរិយសច្ច ៤

១- **ទុក្ខសច្ច** ទុក្ខជាសេចក្តីពិត,

២- **ទុក្ខសមុទយសច្ច** ហេតុនាំឲ្យកើតទុក្ខជាសេចក្តីពិត,

៣- **ទុក្ខនិរោធសច្ច** ការរំលត់ទុក្ខជាសេចក្តីពិត,

៤- **មគ្គសច្ច** ផ្លូវទៅកាន់ទីរំលត់ទុក្ខជាសេចក្តីពិត ។

## បដិច្ចសមុប្បាទ ១២

១- **អវិជ្ជា** ជាបច្ច័យឲ្យកើត **សង្ខារ**,

២- **សង្ខារ** ជាបច្ច័យឲ្យកើត **វិញ្ញាណ**,

៣- **វិញ្ញាណ** ជាបច្ច័យឲ្យកើត **នាមរូប**,

៤- **នាមរូប** ជាបច្ច័យឲ្យកើត **សឡាយតនៈ**,

៥- **សឡាយតនៈ** ជាបច្ច័យឲ្យកើត **ផស្សៈ**,

៦- **ផស្សៈ** ជាបច្ច័យឲ្យកើត **វេទនា**,

៧- **វេទនា** ជាបច្ច័យឲ្យកើត **តណ្ហា**,

៨- **តណ្ហា** ជាបច្ច័យឲ្យកើត **ឧបាទាន**,

៩- **ឧបាទាន** ជាបច្ច័យឲ្យកើត **ភព**,





អារម្មណ៍,

៥- **វិញ្ញាណក្ខន្ធ** ធម្មជាតិដឹងនូវអារម្មណ៍ ។

## អាយតនៈ ១២

១- **ចក្ខាយតនៈ** អាយតនៈ គឺភ្នែក,

២- **រូបាយតនៈ** អាយតនៈ គឺរូប,

៣- **សោតាយតនៈ** អាយតនៈ គឺត្រចៀក,

៤- **សទ្ទាយតនៈ** អាយតនៈ គឺសម្លេង,

៥- **ឃានាយតនៈ** អាយតនៈ គឺច្រមុះ,

៦- **គន្ធាយតនៈ** អាយតនៈ គឺក្លិន,

៧- **ជិវ្ហាយតនៈ** អាយតនៈ គឺអណ្តាត,

៨- **រសាយតនៈ** អាយតនៈ គឺរស,

៩- **កាយាយតនៈ** អាយតនៈ គឺកាយ,

១០- **ផោដ្ឋព្វាយតនៈ** អាយតនៈ គឺផោដ្ឋព្វៈ,

១១- **មនាយតនៈ** អាយតនៈ គឺចិត្ត,

១២- **ធម្មាយតនៈ** អាយតនៈគឺអារម្មណ៍ដែលកើតនឹងចិត្ត។

## ធាតុ ១៨

១- **ចក្ខុធាតុ** ធាតុគឺភ្នែក,

២- **រូបធាតុ** ធាតុគឺរូប,

៣- **ចក្ខុវិញ្ញាណធាតុ** ធាតុគឺវិញ្ញាណអាស្រ័យភ្នែក,

៤- **សោតធាតុ** ធាតុគឺត្រចៀក,

៥- **សទ្ទធាតុ** ធាតុគឺសម្លេង,

៦- **សោតវិញ្ញាណធាតុ** ធាតុគឺវិញ្ញាណអាស្រ័យត្រចៀក,

៧- **ឃានធាតុ** ធាតុច្រមុះ,

៨- **គន្ធធាតុ** ធាតុគឺក្លិន,

៩- **ឃានវិញ្ញាណធាតុ** ធាតុគឺវិញ្ញាណអាស្រ័យច្រមុះ,

១០- **ជីវ្ហាធាតុ** ធាតុគឺអណ្តាត,

១១- **រសធាតុ** ធាតុគឺរស,

១២- **ជីវ្ហាវិញ្ញាណធាតុ** ធាតុគឺវិញ្ញាណអាស្រ័យអណ្តាត,

១៣- **កាយធាតុ** ធាតុគឺកាយ,

១៤- **ផោដ្ឋព្វធាតុ** ធាតុគឺផោដ្ឋព្វៈ,

១៥- **កាយវិញ្ញាណធាតុ** ធាតុគឺគឺវិញ្ញាណអាស្រ័យកាយ,

១៦- **មនោធាតុ** ធាតុគឺចិត្ត,

១៧- **ធម្មធាតុ** ធាតុគឺអារម្មណ៍ដែលកើតនឹងចិត្ត,

១៨- **មនោវិញ្ញាណធាតុ** ធាតុគឺវិញ្ញាណអាស្រ័យចិត្ត ។

## ឥន្ទ្រីយ៍ ២២

១- **ចក្ខុន្ទ្រីយ៍** ភាពជាធំក្នុងការឃើញ,

២- **សោតិន្ទ្រីយ៍** ភាពជាធំក្នុងការឮ,

៣- **ឃានិន្ទ្រីយ៍** ភាពជាធំក្នុងការធុំក្លិន,





៤- **ជីវ្ហិន្ទ្រីយ៍** ភាពជាធំក្នុងការដឹងរសជាតិ,

៥- **កាយិន្ទ្រីយ៍** ភាពជាធំក្នុងការប៉ះពាល់,

៦- **មនិន្ទ្រីយ៍** ភាពជាធំក្នុងការដឹងអារម្មណ៍,

៧- **ឥត្ថិន្ទ្រីយ៍** ភាពជាធំក្នុងភាពជាស្រី,

៨- **បុរិសិន្ទ្រីយ៍** ភាពជាធំក្នុងភាពជាបុរស,

៩- **ជីវិតិន្ទ្រីយ៍** ភាពជាធំក្នុងការរស់នៅ,

១០- **សុខិន្ទ្រីយ៍** ភាពជាធំក្នុងសេចក្តីសុខ,

១១- **ទុក្ខិន្ទ្រីយ៍** ភាពជាធំក្នុងសេចក្តីទុក្ខ,

១២- **សោមនស្សិន្ទ្រីយ៍** ភាពជាធំក្នុងសោមនស្ស,

១៣- **ទោមនស្សិន្ទ្រីយ៍** ភាពជាធំក្នុងទោមនស្ស,

១៤- **ឧបេក្ខិន្ទ្រីយ៍** ភាពជាធំក្នុងឧបេក្ខា,

១៥- **សទ្ធិន្ទ្រីយ៍** ភាពជាធំក្នុងសទ្ធា,

១៦- **វីរិយិន្ទ្រីយ៍** ភាពជាធំក្នុងវីរិយៈ,

១៧- **សតិន្ទ្រីយ៍** ភាពជាធំក្នុងសតិ,

១៨- **សមាធិន្ទ្រីយ៍** ភាពជាធំក្នុងសមាធិ,

១៩- **បញ្ញិន្ទ្រីយ៍** ភាពជាធំក្នុងបញ្ញា,

២០- **អនញ្ញាតញ្ញស្សាមីតិន្ទ្រីយ៍** ភាពជាធំក្នុងការឃើញច្បាស់អរិយសច្ច ៤ ដែលខ្លួនមិនធ្លាប់ឃើញ គឺសោតាបត្តិមគ្គចិត្ត ១,

២១- **អញ្ញិន្ទ្រីយ៍** ភាពជាធំក្នុងការឃើញច្បាស់អរិយសច្ច ៤

វេហូតដល់គោត្រភូញាណ នេះចាត់ជា **ភាវនាមយកាមាវចរ-កុសល** ។

ក្នុងលំដាប់នៃគោត្រភូចិត្ត មគ្គចិត្តកើតឡើងនេះ ចាត់ទុកជាលោកុត្តរកុសល ។ មគ្គចិត្ត កើតឡើងហើយ ឈោងយកនិព្វានជាអារម្មណ៍ ធ្វើកិច្ចក្នុងអរិយសច្ច ៤ គឺ ១- កំណត់ដឹងទុក្ខសច្ច, ២-លះទុក្ខសមុទយសច្ច, ៣-ធ្វើឲ្យច្បាស់នូវនិរោធសច្ច, ៤-ធ្វើឲ្យកើតឡើងនូវមគ្គសច្ច ។ ញាណ សម្បយុត្ត ដោយមគ្គទាំង ៤ មានសោតាបត្តិមគ្គជាដើម ហៅថា **ញាណទស្សនវិសុទ្ធិ** ។

## វិបស្សនូបក្កិលេស

**វិបស្សនូបក្កិលេស** មាន ២ បទ គឺ **វិបស្សនា** + **ឧបក្កិលេស** មានន័យថា ធម៌ជាគ្រឿងចូលទៅសៅហ្មង ដល់វិបស្សនាញាណ មាន ១០ គឺ :

១- **ឱភាស** ពន្លឺដែលកើតឡើងយ៉ាងខ្លាំង ក្នុងពេលចំរើនវិបស្សនា,

២- **ញាណ** បញ្ញាកើតឡើងដ៏ក្លៀវក្លា,

៣- **បីតិ** សេចក្តីរីករាយ ឬ សេចក្តីឆ្អែតចិត្ត,

៤- **បស្សទ្ធិ** សេចក្តីស្ងប់កាយស្ងប់ចិត្ត,

៥- **សុខ** សេចក្តីសុខដ៏ល្អិត ដែលកើតឡើង ក្នុងកាយ និង ចិត្ត,





១០- **ភព** ជាបច្ច័យឲ្យកើត **ជាតិ**,

១១- **ជាតិ** ជាបច្ច័យឲ្យកើត **ជរា**,

១២- **ជរា** ជាបច្ច័យឲ្យកើត **មរណៈ** ។

## ធម៌ជាឫសគល់នៃវិបស្សនា

**ធម៌** ជាឫសគល់នៃវិបស្សនា មានពីរគឺ **សីលវិសុទ្ធិ** និង **ចិត្តវិសុទ្ធិ**

១- **សីលវិសុទ្ធិ** សេចក្តីបរិសុទ្ធិនៃសីល គឺការរក្សាសីល ៥ សីល ៨ សីល ១០ សីល ២២៧ ឲ្យបានបរិសុទ្ធ មិនកន្លងនូវសិក្ខាបទណាមួយ ឬ ការសង្រួម ដោយប្រពៃនូវសីលសិក្ខាទាំងនោះ ។

២- **ចិត្តវិសុទ្ធិ** សេចក្តីបរិសុទ្ធិនៃចិត្ត គឺការរក្សាចិត្តរបស់ខ្លួនឲ្យស្ងប់ ជា អប្បនាសមាធិ (បានឈាន) ឧបចារសមាធិ (ក្បែរឈាន) ឬ យ៉ាងទាបណាស់ ជាខណិកសមាធិ (សមាធិជាខណៈ) ។

## ធម៌ជាតួជាសរីរៈរបស់វិបស្សនា

**ធម៌** ជាតួ ឬ ជាសរីរៈ របស់វិបស្សនា មាន ៥ គឺ :

១- **ទិដ្ឋិវិសុទ្ធិ** សេចក្តីបរិសុទ្ធិនៃការឃើញ ។ ការឃើញមនុស្ស និង សត្វជាដើម ហួសការសន្មតិ គឺឃើញថា ជាធាតុ ៤ ដូចគ្នា ជារូបនាមដូចគ្នា ហើយលះបង់សេចក្តីសំគាល់ថា មនុស្ស

ថា សត្វ បេញបាន នេះហៅថា ទិដ្ឋិវិសុទ្ធិ ។

២- **កង្ខាវិតរណវិសុទ្ធិ** សេចក្ដីបរិសុទ្ធិនៃញាណជាគ្រឿងកន្លងផុតសេចក្ដីសង្ស័យ ។ ការពិចារណារកហេតុបច្ច័យ រករូបនាម រូបកើតមកពីអ្វី? នាមកើតមកពីអ្វី? ដេញរកល្អិតទៅៗ រហូតដល់ឃើញច្បាស់ថា រូបកើតមកពីធម៌ ៥ យ៉ាងគឺ អវិជ្ជា តណ្ហា ឧបាទាន កម្ម អាហារ ។ វេទនា សញ្ញា សង្ខារ កើតមកពីធម៌ ៥ យ៉ាង គឺ អវិជ្ជា តណ្ហា ឧបាទាន កម្ម ផស្សៈ ។ វិញ្ញាណ កើតមកពីធម៌ ៥ យ៉ាង គឺ អវិជ្ជា តណ្ហា ឧបាទាន កម្ម នាមរូប ។ ដូច្នេះ អស់សេចក្ដីសង្ស័យក្នុងបញ្ចក្ខន្ធ ដែលជាអតីតក្ដី អនាគតក្ដី ឬ ក្នុងបច្ចុប្បន្ននេះក្ដី នេះហៅថា **កង្ខាវិតរណវិសុទ្ធិ** ។

៣- **មគ្គាមគ្គញ្ញាណទស្សនវិសុទ្ធិ** សេចក្ដីបរិសុទ្ធិនៃញាណជាគ្រឿងឃើញថា នេះជាផ្លូវ នេះមិនមែនជាផ្លូវ ។ ការពិចារណានាមរូប ឬ បញ្ចក្ខន្ធ រូប វេទនា សញ្ញា សង្ខារ វិញ្ញាណ ឯណានីមួយ ជាអតីតក្ដី ជាអនាគតក្ដី បច្ចុប្បន្នក្ដី ខាងក្នុងក្ដី ខាងក្រៅក្ដី គ្រោតគ្រាតក្ដី ល្អិតក្ដី ថោកទាបក្ដី ប្រណីតក្ដី ឆ្ងាយក្ដី ជិតក្ដី ឃើញសុទ្ធតែជា អនិច្ចំ ទុក្ខំ អនត្តា... ចិត្តចុះស៊ប់ទៅ ។ ឧបកិលេស ១០ គឺ ឱភាស ពន្លឺ ឬ បីតិ ការឆ្អែតកាយ ឆ្អែតចិត្តជាដើម កើតឡើង ជាហេតុនាំឲ្យអ្នកចំរើនវិបស្សនា ប្រឡំ





ថា មគ្គផល កើតឡើងហើយ ចិត្តក៏រីករាយសប្បាយ នឹងឧបកិលេសនោះ នេះគឺជាឧបសគ្គមួយរបស់អ្នកចំរើនវិបស្សនា ។ អ្នកចំរើនវិបស្សនាល្អ គេមិនវង្វេងដោយឧបកិលេសនេះទេ គេដឹងច្បាស់ថា នេះមិនមែនជាមគ្គផល នេះមិនមែនជាផ្លូវទេ ហើយខំប្រឹងចំរើនវិបស្សនា បន្តទៅទៀត ការឃើញដូច្នេះ ហៅថា **មគ្គាមគ្គញ្ញាណទស្សនវិសុទ្ធិ** ។

៤- **បដិបទាញ្ញាណទស្សនវិសុទ្ធិ** សេចក្ដីបរិសុទ្ធិនៃញាណជាគ្រឿងឃើញបដិបទា ដែលនឹងឲ្យអរិយមគ្គកើតឡើង ។ ការពិចារណាសង្ខារធម៌ តាមលំដាប់នៃវិបស្សនាញាណទាំង ៩ ចាប់តាំងអំពី ឧទយព្វយញ្ញាណ រហូតដល់ សច្ចានុលោមិកញ្ញាណ កើតឡើង កិរិយាឃើញដូច្នេះ លោកហៅថា **បដិបទាញ្ញាណទស្សនវិសុទ្ធិ** ។

៥- **ញ្ញាណទស្សនវិសុទ្ធិ** សេចក្ដីបរិសុទ្ធិនៃញាណទស្សនៈ គឺឃើញមគ្គទាំង ៤ ។ សេចក្ដីថា ក្នុងលំដាប់នៃអនុលោមញ្ញាណនោះ គោត្រភូចិត្ត ឈោងយកនិព្វានជាអារម្មណ៍ កន្លងបុថុជ្ជនគោត្រ ចូលក្នុងអរិយគោត្រៗ កើតឡើង ។ គោត្រភូញាណ មិនរាប់ចូលក្នុងបដិបទាញាណទស្សនវិសុទ្ធិ ឬ ញាណទស្សនវិសុទ្ធិទេ ព្រោះតាំងនៅក្នុងទីជាអាវជ្ជនមគ្គ របស់មគ្គញ្ញាណ តែគួររាប់ថាជា វិបស្សនា បាន ។ ការចំរើនវិបស្សនា ចាប់តាំងអំពីដើម

ប្រែថា ធម្មជាតិឯណា ដែលបច្ច័យប្រជុំតាក់តែង ក្នុងទីជាមួយគ្នា ធម្មជាតិនោះ ហៅថា **សង្ខារ** ។

**សង្ខារ** ន័យមួយទៀតថា ធម្មជាតិអ្នកតាក់តែងនូវសង្ខតធម៌ មានវិគ្រោះថា **សង្ខតមភិ សង្ខរោន្តីតិ** ប្រែថា ធម្មជាតិណាតាក់តែងនូវសង្ខតធម៌ ធម្មជាតិនោះ ហៅថា សង្ខារ ។ **សង្ខតធម៌** ជាធម៌ដែលមានបច្ច័យតាក់តែង គឺចិត្ត ចេតសិក រូប ។ **អសង្ខតធម៌** ជាធម៌ដែលមិនមានបច្ច័យតាក់តែង គឺព្រះនិព្វាន ។

**សង្ខារ** គឺធម៌មួយដែលព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ហៅជំនួសនូវ **សង្ខតធម៌** ទាំងអស់ជា **បរមត្ថ** សង្ខារ មិនមែនសត្វ បុគ្គល មនុស្ស ទេវតា ជាដើម សង្ខារ គឺត្រឹមតែជាសភាវធម៌ ដែលកើតឡើងនិងវិនាសទៅវិញ តាមហេតុបច្ច័យតែប៉ុណ្ណោះ ។ ឯពាក្យថា សត្វ បុគ្គល មនុស្ស ទេវតា ព្រហ្ម ស្តេច សេដ្ឋី ជាដើម គឺជាបញ្ញត្តិធម៌តែម្យ៉ាង ដែលមានត្រឹមតែឈ្មោះ ជាលោកវោហារ (សំដីក្នុងលោក) មិនមែនជាសភាវបរមត្ថ ដែលមានប្រាកដឡើយ ។

ក្នុងព្រះពុទ្ធសាសនា ពាក្យថា **សង្ខារ** មានន័យច្រើនយ៉ាង អ្នកសិក្សាត្រូវសង្កេតចំណាំ ឲ្យបានច្បាស់ ជៀសវាងកុំឲ្យច្រឡំគ្នា ដូចជា ពាក្យសង្ខារ នៅក្នុងខន្ធ ៥ ជាដើម ។

**សង្ខារ** មានន័យថា ធម្មជាតិ ដែលបច្ច័យប្រជុំតាក់តែង





៦- **អធិមោក្ខ** ជំនឿស៊ប់ មានកម្លាំងខ្លាំងក្លា ញុំាងចិត្តឲ្យចុះស៊ប់,

៧- **បគ្គហ** សេចក្តីព្យាយាមស្មើ មិនតឹងពេកមិនធូរពេក,

៨- **ឧបដ្ឋាន** សតិដែលតាំងនៅមាំដូចភ្នំ មិនមានកម្រើកញាប់ញ័រ,

៩- **ឧបេក្ខា** ភាពនៃចិត្តប្រព្រឹត្តទៅស្មើៗ កណ្តាលៗ,

១០- **និកន្តិ** សេចក្តីប្រាថ្នា ដ៏ល្អិតស្ងប់ ក្នុងវិបស្សនូបក្កិលេស មានពន្លឺជាដើម ដែលកើតឡើង នៅក្នុងសន្តាន នៃវិបស្សនាជន ។

វិបស្សនូបក្កិលេសទាំង ១០ យ៉ាងនេះ លោកហៅថា ឧបក្កិលេស ដោយភាពនៃធម៌ទាំង ១០ នោះ ជាវត្ថុនាំឲ្យសៅហ្មងដល់វិបស្សនាប៉ុណ្ណោះ ។ លោកមិនបានហៅថា ឧបក្កិលេស ដោយភាពនៃធម៌ទាំង ១០ នោះ ជាអកុសលឡើយ ។

## វិបស្សនាញាណ

**ញាណ** ដ៏កំពូលដែលកើតឡើងដល់យោគាវចរ ក្នុងកិរិយាចំរើន វិបស្សនា លោកហៅថា **វិបស្សនាញាណ** មាន ៩ យ៉ាង គឺ :

១- **ឧទយព្វយញ្ញាណ** បញ្ញាឃើញការកើត និង រលត់នៃសង្ខារ,

២- **ឧទ្ធញ្ញាណ** បញ្ញាឃើញចំពោះតែការរលត់នៃសង្ខារ,

៣- **ភយតូបដ្ឋានញ្ញាណ** បញ្ញាឃើញសង្ខារប្រាកដ គួរឲ្យភ័យខ្លាច,

៤- **អាទីនវញ្ញាណ** បញ្ញាឃើញទោសនៃសង្ខារ,

៥- **និព្វិទាញ្ញាណ** បញ្ញាឃើញថា គួរឲ្យនឿយណាយក្នុងសង្ខារ,

៦- **មុញ្ចិតុកាម្យតាញ្ញាណ** បញ្ញា ប្រាថ្នាចង់ឲ្យរួចចាកសង្ខារ,

៧- **បដិសង្ខាញ្ញាណ** បញ្ញារកឧបាយចង់រំដោះខ្លួនចេញពីសង្ខារ,

៨- **សង្ខារុបេក្ខាញ្ញាណ** បញ្ញាតាំងនៅជាកណ្តាលចំពោះសង្ខារ,

៩- **សច្ចានុលោមិកញ្ញាណ** បញ្ញាអនុលោម តាមវិបស្សនាទាំង ៨ ខាងដើម និង អនុលោមតាមពោធិបក្ខិយធម៌ ៣៧ ប្រការខាងចុង ។

## សោឡសញ្ញាណ ១៦

**ញ្ញាណ** ដែលកើតឡើង ដល់អ្នកចំរើនវិបស្សនា តាមលំដាប់ តាំងពីដើមរហូតដល់ទីបំផុត គឺសម្រេចអរហត្តផល មាន ១៦ យ៉ាង គឺ :





១- **នាមរូបបរិច្ឆេទញ្ញាណ** ញាណកំណត់បែករូបនិងនាម គឺឃើញអ្វីៗ ទាំងពួង មានតែរូប និង នាម តែប៉ុណ្ណោះ,

២- **បច្ចយបរិគ្គហញ្ញាណ** ញាណកំណត់ដឹងហេតុបច្ច័យនៃរូបនាម,

៣- **សម្មសនញ្ញាណ** ញាណពិចារណាឃើញរូបនាម ជាត្រៃលក្ខណ៍,

៤ - ១២ - តាំងពីញាណទី ៤ ដល់ ទី ១២ គឺ វិបស្សនាញាណ ទាំង ៩ ខាងលើ ។

១៣- **គោត្រភូញ្ញាណ** ញាណឆ្លងចាកគោត្របុថុជ្ជន ទៅកាន់គោត្រអរិយៈ ។

១៤- **មគ្គញ្ញាណ** ញាណ ក្នុងអរិយមគ្គទាំង ៤,

១៥- **ផលញ្ញាណ** ញាណ ក្នុងអរិយផលទាំង ៤,

១៦- **បច្ចវេក្ខណញ្ញាណ** ញាណ ពិចារណាពិនិត្យមើលមគ្គផល កិលេសដែលបានលះហើយ កិលេសដែលមិនទាន់បានលះ និង និព្វាន ។ ព្រះអរហន្ត មិនមានការពិចារណាកិលេសដែលមិនទាន់បានលះទេ ព្រោះលោកបានលះអស់រួចទៅហើយ ។

## សង្ខារ

**សង្ខារ** មានន័យថា ធម្មជាតិដែលបច្ច័យប្រជុំតាក់តែងក្នុងទីជាមួយគ្នា មានបទវិគ្គហៈ ថា **សំ ឯកតោ ករិយន្តីតិ សង្ខារា**

**រូបធម៌** និង **នាមធម៌** (*អរូបក្ខន្ធ ៤*) *ហ្នឹងឯង ដែលជាអារម្មណ៍របស់វិបស្សនា ។ រីឯ* **បញ្ញត្តិធម៌** *នោះ មិនមែនជាអារម្មណ៍របស់វិបស្សនាបញ្ញាឡើយ ។ ប៉ុន្តែលោកហៅថាជា* **ធម្មារម្មណ៍** *ជាអារម្មណ៍របស់ចិត្ត និង ចេតសិក ដែលកើតតាមមនោទ្វារ ។*

## ឈាន និង សមាបត្តិ

**ឈាន** និង **សមាបត្តិ** *មានអត្ថន័យផ្សេងគ្នា ។* **ឈាន** *សំដៅយក ការសំឡឹងកសិណ ឬ ការដុតកិលេស ។ រីឯ* **សមាបត្តិ** *សំដៅយកការចូល គឺ ចិត្តចូលក្នុងឈាននោះឯង ។ ប៉ុន្តែមានពេលខ្លះ លោកប្រើពាក្យថា សមាបត្តិ ជំនួសពាក្យថា ឈាន ក៏បានដែរ ។ ឧទាហរណ៍ដូចជាអ្នកបានសម្រេចសមាបត្តិ ៨ គឺ រូបជ្ឈាន ៤ អរូបជ្ឈាន ៤ ។ សមាបត្តិ មាន ៣ គឺ* **ឈានសមាបត្តិ ១ ផលសមាបត្តិ ១ និរោធសមាបត្តិ** ១ ។

**ឈានសមាបត្តិ** *គឺការចូលឈានដែលខ្លួនធ្លាប់បានហើយនោះ សាឡើងវិញ ដើម្បីសោយសេចក្តីសុខ ក្នុងឈាននោះ ។ ព្រោះឈានចិត្តដែលកើតឡើងគ្រាដំបូង (***អាទិកម្មិកឈាន***) បានតែមួយខណៈចិត្ត តែការចូលឈានសាឡើងវិញនេះ អប្បនាជវនៈ អាចកើតឡើងបាន មិនមានកំណត់ ស្រេចហើយតែសមត្ថភាព របស់បុគ្គលអ្នកបានសម្រេចឈាននោះ ។*

**ផលសមាបត្តិ** *គឺអប្បនា ក្នុងនិរោធនៃអរិយផល ។ ព្រះ*





*ក្នុងទីជាមួយគ្នា ក្នុងទីនេះ សំដៅយកសង្ខារ ២ យ៉ាង គឺ :*

១- **ឧបាទិន្នកសង្ខារ** *សង្ខារដែលមានវិញ្ញាណគ្រប់គ្រង បានដល់ អត្តភាព របស់មនុស្ស សត្វ ទេវតា ព្រហ្ម ជាដើម ។ បច្ច័យ របស់ សង្ខារនេះ មាន ៤ យ៉ាង គឺ អវិជ្ជា ១ តណ្ហា ១ កម្ម ១ អាហារ ១ ។*

២- **អនុបាទិន្នកសង្ខារ** *សង្ខារដែលគ្មានវិញ្ញាណគ្រប់គ្រង បានដល់ វត្ថុដែលលោកបញ្ញត្តិ ហៅថា កុដិ វិហារ សាលា កន្ទេល មុង ភួយ ព្រៃឈើ ភ្នំ ផ្កាឈូក ជាដើម ដែលអាស្រ័យនៅក្នុងលោកធាតុ ។*

**សង្ខារ** *មានន័យថាធម្មជាតិតាក់តែងនូវសង្ខតធម៌(បញ្ចក្ខន្ធ) ក្នុងទីនេះ សំដៅយកសង្ខារ ៣ យ៉ាង គឺ បុញ្ញាភិសង្ខារ ១ អបុញ្ញាភិសង្ខារ ១ អនេញ្ជាភិសង្ខារ ១ ។*

១- **បុញ្ញាភិសង្ខារ** *សង្ខារជាបុណ្យ បានដល់ កុសលចេតនា ទាំង ១៣ គឺ កាមាវចរកុសលចេតនា ៨ និង រូបាវចរកុសលចេតនា ៥ ។*

២- **អបុញ្ញាភិសង្ខារ** *សង្ខារមិនមែនជាបុណ្យ បានដល់ អកុសលចេតនាទាំង ១២ គឺ លោភមូល ៨ ទោសមូល ២ និង មោហមូល ២ ។*

៣- **អនេញ្ជាភិសង្ខារ** *សង្ខារមិនញាប់ញ័រ បានដល់*

រូបាវចរកុសលចេតនា ៤ ។ កុសលាកុសលចេតនា ទាំង ២៩ នេះ តាក់តែងសត្វលោកឲ្យកើតក្នុងសុគតិភព និង ទុគ្គតិភព ទើបលោកហៅថា **សង្ខារ** ។

សូម្បីខ្យល់អស្សាសៈបស្សាសៈ គឺខ្យល់ដកដង្ហើមចេញ-ចូល ដែលកើតអំពីចិត្ត ក៏លោកហៅថា **សង្ខារ** គឺ **កាយសង្ខារ** ព្រោះអវយវៈ មានដៃជើង ឬ សរីរៈទាំងមូល ដែលកំរើកញាប់ញ័រទៅបាន អាស្រ័យមានខ្យល់ អស្សាសៈ បស្សាសៈ នេះតាក់តែងឲ្យកំរើកឡើង ។

ម្យ៉ាងទៀត ពាក្យថា **សង្ខារក្ខន្ធ** (ក្នុងខន្ធ៥) មានន័យថា ក្រុមតាក់តែងនូវអារម្មណ៍ បានដល់ចេតសិក ៥០ គឺ ចេតសិក ទាំង ៥២ ដកយកវេទនាចេតសិក ១ សញ្ញាចេតសិក ១ ចេញទៅ សល់ ៥០ ចេតសិក ។ មិនមែនជាខន្ធសំរាប់ប្រតិកម្ម ដូចអ្នកខ្លះថានោះទេ ។

## **បញ្ញត្តិ** និង **បរមត្ថ**

**បញ្ញត្តិ** មានន័យថា ការបញ្ញត្តិ សេចក្តីបញ្ញត្តិ សេចក្តីហាមប្រាម សេចក្តីតែងតាំង មានវិគ្រោះថា **បញ្ញាបនំ បញ្ញត្តិ** ។

**បញ្ញត្តិ** បានដល់ សេចក្តីតែងតាំងនាមទៅលើ វត្ថុ សត្វ សង្ខារ និង ធម៌ដែលជាបរមត្ថ ។

**វត្ថុ** គឺរបស់ ដូចពាក្យថា ផ្ទះ កុដិ វិហារ សាលា ពែង





ប៉ាន់ សៀវភៅ ស្លាបព្រា ជាដើម ។

**សត្វ** គឺជនដែលគេជាប់ជំពាក់ក្នុងបំណង ដូចពាក្យថា គោ ក្របី ជ្រូក មាន់ ទា ជន្លេន ពូស្ពាយ ជាដើម ។

**សង្ខារ** គឺឧបាទិន្នកសង្ខារ សង្ខារដែលមានវិញ្ញាណគ្រប់គ្រង ដូចពាក្យថា បុគ្គល មនុស្ស ទេវតា ព្រហ្ម ជាដើម ។

**សង្ខារ** គឺអនុបាទិន្នកសង្ខារ សង្ខារដែលគ្មានវិញ្ញាណគ្រប់គ្រង ដូចពាក្យថា ដើមចេក ដើមដូង ដើមត្នោត ឈូក ព្រលិត ផ្កាកុលាប ផ្កាម្លិះ ស្មៅ ជាដើម ។

**បរមត្ថធម៌** ដែលមានសេចក្តីល្អិតក្រៃលែង ដូចពាក្យថា បឋវីធាតុ (ធាតុដី) អាបោធាតុ (ធាតុទឹក) តេជោធាតុ (ធាតុភ្លើង) វាយោធាតុ (ធាតុខ្យល់) ជាដើម ។ បុគ្គលកាលដឹង ចងចាំ ឃើញ ពោលនូវពាក្យ ដែលជាឈ្មោះទាំងអស់នេះ លោកហៅថា កាលដឹង កាលចាំ កាលឃើញ ពោលនូវ **បញ្ញត្តិធម៌** ។

**បរមត្ថធម៌** មកពី **បរម** + **អត្ថ** + **ធម៌** ។ **បរម** ប្រែថា ឧត្តម, ខ្ពង់ ខ្ពស់, ប្រសើរ, ក្រៃលែង ។ **អត្ថ** ប្រែថា ប្រយោជន៍, អាថ៌, សេចក្តី ។ ដូច្នេះ **បរមត្ថ** ប្រែថា ប្រយោជន៍ដ៏ឧត្តម, អាថ៌ដ៏ខ្ពង់ខ្ពស់, មានអត្ថយ៉ាងក្រៃលែង ។ បរមត្ថនោះ បានដល់រូបធម៌ ១ នាមធម៌ ១, **រូបក្ខន្ធ** គឺក្រុមរូប ២៨ លោកហៅថា **រូបធម៌** ។

**អរូបក្ខន្ធ** ៤ និង **និព្វាន** ១ ជា ៥ លោកហៅថា **នាមធម៌** ។

ដែរ តែលោកមិនទាន់ជា **សេក្ខៈ** ទេ លោកចាត់ជា **នេវសេក្ខនាសេក្ខៈ** គឺជា **សេក្ខៈ** ក៏មិនមែន ជា **អសេក្ខៈ** ក៏មិនមែន ។

បុថុជ្ជន សោយទុក្ខច្រើន, ព្រះអរិយៈ ជាន់ទាបនៅមានទុក្ខខ្លះដែរ តែតិច សំរាប់ព្រះអរិយៈ ជាន់ខ្ពស់បំផុត អស់ទុក្ខទាំងស្រុង ។ បុថុជ្ជន អន្ទោលកើតស្លាប់ ក្នុងវដ្តសង្សារគ្មានទីបំផុត ឯព្រះអរិយៈ អន្ទោលទៅ ក្នុងភពវដ្តសង្សារ យ៉ាងច្រើនត្រឹម ៧ ជាតិទៀត ត្រូវតែបានសម្រេចព្រះនិព្វាន ។ បុថុជ្ជន អាចវិលទៅកើតក្នុងកំណើតអបាយភូមិ នរក ប្រេត អសុរកាយ និង តិរច្ឆានក៏បាន, ចំណែកព្រះអរិយៈ មិនកើតក្នុងកំណើតអបាយភូមិ ជាដាច់ខាត យ៉ាងទាបបំផុត កើតត្រឹមមនុស្ស ទេវតា ។ល។

ដើម្បីលើកឋានៈ ពីបុថុជ្ជនទៅជាព្រះអរិយៈ ដើម្បីឆ្លងពីលោកិយៈ ទៅរកលោកុត្តរៈ មានផ្លូវបដិបត្តិតែមួយទេ គឺត្រូវតែចំរើនវិបស្សនា ។ ប៉ុន្តែ គេត្រូវខំបដិបត្តិឲ្យមែនទែន រហូតដល់កើតវិបស្សនាញាណ ទាំង ៩ បន្ទាប់ពីនោះ នឹងកើតគោត្រភូញាណ ។ បើអាចឆ្លងគោត្រភូញាណ ចូលដល់មគ្គញាណបាន ឈ្មោះថាបានឆ្លងពីបុថុជ្ជនទៅជាអរិយជន ឆ្លងពី **លោកិយ** ទៅរក **លោកុត្តរ** ។

គួរសង្កេតភាពខុសគ្នាបន្តិចបន្តួច រវាងបុគ្គលអ្នកបានសំរេចសោតាបត្តិមគ្គ និង អ្នកបានសំរេចសោតាបត្តិផល ។ ក្នុងខណៈ





អរិយបុគ្គលគ្រប់ថ្នាក់ អាចចូលផលសមាបត្តិដើម្បីសោយសេចក្ដីសុខស្រដៀងគ្នានឹងព្រះនិព្វាន ក្នុងជីវិតបច្ចុប្បន្ននេះបាន តាមថ្នាក់របស់ខ្លួន ដែលខ្លួនបានសម្រេចហើយ ។ ចំណែកបុថុជ្ជនមិនអាចចូលផលសមាបត្តិបានទេ ព្រោះខ្លួនមិនដែលកើតមគ្គញាណ មិនធ្លាប់មានព្រះនិព្វានជាអារម្មណ៍ ។

**និរោធសមាបត្តិ** ការចូល ឬ សេចក្ដីព្យាយាម ហៅថា សមាបត្តិ, ការរលត់ចិត្តនិងចេតសិក ហៅថា និរោធ ។ រូប និង នាម ជាការៈមួយដ៏ធ្ងន់ ដោយមានចំណង់ចង់ដាក់ចុះនូវការៈនោះមួយរយៈពេល ទើបលោកចូលនិរោធសមាបត្តិ ។

**និរោធសមាបត្តិ** មិនមែនចេះតែចូលបានគ្រប់គ្នាទេ **ព្រះសោតា ព្រះសកិទាគា** មិនអាចចូលនិរោធសមាបត្តិបានទេ ព្រោះលះនូវកាមច្ឆន្ទ ដែលជាអនុស័យមិនទាន់អស់ សមាធិ មិនទាន់ខ្លាំងក្លាមែនទែន មានតែ **ព្រះអរហន្ត** ឬ យ៉ាងទាប **ព្រះអនាគាមី** ទេ ដែលអាចចូលនិរោធសមាបត្តិបាន ។

## អភិញ្ញា

**អភិញ្ញា** គឺបញ្ញាដឹងពិសេសអស្ចារ្យ ដែលកើតអំពីកម្លាំងនៃឈាន មាន ៦ ប្រការ គឺ :

១- **ឥទ្ធិវិធី** សំដែងឫទ្ធិផ្សេងៗបាន,

២- **ទិព្វសោត** ត្រចៀកទិព្វ,

៣- **ចេតោបរិយញ្ញាណ** ដឹងចិត្តអ្នកដទៃបាន,

៤- **បុព្វេនិវាសានុស្សតិ** រឭកជាតិបាន,

៥- **ទិព្វចក្ខុ** (ចតូបបាតញ្ញាណ) ភ្នែកទិព្វ,

៦- **អាសវក្ខយញ្ញាណ** ញាណគឺការក្ស័យអស់អាសវៈ ។

## **បុថុជ្ជន** និង **អរិយជន**

ពាក្យថា **បុថុជ្ជន** មានពីរបទ គឺ **បុថុ** ប្រែថាច្រើន, ក្រាស់ក្រៃ + **ជន** ប្រែថា អ្នកមានកិលេសក្រាស់ គឺលះសំយោជនៈ (កិលេសជាគ្រឿងចង សត្វឲ្យជាប់ក្នុងភពនៃសង្សារវដ្ដ) មិនទាន់បាន ។ បុថុជ្ជន មានពីរពួក គឺ :

១- **អន្ធបុថុជ្ជន** បុថុជ្ជន ងងឹតងងល់ មិនយល់បាបបុណ្យ គុណទោស មិនស្វែងរកធម៌អាថ៌ ។

២- **កល្យាណបុថុជ្ជន** បុថុជ្ជនល្អ មានសីលធម៌ ចេះធ្វើទាន រក្សាសីល ចំរើនភាវនា សមថៈ វិបស្សនា ។

ពាក្យថា **អរិយជន** មានពីរបទ គឺ **អរិយ** ប្រែថា ប្រសើរ + **ជន** ប្រែថា ជនអ្នកចេញចាកសត្រូវពោលគឺកិលេស ឬ ប្រែថា អ្នកប្រសើរ អ្នកខ្ពង់ខ្ពស់ ។ អរិយជន បើរាប់ជាគូ មាន ៤ គូ គឺ អ្នកបានសម្រេច :

-**សោតាបត្តិមគ្គ** **សោតាបត្តិផល** ជាគូ ១,

-**សកទាគាមិមគ្គ** **សកទាគាមិផល** ជាគូ ១,





-**អនាគាមិមគ្គ** **អនាគាមិផល** ជាគូ ១,

-**អរហត្តមគ្គ** **អរហត្តផល** ជាគូ ១ ។

បើរាប់រៀងជាបុរសបុគ្គល មាន ៨ គឺ អ្នកបានសំរេច **សោតាបត្តិមគ្គ** ១ **សោតាបត្តិផល** ១, **សកទាគាមិមគ្គ** ១ **សកទាគាមិផល** ១, **អនាគាមិមគ្គ** ១ **អនាគាមិផល** ១, **អរហត្តមគ្គ** ១ **អរហត្តផល** ១ ។ បើចាត់ពួក មានពីរពួក គឺ ៧ ខាងដើមជា **សេក្ខៈ**, ១ ខាងចុង (អរហត្តផល) ជា **អសេក្ខៈ** ។

**សេក្ខៈ** ប្រែថា អ្នកនៅមានការសិក្សា ។ **អសេក្ខៈ** ប្រែថា អ្នកអស់ការសិក្សា ។ ពាក្យថា សិក្សា ក្នុងភាសាបាលី មិនមែនសំដៅយកត្រឹមតែការរៀនសូត្រនូវទ្រឹស្ដី (បរិយត្តិ) តែម្យ៉ាងទេ សំដៅយករហូតដល់ការអនុវត្តន៍ (បដិបត្តិ) ផង ។ សំរាប់អ្នកសិក្សាក្នុងទីនេះ មានន័យពិសេស សំដៅយកយ៉ាងទាបត្រឹមព្រះសោតាបត្តិមគ្គ ជាដើមឡើងទៅ ដែលកំពុងតែសិក្សា កំចាត់សំយោជនៈ តទៅទៀត ។ ចំណែក **អសេក្ខៈ** អ្នកអស់ការសិក្សា ដើម្បីកំចាត់នូវកិលេស ព្រោះកិលេសទាំងឡាយ មានសំយោជនៈជាដើម លោកបានលះបង់អស់ ជាសមុច្ឆេទប្បហានហើយ ។ **អសេក្ខៈ** សំដៅយកចំពោះតែព្រះអរហន្តប៉ុណ្ណោះ ។ ឯ **បុថុជ្ជន** ពិតមែនតែខិតខំរៀនសូត្រ ដើម្បីកំចាត់បង់ នូវកិលេស

**អរហត្ត** នោះ ជាឈ្មោះនៃផល ទី ៤ ។ **មគ្គ** ជាហេតុ នៃព្រះអរហត្តនោះ ឈ្មោះថា **អរហត្តមគ្គ** ។ ចិត្តដែលសម្បយុត្ត ដោយអរហត្តមគ្គនោះ ឈ្មោះថា **អរហត្តមគ្គចិត្ត** ។

មគ្គ ៤ ដួងនោះ ចាត់ជាលោកុត្តរកុសល ។

ពាក្យថា **លោកុត្តរកុសល** នេះ ព្រោះជាកុសលដែលធ្វើឲ្យឆ្លងផុត ចាកលោក ៣ គឺៈ កាមលោក ១ រូបលោក ១ អរូបលោក ១ ។

ន័យមួយទៀត ពាក្យថា **លោកុត្តរកុសល** នេះ ព្រោះជាកុសលដែលធ្វើឲ្យឆ្លងផុតពី **បុថុជ្ជន** ទៅជា **អរិយបុគ្គល** ។

ន័យមួយទៀត ពាក្យថា **លោកុត្តរកុសល** នេះ ព្រោះជាកុសលដែលកើតឡើង មានព្រះនិព្វានដែលជាលោកុត្តរធម៌ ជាអារម្មណ៍ ។

ន័យមួយទៀត ពាក្យថា **លោកុត្តរកុសល** នេះ ព្រោះជាកុសលដែលមានអំណាច ផុតលើសពីកុសល ជាលោកិយៈទាំងឡាយ រំលត់អកុសលឲ្យដាច់ជាសមុច្ឆេទបាន ។

## **និព្វាន** និង **បរិនិព្វាន**

ពាក្យថា **និព្វាន** មកពីពាក្យថា **និ** + **វាន**, **និ** ប្រែថា ចេញ, ចេញផុត, ចេញផុតស្រឡះ, អស់, ឥត ។ រីឯ **វាន** ជាឈ្មោះតួតណ្ហា ដែលចាក់ស្រែះ, ទាក់ថ្វាក់, រួបរឹត នៅក្នុង





ដែលមគ្គចិត្ត ឬ មគ្គញាណ កើតឡើងកំចាត់សំយោជនកិលេស ៣ ខាងដើម អស់ទៅ បុគ្គលនោះ ឈ្មោះថា បានសំរេចសោតាបត្តិមគ្គ ។ ក្នុងខណៈដែលមគ្គចិត្ត រលត់ទៅ ផលចិត្ត ឬ ផលញ្ញាណ ដែលជាវិបាកកើតឡើងភ្លាម ដោយមិនរង់ចាំពេលវេលា និង មិនមានអ្វីខណ្ឌក្នុងចន្លោះ បុគ្គលនោះ ឈ្មោះថា បានសំរេចសោតាបត្តិផល ។ មគ្គចិត្ត ឬ មគ្គញាណ កើតបានតែម្តងទេ ព្រោះកិលេសត្រូវកំចាត់អស់ជាសមុច្ឆេទប្បហានហើយ មិនមានអ្វីនឹងត្រូវកំចាត់ទៀតទេ ។ ឯផលចិត្ត ឬ ផលញ្ញាណ អាចកើតឡើងច្រើនដងបាន ព្រោះត្រូវការចូលផលសមាបត្តិ តាមកាលដ៏សមគួរ ។

## **លោកុត្តរកុសលចិត្ត**

**សោតាបត្តិមគ្គចិត្តំ សកទាគាមិមគ្គចិត្តំ**
**អនាគាមិមគ្គចិត្តំ អរហត្តមគ្គចិត្តញ្ចេតិ**
**ឥមានិ ចត្តារិបិ លោកុត្តរកុសលចិត្តានិ នាម** ។

ប្រែថាៈ សោតាបត្តិមគ្គចិត្ត ១ ដួង សកទាគាមិមគ្គចិត្ត ១ ដួង អនាគាមិមគ្គចិត្ត ១ ដួង អរហត្តមគ្គចិត្ត ១ ដួង, ចិត្តទាំង ៤ ដួងនេះ ឈ្មោះថា លោកុត្តរកុសលចិត្ត ។

## **សោតាបត្តិមគ្គចិត្ត**

ពាក្យថា **សោតាបត្តិមគ្គចិត្ត** គឺ **សោត** + **អាបត្តិ** + **មគ្គ** +

**ចិត្ត** = **សោតាបត្តិមគ្គចិត្ត** ។

**សោត** ប្រែថា ក្រសែ គឺថា អរិយមគ្គមានអង្គ ៨ បណ្ឌិត ហៅថា សោត ដោយហូរជំរង់ទៅ គឺចូលកាន់ព្រះនិព្វាន ឬ ដូច ជាក្រសែទឹក ដោយការហូរទៅកាន់សមុទ្រ គឺព្រះនិព្វាន ។

**អាបត្តិ** ប្រែថា ការដល់ហើយ គឺ ការសំរេចតាំងពីខាងដើម ជាការសេពគ្រាដំបូងនូវសោតនោះ ។

**មគ្គ** មានន័យថា ការស្វែងរកព្រះនិព្វាន ឬ ផ្លូវព្រះនិព្វាន ត្រូវស្វែងរក ឬ មានន័យថា ផ្លូវជាទីទៅសម្លាប់កិលេសទាំង ឡាយ ។

ចិត្ត ដែលសម្បយុត្តជាមួយមគ្គនោះ ឈ្មោះថា **មគ្គចិត្ត** ។

មគ្គចិត្ត ដែលបានសំរេចក្រសែគ្រាដំបូង ឈ្មោះថា **សោតាបត្តិមគ្គចិត្ត** បានដល់មគ្គចិត្ត របស់ព្រះអរិយបុគ្គល ថ្នាក់ដំបូង ដែលមានបដិសន្ធិទៀត យ៉ាងច្រើន ៧ ជាតិ ក្នុងលោកនេះ ។

## សកទាគាមិមគ្គចិត្ត

ពាក្យថា **សកទាគាមិមគ្គចិត្ត** គឺ **សកឹ** + **អាគាមី** + **មគ្គ** + **ចិត្ត** = **សកទាគាមិមគ្គចិត្ត** ។

**សកឹ** ប្រែថា មួយដង មួយវារៈ,

**អាគាមី** ប្រែថា ត្រឡប់មក,

**សកទាគាមិមគ្គចិត្ត** គឺមគ្គចិត្តដែលញុំាងឲ្យបុគ្គលត្រឡប់





មកកាន់កាមលោកម្តងទៀត បានដល់ចិត្តរបស់ព្រះអរិយបុគ្គល ថ្នាក់ទី ២ ដែលត្រឡប់មកបដិសន្ធិ ក្នុងកាមភូមិតែម្តងប៉ុណ្ណោះ ។

## អនាគាមិមគ្គចិត្ត

ពាក្យថា **អនាគាមិមគ្គចិត្ត** គឺ **ន** = **អន** + **អាគាមី** + **មគ្គ** + **ចិត្ត** = **អនាគាមិមគ្គចិត្ត** ។

**អនាគាមិមគ្គចិត្ត** គឺ ចិត្តដែលញុំាងឲ្យបុគ្គលមិនចាំបាច់ ត្រឡប់មកកាន់កាមលោក សូម្បីតែម្តងទៀតនោះទេ បានដល់ មគ្គចិត្ត របស់ព្រះអរិយបុគ្គល ថ្នាក់ទី ៣ ដែលមិនត្រូវមក បដិសន្ធិ ក្នុងកាមលោក ។

## អរហត្តមគ្គចិត្ត

ពាក្យថា **អរហត្តមគ្គចិត្ត** គឺ **អរហត្ត** + **មគ្គ** + **ចិត្ត** = **អរហត្តមគ្គចិត្ត** ។

ឈ្មោះថា **ព្រះអរហន្ត** ដោយអត្ថថា គួរដល់ការបូជា វិសេស ព្រោះភាពជាទក្ខិណេយ្យបុគ្គល ដ៏កំពូល ។ ម្យ៉ាងទៀត ឈ្មោះថា **អរហន្ត** ដោយអត្ថថា កាំ (កាំកង់ដែលវិលទៅ) គឺ កិលេស ឬ កិលេសដែលជាកាំនៃសង្សារចក្រ ត្រូវលោកកាត់ បំបាក់អស់ហើយ ។ ម្យ៉ាងទៀត ឈ្មោះថា **អរហន្ត** ព្រោះមិន មានការត្រឡប់មកធ្វើបាបកម្មទេ បានដល់ ព្រះអរិយបុគ្គល ថ្នាក់ ទី៤ ។ ភាវៈនៃបុគ្គល ទី៤ នោះ ឈ្មោះថា **អរហត្ត** ។ ពាក្យថា

ជា **ឯកន្តសុខ, បរមសុខ, និរាមិសសុខ** ។

ពាក្យថា **ឯកន្តសុខ** ប្រែថា សុខតែម្យ៉ាង ពីព្រោះសភាពវត្ថុក្នុងលោកតែងមានគូៗ គ្នា ។ បើមានសុខហើយ តែងមានទុក្ខផង, មានក្ដៅតែងមានត្រជាក់, មានល្អតែងមានអាក្រក់, មានសតែងមានខ្មៅ, មានបាប តែងមានបុណ្យ, មានគុណ តែងមានទោស ។ ចំណែកព្រះនិព្វាន គ្មានគូ លោកប្រើពាក្យថា **ឯកន្តៈ** ប្រែថា សុខតែម្យ៉ាង សុខតែចំណែកមួយ គ្មានលាយឡំ ដោយទុក្ខឡើយ ។ នៅក្នុងលោក មានសុខហើយ ប្រែជាទុក្ខវិញ ចំណែកព្រះនិព្វានគ្មានទុក្ខទេ បានជាលោកប្រើពាក្យថា **ឯកន្តសុខ** ប្រែថា សុខតែម្យ៉ាង ។

ពាក្យថា **បរមសុខ** មានពីរបទ គឺ **បរម** + **សុខ** ។ **បរម** ប្រែថា ប្រណីត, ក្រៃលែង, ឧត្ដម រួមមកបានន័យថា សុខដ៏ល្អិតដ៏ក្រៃលែងសុខរកគូប្រដូចគ្មាន ។ នៅក្នុងត្រៃលោក គឺកាមលោក រូបលោក អរូបលោក លោកប្រើពាក្យថា **សុខ** តែមួយម៉ាត់ ប៉ុន្តែព្រះនិព្វាន លោកបន្ថែមពាក្យមួយទៀតថា **បរមសុខ** ។ បានជាលោក ប្រើពាក្យថា បរមសុខ ព្រោះព្រះនិព្វានជាសុខដ៏ក្រៃលែង សុខដ៏ប្រសើរ សុខដ៏ប្រណីត សុខដ៏ឧត្ដម គ្មានទុក្ខមកជ្រៀតជ្រែកបាន ជាសុខដែលព្រះអរិយបុគ្គលទាំងឡាយ មានព្រះពុទ្ធជាដើមប្រាថ្នា ។





សន្ដានចិត្តសត្វ ។ ផ្លាស់ **វ** ជា **ព** តម្រួត **ព** ជា **ព្វ** = **និព្វាន** មានអត្ថន័យថា ធម្មជាតិ ឬ ចិត្តដែលចេញផុតស្រឡះ ចាកតណ្ហា ជាគ្រឿងចាក់ស្រែះរួបរឹត នៅក្នុងសន្ដានចិត្តសត្វ ។ ក្នុងអរិយសច្ច ៤ លោកមិនប្រើពាក្យ **និព្វាន** ទេ គឺលោកប្រើពាក្យ **និរោធ** ប្រែថា ការរលត់ទុក្ខ ដោយគ្មានសេសសល់ ។

បញ្ហា **និព្វាន** ជាបញ្ហាជ្រាលជ្រៅហើយមានអាថ៌កំបាំងផងដែលអ្នកសិក្សាស្រាវជ្រាវ ពុំងាយយល់បាន ដោយស្រួលឡើយ ព្រោះព្រះនិព្វាន ចេញផុតអំពី **សង្ខតធម៌** ។ **សង្ខតធម៌** គឺអ្វីៗទាំងអស់ ក្នុងលោក មានវិញ្ញាណក្ដី ឥតវិញ្ញាណក្ដី កើតឡើងពីហេតុបច្ច័យគ្រឿងផ្សំ ដែលហៅថា **សង្ខារ** ។ ចំណែកព្រះនិព្វាន ជា **អសង្ខតធម៌** ឬ **វិសង្ខារធម៌** ចេញផុតពីហេតុបច្ច័យជាគ្រឿងផ្សំ ពុំអាចឲ្យវិទ្យាសាស្ត្រខាងសម្ភារៈធ្ងុះ មើលឃើញឡើយ ប៉ុន្តែគេអាចសម្រេច និង យល់ច្បាស់ចាក់ធ្ងុះ នូវនិព្វានបាន ដោយផ្លូវវិបស្សនា ព្រោះវិបស្សនានាំឲ្យកើតវិបស្សនាបញ្ញា ឬវិបស្សនាញាណ ចាក់ធ្ងុះនូវព្រះនិព្វាន បាលីថា **បដិវេធធម៌** ។

**បរិនិព្វាន** មកពីពាក្យថា **បរិ** + **និព្វាន**, **បរិ** ជាបុព្វបទ ប្រែថា គ្មានសល់ រួមមកបានន័យថា ការរលត់កិលេស ដោយគ្មានសេសសល់ ដោយដាច់ឫសគល់ ជាសមុច្ឆេទប្បហានៈ ។ ពាក្យថា **បរិនិព្វាន** នេះ ប្រើបានចំពោះតែព្រះអរហន្តទាំងឡាយ

មានព្រះពុទ្ធជាដើម ព្រោះលោកទាំងនោះ រលត់កិលេសអស់គ្មានសេសសល់ ចំណែកអរិយជនថ្នាក់ **សោតា សកទាគា អនាគា** ដែលក្នុងសំយោជនកិលេសលះមិនទាន់អស់ ទើបលោកឲ្យឈ្មោះត្រឹម **និព្វាន** មិនទាន់ឲ្យឈ្មោះថា **បរិនិព្វាន** ឡើយ តែលោកបានឈ្មោះ **និព្វានចិត្ត** រួចហើយ ។ **បរិនិព្វាន** លោកចែកចេញជាពីរបែបគឺ **ឧបាទិសេសនិព្វាន** និង **អនុបាទិសេសនិព្វាន** ។

**ឧបាទិសេសនិព្វាន** បានដល់ព្រះអរហន្តដែលរលត់កិលេសជាសមុច្ឆេទប្បហានៈ ក៏ប៉ុន្តែ នៅមានខន្ធ ៥ ។ ខន្ធ ៥ នេះ ជាតួវិបាកខន្ធ ប៉ុន្តែ អាយតនៈក្តី ផស្សៈក្តី វេទនាក្តី ដែលកើតឡើងមិនបង្កើតជាបុណ្យជាបាបទេ ម៉្លោះហើយខន្ធមានដូចជាគ្មាន បានជាលោកថា លោកបានបរិនិព្វានរួចហើយ ។ **ឧបាទិសេសនិព្វាន** នេះ ជួនកាល លោកហៅថា **កិលេសនិព្វាន** ព្រោះរលត់តែកិលេស នៅសល់ខន្ធ ៥ ។

**អនុបាទិសេសនិព្វាន** ប្រែថា រលត់ទាំងកិលេសរលត់ទាំងខន្ធ បានសេចក្តីថា កិលេសរលត់គ្មានសេសសល់ រីឯខន្ធ ជាវិបាកខន្ធចាស់នោះ ក៏រលត់ទៅទៀត ដោយគ្មានសេសសល់ ។ **អនុបាទិសេសនិព្វាន** ជួនកាល លោកហៅថា **ខន្ធនិព្វាន** ព្រោះរលត់ទាំងកិលេសទាំងខន្ធ ។

**កិលេសនិព្វាន** គឺលោកបានលះកិលេសរួចហើយៗ បាន





និព្វាន ចាប់តាំងពីនៅរស់ម៉្លេះ មិនមែនដល់ពេលស្លាប់ ទើបឈ្មោះថាបាននិព្វានទេ ។ ដំណើរព្រះអរហន្ត ដែលលោកសំរេចព្រះនិព្វាននោះ គឺទុក្ខណា ដែលប្រព្រឹត្តទៅតាមផ្លូវចិត្ត លោកលះបង់បានដោយដាច់ខាត ដូចជាទោមនស្ស សោមនស្ស ប្រកបដោយកាម ដោយកិលេសជាដើម ប៉ុន្តែទុក្ខវេទនាផ្លូវកាយ ពេលលោករស់នៅលោកទទួលការឈឺចាប់ដូចមនុស្សធម្មតាដែរ ។

ព្រះអរហន្ត ប្រើប្រាស់បច្ច័យ ៤ ដូចបុថុជ្ជនដែរ ក៏ប៉ុន្តែ ព្រះទ័យ លោកមិនជាប់ជំពាក់ ដូចបុថុជ្ជនឡើយ ។ ព្រះពុទ្ធជាម្ចាស់ប្រើប្រាស់ បច្ច័យ ៤ ព្រះអង្គគង់នៅក្នុងកុដិ ស្លៀកស្បង់គ្រងចីវរ ឆាន់ចង្ហាន់ ប្រើថ្នាំកែរោគ ប៉ុន្តែ ព្រះទ័យព្រះអង្គ ពុំជាប់ជំពាក់ឡើយ ទោះបីវត្ថុទាំងនោះត្រូវវិនាស ក៏ព្រះអង្គគ្មានទោមនស្ស ឬសោមនស្សឡើយ ព្រោះព្រះអង្គបានលះបង់នូវទោមនស្ស និងសោមនស្សអស់ហើយ ។ ពាក្យថា **លះ** ក្នុងទីនេះ បានន័យថា ឃើញទោសក្នុងវត្ថុទាំងឡាយ គឺលះផ្លូវចិត្ត ប៉ុន្តែ បច្ច័យទាំង ៤ ដែលត្រូវអាស្រ័យ ដើម្បីឲ្យជីវិតប្រព្រឹត្តបានស្រួល លោកនៅតែប្រើប្រាស់ នៅតែមានដដែល គ្រាន់តែមានព្រះទ័យផ្សេងពីមនុស្សធម្មតាប៉ុណ្ណោះ ។

ព្រះអរហន្តទាំងឡាយ មានព្រះពុទ្ធជាដើម ទ្រង់ខិតខំដឹកនាំសត្វទាំងអស់គ្នា ឲ្យបានសំរេចព្រះនិព្វាន ពីព្រោះព្រះនិព្វាននោះ

**ចត្តារោ សតិបដ្ឋានា** ។

ម្នាលភិក្ខុទាំងឡាយ ផ្លូវគឺសតិបដ្ឋានទាំង ៤ នេះ ជាផ្លូវមូល តែមួយ (ប្រព្រឹត្តទៅ) ដើម្បីសេចក្តីបរិសុទ្ធិ នៃសត្វទាំងឡាយ ដើម្បីលះបង់នូវសេចក្តីសោក និង សេចក្តីខ្សឹកខ្សួល ដើម្បីរំលត់ សេចក្តីទុក្ខ និង ទោមនស្ស ដើម្បីបាននូវអរិយមគ្គ ប្រកបដោយ អង្គ ៨ ប្រការ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន" ។

## សតិបដ្ឋាន ៤ នោះ គឺ ៖

១- **កាយានុបស្សនា** សតិរឭកពិចារណាកាយជាអារម្មណ៍,

២- **វេទនានុបស្សនា** សតិរឭកពិចារណាវេទនាជាអារម្មណ៍,

៣- **ចិត្តានុបស្សនា** សតិរឭកពិចារណាចិត្តជាអារម្មណ៍,

៤- **ធម្មានុបស្សនា** សតិរឭកពិចារណាធម៌ជាអារម្មណ៍ ។

គួរកត់សម្គាល់ថា ក្នុងសមថកម្មដ្ឋាន ធម៌ជាអារម្មណ៍សំរាប់ តំកល់ចិត្តឲ្យស្ងប់ ឬ ធម៌ជាបង្គោល សំរាប់ចងក្រៀកចិត្ត ឲ្យនឹង មាន ៤០ ។ ក្នុងវិបស្សនាកម្មដ្ឋាន ធម៌ជាភូមិសំរាប់តំកល់សតិ ហើយពិចារណាឲ្យកើតបញ្ញា មាន ៧៣ ។ ក្នុងសតិបដ្ឋាន ធម៌ជា អារម្មណ៍ មានត្រឹមតែ ៤ ប៉ុណ្ណោះ ដែលស្តាប់ឮទៅ ហាក់ដូច ជាតិច មិនគ្រប់គ្រាន់ ប៉ុន្តែសតិបដ្ឋាន មានអារម្មណ៍ត្រឹមតែ ៤ ប៉ុណ្ណឹង គ្រប់គ្រាន់បរិបូណ៌ហើយ ព្រោះថា អ្វីជារូបធម៌ ចាត់ចូល





ពាក្យថា **និរាមិសសុខ** គឺ **និ** = ប្រាសចាក + **អាមិស** = នុយ + **សុខ** = **និរាមិសសុខ** ប្រែថាសុខប្រាសចាកអាមិស បាន ដល់ព្រះនិព្វាន ។

ពាក្យផ្ទុយនឹង **និរាមិសសុខ** គឺ **អាមិសសុខ** ដែលជាសុខ ជាប់ទាក់ទង ដោយហេតុជាសង្ខតធាតុ ។ **អាមិស** ប្រែថា នុយ អន្ទាក់របស់ចិត្ត ទោះបីអ្នកកើត ក្នុងអរូបព្រហ្ម ជាព្រហ្មជាន់ ខ្ពស់ក៏ដោយ ប៉ុន្តែ ជាប់ក្នុងឈានរបស់ខ្លួន លោកចាត់ទុកជា **អាមិស** ។ ដូច្នេះ **អាមិស** ជាសុខ មាននុយគ្រឿងបញ្ឆោត សុខ ដោយមានឈានជាលក្ខណ្ឌ គឺថា បើអ្នកបានសំរេចឈានជាន់ ខ្ពស់ នៅពេលដែលអស់អំណាចឈានចិត្ត របស់ខ្លួន ក៏ត្រូវធ្លាក់ មកវិញ ទើបលោកហៅថា **អាមិស** ។ ដូចជាសុខរបស់កាមាវចរ សត្វ គឺបានសុខ ដោយការប៉ះអារម្មណ៍ ភ្នែកប៉ះនឹងរូប កើត ចក្ខុវិញ្ញាណ ដឹងថា រូបស្អាត ក៏ជាប់ចិត្តស្រឡាញ់ រូបអាក្រក់ ក៏កើតចិត្តទោមនស្សឡើង ។ ចំណែកព្រះនិព្វាន ដែលហៅថា **និរាមិសសុខ** គឺ ជាសុខប្រាសចាកនុយ ប្រាសចាកហេតុបច្ច័យ ទាំងអស់នេះ ឬក៏ ចេញផុតអំពីដៃរបស់ពួកមារ ។ មារក្នុងទី នេះ បានដល់ខន្ធមារ កិលេសមារជាដើម។ ព្រះនិព្វានជាសុខគ្មាន ហេតុបច្ច័យ ចិត្តពុំជាប់ក្នុងភពណាមួយឡើយ ទើបលោកហៅថា

**និរាមិសសុខ** គឺសុខប្រាសចាកអាមិស ។

**និព្វាន** លោកហៅថា សូន្យ គឺសូន្យនូវ អវិជ្ជា សង្ខារ កិលេស តណ្ហា ខន្ធ ។ អភិធម្មបិដក ពណ៌នាពន្យល់ពាក្យ និព្វាន ថា ការរលត់រលាយអស់ ជាសមុច្ឆេទប្បហាន នៃតណ្ហា (តណ្ហក្ខយ) ទោសៈ (ទោសក្ខយ) មោហៈ (មោហក្ខយ) ។

**និព្វាន** លោកហៅថា មិនសូន្យ គឺ និព្វាន មានសល់ ផលញ្ញាណ ជាពន្លឺ ជាគ្រឿងទ្រទ្រង់ ហៅថា លោកុត្តរផល ។ ផលញ្ញាណ គឺជាតួបញ្ញា (វិបស្សនាបញ្ញា ឬ វិបស្សនាញាណ) ដែលចាក់ធ្លុះ (បដិវេធ) វាំងនន គឺអវិជ្ជា ឃើញច្បាស់ ដោយ បញ្ញាញាណ នូវសច្ចធម៌ និង ត្រៃលក្ខណធម៌ ។ ដូច្នេះហើយ ទើបលោកពោលថា ៖

**តេសំ វូបសមោ សុខោ** ។

ការរំងាប់នូវសង្ខារទាំងឡាយនោះ នាំមកនូវសេចក្តីសុខ ។

**និព្វានំ បរមំ សុខំ**

និព្វាន ជាសុខយ៉ាងក្រៃលែង ។

ដរាបណា អដ្ឋង្គិកមគ្គ ដែលរួមជា សីល សមាធិ បញ្ញា វិបស្សនា សតិបដ្ឋាន នៅស្ថិតស្ថេរជាធរមាន ដរាបនោះ មគ្គ ផល និព្វាន និង ព្រះពុទ្ធសាសនា តែងនៅមានជាដរាប ទោះមាន ព្រះពុទ្ធក្តី អត់មានព្រះពុទ្ធក្តី ។

✻ ✻



# សតិបដ្ឋាន

សតិបដ្ឋាន មកអំពីពាក្យថា **សតិ** + **ប** + **ដ្ឋាន** = **សតិបដ្ឋាន** ។ **សតិ** ប្រែថា ការចងចាំ ការនឹកឃើញ សតិដឹង គឺ ដឹងអំពីបច្ចុប្បន្នកាលនេះ មិនមែនការនឹកឃើញអំពីអតីតកាល ឬ ការយល់សប្តិពីអនាគតទេ ។ **ប** ជាបុព្វបទ មានន័យថា ដោយ ទូលំទូលាយ, ដោយប្រាជ្ញា ។ **ដ្ឋាន** បានសេចក្តីថា ទីតាំង ដូច្នេះ ពាក្យថា **សតិបដ្ឋាន** មានន័យថា ធម៌ជាទីតាំងនៃសតិ ឬ ធិម ជាទីកន្លែងសម្រាប់តំកល់សតិ ដោយប្រើប្រាជ្ញា ឬ ធម៌ជាទីតាំង ស៊ុប របស់សតិ ដោយប្រើប្រាជ្ញា ។

សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅជាមួយជនជាតិ **កុរុ** នៅ **កម្មាសធម្ម** ជាទីផ្សាររបស់អ្នកកុរុ ក្នុងដែន **កុរុ** ។ ដែន **កុរុ** ឬ **រដ្ឋកុរុ** សព្វថ្ងៃ គេហៅថា រដ្ឋ **ហារីយានា** (HARIYANA) នៅជិតទីក្រុងញ៉ូដែល្ហី (NEW DEHLI) ដែលជារដ្ឋធានីនៃប្រទេស ឥណ្ឌា ។ នៅគ្រានោះឯង ព្រះមានព្រះភាគ ទ្រង់ត្រាស់នឹងភិក្ខុ ទាំងឡាយ យ៉ាងដូច្នេះ ថា ៖

**ឯកាយនោ អយំ ភិក្ខវេ មគ្គោ សត្តានំ វិសុទ្ធិយា សោកបរិទេវានំ សមតិក្កមាយ ទុក្ខទោមនស្សានំ អត្ថង្គមាយ ញាយស្ស អធិគមាយ និព្វានស្ស សច្ឆិកិរិយាយ យទិទំ**

ឯណានីមួយនៃបព្វៈទាំង ៦ ក្តី ហៅថា កាយ បានទាំងអស់ ។ ក្នុងសតិបដ្ឋាន មានពាក្យថា **កាយេ កាយានុបស្សី** ជាអ្នកឃើញរឿយៗ នូវកាយក្នុងកាយ..។ ពាក្យថា **កាយ** ក្នុង **កាយ** សំដៅដល់កាយមានច្រើនបព្វៈ ច្រើនបែបឬផ្នែក ។ យោគាវចរមិនមែនលើកយកមកពិចារណាព្រមគ្នាតែម្តងទាំង ៦ បព្វៈនោះទេ គេលើកយកមកពិចារណាម្តងមួយៗ គឺពិចារណាកាយណាឃើញកាយនោះ ក្នុងចំណោយកាយទាំង ៦ មិនមែនឃើញកាយដទៃដែលមិនបានលើកយកមកពិចារណានោះទេ ។ បើនិយាយឲ្យស្រួលស្តាប់ ពាក្យថា ពិចារណារឿយៗ កាយក្នុងកាយ មានន័យថា ពិចារណារឿយៗ នូវកាយណាមួយ ក្នុងបណ្តាកាយទាំង ៦ (បព្វៈទាំង ៦) ។

យើងប្រទះឃើញជាញឹកញាប់ ក្នុងសតិបដ្ឋាន នូវពាក្យថា **អជ្ឈត្តំ វា ពហិទ្ធា វា កាយេ កាយានុបស្សី** ... ជាអ្នកឃើញរឿយៗ នូវកាយក្នុងកាយ ឰដ៏ខាងក្នុង ឬ ឰដ៏ខាងក្រៅ ។ ព្រះអដ្ឋកថាចារ្យ ពន្យល់ថា **អជ្ឈត្ត** ឰដ៏ខាងក្នុង គឺកាយរបស់ខ្លួន **ពហិទ្ធា** ឰដ៏ខាងក្រៅ គឺកាយរបស់បុគ្គលដទៃ ។

### ១- **អានាបាណបព្វៈ**

ភិក្ខុក្នុងសាសនានេះ ទៅនៅក្នុងព្រៃក្តី នៅក្រោមម្លប់ឈើក្តី





ក្នុងពួកកាយ ។ អ្វីជានាមធម៌ ចាត់ចូលក្នុងពួកវេទនា និង ចិត្ត ។ អ្វីជាធម៌ ចាត់ចូលក្នុងធម៌ ។

ក្នុងអដ្ឋកថា លោកសំដែងថា កាយសមគួរដល់អ្នកតណ្ហាចរិត មានបញ្ញាខ្សោយ ។ វេទនា សមគួរដល់អ្នកតណ្ហាចរិត មានបញ្ញាខ្លាំង។ ចិត្ត សមគួរដល់អ្នកទិដ្ឋិចរិត មានបញ្ញាខ្សោយ។ ធម៌ សមគួរដល់អ្នកទិដ្ឋិចរិត មានបញ្ញាខ្លាំង ។ កាយ សមគួរដល់សមថយានិក មានបញ្ញាខ្សោយ ។ វេទនា សមគួរដល់សមថយានិក មានបញ្ញាខ្លាំង ។ ចិត្តសមគួរដល់វិបស្សនាយានិក មានបញ្ញាខ្សោយ ។ ធម៌ សមគួរដល់វិបស្សនាយានិក មានបញ្ញាខ្លាំង ។

ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ផ្លូវគឺសតិបដ្ឋាន ៤ នេះ ជាផ្លូវមូលតែមួយ(ប្រព្រឹត្តទៅ)... ដើម្បីធ្វើឲ្យជាក់ច្បាស់ព្រះនិព្វាន ។ ត្រង់នេះ ចម្ងល់មួយកើតឡើងថា សតិបដ្ឋាន ៤ ជាផ្លូវមូលតែមួយ ចុះអដ្ឋង្គិកមគ្គទៅឯណាទៅ មិនមានទំនាស់ខ្វែងគ្នាទេឬអ្វី? សូមឆ្លើយដោយសង្ខេបថា បើបដិបត្តិសតិបដ្ឋានឲ្យបានល្អ សីល សមាធិ បញ្ញា កើតព្រមមូលគ្នាក្នុងទីនោះតែម្តង ជាហេតុឲ្យបានសម្រេចគោលដៅខ្ពស់បំផុតតែមួយគឺព្រះនិព្វាន ។ បើមិនដើរតាមសតិបដ្ឋានទេ សីលដោយឡែក សមាធិ បញ្ញា ដោយឡែក

គ្មានសាមគ្គីព្រមគ្នា គ្មានកម្លាំងគ្រប់គ្រាន់នឹងសម្រេចមគ្គផលបានទេ ។ ដើរតាមសតិបដ្ឋាន ៤ មិនទំនាស់នឹងអដ្ឋង្គិកមគ្គទេ ព្រោះសតិបដ្ឋាន ៤ ជាតួសម្មាសតិ ដែលមានក្នុងអដ្ឋង្គិកមគ្គនោះស្រាប់ហើយ ។ នរណា បដិបត្តិសតិបដ្ឋាន ៤ នរនោះឈ្មោះថា បដិបត្តិអដ្ឋង្គិកមគ្គ។ នរណា បដិបត្តិអដ្ឋង្គិកមគ្គនរនោះ ត្រូវតែដើរតាមសតិបដ្ឋាន ៤ គឺជាមួយតែគ្នា ។

សុត្តន្តបិដក សំយុត្តនិកាយ មហាវគ្គ ភាគ ទី ៣៨ ទំព័រទី ១០១ បរិយាយថា ៖

ម្នាលភិក្ខុទាំងឡាយ សតិបដ្ឋាន៤ ដែលបុគ្គលឯណានីមួយខ្វល់ខ្វាយហើយ មគ្គដ៏ប្រសើរប្រកបដោយអង្គ ៨ ជាទីទៅកាន់ព្រះនិព្វាន ជាគ្រឿងអស់ទៅនៃទុក្ខដោយប្រពៃ ក៏ឈ្មោះថាបុគ្គលទាំងនោះ បានខ្វល់ខ្វាយហើយដែរ ។

ម្នាលភិក្ខុទាំងឡាយ សតិបដ្ឋាន៤ ដែលបុគ្គលឯណានីមួយប្រារព្ធហើយ មគ្គដ៏ប្រសើរប្រកបដោយអង្គ ៨ ជាទីទៅកាន់ ព្រះនិព្វាន ជាគ្រឿងអស់ទៅនៃទុក្ខដោយប្រពៃ ក៏ឈ្មោះថា បុគ្គលទាំងនោះ បានប្រារព្ធហើយដែរ ។



# កាយានុបស្សនា

**កាយានុបស្សនា** មកអំពីពាក្យ **កាយ** + **អនុបស្សនា** = **កាយានុបស្សនា** ។ កាយគឺរូបរាងកាយទាំងមូល ។ **អនុបស្សនា** ប្រែថាពិនិត្យពិចារណារឿយៗ ។ រួមសេចក្តីមក **កាយានុបស្សនា** មានន័យថា ការពិនិត្យពិចារណារឿយៗ នូវកាយ ។

ពាក្យថា **កាយ** ក្នុងសតិបដ្ឋាន មានន័យប្លែកគ្នាពីកាយរបស់មនុស្សយើង ។ កាយរបស់មនុស្សយើងសំដៅយករូបកាយតែមួយប៉ុណ្ណោះ ចំណែក ពាក្យថា កាយ ក្នុងសតិបដ្ឋាន សំដៅយកធម៌ ៦ **បព្វៈ** (បែប ឬ ផ្នែក) គឺ ៖

១- **អានាបានបព្វៈ** ផ្នែកស្តីអំពីដង្ហើម,

២- **ឥរិយាបថបព្វៈ** ផ្នែកស្តីអំពីឥរិយាបថ,

៣- **សម្បជញ្ញបព្វៈ** ផ្នែកស្តីអំពីការដឹងខ្លួនជានិច្ចនូវឥរិយាបថនៃកាយ,

៤- **បដិកូលបព្វៈ** ផ្នែកស្តីអំពីភាពខ្ពើមរអើមក្នុងកាយ,

៥- **ធាតុបព្វៈ** ផ្នែកស្តីអំពីការពិចារណារូបធាតុ,

៦- **នវសីវថិកាបព្វៈ** ផ្នែកស្តីពីការពិនិត្យមើលទីស្មសាន ៩ យ៉ាង ។

បព្វៈ ទាំង ៦ ដែលបានរៀបរាប់មកហើយនេះក្តី ឬ បព្វៈ

ណាៗ ក៏ដឹងច្បាស់នូវកាយនោះ ដោយអាការៈយ៉ាងនោះៗ ។

ភិក្ខុ ពិចារណាឃើញរឿយៗ នូវកាយក្នុងកាយ ជាខាងក្នុង ជាខាងក្រៅ ជាខាងក្នុង និង ជាខាងក្រៅជាប្រក្រតីគ្រប់ឥរិយាបថទាំង ៤ យ៉ាងនេះឯង ។

ភិក្ខុដឹងថា គ្មានសត្វ គ្មានបុគ្គល ដែលដើរ ដែលឈរ ។ល។ ប៉ុន្តែ វាគ្រាន់តែជាពាក្យសំដីដែលមនុស្សនិយាយថា "អាត្មាអញដើរ" "អាត្មាអញឈរ" តែប៉ុណ្ណោះ ។ល។ ដូច្នេះផង ក៏មានចិត្តមិនអាស្រ័យ នូវដោយតណ្ហា និង ទិដ្ឋិ ផង មិនប្រកៀកប្រកាន់អ្វីតិចតួច ក្នុងលោកផង ។

ភិក្ខុពិចារណាឃើញរឿយៗនូវកាយក្នុងកាយយ៉ាងនេះឯង។

ពាក្យថា **ឥរិយាបថ** មានន័យថា គន្លងនៃការប្រព្រឹត្តិទៅនៃរូបកាយ មាន ៤ យ៉ាង គឺ ដេក ដើរ ឈរ អង្គុយ ។

## ៣- **សម្បជញ្ញបព្វៈ**

ភិក្ខុធ្វើនូវ (សម្បជញ្ញៈ) គឺសេចក្តីដឹងខ្លួនជាប្រក្រតី ក្នុងការដើរទៅខាងមុខ និង ថយក្រោយ ។ ភិក្ខុធ្វើនូវសេចក្តីដឹងខ្លួនជាប្រក្រតី ក្នុងការក្រឡេកមើលទៅមុខ និង ក្រឡេកមើលទៅទិសផ្សេងៗ ។ ភិក្ខុធ្វើនូវសេចក្តីដឹងខ្លួនជាប្រក្រតី ក្នុងការបត់ដៃជើង និង លាដៃជើង ធ្វើនូវសេចក្តីដឹងខ្លួនជាប្រក្រតី ក្នុងការទ្រទ្រង់





នៅក្នុងផ្ទះស្ងាត់ក្តី អង្គុយពែនភ្នែន តាំងកាយឲ្យត្រង់ តំកល់សតិឲ្យមានមុខឆ្ពោះទៅរកកម្មដ្ឋាន, ភិក្ខុមានសតិ ដកដង្ហើមចេញ មានសតិ ដកដង្ហើមចូល ។ កាលដកដង្ហើមចេញវែង ក៏ដឹងច្បាស់ថា "អាត្មាអញដកដង្ហើមចេញវែង" ។ កាលដកដង្ហើមចូលវែង ក៏ដឹងច្បាស់ថា "អាត្មាអញដកដង្ហើមចូលវែង" ។ កាលដកដង្ហើមចេញខ្លី ក៏ដឹងច្បាស់ថា "អាត្មាអញដកដង្ហើមចេញខ្លី" ។ កាលដកដង្ហើមចូលខ្លី ក៏ដឹងច្បាស់ ថា "អាត្មាអញដកដង្ហើមចូលខ្លី" ។

ភិក្ខុសិក្សាថា "អាត្មាអញ នឹងកំណត់ដឹងច្បាស់នូវកាយ គឺខ្យល់ចេញទាំងពួង សឹមដកដង្ហើមចេញ" ។ ភិក្ខុសិក្សាថា "អាត្មាអញ នឹងកំណត់ដឹងច្បាស់នូវកាយ គឺខ្យល់ចូលទាំងពួង សឹមដកដង្ហើមចូល" ។ ភិក្ខុសិក្សាថា "អាត្មាអញនឹងរម្ងាប់នូវកាយសង្ខារ (អស្សាសបស្សាសៈ គឺដង្ហើមចេញ និង ចូល) សឹមដកដង្ហើមចេញ" ។ ភិក្ខុសិក្សាថា "អាត្មាអញនឹងរម្ងាប់នូវកាយសង្ខារ សឹមដកដង្ហើមចូល" ។

គឺដូចជាជាងក្រឡឹង ឬ សិស្សជាងក្រឡឹង ដែលប៉ិនប្រសប់ កាលទាញខ្សែក្រឡឹងវែង ក៏ដឹងច្បាស់ថា "អាត្មាអញកំពុងទាញខ្សែក្រឡឹងវែង, កាលទាញខ្សែក្រឡឹងខ្លី ក៏ដឹងច្បាស់ថា "អាត្មាអញ កំពុងទាញខ្សែក្រឡឹងខ្លី" យ៉ាងណាមិញ, កាលដកដង្ហើម

ចូលវែង ភិក្ខុដឹងច្បាស់ថា “អាត្មាអញកំពុងដកដង្ហើមចូលវែង” កាលដកដង្ហើមចេញវែង ភិក្ខុដឹងច្បាស់ថា “អាត្មាអញ កំពុងដកដង្ហើមចេញវែង” កាលដកដង្ហើមចូលខ្លី ក៏ដឹងច្បាស់ថា “អាត្មាអញកំពុងដកដង្ហើមចូលខ្លី” កាលដកដង្ហើមចេញខ្លី ក៏ដឹងច្បាស់ថា “អាត្មាអញកំពុងដកដង្ហើមចេញខ្លី” ក៏យ៉ាងនោះឯង ។

ភិក្ខុពិចារណារឿយៗ នូវកាយក្នុងកាយ ជាខាងក្នុង (កាយរបស់ខ្លួន) ឬ នូវកាយក្នុងកាយជាខាងក្រៅ និង នូវកាយក្នុងកាយ ទាំងខាងក្នុងទាំងខាងក្រៅ (កាយរបស់ខ្លួន) ។ ភិក្ខុពិចារណាឃើញរឿយៗ នូវធម៌ ដែលជាទីប្រជុំកើតឡើង ក្នុងកាយ និង ពិចារណាឃើញ នូវធម៌ដែលសូន្យទៅក្នុងកាយ និង នូវធម៌ដែលប្រជុំកើតឡើង និង ទាំងធម៌ដែលសូន្យទៅ ក្នុងកាយ ។

ម្យ៉ាងទៀត ស្មារតី (សតិជាគ្រឿងកំណត់នូវកាយ) របស់ភិក្ខុនោះ ក៏ផ្ចង់ឡើងចំពោះថា កាយនេះមានមែន (ប៉ុន្តែមិនមែនសត្វ មិនមែនបុគ្គល មិនមែនស្រី មិនមែនប្រុស មិនមែនខ្លួន មិនមានអ្វីជារបស់ខ្លួន ព្រមទាំងមិនមែនមនុស្ស និង មិនមានអ្វីជារបស់មនុស្សឡើយ) គ្រាន់តែជាទីកំណត់ ដើម្បីឲ្យចំរើនបញ្ញា ដើម្បីឲ្យចំរើនស្មារតីប៉ុណ្ណោះ ។





ភិក្ខុនោះ មានចិត្តមិនអាស្រ័យ (ដោយតណ្ហានិស្ស័យ និង ទិដ្ឋិនិស្ស័យ)ជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ មិនប្រកៀកប្រកាន់អ្វីតិចតួច ក្នុងលោកផង ។

ភិក្ខុពិចារណាឃើញរឿយៗនូវកាយក្នុងកាយយ៉ាងនេះឯង។

អានាបាណស្សតិជាអារម្មណ៍ភាវនាមួយយ៉ាងសំខាន់សំរាប់ចំរើនសមថភាវនា ដើម្បីសំរេចឈានទាំងឡាយ និង សំរាប់ចំរើនវិបស្សនាភាវនា ឬ សំរាប់ចំរើនភាវនាទាំងពីរ រួមគ្នាគឺ សមថៈ និង វិបស្សនា ។

គួរចងចាំថា ពាក្យថា **សិក្សា** ក្នុងភាសាទូទៅ សំដៅយកត្រឹមការរៀនសូត្រចំណេះដឹងផ្សេងៗ តែប៉ុណ្ណោះ ស្មើគ្នានឹងពាក្យមួយទៀត ដែលហៅថា **បរិយត្តិ** ។ ចំណែកពាក្យថា **សិក្សា** ក្នុងសតិបដ្ឋាន សំដៅយកការរៀនសូត្រផង ការបដិបត្តិផង ការសង្កេត ពិនិត្យ លៃលក សម្រួល ការពិសោធន៍ មានព្រមទាំងអស់ ។

## ២- **ឥរិយាបថបព្វៈ**

ភិក្ខុទោះដើរក្តី ទោះឈរក្តី ទោះអង្គុយក្តី ទោះដេកក្តី ក៏ដឹងច្បាស់ថា “អាត្មាអញដើរ អាត្មាអញឈរ អាត្មាអញអង្គុយ អាត្មាអញដេក” ។ ភិក្ខុនោះ តាំងនូវកាយ ដោយអាការៈយ៉ាង

ភិក្ខុពិចារណាឃើញរឿយៗ នូវកាយក្នុងកាយយ៉ាងនេះឯង ។

### ៥- **ធាតុបព្វៈ**

មួយទៀត ភិក្ខុពិចារណាឃើញច្បាស់ នូវរាងកាយនេះឯង ដែលឋិតនៅហើយយ៉ាងណា ដែលតំកល់(តាំង) នៅហើយយ៉ាងណា ដោយកំណត់ថា គ្រាន់តែជាធាតុ ដូច្នេះថា : ក្នុងកាយនេះ មានធាតុដី (បឋវីធាតុ), ធាតុទឹក (អាបោធាតុ), ធាតុភ្លើង (តេជោធាតុ), ធាតុខ្យល់ (វាយោធាតុ) ។

(ធម្មតា) បុរសអ្នកសម្លាប់គោក្តី ឬ សិស្សអ្នកពិឃាតគោក្តី ដែលប៉ិនប្រសប់ ពិឃាតគោ និង វះកាត់ជាកំណាត់ៗ អង្គុយនៅទៀបផ្លូវធំបែកជា ៤ មានឧបមាដូចម្តេចមិញ ។

ភិក្ខុពិចារណាឃើញរឿយៗ អំពីធាតុនីមួយៗ ស្របទៅតាមចរិតលក្ខណៈ របស់ធាតុនេះថា នៅក្នុងកាយនេះ មានធាតុដី ធាតុទឹក ធាតុភ្លើង និង ធាតុខ្យល់ ក៏យ៉ាងនោះដែរ ។

ភិក្ខុពិចារណាឃើញរឿយៗ នូវកាយក្នុងកាយ ជាខាងក្នុង ជាខាងក្រៅ ជាខាងក្នុង និង ជាខាងក្រៅ (ដោយការកំណត់នូវធាតុទាំង ៤) ជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ដូច្នេះ ក៏មានចិត្តមិនអាស្រ័យនូវដោយតណ្ហា និង ទិដ្ឋិ ផង មិនប្រកៀកប្រកាន់អ្វីតិចតួច ក្នុងលោកផង ។





សង្ឃាដី បាត្រ និង ចីវរ ធ្វើនូវសេចក្តីដឹងខ្លួនជាប្រក្រតី ក្នុងការបរិភោគភោជន ផឹកទឹក ទំពាស៊ីខាទនីយ វត្ថុ និង ទទួលរស ធ្វើនូវសេចក្តីដឹងខ្លួនជាប្រក្រតី ក្នុងការបន្ទោបង់នូវឧច្ចារៈ និង បស្សាវៈ ធ្វើនូវសេចក្តីដឹងខ្លួនជាប្រក្រតី ក្នុងការដើរ ឈរ អង្គុយ ដេកលក់ ភ្ញាក់ឡើង, ធ្វើនូវសេចក្តីដឹងខ្លួនជាប្រក្រតី ក្នុងការនិយាយ និង នៅស្ងៀម ។

ភិក្ខុពិចារណាឃើញរឿយៗ នូវកាយក្នុងកាយ ជាខាងក្នុង ជាខាងក្រៅ ជាខាងក្នុង និងជាខាងក្រៅជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ យ៉ាងនេះឯង ។ ដូច្នេះផង, ក៏មានចិត្តមិនអាស្រ័យ នូវដោយតណ្ហា និង ទិដ្ឋិ ផង មិនប្រកៀកប្រកាន់អ្វីតិចតួច ក្នុងលោកផង ។

ភិក្ខុពិចារណាឃើញរឿយៗ នូវកាយក្នុងកាយ យ៉ាងនេះឯង ។

គួរសង្កេតថា ត្រង់ទីបញ្ចប់នៃសតិបដ្ឋានទីមួយៗ មានបាលីថា **អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ** ប្រែថា ជាអ្នកមានសេចក្តីព្យាយាមជាគ្រឿងដុតកិលេស ជាអ្នកមានសម្បជញ្ញៈ ជាអ្នកមានសតិ ដើម្បីកំចាត់បង់នូវអភិជ្ឈា និង ទោមនស្ស ក្នុងលោកចេញ ។

បាលីខាងលើនេះ ចង្អុលប្រាប់លក្ខណៈ នៃអ្នកបដិបត្តិធម

និង ចំណុចសំខាន់ៗ ដែលត្រូវប្រយុទ្ធ ។ អ្នកបដិបត្តិសតិបដ្ឋាន ត្រូវប្រកបដោយគុណលក្ខណៈ ៣ ប្រការ គឺ ៖

១- **អាតាបី** ជាអ្នកមានសេចក្ដីព្យាយាមដុតកំទ្បោចកិលេស,

២- **សម្បជានោ** ជាអ្នកមានសម្បជញ្ញៈ ដឹងខ្លួនជាប្រក្រតី,

៣- **សតិមា** ជាអ្នកមានសតិ មានស្មារតី ។

គួរសង្កេតទៀតថា អ្នកមានសេចក្ដីព្យាយាម ក្នុងទីនេះ លោកប្រើពាក្យថា **អាតាបី** ចេញមកពីពាក្យ **អាតាបៈ** បាន សេចក្ដីថា ដុតកំទ្បោចកិលេសឲ្យសព្វ ។ សេចក្ដីព្យាយាមនេះ មិនមែនធម្មតាទេ មានកម្លាំងខ្លាំងក្លាណាស់ ត្រូវប្រកបព្រមដោយ ធម៌ ៥ យ៉ាង គឺៈ **សទ្ធា វីរិយៈ ខន្តិ សច្ចៈ អធិដ្ឋាន** ហើយ អ្នកបដិបត្តិ ត្រូវតែមានសតិសម្បជញ្ញៈ ជាប់ជានិច្ច ។ ឯទិសដៅ ដែលត្រូវប្រយុទ្ធ គឺដើម្បីលះកំចាត់បង់នូវអភិជ្ឈា (លោភ) និង ទោមនស្ស (ទោសៈ) ។

## ៤- បដិក្កូលបព្វៈ

មួយទៀត ភិក្ខុ (ក្នុងសាសនានេះ) ពិចារណាឃើញច្បាស់ នូវកាយនេះឯង ខាងលើ តាំងពីបាតជើងឡើងទៅ ខាងក្រោម តាំងពីចុងសក់ចុះមក ដែលមានស្បែកបិទបាំងជុំវិញ ពេញដោយ វត្ថុមិនស្អាត មានប្រការផ្សេងៗ យ៉ាងដូច្នេះថា : ក្នុងកាយនេះ





មានសក់ និង រោម មានក្រចក ធ្មេញ ស្បែក សាច់ សរសៃ ទាំងឡាយ ឆ្អឹងទាំងឡាយ ខួរក្នុងឆ្អឹង តម្រងបស្សាវៈ (ទាច) បេះដូង ថ្លើម វាវ ក្រពះ សួត ពោះវៀនធំ ពោះវៀនតូច អាហារថ្មី អាហារចាស់ ទឹកប្រមាត់ ស្លេស្ម ខ្ទុះ ឈាម ញើស ខ្លាញ់ខាប់ ទឹកភ្នែក ខ្លាញ់រាវ ទឹកមាត់ ទឹកសំបោរ ទឹករំអិល ទឹកមូត្រ ។

(ប្រៀបដូច) ថង់ដែលមានមាត់ទាំងពីរខាង ពេញដោយ ធញ្ញជាតិ មានប្រការផ្សេងៗ ធញ្ញជាតិទាំងអស់នោះ គឺ ស្រូវ ខ្សាយ-ស ស្រូវខ្សាយក្រហម សណ្ដែកបាយ សណ្ដែករាជមាស ល្ង និង អង្ករ ។ បុរសដែលមានចក្ខុ គប្បីស្រាយនូវមាត់ថង់នោះ ហើយពិនិត្យមើលដូច្នេះ ថា នេះស្រូវខ្សាយ-ស នេះស្រូវខ្សាយ ក្រហម នេះ សណ្ដែកបាយ នេះសណ្ដែករាជមាស នេះល្ង នេះ អង្ករ មានឧបមាដូចម្ដេចមិញ ។

ភិក្ខុពិចារណាឃើញរឿយៗ នូវកាយក្នុងកាយ ជាខាងក្នុង ជាខាងក្រៅ ជាខាងក្នុង និង ជាខាងក្រៅ(ដោយកំណត់នូវអាការៈ មានសក់ជាដើម) ជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ដូច្នេះផង ក៏មានចិត្តមិនអាស្រ័យនូវដោយតណ្ហា និង ទិដ្ឋិ ផង មិនប្រកៀក ប្រកាន់អ្វីតិចតួច ក្នុងលោកផង ។

៨- សរីរៈនៅសល់តែរាងឆ្អឹងទទេ រោយរាយជាពំនូតៗ កន្លងហួសទៅមួយឆ្នាំហើយ ។ល។

៩- សរីរៈនៅសល់តែរាងឆ្អឹងទទេ ពុកផុយខ្ទេចខ្ទីជាកម្ទេចតូច កម្ទេចធំផ្សេងៗ ដូចម្ដេចមិញ, ភិក្ខុនោះ ក៏បង្អោនសាកសពនោះ មកប្រៀបផ្ទឹមនឹងកាយនេះឯងថា : សូម្បីកាយនេះសោតក៏គង់នឹងមានសភាពជារបស់គួរខ្ពើម ដូច្នេះ គង់នឹងមានប្រភេទ(ក្លាយទៅ)ជាយ៉ាងនេះ នឹងកន្លងនូវភាវៈយ៉ាងនេះពុំបានឡើយ ។

ភិក្ខុពិចារណាឃើញរឿយៗ នូវកាយក្នុងកាយ ជាខាងក្នុង (ដោយការកំណត់នូវអសុភកំពុងហើម ដែលក្អែកកំពុងតែចឹកស៊ីជាដើម) ឬ នូវកាយជាខាងក្នុង កាយជាខាងក្រៅ និង នូវកាយក្នុងកាយ ទាំងខាងក្នុង និង ទាំងខាងក្រៅ គឺកាយរបស់ខ្លួន និង កាយរបស់អ្នកដទៃ ឬ ទាំងពីរ ។

ភិក្ខុពិចារណាឃើញរឿយៗ នូវធម៌ដែលប្រជុំកើតឡើង (សមុទយធម៌) ក្នុងកាយ និង នូវធម៌ដែលសូន្យទៅ (វយធម៌) ក្នុងកាយ និង នូវធម៌ដែលជាទីប្រជុំកើតឡើង ទាំងធម៌ដែលសូន្យទៅ ក្នុងកាយ (សមុទយធម៌ និង វយធម៌ ក្នុងកាយ) ។

ពុំនោះសោត ស្មារតី(សតិរបស់ភិក្ខុនោះ) ក៏ផ្ចង់ឡើងចំពោះថា កាយនេះមានមែន (ប៉ុន្តែមិនមែនសត្វ មិនមែនបុគ្គល មិន





ភិក្ខុពិចារណាឃើញរឿយៗ នូវកាយក្នុងកាយ យ៉ាងនេះឯង ។

គួរកត់សំគាល់ថា ធាតុមានពីរបែប គឺ ១- **ពាហិរធាតុ** ធាតុខាងក្រៅ គឺ ដី ទឹក ភ្លើង ខ្យល់ ខាងក្រៅដូចដែលយើងធ្លាប់ស្គាល់មកហើយនោះ ។ ២- **អជ្ឈត្តិកធាតុ** ធាតុខាងក្នុង គឺ ដី ទឹក ភ្លើង ខ្យល់ ក្នុងរូបកាយយើងនេះឯង ។

ធម្មជាតិ ទ្រទ្រង់នូវសភាវៈរបស់ខ្លួន ហៅថា **ធាតុ** ។ ធាតុដី ទ្រទ្រង់នូវលក្ខណៈរឹង ទន់, ធាតុទឹក ទ្រទ្រង់នូវលក្ខណៈរាវជ្រួតជ្រាប, ធាតុភ្លើង ទ្រទ្រង់នូវលក្ខណៈក្ដៅ, ធាតុខ្យល់ ទ្រទ្រង់នូវលក្ខណៈបក់ទៅមក មានចលនា (កាយសង្ខារ) ។ ធាតុខាងក្រៅ និង ធាតុខាងក្នុង ទ្រទ្រង់នូវលក្ខណៈនេះដូចគ្នា ហេតុនេះរូបកាយ គឺចតុធាតុហ្នឹងឯង ។

## ៦- នវសីវថិកាបព្វៈ

**នវសីវថិកាបព្វៈ** ជាបព្វៈមួយ និយាយពីព្រៃស្មសាន គឺកន្លែងចោលសាកសព ៩ បែប មិនមែនព្រៃស្មសាន ៩ កន្លែងទេ ប៉ុន្តែក្នុងព្រៃស្មសាននោះ មានសាកសពប្លែកៗ គ្នា ដល់ទៅ ៩ បែប គឺ ៖

១- ភិក្ខុគប្បីឃើញនូវសរីរៈស្លាប់ដែលគេចោល ក្នុងព្រៃស្មសាននោះហើយ អស់ ១ ថ្ងៃក្ដី ២ ថ្ងៃក្ដី ៣ ថ្ងៃក្ដី ដែលកំពុងហើម

មានសម្បុរខៀវ មានខ្ទុះហូរចេញ ដូចម្ដេចមិញ, ភិក្ខុនោះ (ក៏បង្អោនសាកសពនោះ) មកប្រៀបផ្ទឹមនឹងកាយនេះឯងថា : សូម្បីកាយនេះសោត ក៏គង់នឹងមានសភាពជារបស់គួរខ្ពើម យ៉ាងនេះ គង់នឹងក្លាយទៅជាឧទ្ធុមាតកអសុភ ជាដើមយ៉ាងនេះ នឹងកន្លងចាកឧទ្ធុមាតកអសុភជាដើមនោះមិនបានឡើយ ។

២- ភិក្ខុគប្បីឃើញនូវសរីរៈស្លាប់ ដែលគេចោល ក្នុងព្រៃស្មសានដែលក្អែកកំពុងតែចឹកស៊ីក្ដី ដែលពួកត្មាតកំពុងតែជញ្ជែងស៊ីក្ដី ដែលពួកត្រដក់កំពុងតែចឹកស៊ីក្ដី ដែលពួកស្វានកំពុងតែកកេរស៊ីក្ដី ដែលពួកចចកកំពុងតែខាំស៊ីក្ដី ដែលពួកបាណកជាតិ (សត្វល្អិតៗ ដូចរុយ ដង្កូវជាដើម) ផ្សេងៗ កំពុងតែជញ្ជក់ស៊ីក្ដី ដូចម្ដេចមិញ, ភិក្ខុនោះ ក៏បង្អោនសាកសពនោះ មកប្រៀបផ្ទឹមនឹងកាយនេះឯងថា : សូម្បីកាយនេះសោត ក៏គង់នឹងមានសភាពជារបស់គួរខ្ពើមដូច្នេះ គង់នឹងក្លាយទៅជាយ៉ាងនេះ នឹងកន្លងនូវភាពយ៉ាងនេះពុំបានឡើយ ។

៣- ភិក្ខុគប្បីឃើញនូវសរីរៈស្លាប់ ដែលគេចោល ក្នុងព្រៃស្មសាន នៅសល់តែរាងឆ្អឹង ព្រមទាំងសាច់ និង ឈាម ដែលមានសរសៃជាគ្រឿងចង យ៉ាងណាមិញ,

៤- សរីរៈនៅសល់តែរាងឆ្អឹង ឥតមានសាច់តែនៅប្រឡាក់





ដោយឈាម មានសរសៃជាគ្រឿងចង ។ល។

៥- សរីរៈនៅមានតែរាងឆ្អឹង ប្រាសចាកសាច់ និង ឈាម មានតែសរសៃជាគ្រឿងចង ។

៦- សរីរៈនៅសល់តែរាងឆ្អឹងទទេ មិនមានសរសៃចងរួតរឹត ខ្ចាត់ខ្ចាយ រាត់រាយទៅក្នុងទិសតូច និង ទិសធំទាំងឡាយ គឺ: ឆ្អឹងដៃទៅដោយឡែក ឆ្អឹងជើងទៅដោយឡែក ឆ្អឹងស្មងទៅដោយឡែក ឆ្អឹងភ្លៅទៅដោយឡែក ឆ្អឹងចង្កេះទៅដោយឡែក ឆ្អឹងខ្នងទៅដោយឡែក ឆ្អឹងជំនីរទៅដោយឡែក ឆ្អឹងទ្រូងទៅដោយឡែក ឆ្អឹងដើមដៃទៅដោយឡែក ឆ្អឹងកំភួនដៃទៅដោយឡែក ឆ្អឹងស្មាទៅដោយឡែក ឆ្អឹង-កទៅដោយឡែក ឆ្អឹងចង្កាទៅដោយឡែក ឆ្អឹងធ្មេញទៅដោយឡែក ឆ្អឹងលលាដ៍ក្បាលទៅដោយឡែក ដូចម្ដេចមិញ, ភិក្ខុនោះ ក៏បង្អោនសាកសពនោះ មកប្រៀបផ្ទឹមនឹងកាយនេះឯងថា : សូម្បីកាយនេះសោត ក៏គង់នឹងមានសភាព ជារបស់គួរខ្ពើមដូច្នេះ គង់នឹងមានប្រភេទជាយ៉ាងនេះ នឹងកន្លងនូវភាវៈយ៉ាងនេះពុំបានឡើយ ។

៧- ភិក្ខុគប្បីឃើញនូវសរីរៈស្លាប់ ដែលគេចោល ក្នុងព្រៃស្មសាន នៅសល់តែរាងឆ្អឹងទទេ មានសម្បុរដូចជាសម្បុរនៃសង្ខ (ខ្យង) យ៉ាងណាមិញ ។ល។

ស្និទ្ធណាស់ រហូតទាល់តែអ្វីៗ ដែលកើតឡើងនៅក្នុងចិត្ត តែងតែបញ្ចេញខ្លួនវាមកជាវេទនានៅលើកាយ ។ ព្រោះហេតុនេះ បានជាព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់នឹងពួកភិក្ខុទាំងឡាយ ថា :

“**វេទនាសមោសរណា សព្វេ** [១] **ធម្មា**

ពួកធម៌ទាំងអស់ មានវេទនាជាទីប្រជុំចុះ ...” ។

ក្នុងការបដិបត្តិ យោគាវចរ មិនអាចលើកយកវេទនាមកពិនិត្យពិសោធម្តងមួយៗ គឺបើពិនិត្យពិសោធវេទនាណា ទទួលដឹងវេទនានោះ ក្នុងចំណោមវេទនាទាំង ៩ ដែលលោកហៅថា វេទនាក្នុងវេទនា ។ ពាក្យថា **អជ្ឈត្ត** ពួដ៏ខាងក្នុង មានន័យថា ផ្ទៃខាងក្នុងរបស់រាងកាយ ។ រីឯពាក្យថា **ពហិទ្ធា** ពួដ៏ខាងក្រៅ មានន័យថា នៅផ្ទៃខាងលើរបស់រាងកាយ ដែលជាន័យសមរម្យជាងន័យថា រាងកាយរបស់អ្នកដទៃ ព្រោះក្នុងវេទនានុបស្សនានេះ ការពិនិត្យមើលអ្នកដទៃគ្មានន័យអ្វីឡើយ ហើយវេទនា របស់អ្នកដទៃ ឬ របស់អ្វីដទៃទៀត ក៏គ្មានប្រយោជន៍អ្វីសោះដែរ ។

ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុពិនិត្យពិសោធពិចារណាឃើញរឿយៗនូវវេទនាក្នុងវេទនាទាំងឡាយនោះ តើធ្វើយ៉ាងដូចម្តេច? ។

ម្នាលភិក្ខុទាំងឡាយ (ក្នុងសាសនានេះ) កាលទទួលសោយ

(១) សុត្តន្តបិដក អង្គុត្តរនិកាយ ទសកនិបាត ភាគទី ៥០ ទំព័រទី ២៣២ ។





មែនស្រី មិនមែនប្រុស ជាដើម) គ្រាន់តែជាទីកំណត់ ដើម្បីឲ្យចំរើនប្រាជ្ញា ដើម្បីឲ្យចំរើនស្មារតីប៉ុណ្ណោះ ។

ភិក្ខុនោះ មានចិត្តមិនអាស្រ័យ (តណ្ហានិស្ស័យ និង ទិដ្ឋិនិស្ស័យ) ផង មិនប្រកៀកប្រកាន់អ្វីតិចតួច ក្នុងលោកផង ។

ភិក្ខុពិចារណាឃើញរឿយៗ នូវកាយក្នុងកាយ ជាប្រក្រតីគ្រប់ឥរិយាបថទាំង ៤ យ៉ាងនេះឯង ។

ព្រះបរមសាស្តា ទ្រង់ទូន្មានភិក្ខុ (ក្នុងទីនេះ គឺអ្នកស្តាប់ធម្មទេសនា របស់ព្រះពុទ្ធ) ឲ្យពិចារណារឿយៗ នូវកាយក្នុងកាយទាំង ៦ បព្វៈ(បែប)នេះ គឺទ្រង់ចង់ឲ្យភិក្ខុយល់ច្បាស់ តាមបញ្ញាញាណ នូវទុក្ខទោស និង តម្លៃរបស់កាយ ។ កាលបើចាក់ធ្លុះ (បដិវេធ) នាំងខ្មៅគឺអវិជ្ជា ពិសោធឃើញសភាវពិត របស់កាយ និង វេទនាសម្ពន្ធរបស់វា ភិក្ខុក៏កើតនិព្វិទា នឿយណាយស្អប់ខ្ពើមកាយ អស់មានការប្រកាន់មាំ (ឧបាទាន) ដែលជាបច្ច័យឲ្យមានជាតិ ជរា មរណៈ ។ សត្វលោក តែងងប់ងុលនឹងបញ្ចុបាទានក្ខន្ធ (ខន្ធ ៥) ដែលមានតណ្ហាជាបច្ច័យ ទើបព្រះជិនស្រី មានដីកា ថា ៖

**តណ្ហក្ខយោ សព្វទុក្ខំ ជិនាតិ**

ការអស់ទៅនៃតណ្ហា រមែងឈ្នះនូវទុក្ខទាំងពួង ។

# វេទនានុបស្សនា

**វេទនានុបស្សនា** មកពីពាក្យថា **វេទនា** + **អនុបស្សនា**= **វេទនានុបស្សនា** ។ **វេទនា** ប្រែថា ការទទួលអារម្មណ៍, ការសោយឬរងអារម្មណ៍ ឬ ការទទួលដឹងអារម្មណ៍ ។ **អនុបស្សនា** ប្រែថា ការពិនិត្យពិចារណារឿយៗ ។ រួមសេចក្តីមក **វេទនានុបស្សនា** មានន័យថា ការពិនិត្យពិសោធពិចារណារឿយៗ នូវវេទនាទាំងឡាយ ។

តាមសេចក្តីពិតជាទូទៅ ព្រះពុទ្ធទ្រង់សំដែងអំពីវេទនា ៥ យ៉ាង គឺ ៖

១- **សុខវេទនា** វេទនាជាទីរីករាយខាងផ្លូវកាយ,

២- **ទុក្ខវេទនា** វេទនាមិនជាទីរីករាយខាងផ្លូវកាយ,

៣- **សោមនស្សវេទនា** វេទនាជាទីរីករាយខាងផ្លូវចិត្ត,

៤- **ទោមនស្សវេទនា** វេទនាមិនជាទីរីករាយខាងផ្លូវចិត្ត,

៥- **ឧបេក្ខាវេទនា** វេទនាមិនជាទីរីករាយ ឬ មិនជាទីមិនរីករាយតាមផ្លូវកាយ ឬ តាមផ្លូវចិត្ត (ឧបេក្ខា ប្រែថា កណ្តាល ឬ ជើយៗ ឬ អព្យាក្រិត) ។

ក៏ប៉ុន្តែ ក្នុងមហាសតិបដ្ឋានសូត្រ ព្រះពុទ្ធទ្រង់សំដែងទុកត្រឹម ៩ យ៉ាងប៉ុណ្ណោះ គឺ ៖





១- **សុខវេទនា** វេទនាជាសុខ,

២- **ទុក្ខវេទនា** វេទនាជាទុក្ខ,

៣- **អទុក្ខមសុខវេទនា** វេទនាមិនជាទុក្ខមិនជាសុខ,

៤- **សាមិសសុខវេទនា** វេទនាជាសុខ ប្រកបដោយការជំពាក់ចិត្ត,

៥- **សាមិសទុក្ខវេទនា** វេទនាជាទុក្ខ ប្រកបដោយការជំពាក់ចិត្ត,

៦- **និរាមិសសុខវេទនា** វេទនាជាសុខ ដោយគ្មានការជំពាក់ចិត្ត,

៧- **និរាមិសទុក្ខវេទនា** វេទនាជាទុក្ខ គ្មានការជំពាក់ចិត្ត,

៨- **សាមិសអទុក្ខមសុខវេទនា** វេទនាមិនមែនទុក្ខ មិនមែនសុខ ប្រកបដោយការជំពាក់ចិត្ត,

៩- **និរាមិសអទុក្ខមសុខវេទនា** វេទនាមិនមែនទុក្ខ មិនមែនសុខ ដោយគ្មានការជំពាក់ចិត្ត ។

វេទនាទាំង ៩ បែបខាងលើនេះ និយាយតែអំពីវេទនាផ្លូវកាយ ពុំបាននិយាយអំពីផ្លូវចិត្តឡើយ ។ ព្រះដ៏មានព្រះភាគទ្រង់សំដែងសង្កត់ធ្ងន់ទៅលើកាយវេទនាយ៉ាងនេះ ក៏ព្រោះព្រះអង្គទ្រង់ឈ្វេងយល់ថា ចិត្ត និង កាយ មានការទាក់ទងគ្នាយ៉ាងជិត

ដល់បញ្ចកាមគុណ គឺ រូប សម្លេង ក្លិន រស ផោដ្ឋព្វៈ បានដល់បច្ច័យ ៤ គឺចីវរ បិណ្ឌបាត សេនាសនៈ គិលានភេសជ្ជៈ បានដល់ទុយ គ្រឿងបញ្ឆោត ចំណី...។ **សាមិសសុខ** គឺសុខប្រកបដោយការជាប់ចិត្ត ឬ កាមគុណ ។ **និរាមិសសុខ** (**និ** + **អាមិស** ) គឺសុខប្រាសចាកអាមិស ។

វេទនា ដើរតួសំខាន់ណាស់ ក្នុងដំណើរឆ្ពោះទៅរកមគ្គផល គឺព្រះនិព្វាន ព្រោះថា បើយើងពិសោធពិចារណា យ៉ាងត្រឹមត្រូវ អំពីវេទនា យើងនឹងអាចឃើញត្រៃលក្ខណធម៌ គឺ **អនិច្ចំ ទុក្ខំ អនត្តា**។ ព្រះពុទ្ធទ្រង់ត្រាស់ថា **សព្វេ វេទនា អនិច្ចា**... វេទនាទាំងឡាយមិនទៀង ប្រែប្រួល កើតរលត់ៗ (សមុទយវយៈ) ។ កាលបើពិសោធដឹងច្បាស់អំពីអនិច្ចា (ភាពមិនទៀងទាត់) នៅលើរូបកាយរបស់យើងហើយ ទុក្ខំ និង អនត្តា (ភាពមិនមែនខ្លួន) នឹងត្រូវពិនិត្យពិសោធ យល់បានដោយងាយ ។

អាស្រ័យហេតុនេះ ក្នុងការបដិបត្តិសតិបដ្ឋាន ការពិសោធន៍ឃើញអនិច្ចា កើតឡើងហើយ រលត់ទៅវិញ មានតួនាទីសំខាន់ណាស់ ។ ការពិសោធន៍ឃើញអនិច្ចា តាមភាពដែលវាបញ្ចេញឲ្យឃើញនៅក្នុងចិត្ត និង កាយនេះ គេហៅថា វិបស្សនា ហើយ ការបដិបត្តិវិបស្សនា គឺដូចគ្នានឹងការបដិបត្តិសតិបដ្ឋានដែរ ។





នូវសុខវេទនា ក៏ដឹងច្បាស់ថា “អាត្មាអញសោយនូវវេទនា ជាសុខ” ។ កាលសោយនូវទុក្ខវេទនា ក៏ដឹងច្បាស់ថា “អាត្មាអញសោយនូវទុក្ខវេទនា” ។ កាលសោយនូវអទុក្ខមសុខវេទនា ក៏ដឹងច្បាស់ថា “អាត្មាអញសោយនូវវេទនាឥតទុក្ខឥតសុខ” ។ កាលសោយនូវសាមិសសុខវេទនា ក៏ដឹងច្បាស់ថា “អាត្មាអញសោយនូវសុខវេទនាប្រកបដោយអាមិស“ ។ កាលទទួលនូវសាមិសទុក្ខវេទនា ក៏ដឹងច្បាស់ថា “អាត្មាអញទទួលនូវទុក្ខវេទនា ប្រកបដោយអាមិស” ។ កាលសោយនូវនិរាមិសសុខវេទនា ក៏ដឹងច្បាស់ថា “អាត្មាអញសោយនូវសុខវេទនាប្រាសចាកអាមិស” ។ កាលសោយនូវនិរាមិសទុក្ខវេទនា ក៏ដឹងច្បាស់ថា “អាត្មាអញសោយនូវទុក្ខវេទនា ប្រាសចាកអាមិស” ។ កាលសោយ នូវសាមិសអទុក្ខមសុខវេទនា ក៏ដឹងច្បាស់ថា “អាត្មាអញសោយនូវអទុក្ខមសុខវេទនា ប្រកបដោយអាមិស” ។ កាលសោយនូវនិរាមិសអទុក្ខមសុខវេទនា ក៏ដឹងច្បាស់ថា “អាត្មាអញ សោយនូវអទុក្ខមសុខវេទនា ប្រាសចាកអាមិស” ។

ដូច្នេះ ភិក្ខុពិចារណារឿយៗ នូវវេទនាក្នុងវេទនាទាំងឡាយជាខាងក្នុង នូវវេទនាទាំងឡាយ ជាខាងក្រៅ ឬ នូវវេទនា ក្នុងវេទនាទាំងឡាយ ទាំងខាងក្នុង ទាំងខាងក្រៅ ។

ភិក្ខុពិចារណារឿយៗ នូវធម៌ដែលជាទីប្រជុំកើតឡើង ក្នុងវេទនាទាំងឡាយ ឬ ធម៌ដែលសូន្យទៅក្នុងវេទនាទាំងឡាយ និងទាំងធម៌ដែលប្រជុំកើតឡើង ទាំងធម៌ដែលសូន្យទៅ ក្នុងវេទនាទាំងឡាយ ។

ម្យ៉ាងទៀត ស្មារតី (សតិជាគ្រឿងកំណត់នូវវេទនា) នៃភិក្ខុនោះ ក៏ផ្ចង់ឡើងចំពោះថា វេទនានេះមានមែន (ប៉ុន្តែមិនមែនសត្វ មិនមែនបុគ្គលមិនមែនស្រី មិនមែនប្រុសជាដើម) គ្រាន់តែជាទីកំណត់ដើម្បីឲ្យចំរើនប្រាជ្ញា ដើម្បីឲ្យចំរើនស្មារតីប៉ុណ្ណោះ ។

ភិក្ខុនោះ មានចិត្តមិនអាស្រ័យ (ដោយតណ្ហា និង ទិដ្ឋិ) ផង មិនប្រកៀកប្រកាន់អ្វីតិចតួច ក្នុងលោកផង ។

ភិក្ខុពិចារណាឃើញរឿយៗ នូវវេទនាក្នុងវេទនា ជាប្រក្រតីគ្រប់ឥរិយាបថទាំង ៤ យ៉ាងនេះឯង ។

ពាក្យថា **វេទនា** ប្រែថា ការសោយអារម្មណ៍, តើសោយអារម្មណ៍តាមរបៀបណា? ក្រោយពេលដែលអាយតនៈខាងក្នុង (ទ្វារអារម្មណ៍) ទាំង ៦ មានភ្នែកជាដើម ប៉ះអាយតនៈ ខាងក្រៅ (អារម្មណ៍) ទាំង ៦ មានរូបជាដើម វិញ្ញាណ ក៏កើតឡើង ។ បន្ទាប់មក ផស្សៈ ឬ សម្ផស្សៈ កើតឡើង ។ អាស្រ័យផស្សៈ មានធម្មជាតិមួយទៀត ទទួលនាទីសោយ(ទទួលដឹង)នូវអារម្មណ៍





ជាសុខ ជាទុក្ខ ឬ មិនសុខមិនទុក្ខ កើតឡើង ។ ធម្មជាតិនោះឈ្មោះថា **វេទនា** ។

ក្នុងបដិច្ចសមុប្បាទ (ធម៌ដែលកើតមានឡើង ដោយសារបច្ច័យ) ព្រះពុទ្ធទ្រង់បានសំដែងថា :

“**សឡាយតនបច្ចយា ផស្សោ** អាយតនៈទាំង៦ ជាបច្ច័យនាំឲ្យកើតសម្ផស្ស” ។

“**ផស្សបច្ចយា វេទនា** សម្ផស្ស (ការប៉ះ) ជាបច្ច័យនាំឲ្យកើតវេទនា” ។

“**វេទនាបច្ចយា តណ្ហា** វេទនាជាបច្ច័យនាំឲ្យកើតតណ្ហា” ។

ការពន្យល់ពាក្យថា **វេទនា** តាមរយៈសុតមយបញ្ញា មិនលំបាកទេ ប៉ុន្តែគេមិនអាចយល់ពីអត្ថន័យជ្រាលជ្រៅ នៃពាក្យវេទនានេះបានឡើយ លុះត្រាតែគេពិសោធផ្ទាល់ តាមរយៈភាវនាមយបញ្ញា ទើបគេទទួលស្គាល់យល់ពីអាថ៌កំបាំង នៃពាក្យនេះបាន យ៉ាងពិតប្រាកដ ។

ពាក្យថា **សាមិស** បានសេចក្តីថា ប្រកបដោយការជាប់ចិត្ត ឬ ឧបាទាន ។ តាមន័យដើម គឺ **ស** + **អាមិស** ដែលមានសាច់ ។ ពាក្យថា **អាមិស** ប្រែថា វត្ថុដែលចិត្តជាប់ជំពាក់ ឬ ប្រាថ្នា បាន

ឥរិយាបថទាំង ៤ យ៉ាងនេះឯង ។

ក្នុងចិត្តានុបស្សនានេះ ព្រះបរមគ្រូ ទូន្មានភិក្ខុឲ្យពិចារណា រឿយៗ ដោយសតិរឭកដឹងជានិច្ច អំពីចិត្តប្រកបដោយកិលេស និង ចិត្តមិនប្រកបដោយកិលេស ក្នុងពុទ្ធបំណង ឲ្យភិក្ខុស្គាល់ច្បាស់នូវកិលេសធម៌ រួចព្យាយាមដុតកំឡោច (តបៈ) ឲ្យអស់ពីសន្តានចិត្ត ព្រោះធម្មជាតិរបស់ចិត្ត តែងស្ថិតនៅក្រោមអំណាចរបស់កិលេស ត្រូវកិលេសរួបរិត ពុំងាយយកឈ្នះវាបាន ដោយងាយឡើយ ។ ព្រះជិនស្រី ទ្រង់ត្រាស់ថា ៖

**យោ សហស្សំ សហស្សេន សង្គាមេ មានុសេ ជិនេ**
**ឯកញ្ច ជេយ្យមត្តានំ ស វេ សង្គាមជុត្តមោ ។**

សូម្បីបុគ្គលអាចយកជ័យជំនះ លើមនុស្សបានរាប់ពាន់នាក់ ក្នុងសង្គ្រាមរាប់ពាន់ដងក៏ដោយ ក៏មិនប្រសើរជាងការឈ្នះ លើខ្លួនឯងតែម្នាក់ឡើយ បុគ្គលអ្នកឈ្នះខ្លួនឯង ឈ្មោះថាជាអ្នកឈ្នះសង្គ្រាមដ៏ប្រសើរបំផុត ។

**អត្តា ហវេ ជិតំ សេយ្យោ**

ឈ្នះខ្លួនឯង ប្រសើរជាងឈ្នះអ្វីៗទាំងអស់ ។

ពាក្យថាឈ្នះខ្លួនឯង មានន័យថា ឈ្នះកិលេសតណ្ហា ដែលធ្វើចិត្តឲ្យសៅហ្មង ។ ដើម្បីជំរះចិត្តឲ្យស្អាត ត្រូវបដិបត្តិវិបស្សនា ឬ សតិបដ្ឋាន តាមឱវាទរបស់ព្រះអរហំសម្មាសម្ពុទ្ធ ។



# ចិត្តានុបស្សនា

ភិក្ខុទាំងឡាយ ពិចារណាឃើញរឿយៗ នូវចិត្តក្នុងចិត្ត តើយ៉ាងដូចម្តេច? ។ ភិក្ខុ ក្នុងសាសនានេះ

១- ទោះបីចិត្តប្រកបដោយរាគៈ (លោភមូល ៨ ប្រការ) ក៏ដឹងច្បាស់ថា “អាត្មាអញមានចិត្តប្រកបដោយរាគៈ” ។

២- ទោះបីចិត្តប្រាសចាករាគៈ (អរាគៈ ជាលោកិយកុសលចិត្ត និង អព្យាកតចិត្ត) ក៏ដឹងច្បាស់ថា “អាត្មាអញមានចិត្តប្រាសចាករាគៈ” ។

៣- ទោះបីចិត្តប្រកបដោយទោសៈ (ទោសមូលពីរប្រការ) ក៏ដឹងច្បាស់ថា “អាត្មាអញមានចិត្តប្រកបដោយទោសៈ” ។

៤- ទោះបីចិត្តប្រាសចាកទោសៈ (អទោសៈ ជាលោកិយកុសលចិត្ត និង អព្យាកតចិត្ត) ក៏ដឹងច្បាស់ថា “អាត្មាអញ មានចិត្តប្រាសចាកទោសៈ” ។

៥- ទោះបីចិត្តប្រកបដោយមោហៈ (មោហមូលពីរប្រការ) ក៏ដឹងច្បាស់ថា “អាត្មាអញ មានចិត្តប្រកបដោយមោហៈ” ។

៦- ទោះបីចិត្តប្រាសចាកមោហៈ (អមោហៈ ជាលោកិយកុសលចិត្ត និង អព្យាកតចិត្ត) ក៏ដឹងច្បាស់ថា “អាត្មាអញ មានចិត្តប្រាសចាកមោហៈ” ។

៧- ទោះបីចិត្តរួញរា (ចិត្តដែលថីនមិទ្ធៈគ្របសង្កត់) ក៏ដឹងច្បាស់ថា "អាត្មាអញ មានចិត្តរួញរា" ។

៨- ទោះបីចិត្តរាយមាយ (ឧទ្ធច្ចសហគតចិត្ត) ក៏ដឹងច្បាស់ថា "អាត្មាអញ មានចិត្តរាយមាយ" ។

៩- ទោះបីចិត្តដល់នូវភាពជាធំ (ជារូបាវចរចិត្ត និង អរូបាវចរចិត្ត) ក៏ដឹងច្បាស់ថា"អាត្មាអញមានចិត្តដល់នូវភាវៈជាធំ" ។

១០- ទោះបីចិត្តមិនដល់នូវភាវៈជាធំ (កាមាវចរចិត្ត) ក៏ដឹងច្បាស់ថា "អាត្មាអញមានចិត្តមិនដល់នូវភាវៈជាធំ" ។

១១- ទោះបីចិត្ត មានចិត្តដទៃប្រសើរជាង (នៅជាកាមាវចរចិត្ត) ក៏ដឹងច្បាស់ថា"អាត្មាអញនៅមានចិត្តដទៃប្រសើរជាង" ។

១២- ទោះបីចិត្ត មិនមានចិត្តដទៃប្រសើរជាង (ជារូបាវចរចិត្ត និង អរូបាវចរចិត្ត) ក៏ដឹងច្បាស់ថា "អាត្មាអញ មិនមានចិត្តដទៃប្រសើរជាង" ។

១៣- ទោះបីចិត្ត តំកល់ (តាំង) នៅមាំ (ជាអប្បនាសមាធិ និង ឧបចារសមាធិ) ក៏ដឹងច្បាស់ថា "អាត្មាអញ មានចិត្តតំកល់នៅមាំ" ។

១៤- ទោះបីចិត្តមិនតំកល់នៅមាំ ប្រាសចាកសមាធិទាំងពីរ ក៏ដឹងច្បាស់ថា "អាត្មាអញ មានចិត្តមិនតំកល់នៅមាំ" ។





១៥- ទោះបីចិត្តរួចស្រឡះ ក៏ដឹងច្បាស់ថា "អាត្មាអញ មានចិត្តរួចស្រឡះ" ។

១៦- ទោះបីចិត្តមិនទាន់រួចស្រឡះ ក៏ដឹងច្បាស់ថា "អាត្មាអញ មានចិត្តមិនទាន់រួចស្រឡះ" ។

ដូច្នេះ ភិក្ខុពិចារណារឿយៗនូវចិត្តក្នុងចិត្ត ជាខាងក្នុង(ដោយការកំណត់នូវចិត្តមានចិត្តប្រកបដោយរាគៈជាដើម) ឬ នូវចិត្តក្នុងចិត្តជាខាងក្រៅ និង នូវចិត្តក្នុងចិត្តទាំងខាងក្នុង និង ទាំងខាងក្រៅ ។

ភិក្ខុពិចារណាឃើញរឿយៗ នូវធម៌ដែលជាទីប្រជុំកើតឡើងក្នុងចិត្ត ឬ នូវធម៌ដែលសូន្យទៅក្នុងចិត្ត និង ទាំងធម៌ដែលប្រជុំកើតឡើង ទាំងធម៌ដែលសូន្យទៅក្នុងចិត្ត ។

ម្យ៉ាងទៀត ស្មារតី (សតិជាគ្រឿងកំណត់នូវចិត្ត) នៃភិក្ខុនោះ ក៏ផ្ចង់ចំពោះទៅថា គ្រាន់តែជាចិត្ត (មិនមែនសត្វ មិនមែនបុគ្គល មិនមែនស្រី មិនមែនប្រុសជាដើម) គ្រាន់តែជាទីកំណត់ដើម្បីឲ្យចំរើនប្រាជ្ញា ដើម្បីឲ្យចំរើនស្មារតីប៉ុណ្ណោះ ។

ភិក្ខុនោះ មានចិត្តមិនអាស្រ័យ(ដោយតណ្ហា និង ទិដ្ឋិ) ផងមិនប្រកៀកប្រកាន់អ្វីតិចតួច ក្នុងលោកផង ។

ភិក្ខុពិចារណាឃើញរឿយៗ នូវចិត្តក្នុងចិត្តជាប្រក្រតី គ្រប់

វិចិកិច្ឆា ដែលលះបង់បានហើយ មិនកើតតទៅទៀត ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះ ។

### ២- **ខន្ធបព្វៈ**

ភិក្ខុ ក្នុងសាសនានេះ ពិចារណាឃើញរឿយៗ នូវធម៌ក្នុងធម៌ទាំងឡាយ គឺ “**ឧបាទានក្ខន្ធ** ៥ គឺ ១-**រូបក្ខន្ធ** ២-**វេទនាខន្ធ** ៣-**សញ្ញាខន្ធ** ៤-**សង្ខារក្ខន្ធ** ៥-**វិញ្ញាណក្ខន្ធ** ។

ភិក្ខុ ក្នុងសាសនានេះ

១- ដឹងច្បាស់ថាៈ **រូប** មានប្រមាណប៉ុណ្ណេះ ធម៌ដែលជាដែនកើតឡើងនៃរូប មានប្រមាណប៉ុណ្ណេះ និង ធម៌ដែលជាដែនរលត់ (វិនាស) នៃរូប មានប្រមាណប៉ុណ្ណេះ ។

២- ដឹងច្បាស់ថាៈ **វេទនា** មានប្រមាណប៉ុណ្ណេះ ធម៌ដែលជាដែនកើតឡើងនៃវេទនា មានប្រមាណប៉ុណ្ណេះ និង ធម៌ដែលជាដែនរលត់នៃវេទនា មានប្រមាណប៉ុណ្ណេះ ។

៣- ដឹងច្បាស់ថាៈ **សញ្ញា** មានប្រមាណប៉ុណ្ណេះ ធម៌ដែលជាដែនកើតឡើងនៃសញ្ញា មានប្រមាណប៉ុណ្ណេះ និង ធម៌ដែលជាដែនរលត់នៃសញ្ញា មានប្រមាណប៉ុណ្ណេះ ។

៤- ដឹងច្បាស់ថាៈ **សង្ខារ** មានប្រមាណប៉ុណ្ណេះ ធម៌ដែលជាដែនកើតឡើងនៃសង្ខារ មានប្រមាណប៉ុណ្ណេះ និង ធម៌



# ធម្មានុបស្សនា

ធម្មានុបស្សនា គឺការពិចារណាឃើញរឿយៗនូវធម៌ក្នុងធម៌ទាំងឡាយមាន ៦ បព្វៈ ឬ បែប ។

### ១- **នីវរណបព្វៈ**

ភិក្ខុពិចារណាឃើញរឿយៗ នូវធម៌ក្នុងធម៌ គឺនីវរណៈ ៥ : ១- **កាមច្ឆន្ទៈ** (សេចក្តីប្រាថ្នាក្នុងកាម), ២- **ព្យាបាទ** (ការញុំាងប្រយោជន៍ និង សេចក្តីសុខរបស់អ្នកដទៃឲ្យវិនាស), ៣-**ថីនមិទ្ធៈ** (សេចក្តីខ្ជិលច្រអូស ឬ រួញរា), ៤- **ឧទ្ធច្ចកុក្កុច្ចៈ** (សេចក្តីរាយមាយ), ៥- **វិចិកិច្ឆា** (សេចក្តីសង្ស័យ) ។

ភិក្ខុក្នុងសាសនានេះ

១- ទោះ **កាមច្ឆន្ទៈ** មាននៅក្នុងសន្តានចិត្តនៃខ្លួន ក៏ដឹងច្បាស់ថា “កាមច្ឆន្ទៈ មាននៅក្នុងសន្តានចិត្តរបស់អាត្មាអញ” ។ ទោះ **កាមច្ឆន្ទៈ** មិនមាននៅក្នុងសន្តានចិត្តនៃខ្លួន ក៏ដឹងច្បាស់ថា “កាមច្ឆន្ទៈ មិនមាននៅក្នុងសន្តានចិត្តរបស់អាត្មាអញ” ។ ទោះ កាមច្ឆន្ទៈ ដែលមិនទាន់កើតឡើង ហើយកើតឡើងបាន ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះ ។ កាលលះបង់នូវកាមច្ឆន្ទៈ ដែលកើតឡើងហើយ ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះ។ កាមច្ឆន្ទៈ ដែលលះបង់បានហើយ មិនកើតតទៅទៀត ដោយ

ហេតុណា ក៏ដឹងច្បាស់នូវហេតុនោះ ។

២- ទោះ **ព្យាបាទ** មាននៅក្នុងសន្តានចិត្តនៃខ្លួនក៏ដឹងច្បាស់ថា "ព្យាបាទ មាននៅក្នុងសន្តានចិត្ត របស់អាត្មាអញ" ។ ទោះព្យាបាទមិនមាននៅក្នុងសន្តានចិត្តនៃខ្លួន ក៏ដឹងច្បាស់ថា "ព្យាបាទមិនមាននៅក្នុងសន្តានចិត្តរបស់អាត្មាអញ" ។ ទោះព្យាបាទដែលមិនទាន់កើតឡើង ហើយកើតឡើងបាន ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះ" ។ កាលលះបង់នូវព្យាបាទ ដែលកើតឡើងហើយ ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះ ។ ព្យាបាទដែលលះបង់បានហើយ មិនកើតតទៅទៀត ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះ ។

៣- ទោះ **ថីនមិទ្ធៈ** មាននៅក្នុងសន្តានចិត្តនៃខ្លួន ក៏ដឹងច្បាស់ថា "ថីនមិទ្ធៈ មាននៅក្នុងសន្តានចិត្ត របស់អាត្មាអញ" ។ ទោះថីនមិទ្ធៈ មិនមាននៅក្នុងសន្តានចិត្តនៃខ្លួន ក៏ដឹងច្បាស់ថា "ថីនមិទ្ធៈ មិនមាននៅក្នុងសន្តានចិត្តរបស់អាត្មាអញ" ។ ទោះថីនមិទ្ធៈ ដែលមិនទាន់កើតឡើង ហើយកើតឡើងបាន ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះ ។ កាលលះបង់នូវថីនមិទ្ធៈ ដែលកើតឡើងហើយ ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះ ។ ថីនមិទ្ធៈ ដែលលះបង់បានហើយ មិនកើតតទៅទៀត



ព្រះពុទ្ធដីកា

ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះ ។

៤- ទោះ **ឧទ្ធច្ចកុក្កុច្ចៈ** មាននៅក្នុងសន្តានចិត្តនៃខ្លួន ក៏ដឹងច្បាស់ថា "ឧទ្ធច្ចកុក្កុច្ចៈ មាននៅក្នុងសន្តានចិត្ត របស់អាត្មាអញ" ។ ទោះឧទ្ធច្ចកុក្កុច្ចៈ មិនមាននៅក្នុងសន្តានចិត្តនៃខ្លួន ក៏ដឹងច្បាស់ថា "ឧទ្ធច្ចកុក្កុច្ចៈ មិនមាននៅក្នុងសន្តានចិត្ត របស់អាត្មាអញ" ។ ទោះឧទ្ធច្ចកុក្កុច្ចៈ ដែលមិនទាន់កើតឡើង ហើយកើតឡើងបាន ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះ ។ កាលលះបង់នូវឧទ្ធច្ចកុក្កុច្ចៈ ដែលកើតឡើងហើយ ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះ ។ ឧទ្ធច្ចកុក្កុច្ចៈ ដែលលះបង់បានហើយ មិនកើតតទៅទៀត ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះ ។

៥- ទោះ **វិចិកិច្ឆា** មាននៅក្នុងសន្តានចិត្តនៃខ្លួន ក៏ដឹងច្បាស់ថា "វិចិកិច្ឆា មាននៅក្នុងសន្តានចិត្ត របស់អាត្មាអញ" ។ ទោះ វិចិកិច្ឆា មិនមាននៅក្នុងសន្តានចិត្តនៃខ្លួន ក៏ដឹងច្បាស់ថា "វិចិកិច្ឆា មិនមាននៅក្នុងសន្តានចិត្ត របស់អាត្មាអញ" ។ ទោះ វិចិកិច្ឆា ដែលមិនទាន់កើតឡើង ហើយកើតឡើងបាន ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះ ។ កាលលះបង់នូវវិចិកិច្ឆា ដែលកើតឡើងហើយ ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះ ។

កើតឡើង ដោយហេតុណា ក៏ដឹងច្បាស់ នូវហេតុនោះ ។ សំយោជនធម៌ ដែលលះបង់បានហើយ មិនកើតតទៅទៀត ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះ ។

-ដឹងច្បាស់នូវ **ចិត្តប្រសាទ** ផង ដឹងច្បាស់នូវ **ធម្មារម្មណ៍** ទាំងឡាយផង ។ មួយទៀត សំយោជនធម៌ណា ដែលអាស្រ័យនូវចិត្ត និង ធម្មារម្មណ៍ ទាំងពីរនោះ ហើយកើតឡើង ក៏ដឹងច្បាស់ នូវសំយោជនធម៌នោះ ។ សំយោជនធម៌ ដែលមិនទាន់កើតឡើង ហើយកើតឡើងបាន ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះ ។ កាលលះបង់បាននូវសំយោជនធម៌ ដែលកើតឡើង ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះ ។ សំយោជនធម៌ ដែលលះបង់បានហើយ មិនកើតតទៅទៀត ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះ ។

## ៤- **ពោជ្ឈង្គបព្វៈ**

ភិក្ខុពិចារណារឿយៗ នូវធម៌ក្នុងធម៌ទាំងឡាយ គឺ **ពោជ្ឈង្គ** (អង្គនៃធម៌ជាគ្រឿងត្រាស់ដឹង) ៧ ប្រការ គឺ: ១- **សតិ** (ការប្រុងស្មារតី), ២- **ធម្មវិចយ** (សភាវៈពិចារណានូវធម៌), ៣- **វីរិយៈ** (សេចក្តីព្យាយាម), ៤- **បីតិ** (ធម្មជាតិញ៉ាំងកាយ និង ចិត្ត ឲ្យឆ្អែត ឬ ឲ្យចំរើន), ៥- **បស្សទ្ធិ** (សេចក្តីស្ងប់កាយ និង ចិត្ត),





ដែលជាដែនរលត់នៃសង្ខារ មានប្រមាណប៉ុណ្ណេះ ។

៥- ដឹងច្បាស់ថា: **វិញ្ញាណ** មានប្រមាណប៉ុណ្ណេះ ធម៌ដែលជាដែនកើតឡើងនៃវិញ្ញាណ មានប្រមាណប៉ុណ្ណេះ និង ធម៌ដែលជាដែនរលត់នៃវិញ្ញាណ មានប្រមាណប៉ុណ្ណេះ ។

## ៣- **អាយតនបព្វៈ**

អាយតនៈ ខាងក្នុង ៦ (ជាឥន្ទ្រីយ៍) គឺ ភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ និង ចិត្ត ។

អាយតនៈ ខាងក្រៅ ៦ (ជាអារម្មណ៍) គឺ រូប សំឡេង ក្លិន រស ផោដ្ឋព្វៈ និង ធម៌ (ជាធម្មារម្មណ៍) ។

ភិក្ខុពិចារណាឃើញរឿយៗ នូវធម៌ក្នុងធម៌ទាំងឡាយ គឺ អាយតនៈខាងក្នុង ៦ និង អាយតនៈខាងក្រៅ ៦ យ៉ាងដូច្នេះថា៖

ភិក្ខុ ក្នុងសាសនានេះ

-ដឹងច្បាស់នូវ **ចក្ខុប្រសាទ** ដឹងច្បាស់នូវ **រូបារម្មណ៍** ទាំងឡាយ ។ មួយទៀត សំយោជនធម៌ណា ដែលអាស្រ័យនូវភ្នែក និង រូប ទាំងពីរនោះ ហើយកើតឡើង ក៏ដឹងច្បាស់នូវសំយោជនធម៌នោះ។ សំយោជនធម៌ដែលមិនទាន់កើតឡើងហើយកើតឡើងបាន ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះ។ កាលលះបង់បាន នូវសំយោជនធម៌ដែលកើតឡើង ដោយហេតុណា

ក៏ដឹងច្បាស់នូវហេតុនោះ ។ សំយោជនធម៌ ដែលលះបង់បាន
ហើយ មិនកើតតទៅទៀត ដោយហេតុណា ក៏ដឹងច្បាស់នូវ
ហេតុនោះ ។

-ដឹងច្បាស់នូវ **សោតប្រសាទ** ផង ដឹងច្បាស់នូវ **សទ្ទា-
រម្មណ៍** ទាំងឡាយផង ។ មួយទៀត សំយោជនធម៌ណា ដែល
អាស្រ័យនូវត្រចៀក និង សំឡេង ទាំងពីរនោះ ហើយកើត
ឡើង ក៏ដឹងច្បាស់នូវសំយោជនធម៌នោះ ។ សំយោជនធម៌
ដែលមិនទាន់កើតឡើង ហើយកើតឡើងបាន ដោយហេតុណា
ក៏ដឹងច្បាស់នូវហេតុនោះ ។ កាលលះបង់បាន នូវសំយោជនធម៌
ដែលកើតឡើង ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះ ។
សំយោជនធម៌ ដែលលះបង់បានហើយ មិនកើតតទៅទៀត
ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះ ។

-ដឹងច្បាស់នូវ **ឃានប្រសាទ** ផង ដឹងច្បាស់នូវ **គន្ធា-
រម្មណ៍** ទាំងឡាយផង ។ មួយទៀត សំយោជនធម៌ណា ដែល
អាស្រ័យនូវច្រមុះ និង ក្លិន ទាំងពីរនោះ ហើយកើតឡើង ក៏ដឹង
ច្បាស់នូវសំយោជនធម៌នោះ ។ សំយោជនធម៌ ដែលមិនទាន់
កើតឡើង ហើយកើតឡើងបាន ដោយហេតុណា ក៏ដឹងច្បាស់នូវ
ហេតុនោះ ។ កាលលះបង់បាន នូវសំយោជនធម៌ ដែលកើត





ឡើង ដោយហេតុណា ក៏ដឹងច្បាស់ នូវហេតុនោះ ។ សំយោជន-
ធម៌ ដែលលះបង់បានហើយ មិនកើតតទៅទៀត ដោយហេតុណា
ក៏ដឹងច្បាស់នូវហេតុនោះ ។

-ដឹងច្បាស់នូវ **ជិវ្ហាប្រសាទ** ផង ដឹងច្បាស់នូវ **រសា-
រម្មណ៍** ទាំងឡាយផង ។ មួយទៀត សំយោជនធម៌ណា ដែល
អាស្រ័យនូវអណ្តាត និង រស ទាំងពីរនោះ ហើយកើតឡើង
ក៏ដឹងច្បាស់នូវសំយោជនធម៌នោះ ។ សំយោជនធម៌ ដែលមិន
ទាន់កើតឡើងហើយ កើតឡើងបាន ដោយហេតុណា ក៏ដឹង
ច្បាស់នូវហេតុនោះ ។ កាលលះបង់បាន នូវសំយោជនធម៌ដែល
កើតឡើង ដោយហេតុណា ក៏ដឹងច្បាស់ នូវហេតុនោះ ។
សំយោជនធម៌ ដែលលះបង់បានហើយ មិនកើតតទៅទៀត
ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះ ។

-ដឹងច្បាស់នូវ **កាយប្រសាទ** ផង ដឹងច្បាស់នូវ **ផោដ្ឋព្វា-
រម្មណ៍** ទាំងឡាយផង ។ មួយទៀត សំយោជនធម៌ណា ដែល
អាស្រ័យនូវកាយ និង ផោដ្ឋព្វៈ ទាំងពីរនោះ ហើយកើតឡើង
ក៏ដឹងច្បាស់ នូវសំយោជនធម៌នោះ ។ សំយោជនធម៌ ដែល
មិនទាន់កើតឡើង ហើយកើតឡើងបាន ដោយហេតុណា ក៏ដឹង
ច្បាស់នូវហេតុនោះ ។ កាលលះបង់បាននូវសំយោជនធម៌ ដែល

៧- ទោះបី **ឧបេក្ខាសម្ពោជ្ឈង្គ** មាននៅក្នុងសន្តានចិត្ត នៃខ្លួន ក៏ដឹងច្បាស់ថា ឧបេក្ខាសម្ពោជ្ឈង្គ មាននៅក្នុងសន្តានចិត្ត របស់អាត្មាអញ ។ ទោះបី ឧបេក្ខាសម្ពោជ្ឈង្គ មិនមាននៅក្នុងសន្តានចិត្តនៃខ្លួន ក៏ដឹងច្បាស់ថា ឧបេក្ខាសម្ពោជ្ឈង្គ មិនមាននៅក្នុងសន្តានចិត្ត របស់អាត្មាអញ ។ ទោះបី ឧបេក្ខាសម្ពោជ្ឈង្គ មិនទាន់កើតឡើង ហើយកើតឡើងបាន ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះ ។ ការចំរើនពេញបរិបូណ៌ នៃឧបេក្ខា-សម្ពោជ្ឈង្គ ដែលកើតឡើងហើយ ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះ ។

## ៥- **អរិយសច្ចបព្វៈ**

ភិក្ខុពិចារណាឃើញរឿយៗ នូវធម៌ក្នុងធម៌ទាំងឡាយ គឺ អរិយសច្ច ៤ គឺ :

ភិក្ខុក្នុងសាសនានេះ

១- ដឹងច្បាស់ពិតប្រាកដថា នេះជា **ទុក្ខ**

២- ដឹងច្បាស់ពិតប្រាកដថា នេះជា **ហេតុឱ្យកើតទុក្ខ**

៣- ដឹងច្បាស់ពិតប្រាកដថា នេះជា **ការរំលត់ទុក្ខ**

៤- ដឹងច្បាស់ពិតប្រាកដថា នេះជា **ទុក្ខនិរោធគាមិនីបដិបទា**

(មាគ៌ាឆ្ពោះទៅរកការរំលត់ទុក្ខ) ។



ព្រះពុទ្ធដីកា

៦- **សមាធិ** (តាំងចិត្តនៅស្មើក្នុងអារម្មណ៍), ៧- **ឧបេក្ខា** (ការតាំងចិត្តជាកណ្តាល ឬ ព្រងើយ) ។

ភិក្ខុ ក្នុងសាសនានេះ

១- ទោះបី **សតិសម្ពោជ្ឈង្គ** មាននៅក្នុងសន្តានចិត្តនៃខ្លួន ក៏ដឹងច្បាស់ថា សតិសម្ពោជ្ឈង្គ មាននៅក្នុងសន្តានចិត្ត របស់អាត្មាអញ ។ ទោះបីសតិសម្ពោជ្ឈង្គ មិនមាននៅក្នុងសន្តានចិត្តនៃខ្លួន ក៏ដឹងច្បាស់ថា សតិសម្ពោជ្ឈង្គ មិនមាននៅក្នុងសន្តានចិត្ត របស់អាត្មាអញ ។ ទោះបីសតិសម្ពោជ្ឈង្គ មិនទាន់កើតឡើង ហើយកើតឡើងបាន ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះ។ កិរិយាចំរើនពេញបរិបូណ៌ នៃសតិសម្ពោជ្ឈង្គ ដែលកើតឡើង ហើយ ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះ ។

២- ទោះបី **ធម្មវិចយសម្ពោជ្ឈង្គ** មាននៅក្នុងសន្តានចិត្ត នៃខ្លួន ក៏ដឹងច្បាស់ថា ធម្មវិចយសម្ពោជ្ឈង្គ មាននៅក្នុងសន្តាន ចិត្ត របស់អាត្មាអញ ។ ទោះបីធម្មវិចយសម្ពោជ្ឈង្គ មិនមាននៅ ក្នុងសន្តានចិត្តនៃខ្លួន ក៏ដឹងច្បាស់ថា ធម្មវិចយសម្ពោជ្ឈង្គ មិន មាននៅក្នុងសន្តានចិត្ត របស់អាត្មាអញ ។ ទោះបីធម្មវិចយ-សម្ពោជ្ឈង្គ មិនទាន់កើតឡើង ហើយកើតឡើងបាន ដោយ ហេតុណា ក៏ដឹងច្បាស់ នូវហេតុនោះ ។ កិរិយាចំរើនពេញ

បរិបូណ៌ នៃធម្មវិចយសម្ពោជ្ឈង្គ ដែលកើតឡើងហើយ ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះ ។

៣- ទោះបី **វីរិយសម្ពោជ្ឈង្គ** មាននៅក្នុងសន្តានចិត្តនៃខ្លួន ក៏ដឹងច្បាស់ថា វីរិយសម្ពោជ្ឈង្គ មាននៅក្នុងសន្តានចិត្ត របស់អាត្មាអញ ។ ទោះបី វីរិយសម្ពោជ្ឈង្គ មិនមាននៅក្នុងសន្តានចិត្តនៃខ្លួន ក៏ដឹងច្បាស់ថា វីរិយសម្ពោជ្ឈង្គ មិនមាននៅក្នុងសន្តានចិត្តរបស់អាត្មាអញ ។ ទោះបី វីរិយសម្ពោជ្ឈង្គ មិនទាន់កើតឡើងហើយកើតឡើងបាន ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះ។ កិរិយាចំរើនពេញបរិបូណ៌ នៃវីរិយសម្ពោជ្ឈង្គ ដែលកើតឡើងហើយ ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះ ។

៤- ទោះបី **បីតិសម្ពោជ្ឈង្គ** មាននៅក្នុងសន្តានចិត្តនៃខ្លួន ក៏ដឹងច្បាស់ថា បីតិសម្ពោជ្ឈង្គ មាននៅក្នុងសន្តានចិត្ត របស់អាត្មាអញ ។ ទោះបី បីតិសម្ពោជ្ឈង្គ មិនមាននៅក្នុងសន្តានចិត្តនៃខ្លួន ក៏ដឹងច្បាស់ថា បីតិសម្ពោជ្ឈង្គ មិនមាននៅក្នុងសន្តានចិត្តរបស់អាត្មាអញ ។ ទោះបី បីតិសម្ពោជ្ឈង្គ មិនទាន់កើតឡើងហើយកើតឡើងបាន ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះ។ កិរិយាចំរើនពេញបរិបូណ៌ នៃបីតិសម្ពោជ្ឈង្គ ដែលកើតឡើងហើយ ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះ ។





៥- ទោះបី **បស្សទ្ធិសម្ពោជ្ឈង្គ** មាននៅក្នុងសន្តានចិត្តនៃខ្លួនក៏ដឹងច្បាស់ថា បស្សទ្ធិសម្ពោជ្ឈង្គមាននៅក្នុងសន្តានចិត្តរបស់អាត្មាអញ ។ ទោះបី បស្សទ្ធិសម្ពោជ្ឈង្គ មិនមាននៅក្នុងសន្តានចិត្តនៃខ្លួន ក៏ដឹងច្បាស់ថា បស្សទ្ធិសម្ពោជ្ឈង្គ មិនមាននៅក្នុងសន្តានចិត្ត របស់អាត្មាអញ ។ ទោះបី បស្សទ្ធិសម្ពោជ្ឈង្គ មិនទាន់កើតឡើង ហើយកើតឡើងបាន ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះ ។ ការចំរើនពេញបរិបូណ៌ នៃបស្សទ្ធិសម្ពោជ្ឈង្គ ដែលកើតឡើងហើយ ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះ ។

៦- ទោះបី **សមាធិសម្ពោជ្ឈង្គ** មាននៅក្នុងសន្តានចិត្ត នៃខ្លួន ក៏ដឹងច្បាស់ថា សមាធិសម្ពោជ្ឈង្គ មាននៅក្នុងសន្តានចិត្តរបស់អាត្មាអញ ។ ទោះបី សមាធិសម្ពោជ្ឈង្គ មិនមាននៅក្នុងសន្តានចិត្តនៃខ្លួន ក៏ដឹងច្បាស់ថា សមាធិសម្ពោជ្ឈង្គ មិនមាននៅក្នុងសន្តានចិត្ត របស់អាត្មាអញ ។ ទោះបី សមាធិសម្ពោជ្ឈង្គ មិនទាន់កើតឡើង ហើយកើតឡើងបាន ដោយហេតុណា ក៏ដឹងច្បាស់ នូវហេតុនោះ ។ ការចំរើនពេញបរិបូណ៌ នៃសមាធិសម្ពោជ្ឈង្គ ដែលកើតឡើងហើយ ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះ ។

ម្នាលភិក្ខុទាំងឡាយ ចុះដូចម្តេចដែលហៅថា **ទោមនស្សៈ** (សេចក្តីអាក់អន់ចិត្ត) ? ។

សេចក្តីអាក់អន់ចិត្ត, សេចក្តីមិនសប្បាយចិត្ត, សេចក្តីលំបាក ដែលបណ្តាលមកអំពីមនោសម្ផស្ស គឺការប៉ះពាល់ តាមផ្លូវចិត្ត ។ ម្នាលភិក្ខុទាំងឡាយ នេះហើយហៅថា **ទោមនស្សៈ** ។

ម្នាលភិក្ខុទាំងឡាយ ចុះដូចម្តេចដែលហៅថា **ឧបាយាសៈ** (សេចក្តីចង្អៀតចង្អល់ចិត្ត) ? ។

កាលណា គេជួបប្រទះនឹងការបាត់បង់ ឬ អពមង្គលផ្សេងៗ ដែលនាំឲ្យកើតសេចក្តីព្រួយចិត្តបែបណា, ភាពតានតឹងនៅក្នុងចិត្ត, សេចក្តីចង្អៀតចង្អល់ចិត្ត, សេចក្តីខ្លោចផ្សាចិត្ត, ភាពនៃការតានតឹង និង សេចក្តីចង្អៀតចង្អល់នៅក្នុងចិត្ត ។ ម្នាលភិក្ខុទាំងឡាយ នេះហើយហៅថា **ឧបាយាសៈ** ។

ម្នាលភិក្ខុទាំងឡាយ ចុះដូចម្តេចដែលហៅថា **អប្បិយេហិសម្បយោគទុក្ខ** (ទុក្ខដោយការជួបប្រសព្វ ជាមួយនឹងរបស់មិនចូលចិត្ត) ? ។

នៅទីណា និង នៅពេលណា គេជួបប្រសព្វនឹងរូបារម្មណ៍ (រូបភាព), សទ្ទារម្មណ៍ (សំឡេង), គន្ធារម្មណ៍ (ក្លិន), រសារម្មណ៍ (រសជាតិ), ផោដ្ឋព្វារម្មណ៍ (ការប៉ះដោយកាយ), ធម្មា-





## ទុក្ខសច្ច

ម្នាលភិក្ខុទាំងឡាយ! ចុះសេចក្តីពិតអំពី **ទុក្ខ** នោះ តើយ៉ាងដូចម្តេច? ។

គឺ ជាតិ (កំណើត), ជរា (សេចក្តីចាស់), ព្យាធិ (ជំងឺ), មរណៈ(សេចក្តីស្លាប់), សោកៈ (សេចក្តីសោកស្តាយស្រណោះ), បរិទេវៈ (សេចក្តីខ្សឹកខ្សួល), ទុក្ខ (សេចក្តីលំបាកកាយ), ទោមនស្ស (សេចក្តីអាក់អន់ចិត្ត), ឧបាយាសៈ (សេចក្តីចង្អៀតចង្អល់ចិត្ត), អប្បិយេហិសម្បយោគទុក្ខ (ការជួបប្រសព្វនឹងរបស់ដែលមិនចូលចិត្ត), បិយេហិវិប្បយោគទុក្ខ (ការព្រាត់ប្រាសចាករបស់ដែលជាទីចូលចិត្ត), យម្បិច្ឆំ ន លភតិ តម្បិទុក្ខ (ការប្រាថ្នាចង់បានរបស់ណា ហើយមិនបានដូចប្រាថ្នា) ទាំងអស់នេះជាទុក្ខ ។ ដោយសង្ខេប បញ្ចុបាទានក្ខន្ធ (ការប្រកាន់ខ្ជាប់ទៅលើខន្ធ ៥) ជា **ទុក្ខ** ។

ម្នាលភិក្ខុទាំងឡាយ! ចុះដូចម្តេចហៅថា **ជាតិ** ឬ **កំណើត**?

គឺ កំណើត គឺការកើតនៃសត្វទាំងឡាយ ក្នុងសត្តនិកាយផ្សេងៗ, ការចាប់បដិសន្ធិ, ការកើតចេញពីផ្ទៃម្តាយ, ការវិវឌ្ឍន៍ទៅរកកំណើត, ការកើតឡើងនៃខន្ធ, ការបានមកនូវអាយតនៈរបស់សត្វទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ នេះហើយហៅថា

**ជាតិ** ឬ **កំណើត** ។

ម្នាលភិក្ខុទាំងឡាយ ចុះដូចម្ដេចដែលហៅថា **ជរា** (សេចក្ដីចាស់)? ។

ជរា គឺសេចក្ដីចាស់គ្រាំគ្រា របស់សត្វទាំងឡាយ ក្នុងសត្តនិកាយផ្សេងៗ, ការចុះទន់ខ្សោយ និង ការទ្រុឌទ្រោម, ភាពបាក់ធ្មេញ, សក់ស្កូវ, ស្បែកជ្រីវជ្រួញ, ការរួញថយនៃអាយុ, ការទ្រុឌទ្រោម នៃឥន្ទ្រីយ៍ទាំងឡាយរបស់សត្វលោក ។ ម្នាលភិក្ខុទាំងឡាយ នេះហើយហៅថា **ជរា** ។

ម្នាលភិក្ខុទាំងឡាយ ចុះដូចម្ដេចទៅដែលហៅថា **មរណៈ** (សេចក្ដីស្លាប់)? ។

មរណៈ គឺការបាត់បង់, ការចេញចាករបស់សត្វទាំងឡាយពីសត្តនិកាយផ្សេងៗ, ការបែកធ្លាយ, ការបាត់បង់, ការរលត់ទៅវិញនៃជីវិត, សេចក្ដីស្លាប់, កាលកិរិយា, ការបែកធ្លាយ នៃខន្ធទាំងឡាយ, ការបោះបង់ចោលកាយ, ការផ្ដាច់ផ្ដិលជីវិតិន្ទ្រីយ៍របស់សត្វទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ នេះហើយហៅថា **មរណៈ** ។

ម្នាលភិក្ខុទាំងឡាយ ចុះដូចម្ដេចទៅដែលហៅថា **សោកៈ** (សេចក្ដីស្ដាយស្រណោះ)? ។





កាលណា គេជួបប្រទះនឹងការខាតបង់ ឬ អពមង្គលផ្សេងៗ ដែលនាំឲ្យមានសេចក្ដីព្រួយចិត្ត បែបណាមួយ, សេចក្ដីស្ដាយស្រណោះ, សេចក្ដីស្រងេះស្រងោច, សេចក្ដីសង្រេងសង្រែ, សេចក្ដីក្រៀមក្រំក្នុងចិត្តរបស់សត្វ ។ ម្នាលភិក្ខុទាំងឡាយ នេះហើយហៅថា **សោកៈ** ។

ម្នាលភិក្ខុទាំងឡាយ ចុះដូចម្ដេចទៅដែលហៅថា **បរិទេវៈ** (សេចក្ដីខ្សឹកខ្សួល) ? ។

កាលណា គេជួបប្រទះនឹងការខាតបង់ ឬ អពមង្គលផ្សេងៗ ដែលនាំឲ្យមានសេចក្ដីព្រួយចិត្ត បែបណាមួយ, ការយំសោកខ្សឹកខ្សួល ទួញ រៀបរាប់, ទួញត្អូញត្អែ, យំអណ្ដើតអណ្ដក់, ភាពនៃការខ្សឹកខ្សួល និង យំអណ្ដើតអណ្ដក់ ។ ម្នាលភិក្ខុទាំងឡាយ នេះហើយហៅថា **បរិទេវៈ** ។

ម្នាលភិក្ខុទាំងឡាយ ចុះដូចម្ដេចទៅដែលហៅថា **ទុក្ខៈ** (សេចក្ដីលំបាកកាយ) ? ។

កាលណា មានការលំបាកនៅក្នុងកាយ, មានសេចក្ដីមិនសប្បាយ, មានការឈឺចុកចាប់ដែលបណ្ដាលមកពីកាយសម្ផស្ស គឺការប៉ះពាល់តាមផ្លូវកាយ ។ ម្នាលភិក្ខុទាំងឡាយ នេះហើយហៅថា **ទុក្ខៈ** ។

របស់ដែលគេប្រាថ្នាចង់បានទុំះ ជាទុក្ខ ។

ម្នាលភិក្ខុទាំងឡាយ ពួកសត្វដែលមានសេចក្ដីស្ដាយស្រណោះ, សេចក្ដីខ្សឹកខ្សួល, សេចក្ដីលំបាកកាយ, សេចក្ដីអាក់អន់ចិត្ត, ឬ សេចក្ដីចង្អៀតចង្អល់ចិត្តជាធម្មតា តែងមានសេចក្ដីប្រាថ្នាកើតឡើងយ៉ាងនេះថា ធ្វើដូចម្ដេចហ្ន៎ កុំឲ្យយើងទាំងឡាយមានសេចក្ដីស្ដាយស្រណោះ សេចក្ដីខ្សឹកខ្សួល, សេចក្ដីលំបាកកាយ, សេចក្ដីអាក់អន់ចិត្ត, ឬ សេចក្ដីចង្អៀតចង្អល់ចិត្ត? ពុំនោះសោត ធ្វើដូចម្ដេចទៅហ្ន៎ កុំឲ្យមានសេចក្ដីស្ដាយស្រណោះ សេចក្ដីខ្សឹកខ្សួល, សេចក្ដីលំបាកកាយ, សេចក្ដីអាក់អន់ចិត្ត, ឬ សេចក្ដីចង្អៀតចង្អល់ចិត្ត កើតមានដល់យើងទាំងឡាយ? តែពួកសត្វ មិនអាចសំរេចសេចក្ដីប្រាថ្នានេះបាន ដោយគ្រាន់តែប្រាថ្នាទទេៗ នោះ កើតឡើយ ហើយការមិនបានរបស់ដែលគេប្រាថ្នាចង់បានទុំះ ជាទុក្ខ ។

ម្នាលភិក្ខុទាំងឡាយ ចុះដូចម្ដេចដែលហៅ ដោយសង្ខេបថា **បញ្ចុបាទានក្ខន្ធទុក្ខ** គឺការប្រកាន់ខ្ជាប់ទៅលើខន្ធ ៥ នោះជាទុក្ខ? សេចក្ដីនេះមានដូចតទៅៈ ការប្រកាន់ខ្ជាប់ទៅលើ **រូបក្ខន្ធ** ជាទុក្ខ, ការប្រកាន់ខ្ជាប់ទៅលើ **វេទនាខន្ធ** ជាទុក្ខ, ការប្រកាន់ខ្ជាប់ទៅលើ **សញ្ញាខន្ធ** ជាទុក្ខ, ការប្រកាន់ខ្ជាប់ទៅលើ**សង្ខារក្ខន្ធ**





រម្មណ៍ (ធម៌), រូប, សំឡេង, ក្លិន, រស, សម្ផស្ស, ឬ ធម្មារម្មណ៍ដែលមិនជាទីប្រាថ្នា, មិនជាទីត្រេកអរ, មិនជាទីគាប់ចិត្ត ពុំនោះសោត នៅទីណា និង នៅពេលណា គេជួបប្រទះនឹងជនទាំងឡាយណាដែលប្រាថ្នាឲ្យគេមានអពមង្គល, សេចក្ដីឈឺចាប់, សេចក្ដីលំបាកផ្សេងៗ ឬ ឲ្យគេមានអសន្តិសុខ, ការដែលជួបប្រសព្វ, ជួបប្រទះ, ជួបទាក់ទង នៅប្រឡូកប្រឡំជាមួយនឹងអារម្មណ៍ ឬ ជនទាំងឡាយនោះ ។ ម្នាលភិក្ខុទាំងឡាយ នេះហើយហៅថា **អប្បិយេហិ សម្បយោគទុក្ខ** ។

ម្នាលភិក្ខុទាំងឡាយ ចុះដូចម្ដេចទៅដែលហៅថា **បិយេហិ វិប្បយោគទុក្ខ** (ឬ ទុក្ខដោយការព្រាត់ប្រាសអំពីរបស់ដែលជាទីស្រឡាញ់ចូលចិត្ត) ? ។

នៅទីណា និង នៅពេលណា គេជួបប្រសព្វនឹងរូបារម្មណ៍ (រូបភាព), សទ្ទារម្មណ៍ (សំឡេង), គន្ធារម្មណ៍ (ក្លិន), រសារម្មណ៍ (រសជាតិ), ផោដ្ឋព្វារម្មណ៍ (ការប៉ះដោយកាយ), ធម្មារម្មណ៍ (ធម៌), រូប, សំឡេង, ក្លិន, រស, សម្ផស្ស, ឬ ធម្មារម្មណ៍ដែលជាទីប្រាថ្នា, ជាទីត្រេកអរ, ជាទីគាប់ចិត្ត, ពុំនោះសោត នៅទីណា និង នៅពេលណា គេជួបប្រទះនឹងជនទាំងឡាយណា ដែលប្រាថ្នាឲ្យគេមានសុភមង្គល, មានភាពរុងរឿង,

មានសេចក្ដីសុខ និង សេចក្ដីចំរើន, សេចក្ដីក្សេមក្សាន្ត ដូចមាតា និង បិតាក្ដី, បងប្អូនប្រុស និង បងប្អូនស្រីក្ដី, មិត្តភក្ដិ និង សហសេវិក ក្ដី, ឬ ញាតិសាលោហិតក្ដី, កាលណាគេត្រូវព្រាត់ប្រាស, មិនបានជួប, មិនបានប្រាស្រ័យទាក់ទងគ្នា ឬក៏មិនបាននៅប្រឡូកប្រឡំជាមួយនឹងអារម្មណ៍ ឬ ជនទាំងឡាយនោះ ។ ម្នាលភិក្ខុទាំងឡាយ នេះហើយហៅថា **បិយេហិ វិប្បយោគទុក្ខ** ។

ម្នាលភិក្ខុទាំងឡាយ ចុះដូចម្ដេចដែលហៅថា **យម្បិច្ឆំ ន លភតិ តម្បិទុក្ខ** (ឬ ទុក្ខដោយការចង់បានរបស់ណា ហើយមិនបានរបស់នោះដូចប្រាថ្នា) ? ។

ម្នាលភិក្ខុទាំងឡាយ ពួកសត្វដែលមានជាតិកំណើត ជាធម្មតា តែងមានសេចក្ដីប្រាថ្នាកើតឡើងយ៉ាងនេះថា: ធ្វើដូចម្ដេចហ្ន៎ កុំឲ្យយើងទាំងឡាយមានជាតិកំណើតជាធម្មតា? ពុំនោះសោត ធ្វើដូចម្ដេចហ្ន៎ កុំឲ្យជាតិកំណើត កើតមានដល់យើងទាំងឡាយ? តែពួកសត្វ មិនអាចសំរេចសេចក្ដីប្រាថ្នានេះបាន ដោយគ្រាន់តែប្រាថ្នាទទេៗនោះកើតឡើយ ហើយការមិនបានរបស់ដែលគេប្រាថ្នាចង់បាននុ៎ះ ជាទុក្ខ ។

ម្នាលភិក្ខុទាំងឡាយ ពួកសត្វដែលមានជរា គឺសេចក្ដីចាស់គ្រាំគ្រាជាធម្មតា តែងមានសេចក្ដីប្រាថ្នាកើតឡើង យ៉ាងនេះ ថា:





ធ្វើដូចម្ដេចហ្ន៎ កុំឲ្យយើងទាំងឡាយ មានជរាជាធម្មតា? ពុំនោះសោត ធ្វើដូចម្ដេចហ្ន៎ កុំឲ្យជរាកើតមានដល់យើងទាំងឡាយ? តែពួកសត្វមិនអាចសំរេចសេចក្ដីប្រាថ្នានេះបានដោយគ្រាន់តែប្រាថ្នាទទេៗ នោះ កើតឡើយ, ហើយការមិនបានរបស់ដែលគេប្រាថ្នាចង់បាននុ៎ះ ជាទុក្ខ ។

ម្នាលភិក្ខុទាំងឡាយ ពួកសត្វដែលមានព្យាធិ គឺជម្ងឺ ជាធម្មតា តែងមានសេចក្ដីប្រាថ្នាកើតឡើងយ៉ាងនេះថា ធ្វើដូចម្ដេចហ្ន៎ កុំឲ្យយើងទាំងឡាយមានជម្ងឺជាធម្មតា? ពុំនោះសោត ធ្វើដូចម្ដេចហ្ន៎ កុំឲ្យជម្ងឺកើតមានដល់យើងទាំងឡាយ? តែពួកសត្វមិនអាចសំរេចសេចក្ដីប្រាថ្នានេះបាន ដោយគ្រាន់តែប្រាថ្នាទទេៗនោះកើតឡើយ ហើយការមិនបានរបស់ដែលគេប្រាថ្នាចង់បាននុ៎ះ ជាទុក្ខ ។

ម្នាលភិក្ខុទាំងឡាយ ពួកសត្វដែលមានមរណៈ គឺសេចក្ដីស្លាប់ជាធម្មតា តែងមានសេចក្ដីប្រាថ្នាកើតឡើងយ៉ាងនេះថា ធ្វើដូចម្ដេចហ្ន៎ កុំឲ្យយើងទាំងឡាយមានសេចក្ដីស្លាប់ជាធម្មតា? ពុំនោះសោត ធ្វើដូចម្ដេចហ្ន៎ កុំឲ្យសេចក្ដីស្លាប់កើតមាន ដល់យើងទាំងឡាយ? តែពួកសត្វមិនអាចសម្រេចនូវសេចក្ដីប្រាថ្នានេះបាន ដោយគ្រាន់តែប្រាថ្នាទទេៗ នោះ កើតឡើយ ហើយការមិនបាន

ហើយតាំងនៅត្រង់នុ៎ះ ។

ចិត្តដែលធ្វើប្រតិកម្មចំពោះរូបារម្មណ៍ទាំងឡាយ, ចិត្តដែលធ្វើប្រតិកម្ម ចំពោះសទ្ទារម្មណ៍ទាំងឡាយ, ចិត្តដែលធ្វើប្រតិកម្មចំពោះគន្ធារម្មណ៍ទាំងឡាយ, ចិត្តដែលធ្វើប្រតិកម្មចំពោះរសារម្មណ៍ទាំងឡាយ, ចិត្តដែលធ្វើប្រតិកម្មចំពោះផោដ្ឋព្វារម្មណ៍ទាំងឡាយ, ចិត្តដែលធ្វើប្រតិកម្មចំពោះធម្មារម្មណ៍ទាំងឡាយ មានភាពគួរជាទីស្រឡាញ់ គួរជាទីរីករាយ នៅក្នុងលោក គឺនៅត្រង់ហ្នឹងហើយ ដែលតណ្ហាកើតឡើង ហើយតាំងនៅត្រង់នុ៎ះ ។

សេចក្តីប្រាថ្នាចំពោះរូបារម្មណ៍ទាំងឡាយ, សេចក្តីប្រាថ្នាចំពោះសទ្ទារម្មណ៍ទាំងឡាយ, សេចក្តីប្រាថ្នាចំពោះគន្ធារម្មណ៍ទាំងឡាយ, សេចក្តីប្រាថ្នាចំពោះរសារម្មណ៍ទាំងឡាយ, សេចក្តីប្រាថ្នាចំពោះផោដ្ឋព្វារម្មណ៍ទាំងឡាយ, សេចក្តីប្រាថ្នាចំពោះធម្មារម្មណ៍ទាំងឡាយ មានភាពគួរជាទីស្រឡាញ់ គួរជាទីរីករាយ នៅក្នុងលោក គឺនៅត្រង់ហ្នឹងហើយ ដែលតណ្ហាកើតឡើង ហើយតាំងនៅត្រង់នុ៎ះ ។

សេចក្តីនឹកភ្នកអំពីរូបារម្មណ៍ទាំងឡាយ, សេចក្តីនឹកភ្នកអំពីសទ្ទារម្មណ៍ទាំងឡាយ, សេចក្តីនឹកភ្នកអំពីគន្ធារម្មណ៍ទាំងឡាយ, សេចក្តីនឹកភ្នកអំពីរសារម្មណ៍ទាំងឡាយ, សេចក្តីនឹកភ្នកអំពី





ជាទុក្ខ, ការប្រកាន់ខ្ជាប់ទៅលើ **វិញ្ញាណក្ខន្ធ** ជាទុក្ខ, ម្នាលភិក្ខុទាំងឡាយ នេះជាទុក្ខ ដោយការប្រកាន់ខ្ជាប់ទៅលើខន្ធ ៥ ។

ម្នាលភិក្ខុទាំងឡាយ នេះហើយគឺ **ទុក្ខអរិយសច្ច** គឺសេចក្តីពិតអំពីទុក្ខ ។

## ទុក្ខសមុទយសច្ច

ម្នាលភិក្ខុទាំងឡាយ ចុះដូចម្តេចហៅថា **ទុក្ខសមុទយសច្ច** ឬ សេចក្តីពិតអំពីមូលហេតុរបស់ទុក្ខ? ។

គឺ **តណ្ហា** សេចក្តីប្រាថ្នាចង់បាននេះ ដែលជាធម្មជាតិ នាំឲ្យមានកំណើតជាថ្មីទៀត ប្រកបដោយតម្រេករីករាយ និងសេចក្តីត្រេកត្រអាលនៅទីនេះ, រួចហើយនៅទីនោះ តទៅទៀត គឺ **កាមតណ្ហា** សេចក្តីប្រាថ្នាក្នុងកាមគុណ, **ភវតណ្ហា** សេចក្តីប្រាថ្នា ក្នុងជាតិកំណើតជាថ្មីទៀត, **វិភវតណ្ហា** សេចក្តីប្រាថ្នាក្នុងភាពសូន្យ ។

ម្នាលភិក្ខុទាំងឡាយ ចុះតណ្ហានេះ កើតឡើង នៅទីណា ហើយតាំងនៅទីណា? ។

ក្នុងលោកនេះ ទោះនៅក្នុងទីណាក៏ដោយ ដរាបណា មានរបស់គួរជាទីស្រឡាញ់, គួរជាទីរីករាយ, ដរាបនោះ តណ្ហា កើតឡើង ហើយតាំងនៅត្រង់ទីនោះឯង ។

*ចុះក្នុងលោកនេះ តើមានរបស់អ្វី ដែលគួរជាទីស្រឡាញ់, គួរជាទីរីករាយ ? ។*

**ភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ** *និង* **ចិត្ត** *ជារបស់គួរជាទីស្រឡាញ់, គួរជាទីរីករាយនៅក្នុងលោក គឺនៅត្រង់ហ្នឹងហើយ ដែលតណ្ហាកើតឡើង ហើយតាំងនៅត្រង់នុ៎ះ ។*

**រូបារម្មណ៍** *(រូប),* **សទ្ទារម្មណ៍** *(សំឡេង),* **គន្ធារម្មណ៍** *(ក្លិន),* **រសារម្មណ៍** *(រសជាតិ),* **ផោដ្ឋព្វារម្មណ៍** *(ការប៉ះពាល់ត្រូវដោយកាយ),* **ធម្មារម្មណ៍** *(ធម៌) ជារបស់គួរជាទីស្រឡាញ់, គួរជាទីរីករាយនៅក្នុងលោក គឺនៅត្រង់ហ្នឹងហើយ ដែលតណ្ហាកើតឡើង ហើយតាំងនៅត្រង់នុ៎ះ ។*

**ចក្ខុវិញ្ញាណ** *(ធម្មជាតិដឹងច្បាស់នូវអារម្មណ៍របស់ភ្នែក),* **សោតវិញ្ញាណ** *(ធម្មជាតិដឹងច្បាស់នូវអារម្មណ៍របស់ត្រចៀក),* **ឃានវិញ្ញាណ** *(ធម្មជាតិដឹងច្បាស់នូវអារម្មណ៍របស់ច្រមុះ),* **ជិវ្ហាវិញ្ញាណ** *(ធម្មជាតិដឹងច្បាស់នូវអារម្មណ៍របស់អណ្តាត),* **កាយវិញ្ញាណ** *(ធម្មជាតិដឹងច្បាស់នូវអារម្មណ៍របស់កាយ),* **មនោវិញ្ញាណ** *(ធម្មជាតិដឹងច្បាស់នូវអារម្មណ៍របស់ចិត្ត) មានភាពគួរជាទីស្រឡាញ់ គួរជាទីរីករាយក្នុងលោក គឺនៅត្រង់ហ្នឹងហើយ ដែលតណ្ហាកើតឡើង ហើយតាំងនៅត្រង់នុ៎ះ ។*





**ចក្ខុសម្ផស្ស** *(ការប៉ះរបស់ភ្នែក),* **សោតសម្ផស្ស** *(ការប៉ះរបស់ត្រចៀក),* **ឃានសម្ផស្ស** *(ការប៉ះរបស់ច្រមុះ),* **ជិវ្ហាសម្ផស្ស** *(ការប៉ះរបស់អណ្តាត),* **កាយសម្ផស្ស** *(ការប៉ះរបស់កាយ),* **មនោសម្ផស្ស** *(ការប៉ះរបស់ចិត្ត) មានភាពគួរជាទីស្រឡាញ់ គួរជាទីរីករាយនៅក្នុងលោក គឺនៅត្រង់ហ្នឹងហើយ ដែលតណ្ហាកើតឡើង ហើយតាំងនៅត្រង់នុ៎ះ ។*

*វេទនា កើតមកពី* **ចក្ខុសម្ផស្ស** *វេទនា កើតមកពី* **សោតសម្ផស្ស** *វេទនា កើតមកពី* **ឃានសម្ផស្ស** *វេទនា កើតមកពី* **ជិវ្ហាសម្ផស្ស** *វេទនា កើតមកពី* **កាយសម្ផស្ស** *វេទនា កើតមកពី* **មនោសម្ផស្ស** *មានភាពគួរជាទីស្រឡាញ់ គួរជាទីរីករាយ នៅក្នុងលោក គឺនៅត្រង់ហ្នឹងហើយ ដែលតណ្ហាកើតឡើង ហើយតាំងនៅត្រង់នុ៎ះ ។*

*សញ្ញា សំគាល់នូវ* **រូបារម្មណ៍** *ទាំងឡាយ, សញ្ញា សំគាល់នូវ* **សទ្ទារម្មណ៍** *ទាំងឡាយ, សញ្ញាសំគាល់នូវ* **គន្ធារម្មណ៍** *ទាំងឡាយ, សញ្ញា សំគាល់នូវ* **រសារម្មណ៍** *ទាំងឡាយ, សញ្ញា សំគាល់នូវ* **ផោដ្ឋព្វារម្មណ៍** *ទាំងឡាយ, សញ្ញា សំគាល់នូវ* **ធម្មារម្មណ៍** *ទាំងឡាយ មានភាពគួរជាទីស្រឡាញ់ គួរជាទីរីករាយនៅក្នុងលោក គឺនៅត្រង់ហ្នឹងហើយ ដែលតណ្ហាកើតឡើង*

ដែលធ្វើនូវប្រតិកម្មចំពោះសទ្ទារម្មណ៍ទាំងឡាយ, ចិត្តដែលធ្វើនូវប្រតិកម្មចំពោះគន្ធារម្មណ៍ទាំងឡាយ, ចិត្តដែលធ្វើប្រតិកម្មចំពោះរសារម្មណ៍ទាំងឡាយ, ចិត្តដែលធ្វើប្រតិកម្មចំពោះផោដ្ឋព្វារម្មណ៍ទាំងឡាយ, ចិត្តដែលធ្វើនូវប្រតិកម្ម ចំពោះធម្មារម្មណ៍ទាំងឡាយ មានភាពគួរជាទីស្រឡាញ់ គួរជាទីរីករាយ នៅក្នុងលោក គឺនៅត្រង់ហ្នឹងហើយ ដែលគេអាចរំលត់ និង កំចាត់តណ្ហានេះ ។

សេចក្តីប្រាថ្នាចំពោះរូបារម្មណ៍ទាំងឡាយ, សេចក្តីប្រាថ្នាចំពោះសទ្ទារម្មណ៍ទាំងឡាយ, សេចក្តីប្រាថ្នាចំពោះគន្ធារម្មណ៍ទាំងឡាយ, សេចក្តីប្រាថ្នាចំពោះរសារម្មណ៍ទាំងឡាយ, សេចក្តីប្រាថ្នាចំពោះផោដ្ឋព្វារម្មណ៍ទាំងឡាយ, សេចក្តីប្រាថ្នាចំពោះធម្មារម្មណ៍ទាំងឡាយ មានភាពគួរជាទីស្រឡាញ់ គួរជាទីរីករាយ នៅក្នុងលោក គឺនៅត្រង់ហ្នឹងហើយ ដែលគេអាចរំលត់ និងកំចាត់តណ្ហានេះ ។

សេចក្តីនឹកក្នុកអំពីរូបារម្មណ៍ទាំងឡាយ, សេចក្តីនឹកក្នុកអំពីសទ្ទារម្មណ៍ទាំងឡាយ, សេចក្តីនឹកក្នុកអំពីគន្ធារម្មណ៍ទាំងឡាយ, សេចក្តីនឹកក្នុកអំពីរសារម្មណ៍ទាំងឡាយ, សេចក្តីនឹកក្នុកអំពីផោដ្ឋព្វារម្មណ៍ទាំងឡាយ, សេចក្តីនឹកក្នុកអំពីធម្មារម្មណ៍ទាំងឡាយ មានភាពគួរជាទីស្រឡាញ់ គួរជាទីរីករាយ នៅក្នុងលោក





ផោដ្ឋព្វារម្មណ៍ទាំងឡាយ, សេចក្តីនឹកក្នុកអំពីធម្មារម្មណ៍ទាំងឡាយ មានភាពគួរជាទីស្រឡាញ់ គួរជាទីរីករាយ នៅក្នុងលោក គឺនៅត្រង់ហ្នឹងហើយ ដែលតណ្ហាកើតឡើង ហើយតាំងនៅត្រង់នុ៎ះ ។

ការពិចារណាវិលវល់ ក្នុងរូបារម្មណ៍ទាំងឡាយ, ការពិចារណាវិលវល់ ក្នុងសទ្ទារម្មណ៍ទាំងឡាយ, ការពិចារណាវិលវល់ក្នុងគន្ធារម្មណ៍ទាំងឡាយ, ការពិចារណាវិលវល់ក្នុងរសារម្មណ៍ទាំងឡាយ, ការពិចារណាវិលវល់ ក្នុងផោដ្ឋព្វារម្មណ៍ទាំងឡាយ, ការពិចារណាវិលវល់ក្នុងធម្មារម្មណ៍ទាំងឡាយ មានភាពគួរជាទីស្រឡាញ់ គួរជាទីរីករាយ នៅក្នុងលោក គឺនៅត្រង់ហ្នឹងហើយ ដែលតណ្ហាកើតឡើង ហើយតាំងនៅត្រង់នុ៎ះ ។

ម្នាលភិក្ខុទាំងឡាយ នេះគឺ **ទុក្ខសមុទយអរិយសច្ច** សេចក្តីពិតអំពីមូលហេតុរបស់ទុក្ខ ។

## ទុក្ខនិរោធសច្ច

ម្នាលភិក្ខុទាំងឡាយ ចុះដូចម្តេចហៅថា **ទុក្ខនិរោធសច្ច** គឺសេចក្តីពិតអំពីការរលត់ទុក្ខ? ។

គឺការរលត់បាត់ទាំងស្រុងគ្មានសេសសល់នៃតណ្ហានេះឯង, ការលះបង់ និង ការរលាស់ចោលទាំងស្រុងនូវតណ្ហានេះ ការរួច

រដោះ និង ការផ្ដាច់ចេញស្រឡះពីតណ្ហានេះ ។ ម្នាលភិក្ខុទាំងឡាយ តើគេអាចរំលត់ និង កំចាត់បង់នូវតណ្ហានេះនៅទីណា? នៅក្នុងលោកនេះ នៅទីណាក៏ដោយ ដរាបណា នៅមានរបស់គួរជាទីស្រឡាញ់, គួរជាទីរីករាយ ដរាបនោះ គេអាចរំលត់ និង កំចាត់បង់នូវតណ្ហានេះ នៅត្រង់ទីនោះឯង ។

តែនៅក្នុងលោក (នៃចិត្តនិងរូប) នេះ តើមានអ្វីដែលគួរជាទីស្រឡាញ់ គួរជាទីរីករាយ? ។

ភ្នែក, ត្រចៀក, ច្រមុះ, អណ្ដាត, កាយ, ចិត្ត ជារបស់គួរជាទីស្រឡាញ់ គួរជាទីរីករាយនៅក្នុងលោក គឺនៅត្រង់ហ្នឹងហើយ ដែលគេអាចរំលត់ និង កំចាត់បង់តណ្ហានេះ ។

រូបារម្មណ៍ទាំងឡាយ, សទ្ទារម្មណ៍ទាំងឡាយ, គន្ធារម្មណ៍ទាំងឡាយ, រសារម្មណ៍ទាំងឡាយ, ផោដ្ឋព្វារម្មណ៍ទាំងឡាយ, ធម្មារម្មណ៍ទាំងឡាយ មានភាពគួរជាទីស្រឡាញ់ គួរជាទីរីករាយនៅក្នុងលោក គឺនៅត្រង់ហ្នឹងហើយដែលគេអាចរំលត់ និង កំចាត់តណ្ហានេះ ។

ចក្ខុវិញ្ញាណ, សោតវិញ្ញាណ, ឃានវិញ្ញាណ, ជិវ្ហាវិញ្ញាណ, កាយវិញ្ញាណ, មនោវិញ្ញាណ មានភាពគួរជាទីស្រឡាញ់ គួរជាទីរីករាយ នៅក្នុងលោក គឺនៅត្រង់ហ្នឹងហើយ ដែលគេអាច





រំលត់ និង កំចាត់តណ្ហានេះ ។

ចក្ខុសម្ផស្ស, សោតសម្ផស្ស, ឃានសម្ផស្ស, ជិវ្ហាសម្ផស្ស, កាយសម្ផស្ស, មនោសម្ផស្ស មានភាពគួរជាទីស្រឡាញ់ គួរជាទីរីករាយ នៅក្នុងលោក គឺនៅត្រង់ហ្នឹងហើយ ដែលគេអាចរំលត់ និង កំចាត់តណ្ហានេះ ។

វេទនាកើតមកអំពីចក្ខុសម្ផស្ស, វេទនាកើតមកអំពីសោត-សម្ផស្ស, វេទនាកើតអំពីឃានសម្ផស្ស, វេទនាកើតមកអំពីជិវ្ហាសម្ផស្ស, វេទនាកើតមកអំពីកាយសម្ផស្ស, វេទនាកើតមកអំពីមនោសម្ផស្ស មានភាពគួរជាទីស្រឡាញ់ គួរជាទីរីករាយ នៅក្នុងលោក គឺនៅត្រង់ហ្នឹងហើយ ដែលគេអាចរំលត់ និង កំចាត់តណ្ហានេះ ។

សញ្ញា សំគាល់នូវរូបារម្មណ៍ទាំងឡាយ, សញ្ញាសំគាល់នូវសទ្ទារម្មណ៍ទាំងឡាយ, សញ្ញា សំគាល់នូវគន្ធារម្មណ៍ទាំងឡាយ, សញ្ញា សំគាល់នូវរសារម្មណ៍ទាំងឡាយ, សញ្ញា សំគាល់នូវផោដ្ឋព្វារម្មណ៍ទាំងឡាយ, សញ្ញា សំគាល់នូវធម្មារម្មណ៍ទាំងឡាយ មានភាពគួរជាទីស្រឡាញ់ គួរជាទីរីករាយ នៅក្នុងលោក គឺនៅត្រង់ហ្នឹងហើយដែលគេអាចរំលត់ និង កំចាត់តណ្ហានេះ ។

ចិត្តដែលធ្វើនូវប្រតិកម្ម ចំពោះរូបារម្មណ៍ទាំងឡាយ, ចិត្ត

ភិក្ខុញុាំងឆន្ទៈ ឲ្យកើតឡើង ប្រឹងប្រែងខំប្រារព្ធព្យាយាម ផ្គងចិត្តតាំងព្យាយាមយ៉ាងមាំ ដើម្បីញុាំងកុសលធម៌ទាំងឡាយដែលបានកើតមានហើយ ឲ្យនៅស្ថិតស្ថេរចិរកាល ឲ្យរីកចំរើនពេញបរិបូណ៌ក្រៃលែង ។ ម្នាលភិក្ខុទាំងឡាយ នេះហើយ ដែលហៅថា **សម្មាវាយាមោ** ការព្យាយាមត្រូវ ។

ម្នាលភិក្ខុទាំងឡាយ ចុះដូចម្ដេចហៅថា **សម្មាសតិ** ការតាំងសតិត្រូវ? ។ ក្នុងទីនេះ ភិក្ខុតាំងនៅស៊ប់ប្រកបដោយសតិដឹង និង ការយល់ច្បាស់ជាប់ជានិច្ចអំពីសេចក្ដីមិនទៀង ពិនិត្យមើលកាយក្នុងកាយ ដោយបានកំចាត់ចោលនូវលោភៈ និង ទោសៈ ចំពោះរបស់ក្នុងលោកនេះ, ភិក្ខុតាំងនៅប្រកបដោយសតិដឹង និង ការយល់ច្បាស់ជាប់ជានិច្ច អំពីសេចក្ដីមិនទៀង ពិនិត្យមើលវេទនាក្នុងវេទនាទាំងឡាយ ដោយបានកំចាត់ចោលនូវលោភៈនិងទោសៈ ចំពោះរបស់ក្នុងលោកនេះ, ភិក្ខុតាំងនៅប្រកបដោយសតិដឹង និង ការយល់ច្បាស់ជាប់ជានិច្ច អំពីសេចក្ដីមិនទៀង ពិនិត្យមើលចិត្តក្នុងចិត្តទាំងឡាយ ដោយបានកំចាត់ចោលនូវលោភៈនិងទោសៈ ចំពោះរបស់ក្នុងលោកនេះ, ភិក្ខុតាំងនៅប្រកបដោយសតិដឹង និង ការយល់ច្បាស់ជាប់ជានិច្ច អំពីសេចក្ដីមិនទៀង ពិនិត្យមើលធម៌ក្នុងធម៌ទាំងឡាយ ដោយបានកំចាត់ចោល នូវលោភៈ





គឺនៅត្រង់ហ្នឹងហើយដែលគេអាចរំលត់ និង កំចាត់តណ្ហានេះ ។

ការពិចារណាវិលវល់ ក្នុងរូបារម្មណ៍ទាំងឡាយ, ការពិចារណាវិលវល់ ក្នុងសទ្ទារម្មណ៍ទាំងឡាយ, ការពិចារណាវិលវល់ ក្នុងគន្ធារម្មណ៍ទាំងឡាយ, ការពិចារណាវិលវល់ក្នុងរសារម្មណ៍ទាំងឡាយ, ការពិចារណាវិលវល់ ក្នុងផោដ្ឋព្វារម្មណ៍ទាំងឡាយ, ការពិចារណាវិលវល់ក្នុងធម្មារម្មណ៍ទាំងឡាយ មានភាពគួរជាទីស្រឡាញ់ គួរជាទីរីករាយ នៅក្នុងលោក គឺនៅត្រង់ហ្នឹងហើយដែលគេអាចរំលត់ និង កំចាត់តណ្ហានេះ ។

ម្នាលភិក្ខុទាំងឡាយ នេះគឺ **ទុក្ខនិរោធអរិយសច្ច** សេចក្ដីពិតអំពីការរំលត់ទុក្ខ ។

## មគ្គសច្ច

ម្នាលភិក្ខុទាំងឡាយ ចុះដូចម្ដេចហៅថា **មគ្គសច្ច** គឺសេចក្ដីពិតអំពីមាគ៌ាឆ្ពោះទៅកាន់ការរំលត់ទុក្ខ? ។ គឺ **អដ្ឋង្គិកមគ្គ** មាគ៌ាដ៏ប្រសើរប្រកបដោយអង្គ ៨ នេះឯង គឺៈ **សម្មាទិដ្ឋិ** ការយល់ឃើញត្រូវ, **សម្មាសង្កប្បោ** ការត្រិះរិះត្រូវ, **សម្មាវាចា** ការប្រើសំដីត្រូវ, **សម្មាកម្មន្តោ** ការប្រកបការងារត្រូវ, **សម្មាអាជីវោ** ការចិញ្ចឹមជីវិតត្រូវ, **សម្មាវាយាមោ** ការព្យាយាមត្រូវ, **សម្មាសតិ** ការតាំងសតិត្រូវ, **សម្មាសមាធិ** ការតំកល់ចិត្តត្រូវ ។

ម្នាលភិក្ខុទាំងឡាយ ចុះដូចម្ដេចហៅថា **សម្មាទិដ្ឋិ** ការយល់ឃើញត្រូវ? ។ គឺ ការដឹងច្បាស់នូវទុក្ខ, ការដឹងច្បាស់នូវហេតុឲ្យកើតទុក្ខ, ការដឹងច្បាស់នូវហេតុផលនៃការរំលត់ទុក្ខ, ការដឹងច្បាស់នូវមាគ៌ា ឆ្ពោះទៅកាន់ការរំលត់ទុក ។ ម្នាលភិក្ខុទាំងឡាយ នេះហើយដែលហៅថា **សម្មាទិដ្ឋិ** ការយល់ឃើញត្រូវ ។

ម្នាលភិក្ខុទាំងឡាយ ចុះដូចម្ដេចហៅថា **សម្មាសង្កប្បោ** ការត្រិះរិះត្រូវ? ។ គឺ ការត្រិះរិះដើម្បីលះបង់កាមគុណ, ការត្រិះរិះដើម្បីប្រាសចាកការព្យាបាទ, ការត្រិះរិះដើម្បីប្រាសចាកការប្រើកម្លាំងឃោរឃៅ គឺការមិនបៀតបៀនអ្នកដទៃ ។ ម្នាលភិក្ខុទាំងឡាយ នេះហើយដែលហៅថា **សម្មាសង្កប្បោ** ការត្រិះរិះត្រូវ ។

ម្នាលភិក្ខុទាំងឡាយ ចុះដូចម្ដេចហៅថា **សម្មាវាចា** ការប្រើសំដីត្រូវ? ។ គឺ កិរិយាវៀរចាកការពោល នូវពាក្យកុហក, កិរិយាវៀរចាកការនិយាយបង្កាច់និយាយដើមគេ, កិរិយាវៀរចាកការនិយាយញុះញង់ធ្វើឲ្យបែកបាក់សាមគ្គី, កិរិយាវៀរចាកការពោលពាក្យទ្រគោះបោះបោក, កិរិយាវៀរចាកការនិយាយពាក្យរោយរាយឥតប្រយោជន៍ ។ ម្នាលភិក្ខុទាំងឡាយ នេះហើយដែលហៅថា **សម្មាវាចា** ការប្រើសំដីត្រូវ ។

ម្នាលភិក្ខុទាំងឡាយ ចុះដូចម្ដេចហៅថា **សម្មាកម្មន្តោ** ការ



ព្រះពុទ្ធដីកា

ប្រកបការងារត្រូវ? ។ កិរិយាវៀរចាកការសម្លាប់សត្វ, កិរិយាវៀរចាកការកាន់យករបស់ដែលម្ចាស់គេមិនបានឲ្យ និង កិរិយាវៀរចាកការប្រព្រឹត្តិខុសក្នុងកាម ។ ម្នាលភិក្ខុទាំងឡាយ នេះហើយ ដែលហៅថា **សម្មាកម្មន្តោ** ការប្រកបការងារត្រូវ ។

ម្នាលភិក្ខុទាំងឡាយ ចុះដូចម្ដេចហៅថា **សម្មាអាជីវោ** ការចិញ្ចឹមជីវិតត្រូវ? ។ ក្នុងទីនេះ គឺព្រះអរិយសាវ័កដែលបានលះបង់ការចិញ្ចឹមជីវិតខុស ហើយរស់នៅដោយការចិញ្ចឹមជីវិតត្រូវ ។ ម្នាលភិក្ខុទាំងឡាយ នេះហើយដែលហៅថា **សម្មាអាជីវោ** ការចិញ្ចឹមជីវិតត្រូវ ។

ម្នាលភិក្ខុទាំងឡាយ ចុះដូចម្ដេចហៅថា **សម្មាវាយាមោ** ការព្យាយាមត្រូវ? ។ ក្នុងទីនេះ ភិក្ខុញុំាងឆន្ទៈ ឲ្យកើតឡើង ប្រឹងប្រែងខំប្រារព្ធព្យាយាម ផ្គងចិត្តតាំងព្យាយាមយ៉ាងមាំ ដើម្បីការពារអកុសលធម៌ទាំងឡាយដែលមិនទាន់កើតកុំឲ្យកើតឡើងបាន។ ភិក្ខុញុំាងឆន្ទៈ ឲ្យកើតឡើងប្រឹងប្រែងខំប្រារព្ធព្យាយាម ផ្គងចិត្តតាំងព្យាយាមយ៉ាងមាំ ដើម្បីកំចាត់បង់នូវអកុសលធម៌ទាំងឡាយដែលបានកើតឡើងហើយ ។ ភិក្ខុញុំាងឆន្ទៈ ឲ្យកើតឡើង ប្រឹងប្រែងខំប្រារព្ធព្យាយាម ផ្គងចិត្តតាំងព្យាយាមយ៉ាងមាំ ដើម្បីញុំាងកុសលធម៌ទាំងឡាយ ដែលមិនទាន់កើតមានឡើង ឲ្យកើតមាន

ម្នាលភិក្ខុទាំងឡាយ កុំថាឡើយអស់ ៤ ឆ្នាំ... ។ល។

ម្នាលភិក្ខុទាំងឡាយ កុំថាឡើយអស់ ៣ ឆ្នាំ... ។ល។

ម្នាលភិក្ខុទាំងឡាយ កុំថាឡើយអស់ ២ ឆ្នាំ... ។ល។

ម្នាលភិក្ខុទាំងឡាយ កុំថាឡើយអស់ ១ ឆ្នាំ... ។ល។

ម្នាលភិក្ខុទាំងឡាយ កុំថាឡើយអស់ ៧ ខែ... ។ល។

ម្នាលភិក្ខុទាំងឡាយ កុំថាឡើយអស់ ៦ ខែ... ។ល។

ម្នាលភិក្ខុទាំងឡាយ កុំថាឡើយអស់ ៥ ខែ... ។ល។

ម្នាលភិក្ខុទាំងឡាយ កុំថាឡើយអស់ ៤ ខែ... ។ល។

ម្នាលភិក្ខុទាំងឡាយ កុំថាឡើយអស់ ៣ ខែ... ។ល។

ម្នាលភិក្ខុទាំងឡាយ កុំថាឡើយអស់ ២ ខែ... ។ល។

ម្នាលភិក្ខុទាំងឡាយ កុំថាឡើយអស់ ១ ខែ... ។ល។

ម្នាលភិក្ខុទាំងឡាយ កុំថាឡើយអស់កន្លះខែ, បើបុគ្គលណាម្នាក់ បានចំរើនសតិបដ្ឋានទាំង ៤ នេះ ឥតខ្ចោះ តាមរបៀបនេះ អស់ ៧ ថ្ងៃ, បុគ្គលនោះ គង់នឹងបានសំរេចផលណាមួយ ក្នុងចំណោមផលទាំងពីរនេះ ថ្នាក់យ៉ាងខ្ពស់បំផុត គឺ ភាវៈជាព្រះអរហន្ត ឬ បើមានឧបាទានក្ខន្ធ នៅសេសសល់ខ្លះ ក៏បានថ្នាក់អនាគាមីដែរ ។

ដោយមកពីហេតុនេះហើយ ទើបព្រះសម្មាសម្ពុទ្ធ មានព្រះ





និង ទោសៈ ចំពោះរបស់ក្នុងលោកនេះ ។

ម្នាលភិក្ខុទាំងឡាយ នេះហើយដែលហៅថា **សម្មាសតិ** ការតាំងសតិត្រូវ ។

ម្នាលភិក្ខុទាំងឡាយ ចុះដូចម្តេចហៅថា **សម្មាសមាធិ** ការតំកល់ចិត្តឲ្យនឹងត្រូវ? ។ ម្នាលភិក្ខុទាំងឡាយ ក្នុងទីនេះ ភិក្ខុបានរួចចាកកាមទាំងឡាយ បានរួចចាកអកុសលធម៌ទាំងឡាយ រួចចូលទៅកាន់បឋមជ្ឈាន ដែលប្រកបដោយវិតក្កៈ និង វិចារៈ មានបីតិ និង សុខ ដែលកើតមកអំពីសេចក្តីស្ងប់ស្ងាត់ ហើយក៏តាំងនៅក្នុងបឋមជ្ឈាននេះ ។ លុះវិតក្កៈ និង វិចារៈ បានរម្ងាប់ហើយ ភិក្ខុក៏ចូលទៅកាន់ទុតិយជ្ឈាន ដោយមានសេចក្តីស្ងប់នៅខាងក្នុង និង សភាពជាចិត្តខ្ពស់ឯកគ្មានវិតក្កៈ គ្មានវិចារៈ មានតែបីតិ និង សេចក្តីសុខ ដែលកើតមកអំពីសមាធិចិត្ត ហើយក៏តាំងនៅក្នុងទុតិយជ្ឈាននេះ ។

លុះបីតិចិត្តបានរម្ងាប់ហើយ ភិក្ខុតាំងនៅ ក្នុងភាពឧបេក្ខា ដោយមានសតិដឹង ពេញបរិបូណ៌ ចំពោះវេទនា និង ការយល់ច្បាស់ជាប់ជានិច្ច អំពីសេចក្តីមិនទៀង ហើយពិសោធឃើញសេចក្តីសុខតែម៉្យាងនៅក្នុងខ្លួន ដែលព្រះអរិយបុគ្គល សំដែងថា **“មានតែបុគ្គលដែលប្រកប ដោយភាពឧបេក្ខា និង សតិ នេ**

**ដែលអាចពិសោធឃើញនូវសេចក្តីសុខនេះ**” ភិក្ខុ ចូលទៅកាន់តតិយជ្ឈាន ហើយតាំងនៅក្នុងតតិយជ្ឈាននេះ ។ លុះបានរម្ងាប់សេចក្តីសុខ និង ទុក្ខហើយ ដោយសេចក្តីសោមនស្ស និង ទោមនស្ស បានរលាយបាត់អស់ពីមុនមកដែរ ភិក្ខុចូលទៅកាន់សភាពមួយ ដែលនៅផុតពីសេចក្តីសុខ និង សេចក្តីទុក្ខ គឺ ចតុត្ថជ្ឈាន ដែលមានភាពបរិសុទ្ធិទាំងស្រុងដោយមានភាពឧបេក្ខា និង សតិដឹង ហើយក៏តាំងនៅក្នុងចតុត្ថជ្ឈាននេះ ។

ម្នាលភិក្ខុទាំងឡាយ នេះហើយហៅថា **សម្មាសមាធិ** ការតំកល់ចិត្តឲ្យនឹងត្រូវ ។

ម្នាលភិក្ខុទាំងឡាយ នេះហើយហៅថា **ទុក្ខនិរោធគាមិនីបដិបទាអរិយសច្ច** សេចក្តីពិតអំពីមាគ៌ាឆ្ពោះទៅរកការរំលត់ទុក្ខ។

តាមរបៀបនេះ ភិក្ខុតាំងនៅពិនិត្យមើលធម៌ ក្នុងធម៌ទាំងឡាយ នៅខាងក្នុង, ឬ តាំងនៅពិនិត្យមើលធម៌ក្នុងធម៌ នៅខាងក្រៅ, ឬ តាំងនៅពិនិត្យមើលធម៌ ក្នុងធម៌ទាំងឡាយ នៅខាងក្នុងផង នៅខាងក្រៅផង ។ តាមរបៀបនេះ ភិក្ខុតាំងនៅពិនិត្យមើលធម៌ដែលកើតឡើងក្នុងធម៌ទាំងឡាយ, ឬ តាំងនៅពិនិត្យមើលធម៌ដែលរលត់បាត់ទៅវិញ នៅក្នុងធម៌ទាំងឡាយ, ឬ តាំងនៅពិនិត្យមើលធម៌ដែលកើតឡើង និង រលត់បាត់ទៅវិញ នៅក្នុងធម៌ទាំង





ឡាយ ក្នុងពេលជំណាលគ្នា ។ សតិដែលដឹងថា “នេះគ្រាន់តែជាធម៌” បានតាំងស៊ប់នៅក្នុងចិត្តរបស់ភិក្ខុ ។ តាមរបៀបនេះ ភិក្ខុខំពង្រីកសតិដឹង របស់ខ្លួនឲ្យរីកចំរើនឡើង រហូតទៅដល់កម្រិតមួយដែលគ្មានអ្វីក្រៅអំពីការយល់ច្បាស់ និង សតិដឹងសុទ្ធសាធនោះឡើយ ។ តាមរបៀបនេះ ភិក្ខុតាំងនៅដាច់ស្រឡះ គ្មានជាប់ជំពាក់ចិត្ត ឬ លោភលន់អ្វី ចំពោះរបស់នៅក្នុលោកនេះ សោះឡើយ ។

ម្នាលភិក្ខុទាំងឡាយ នេះហើយជារបៀប ដែលភិក្ខុតាំងនៅពិនិត្យមើលធម៌ ក្នុងធម៌ទាំងឡាយ ស្តីអំពីអរិយសច្ច ៤ ។

## ៦- សតិបដ្ឋានភាវនានិសង្ស

ម្នាលភិក្ខុទាំងឡាយ! ជាការពិតណាស់ បើបុគ្គលណាម្នាក់ បានចំរើនសតិបដ្ឋានទាំង ៤ ឥតខ្វោះ តាមរបៀបនេះ អស់ ៧ ឆ្នាំ បុគ្គលនោះគង់នឹងបានសំរេចផលណាមួយ ក្នុងចំណោមផលទាំងពីរនេះ ថ្នាក់យ៉ាងខ្ពស់បំផុត គឺ ភាវៈជាព្រះអរហន្ត ឬ បើមានឧបាទានក្ខន្ធនៅសេសសល់ខ្លះ ក៏បានថ្នាក់អនាគាមីដែរ ។

ម្នាលភិក្ខុទាំងឡាយ កុំថាឡើយអស់ ៧ ឆ្នាំ... ។ល។

ម្នាលភិក្ខុទាំងឡាយ កុំថាឡើយអស់ ៦ ឆ្នាំ... ។ល។

ម្នាលភិក្ខុទាំងឡាយ កុំថាឡើយអស់ ៥ ឆ្នាំ... ។ល។

**បដិវេធ** ។

១- **បរិយត្តិ** គឺការសិក្សា ការអាន ទន្ទេញ ស្តាប់ ឲ្យចាំ ឲ្យយល់ពាក្យប្រៀនប្រដៅ របស់ព្រះពុទ្ធ ដែលមានចែងនៅក្នុងព្រះត្រៃបិដក ។

២- **បដិបត្តិ** គឺការប្រតិបត្តិ (អនុវត្តិ) តាមព្រះធម៌វិន័យ សំដៅដល់ការប្រតិបត្តិតាម សីល សមាធិ បញ្ញា មានការចំរើនវិបស្សនាកម្មដ្ឋាន ឬ សតិបដ្ឋាន ជាដើម ។ល។

៣- **បដិវេធ** គឺការចាក់ធ្លុះនៅនាំងអវិជ្ជា ហើយឃើញច្បាស់ត្រៃលក្ខណធម៌ ក្នុងខន្ធ ៥ ថា **អនិច្ចំ ទុក្ខំ អនត្តា** ។

ក្នុងសម័យពុទ្ធកាល សង្ឃសាវកនៃព្រះពុទ្ធ បានប្រតិបត្តិល្អត្រឹមត្រូវ តាមគន្លងធម៌បីប្រការ គឺ បរិយត្តិ, បដិបត្តិ និង បដិវេធ នេះឯង ទើបព្រះសង្ឃទាំងឡាយនោះ បានចាក់ធ្លុះលុះមគ្គផល បានជាអរិយបុគ្គល ឬ លោកុត្តរបុគ្គល ។ អរិយ-បុគ្គល ឬ លោកុត្តរបុគ្គល មានន័យថា បុគ្គលដែលបានចាក់ធ្លុះលុះក្នុងអរិយសច្ច ៤ ឬ លោកុត្តរធម៌ គឺ ធម៌ហួសផុតលោកទាំងបី ។ អរិយបុគ្គល ឬ លោកុត្តរបុគ្គល ពុំមែនមានន័យថាបុគ្គលដែលពូកែចេះចាំពន្យល់អំពីអរិយសច្ច ៤ ឬ លោកុត្តរធម៌ ឬ បរមត្ថធម៌នោះទេ ។ ដើម្បីឆ្លងពីបុថុជ្ជនគោត្រ ទៅរកអរិយ-





បន្ទូលថា “ម្នាលភិក្ខុទាំងឡាយ នេះជាផ្លូវមូលតែមួយគត់ ប្រព្រឹត្តទៅដើម្បីសេចក្តីបរិសុទ្ធិនៃសត្វទាំងឡាយ, ដើម្បីឲ្យបានរួចចាកសេចក្តីសោក និង សេចក្តីខ្សឹកខ្សួលទាំងឡាយ, ដើម្បីកំចាត់បង់នូវសេចក្តីទុក្ខ និង ទោមនស្សទាំងឡាយ, ដើម្បីបានសំរេចនូវអរិយមគ្គ, ដើម្បីឲ្យបានពិសោធឃើញនូវព្រះនិព្វាន, ផ្លូវនេះ គឺ សតិបដ្ឋាន ៤ នេះឯង” ។

ព្រះដ៏មានព្រះភាគ ទ្រង់បានសំដែងហើយយ៉ាងនេះ ។ ភិក្ខុទាំងឡាយ ក៏មានសេចក្តីត្រេកអរ រីករាយនឹងភាសិត របស់ព្រះដ៏មានព្រះភាគ ។

**សព្វរសំ ធម្មរសោ ជិនាតិ**

រសធម៌ រមែងឈ្នះនូវរសទាំងពួង ។

**សព្វរតឹ ធម្មរតិ ជិនាតិ**

សេចក្តីត្រេកអរក្នុងធម៌ តែងឈ្នះសេចក្តីត្រេកអរទាំងពួង ។

**បញ្ញាយ តិត្តិនំ សេដ្ឋំ ន សោ កាមេហិ តប្បតិ**
**បញ្ញាយ តិត្តំ បុរិសំ តណ្ហា ន កុរុតេ វសំ**

បណ្តាសេចក្តីឆ្អែតទាំងឡាយ សេចក្តីឆ្អែតដោយបញ្ញាប្រសើរបំផុត, អ្នកឆ្អែតដោយបញ្ញានុ៎ះរមែងមិនក្តៅក្រហាយដោយកាម, តណ្ហាធ្វើអ្នកឆ្អែតដោយបញ្ញា ឲ្យលុះក្នុងអំណាចមិនបាន ។

# អវសានកថា

ព្រះបរមសាស្តា ទ្រង់មានព្រះទ័យប្រកបដោយ វិសុទ្ធិគុណ បញ្ញាគុណ និង ករុណាគុណ។ ទ្រង់ស្វែងរកសេចក្តីសុខសន្តិភាព ជូនពិភពលោក តាំងតែពីព្រះអង្គបានត្រាស់ដឹង នូវសម្មាសម្ពោធិញ្ញាណមកម្ល៉េះ គឺ ២៥៤៣ ឆ្នាំកន្លងមកហើយ (សតវត្សទី៦ មុនគ្រិស្តសករាជ) ។ ព្រះអង្គទេសនាទូន្មានប្រៀនប្រដៅមនុស្សសត្វ កុំឲ្យបៀតបៀនគ្នា ឲ្យរួមរស់ជាមួយគ្នា ដោយសន្តិភាព ហើយរៀបចំសង្គមឲ្យមានវឌ្ឍនធម៌ និង សីលធម៌ ។ ព្រះអង្គត្រាស់ថា **អព្យាបជ្ឈំ សុខំ លោកេ** ការមិនបៀតបៀនគ្នាជាសុខក្នុងលោក **នត្ថិ សន្តិ បរំ សុខំ** សុខដទៃក្រៅអំពីសេចក្តីស្ងប់មិនមានឡើយ ។

អង្គការសហប្រជាជាតិ យល់តម្លៃព្រះពុទ្ធសាសនា ដែលមានពាក្យប្រៀនប្រដៅដ៏មានខ្លឹមសារ គឺធម៌អហឹង្សា ការមិនបៀតបៀនគ្នា ដែលជាមូលដ្ឋាន នៃសុខសន្តិភាព របស់មនុស្ស ក្នុងពិភពលោក ក៏បានសំរេចអនុម័តឲ្យធ្វើបុណ្យ **ពិសាខបូជា របស់ព្រះពុទ្ធសាសនា** នៅទីស្នាក់ការ **អង្គការសហប្រជាជាតិ តាំងពីថ្ងៃទី ១០ ខែធ្នូ ឆ្នាំ ១៩៩៩ (ព.ស.២៥៤៣)** ។

សេចក្តីសុខសន្តិភាព ទាំងនៅក្នុងបច្ចុប្បន្នកាល ទាំងនៅ





បរលោក ជាកម្មវត្ថុនៃព្រះពុទ្ធទាំងឡាយ ទើបព្រះអង្គមានព្រះពុទ្ធដីកាថា "**សព្វបាបស្ស អករណំ** មិនត្រូវធ្វើបាបគ្រប់យ៉ាង ដែលរាប់បញ្ចូលទៅក្នុង **សីល, កុសលស្សូបសម្បទា** ត្រូវបំពេញបុណ្យកុសល ដែលរាប់បញ្ចូលទៅក្នុង **សមាធិ, សចិត្តបរិយោទបនំ** ត្រូវជំរះចិត្តរបស់ខ្លួនឲ្យស្អាតបរិសុទ្ធផូរផង់ ដែលរាប់បញ្ចូលទៅក្នុង **បញ្ញា** ។ សីល សមាធិ បញ្ញា នេះ គឺជាសេចក្តីបំព្រួញ នៃអដ្ឋង្គិកមគ្គ (មគ្គសច្ច) ដែលជាផ្លូវប្រតិបត្តិឆ្ពោះទៅរកការត្រាស់ដឹងជាព្រះពុទ្ធ និង ការឃើញនូវអរិយសច្ច ៤ នៃព្រះអរហន្តទាំងឡាយ ។

ព្រះពុទ្ធទ្រង់ត្រាស់សំដែងថា "**យោ ធម្មំ បស្សតិ សោ ពុទ្ធំ បស្សតិ** ប្រែថា បុគ្គលណាឃើញធម៌ បុគ្គលនោះឈ្មោះថាឃើញព្រះពុទ្ធ ។ ពាក្យថា **ឃើញធម៌** បានសេចក្តីថា ប្រតិបត្តិពិសោធ ដោយខ្លួនឯង យ៉ាងសុក្រឹត នូវ សីល សមាធិ បញ្ញា នេះឯង ។ មួយទៀត ព្រះសម្ពុទ្ធ សព្វព្រះទ័យបុគ្គលណា ដែលប្រតិបត្តិពិសោធ តាមព្រះធម៌វិន័យ បានត្រឹមត្រូវតាមគន្លងធម៌ ហើយទ្រង់ត្រាស់សរសើរទៀតថា បុគ្គលនោះ បានបូជាព្រះអង្គ ដោយបដិបត្តិបូជា ជាបូជាប្រសើរលើសបូជាដទៃ ។

ធម៌ មានបីប្រការ ឬ បីជំហាន គឺ **បរិយត្តិ, បដិបត្តិ** និង

ដូចគ្នា សមដូចជាភាសិតបរទេសមួយថា **ទ្រឹស្តីដោយគ្មានការអនុវត្តិ គឺដូចជាជនពិការជើង អនុវត្តិដោយគ្មានទ្រឹស្តី គឺប្រហោងខ្លួងឥតបានផល** (Theory without practice is Lame. Practice without theory is empty.)។ ការធ្វើវិបស្សនា ពុំមែនការអង្គុយពែនភ្នែនស្ងៀម ធ្មេចភ្នែក ភ្លេចខ្លួនឈឹង ឥតដឹងអ្វី ឥតគិតពិចារណាអ្វីសោះ ស្រាប់តែកើតបញ្ញា ឃើញច្បាស់នោះទេ ។ បដិបត្តិ ត្រូវពឹងបរិយត្តិ, រីបរិយត្តិ ក៏ត្រូវពឹងបដិបត្តិដែរ តាមរបៀបនេះ ទើបបានទទួលលទ្ធផលល្អ មានសារប្រយោជន៍ ។

ឱសថការី ដ៏ចំណាននទាំងឡាយ ក្នុងលោក បានចម្រាញ់ផ្សំឱសថដ៏ពិសេស សំរាប់ព្យាបាលរោគ តាមផ្លូវកាយ យ៉ាងមានប្រសិទ្ធិភាព ប៉ុន្តែមិនអាចព្យាបាលរោគតាមផ្លូវចិត្តបានឡើយ ។ ចំណែកធម្មឱសថ គឺវិបស្សនាធម៌ ជាឱសថសំរាប់ជួយព្យាបាលរោគខាងផ្លូវចិត្តដោយពិត ។ ដូច្នេះ សាធុជនទាំងប្រុសស្រី កាលបើមានរោគាព្យាធិកើតឡើង ក្នុងករជ្ជកាយ គួរស្វែងរកថ្នាំពេទ្យមកព្យាបាលរោគ ប៉ុន្តែប្រសិនបើជម្ងឺផ្លូវចិត្តដែលកើតឡើងពីកម្ម-វិបាក(ផលនៃកម្ម) ឬក៏ សម្ពាធនៃសង្គម ឬក៏ ទំនាស់ក្នុងគ្រួសារជាដើម គួររកធម៌ជាទីពឹង ចំរើនវិបស្សនាកម្មដ្ឋាន សំអាតចិត្តឲ្យបរិសុទ្ធ ដើម្បីរំងាប់រោគទាំងឡាយនោះ ហើយសោយនូវបីតិ និង





គោត្រ ត្រូវឆ្លងតាមរយៈគោត្រភូញាណ ដែលជាញាណមួយ នៃវិបស្សនាញាណ ពុំមែនឆ្លងតាមរយៈបរិយត្តិ មួយប្រការនោះទេ ទោះបីជាពូកែចេះចាំយល់ន័យព្រះត្រៃបិដកទាំងអស់ក៏ដោយ តែបើខ្វះបដិបត្តិ និង បដិវេធ ពិតជាឆ្លងពីបុថុជ្ជនទៅអរិយជន ពុំរួចឡើយ ។

ព្រះពុទ្ធសាសនា ជាសាសនាកម្មនិយម ជឿបុណ្យ ជឿបាប ជឿកម្មផល ព្រមទាំងបានយក កម្មផល ជាមូលដ្ឋានផង ។ កម្ម (អកុសល និង កុសល) ឲ្យផលរួមគ្នាច្រើនឡើង លោកហៅថា ផលវិបាក ឬ វិបាកវិញ្ញាណ ដែលជាតួបដិសន្ធិ របស់សត្វ នាំឲ្យសត្វមានកំណើតថ្មី ជីវិតថ្មី ។ កម្ម ក្នុងព្រះពុទ្ធសាសនា ស្តីពីអំពើដែលបុគ្គលម្នាក់ៗ ធ្វើដោយកាយ វាចា និង ចិត្ត ហើយមានចេតនាជាដើមចម ។ បើគ្មានបំណង ឬ ចេតនា កម្ម ក៏គ្មានដែរ ។ ចេតនា ជាតួកម្ម ដូចជាព្រះពុទ្ធវចនថា “**ចេតនាហំ ភិក្ខវេ កម្មំ វទាមិ** ប្រែថា ម្នាលភិក្ខុទាំងឡាយ តថាគតហៅថា ចេតនា ជាតួកម្ម” ។ ចេតនា គឺជាគំនិតដែលនាំចិត្តឲ្យភ្ញាក ឲ្យផ្តួចផ្តើម ។ ចេតនានេះ ហើយជាតួចេតសិក ដែលដឹកនាំចិត្តឲ្យចេះគិត ។ អាស្រ័យហេតុនេះ ទើបព្រះមានព្រះភាគទ្រង់ទូន្មានឲ្យសត្វលោកអប់រំចិត្តរបស់ខ្លួនឲ្យបានបរិសុទ្ធផូរផង់ ព្រោះសត្វលោកត្រូវចិត្ត

ដឹកនាំ (**ចិត្តេន នីយតិ លោកោ**) ហើយគឺចិត្តនេះឯង ដែលបុគ្គលទូន្មានបានដោយកម្រ ។ រីឯការជុសខាត់ជម្រះចិត្ត ត្រូវពឹងទៅលើកិច្ចធុរៈពីរយ៉ាង នៃព្រះពុទ្ធសាសនា គឺ **គន្ថធុរៈ** និង **វិបស្សនាធុរៈ** (ធម្មបទ ភាគទី១ យមកវគ្គ) ។

**គន្ថធុរៈ** គឺជាធុរៈមួយផ្នែក ខាងសិក្សាសូត្ររៀនព្រះបរិយត្តិធម៌ គឺព្រះត្រៃបិដក ។ គន្ថធុរៈ នាំឲ្យសិក្ខាជនរីកចំរើនប្រាជ្ញាពីរយ៉ាង គឺៈ សុតមយបញ្ញា និង ចិន្តមយបញ្ញា ។

**វិបស្សនាធុរៈ** គឺជាធុរៈផ្នែកខាងអប់រំទូន្មានចិត្ត ។ វិបស្សនាធុរៈ នាំឲ្យវិបស្សនាយានិក (អ្នកចំរើនវិបស្សនា) ចំរើនបញ្ញាម៉្យាង ឈ្មោះថា ភាវនាមយបញ្ញា ដែលជាបញ្ញាបានមកពីការបដិបត្តិពិសោធផ្ទាល់ខ្លួន ។

**វិបស្សនាធុរៈ** ជាកិច្ចប្រតិបត្តិមួយដ៏សំខាន់ ក្នុងការអប់រំទូន្មានចិត្ត ។ ចិត្ត ជានាមធម៌ ជាធម្មជាតិឃ្លេងឃ្លោងឆាប់កម្រើកញាប់ញ័រ នៅពេលដែលប៉ះទង្គិចនឹងអារម្មណ៍ ពិបាករក្សា ផ្ចុញផ្ដាល់បានដោយកម្រ កើតរលត់រហ័សប្រព្រឹត្តទៅតាមទ្វារ ៦ គឺៈ ទ្វារភ្នែក ត្រចៀក ច្រមុះ អណ្ដាត កាយ និង មនោទ្វារ ។ ចិត្តនេះ កាលបើមិនបានអប់រំ តែងតែលិចចុះទៅក្នុងអំណាចនៃតណ្ហា (សេចក្ដីប្រាថ្នា) ។ កាលបើតណ្ហាគ្របសង្កត់ហើយ ចិត្តតែងតែ





ស្វែងរកអារម្មណ៍ ហើយប្រមូលទុកក្នុងខ្លួនយ៉ាងច្រើន ។

ក្នុងពេលចិត្តស្វែងរកអារម្មណ៍នោះ ជួនកាលក៏ប្រទះនឹងអារម្មណ៍ល្អ ជួនកាលក៏ប្រទះនឹងអារម្មណ៍អាក្រក់ ជាទីគាប់ចិត្តខ្លះ មិនជាទីគាប់ចិត្តខ្លះ ។ ម្ល៉ោះហើយសេចក្ដីសោក ខ្សឹកខ្សួលទុក្ខទោមនស្ស ឬ សេចក្ដីសុខសោមនស្ស ស្រស់ស្រាយ ក៏កើតឡើង ក្នុងចិត្តរឿយៗ ។ កាលបើចិត្តមានភាពប្រែប្រួល ទៅតាមខ្សែអារម្មណ៍ដូច្នេះហើយ សត្វលោកទាំងអស់ តែងទទួលរងនូវសេចក្ដីទុក្ខគ្រប់យ៉ាង ។

នៅក្នុងលោកនេះ ធម៌សំរាប់រំដោះខ្លួន ឲ្យចេញផុតចាកសេចក្ដីទុក្ខ គ្មានធម៌អ្វីក្រៅពីវិបស្សនាឡើយ ។ វិបស្សនានេះជួយសង្កត់សង្កិន នូវតណ្ហា ឲ្យចុះទ្រុឌទ្រោម កុំឲ្យរីករាលដាលទៅបាន ។ តណ្ហា ជាប្រភពនៃសេចក្ដីទុក្ខ ។ ព្រះពុទ្ធអង្គទ្រង់ត្រាស់ថា “ទឹកសមុទ្រមានជោរ មាននាច រីឯតណ្ហា របស់សត្វលោក គ្មានចេះនាចសោះឡើយ” ។

សូមកុំភ្លេចថា ការអប់រំចិត្ត ត្រូវតែពឹងលើ គន្ថធុរៈ និង វិបស្សនាធុរៈ ។ ធុរៈទាំងពីរនេះ ត្រូវពឹងគ្នាទៅវិញទៅមក មិនអាចអត់មួយ មានមួយបានឡើយ ព្រោះ **ទ្រឹស្ដីដោយគ្មានការអនុវត្តិ** និង **អនុវត្តិ ដោយគ្មានទ្រឹស្ដី** មិនសូវមានប្រយោជន៍

ទាំងឡាយមិនរើសមុខ មិនរើសវណ្ណៈ មិនរើសនិកាយ... ។ ចំណែកបច្ចុប្បន្ននេះវិញ ព្រះពុទ្ធសាសន៍នេះ ក៏នៅតែសម្រាប់មនុស្សទូទៅ លើពិភពលោក ដោយគ្មានរើសអើងពូជសាសន៍ និកាយ ដូចក្នុងអតីតកាលដដែល ។ អាស្រ័យហេតុនេះ បានជាមជ្ឈមណ្ឌលវិបស្សនាអន្តរជាតិ រីករាលដាលដុះដូចផ្សិត ជាសក្ខីភាព បង្ហាញថា ព្រះពុទ្ធដីកា ត្រូវបានគេអនុវត្ត យ៉ាងយកចិត្តទុកដាក់ ហើយបានទទួលផលភ្លាមៗមិនរើសពេលវេលា(អកាលិកោ) ទៀតផង ។

សរុបសេចក្តីមក ព្រះពុទ្ធសាសនា ជាមាគ៌ានៃជីវិត និង ជាចរិយាវិទ្យា សំរាប់ជីវិត ព្រោះព្រះពុទ្ធសាសនា ទូន្មានមនុស្សឲ្យប្រុងប្រយ័ត្ន កុំឲ្យធ្វេសប្រហែស (អប្បមាទធម៌) កុំឲ្យស្រវឹង (អមទធម៌) ឲ្យប្រកបព្រមដោយសម្បទា ៤ គឺ **ឧដ្ឋានសម្បទា** (បរិបូណ៌ដោយសេចក្តីព្យាយាមប្រឹងប្រែង ប្រកបការងារមិនខ្ជិលប្រអូស មិនក្រាញ, ២- **អារក្ខសម្បទា** (ជល់ព្រមដោយការចេះថែរក្សាកាន់កាប់ទ្រព្យសម្បត្តិ កុំឲ្យវិនាស ដោយប្រការផ្សេងៗ), ៣- **កល្យាណមិត្តតា** (សេពគប់រាប់អានរកមិត្តដែលល្អ ស្មោះស ទៀងត្រង់ ត្រឹមត្រូវ មានប្រាជ្ញា ចេះជួយគ្នាទៅវិញទៅមក), ៤- **សមជីវិតា** (ចិញ្ចឹមជីវិតត្រឹមត្រូវតាមគន្លងធម៌ និង ច្បាប់ ហើយ





សុខៈ និង រស់នៅក្នុងសង្គមប្រកបដោយភាពស្រស់ស្រាយ និង ដោយក្តីសង្ឃឹម ។

វិបស្សនា មិនត្រឹមតែជួយមនុស្ស ឲ្យជារោគតាមផ្លូវចិត្តប៉ុណ្ណោះទេ ថែមទាំងជួយសម្រុះសម្រួល ដល់សង្គមមនុស្ស ឲ្យចេះរស់នៅជាមួយគ្នាដោយគ្មានទំនាស់។ ព្រោះហេតុអ្វី? ព្រោះថា វិបស្សនា ដែលមានន័យថា "ឃើញរបស់ទាំងឡាយតាមភាពពិតរបស់វា" នេះ កាលបើមនុស្សនៅក្នុងសង្គម អប់រំបំរើន ឲ្យបានច្រើនឡើងៗ ហើយ មនុស្សក្នុងសង្គម នឹងអាចឃើញនូវសេចក្តីពិតបាន ឃើញថា អត្តភាពនៃមនុស្សម្នាក់ៗ គ្មានសារសំខាន់អ្វីឡើយ មានត្រឹមតែខន្ធ ៥ អាយតនៈ ១២ ធាតុ ១៨ ឬ ធាតុ ៤ គឺ ដី ទឹក ភ្លើង ខ្យល់ ប្រជុំតាត់តែងក្នុងទីជាមួយគ្នា ឬ ឃើញត្រឹមតែសង្ខារធម៌ មានកិរិយាកើតឡើង វិនាសទៅវិញជាធម្មតា មិនឃើញមាន សត្វ បុគ្គល ស្រី ប្រុស ចិន ចាម ជ្វា ខ្មែរ ថៃ បារាំង អាមេរិកាំងឡើយ ។ កាលបើសង្គមបានឃើញនូវសភាវៈពិត ដូចបានពោលមកហើយ ក៏នាំគ្នាឈប់ប្រកាន់គ្នានឹងគ្នា ហើយក៏ចែកគ្នារស់ ដោយស្រួលទៅវិញទៅមកក្នុងក្របខណ្ឌនៃសីលធម៌ ដែលហៅថា សិល្បៈនៃការរស់នៅ (The art of living ) គឺរស់នៅក្នុងសុខសន្តិភាព ។

សព្វថ្ងៃនេះ ព្រះពុទ្ធសាសនា មានឥទ្ធិពលខ្លាំងណាស់ទៅលើប្រទេសនៅអឺរ៉ុប និងនៅ អាមេរិក ។ ជនជាតិនៃប្រទេសទាំងនោះ ចូលកាន់ព្រះពុទ្ធសាសនាមានច្រើនណាស់ ហើយអ្នកដែលចូលនោះ ភាគច្រើនជាអ្នកចេះដឹង ដូចជាបណ្ឌិតសាស្ត្រាចារ្យ មេធាវី វិស្វករ ជាដើម ។ មុននឹងសំរេចចិត្តចូល ពួកគេបានទៅសិក្សាព្រះពុទ្ធសាសនា នៅប្រទេស ស្រីលង្កា ថៃ ភូមា និងឥណ្ឌា ហើយបានស្រាវជ្រាវអានសៀវភៅព្រះពុទ្ធសាសនា ជាច្រើនក្បាល ក៏យល់ដឹងច្បាស់ថា ព្រះពុទ្ធសាសនា មានពាក្យប្រៀនប្រដៅ ដ៏ជ្រាលជ្រៅណាស់ មានហេតុផល តាមលក្ខណៈវិទ្យាសាស្ត្រ ហើយជាញាណទស្សនវិជ្ជា អាចរំដោះទុក្ខបាន។ មិនត្រឹមតែរៀនខាងទ្រឹស្តីទេ ពួកគេចូលចិត្តអនុវត្តផ្នែកវិបស្សនា ការអប់រំចិត្ត ដើម្បីឲ្យឃើញការពិត ជាខ្លឹមសារ នៃព្រះពុទ្ធសាសនា ដើម្បីឲ្យដល់គោលដៅគឺព្រះនិព្វាន ជាការរំលត់ទុក្ខ ផងដែរ ។

មិនតែប៉ុណ្ណោះ ពួកគេទាំងអស់នេះ ដែលមកអំពីនិកាយផ្សេងៗ បានយល់យ៉ាងច្បាស់ថា ព្រះពុទ្ធពុំដែលបង្រៀននិកាយសាសនាណាមួយ លទ្ធិនិយមណានីមួយទេ ព្រះអង្គបានបង្រៀនតែព្រះធម៌ គឺមាគ៌ារំដោះខ្លួនពីសេចក្តីទុក្ខ ដែលជាធម៌សាកល ។ គេដឹងទៀតថា ទុក្ខកើតមកពីកិលេសតណ្ហា កាលបើកិលេស-





តណ្ហា ធ្វើចិត្តឲ្យសៅហ្មងហើយ សេចក្តីសៅហ្មងនោះ មិនមែនជាចិត្តសៅហ្មងរបស់ពុទ្ធបរិស័ទ គ្រិស្តបរិស័ទ មូស្លិមបរិស័ទ ហិនឌូបរិស័ទ... តែប៉ុណ្ណោះទេ គឺជាចិត្តហ្មងសៅរបស់អ្នកដែលមិនបានអប់រំជម្រះចិត្តឲ្យបរិសុទ្ធ ក្នុងពិភពលោក ។ ចំណែកមធ្យោបាយតែមួយគត់សំរាប់សំអាតចិត្ត គឺវិបស្សនា ហើយមិនមែនសម្រាប់តែពុទ្ធសាសនិកប៉ុណ្ណោះទេ គឺសម្រាប់មនុស្សជាតិគ្រប់សាសន៍និកាយ លើពិភពលោកផងដែរ ។

ពួកគេយល់យ៉ាងច្បាស់ទៀតថា តាមរយៈ វិបស្សនា មនុស្សគ្រប់ជាតិសាសន៍ អាចធ្វើចិត្តរបស់ខ្លួនឲ្យបរិសុទ្ធ ហើយចិត្តបរិសុទ្ធ តែងពោរពេញទៅដោយមេត្តាធម៌ ចំពោះជនទូទៅពោរពេញទៅដោយករុណាធម៌ ចំពោះភាពទន់ខ្សោយ និង រាល់សេចក្តីទុក្ខរបស់អ្នកដទៃ បរិបូណ៌ដោយឧបេក្ខា ក្នុងការប្រឈមមុខ ចំពោះស្ថានភាពផងទាំងពួង ។ និយាយរួម អ្វីៗដែលព្រះពុទ្ធទ្រង់បានប្រៀនប្រដៅ គឺជាសិល្បសាស្ត្រ នៃការរស់នៅសុខដុមរមនា និង ជាវិទ្យាសាស្ត្រខាងផ្លូវកាយ និង ចិត្ត ដោយពិត ។

ក្នុងពុទ្ធសម័យ វិស័យពុទ្ធសាសនា រីកសាយភាយ យ៉ាងឆាប់រហ័ស ក្នុងប្រទេសឥណ្ឌា ដោយសារតែព្រះពុទ្ធអង្គ ទ្រង់សម្តែងពីសច្ចធម៌ (ធម្មជាតិពិតជាសកល) ប្រោសទូន្មានបុគ្គល

ពិភពលោក និង គ្រោះថ្នាក់ធម្មជាតិទាំងឡាយ បរវៀសចៀស ឆ្ងាយពីដែនដីខ្មែរ ។

**សព្វេ សត្តា អវេរិនោ ហោន្តុ**

សូមសត្វលោកទាំងឡាយទាំងពួង កុំឲ្យមានពៀរនឹងគ្នា

**សព្វេ សត្តា ខេមិនោ ហោន្តុ**

សូមសត្វលោកទាំងឡាយទាំងពួងបានដល់នូវសេចក្តីក្សេមក្សាន្ត

**សព្វេ សត្តា សុខិនោ ហោន្តុ**

សូមសត្វលោកទាំងឡាយទាំងពួងបានប្រកបដោយសេចក្តីសុខ ជានិច្ចនិរន្តរ៍ ។

**ចប់ដោយសន្តិ**

សរសេរចប់នៅ ឡុងប៊ិច រដ្ឋកាលីហ្វូញ៉ា ស.អ.រ.

Long Beach California U.S.A.

ថ្ងៃ ១០ រោច ខែពិសាខ ឆ្នាំឆ្លូវ ឯកស័ក ព.ស. ២៥៥៣

ត្រូវនឹងថ្ងៃទី ១៨ ខែឧសភា គ.ស. ២០០៩

ឈុន-គឹមអៀត





លែលក ចាយវាយធនធាន មិនខ្វះខ្វាយ ឥតបើគិត) ឲ្យយកខ្លួនជាធំ យកខ្លួនជាទីពឹងរបស់ខ្លួន (**អត្តា ហិ អត្តនោ នាថោ**) កុំមើលងាយអត្តភាពរបស់ខ្លួន ទៅពឹងអ្នកដទៃ កុំធ្វើជាស្រមោល ឬ អាយ៉ងនៃអ្នកដទៃ ។

គួរជ្រាបថា ព្រះសម្ពុទ្ធ ពុំអាចប្រោសសត្វដែលមានសីល-ព្វតបរាមាសសំយោជន (ការប្រកាន់ជាប់ នូវសីលវត្តិប្រតិបត្តិដោយធ្វើតាមគ្នាយ៉ាងងិតងងល់ ហើយយល់ថា អាចជួយឲ្យរួចទុក្ខបាន) មានវិធីបន់ស្រន់អង្វរករ វិធីសូត្រ (Pray) ជាដើមបានទេ ។ ព្រះអង្គថែមទាំងបន្ទោសទៀតថា អំពើទាំងនេះ គឺជាការបន្ទោកបន្ទាបខ្លួន ហើយពុំអាចយឹតយោង ស្រោចស្រង់ខ្លួន បានឡើយ ។ ផ្ទុយទៅវិញ ធម៌របស់ព្រះអង្គ ជាធម៌ស្រោចស្រង់ខ្លួនឯង គឺនិយ្យានិកធម៌ ប្រែថា សេចក្តីបរិសុទ្ធិ ត្រូវធ្វើដោយខ្លួនឯង ។ ព្រះអង្គទ្រង់ត្រាស់ទុក នៅក្នុងមហាបរិនិព្វានសូត្រថា "**ភិក្ខវេ អត្តទីបោ វិហរថ អត្តសរណា អនញ្ញសរណា** ប្រែថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរយកខ្លួនជាកោះពឹងខ្លួនឯង ចូរយកខ្លួនជាទីពឹង ចូរកុំយកអ្នកដទៃមកធ្វើជាទីពឹងខ្លួនឡើយ" ។

ម៉្យាងទៀត ធម៌(ព្រះត្រៃបិដក) ដែលព្រះសម្ពុទ្ធទ្រង់សំដែងប្រោសសត្វ ដោយពិត មិនមែនជាគ្រឿងតាំងទុកសំរាប់លំអ នៅ

ក្នុងទូ ឬ បណ្ណាល័យទេ ឬ នឹងថា ជាធម៌ ឬ វិជ្ជាសំរាប់សិក្សា បែបជាប្រវត្តិសាស្ត្រ បែបជាអក្សរសាស្ត្រ ក៏ពុំមែនដែរ ឬក៏ នឹងថា រក្សាទុកសំរាប់អ្នកប្រាជ្ញ ឬ ពួកបញ្ញវន្តទាំងឡាយ ក៏ទេដែរ ។ ធម៌របស់ព្រះអង្គជាធម៌សំរាប់សិក្សាឲ្យចេះដឹង ហៅថា **បរិយត្តិធម៌** (រៀនសូត្រឲ្យចេះដឹង) រៀនសូត្រចេះដឹងហើយ ត្រូវតែប្រតិបត្តិតាម ហៅថា **បដិបត្តិធម៌** (ធ្វើតាមធម៌ដែលបានរៀនសូត្រចេះដឹង) បើបានប្រព្រឹត្តប្រតិបត្តិត្រឹមត្រូវតាមគន្លងធម៌នេះហើយ នឹងបានផល គឺការត្រាស់ដឹង "**សម្មាសម្ពោធិញ្ញាណ**" ហើយបានសំរេច **មោក្ខធម៌** (ការរួចចាកទុក្ខទាំងពួង) ហៅថា **បដិវេធ** (ការត្រាស់ដឹងធម៌) បានសេចក្ដីថា ធម៌ព្រះអង្គនេះ សំរាប់រៀនឲ្យចេះ ចេះហើយធ្វើតាម ធ្វើតាមហើយ បានផលផ្លែផ្កា គឺសេចក្ដីសុខនៅក្នុងបច្ចុប្បន្នជាតិនេះឯង និង ជាដំណើរដើរទៅកាន់បរម-សុខ នៅក្នុងលោកុត្តរធម៌ផង ។

ដូច្នេះ ធម៌របស់ព្រះអង្គ ពុំមែនគ្រាន់តែល្អមើលទេ គឺទុកជានាវាសំរាប់ជិះឆ្លង ហើយចម្លងសត្វ ឲ្យឆ្លងផុតអន្លង់ទុក្ខ គឺមហាសាគរ ដែលហៅថា "**វាលវដ្តសង្សារ**" (ការអន្ទោលកើតស្លាប់) ។ នាវា មានពីរយ៉ាងគឺ **នាវាត្រៃលោក** និង **នាវាត្រៃលក្ខណ៍** ។ មនុស្សសព្វថ្ងៃ ចូលចិត្តជិះនាវាត្រៃលោក ជាង





នាវាត្រៃលក្ខណ៍ ។

ប៉ុន្តែ ទោះជាក្នុងករណីយណាក៏ដោយ ព្រះពុទ្ធបរមគ្រូព្រះអង្គពុំអាចអូសទាញសត្វដែលគ្មានឧបនិស្ស័យ យកទៅដាក់ដល់ស្ថានសួគ៌ ឬ ស្ថានបរមសុខ គឺព្រះនិព្វានបានទេ បើសត្វទាំងឡាយនោះ មិនប្រតិបត្តិត្រឹមត្រូវដោយខ្លួនឯង នូវ សីល សមាធិ បញ្ញា ។ ព្រះអង្គទ្រង់សំដែងក្នុងធម្មបទថា "**តុម្ហេហិ កិច្ចមាតប្បំ អក្ខាតារោ តថាគតា** ប្រែថា អ្នកទាំងឡាយ ត្រូវធ្វើការឲ្យបានសំរេចដោយខ្លួនឯង តថាគត គ្រាន់តែជាអ្នកប្រាប់ផ្លូវ" ។

ជាអវសាន ខ្ញុំសូមឲ្យមិត្តអ្នកអានបានជួបប្រទះនូវពុទ្ធពរទាំងឡាយ ៤ ប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។

សូមឲ្យព្រះពុទ្ធសាសនា គង់វង្សស្ថិតស្ថេរ យឺនយូរ គ្រប់កំណត់ ៥,០០០ ព្រះវស្សា ដើម្បីជាម្លប់សាខាត្រជាក់ត្រជុំ ដល់សត្វនិករ ក្នុងត្រៃភព ។

សូមឲ្យព្រះរាជាណាចក្រកម្ពុជា ស្ថិតនៅ ក្នុងសេចក្ដីសុខសន្តិភាព ប្រាសចាកសង្គ្រាម ជានិច្ចនិរន្តរ៍ ។ សូមឲ្យវឌ្ឍនភាពសុខមាលភាព សុភមង្គល កើតមានដល់ប្រជាពលរដ្ឋខ្មែរទូទាំងប្រទេស ។ សូមឲ្យជម្ងឺកាចសាហាវផ្សេងៗ ដែលកំពុងរាតត្បាត

| | |
|---|---|
| លោក ង៉ូវ-គា និង អ្នកស្រី ឈុន-គីមអេង | ១០០ដុ |
| ឧបាសកឈុន-ស៊ី ឧបាសិកា គី-ឈុីវអ៊ី និង បុត្រ | ១០០ដុ |
| ឧបាសិកា ឃីន-សារ៉ាត ព្រមទាំងបុត្រ | ១០០ដុ |
| ឧបាសិកា អៀប-ឆៃហុង | ១០០ដុ |
| ឧបាសក ថោ-ឃៀម ឧបាសិកា ខ្វៅ-កែវ និង បុត្រ | ១០០ដុ |
| ឧបាសិកា កែវ-ហៀម | ១០០ដុ |
| ភិក្ខុវិនយធរោ មហាឃិន-នឿន | ១០០ដុ |
| លោក លឹម-សៀកអាំង និង អ្នកស្រី លឹម-សុខង៉ោ | ៧០ដុ |
| លោក តោ-ប៊ុនហ៊ុយ និង អ្នកស្រី សុខ-ថាន | ៥០ដុ |
| ឧបាសិកា តាន់-ឡើយ ព្រមទាំងបុត្រ | ៥០ដុ |
| លោក BOB និង អ្នកស្រី ហុង-គីមហ៊្វរ | ៥០ដុ |
| ឧបាសិកា នីវ-ស៊ីវហ៊ែរ ព្រមទាំងចៅ | ៥០ដុ |
| ឧបាសិកា អ៊ុន-សំខាន់ ព្រមទាំងបុត្រ | ៥០ដុ |
| លោក អ៊ឹង-កុសល និង អ្នកស្រី ហុង-គីមនី | ៥០ដុ |
| លោក នូ-យុទ្ធារៈ និង អ្នកស្រី ហុង-គីមណា | ៥០ដុ |
| លោក LANCE និង អ្នកស្រី ហុង-គីមណាន | ៥០ដុ |
| លោក ហ៊ល-ប៉ុន | ៥០ដុ |
| លោក ចេង-អៀងលី និង អ្នកស្រី សុង-ទូច | ៤០ដុ |
| លោក ជា-សាន និង អ្នកស្រី ចាប-ខេង | ៣០ដុ |
| ឧបាសិកា សុខា | ៣០ដុ |



# ឈ្មោះសៀវភៅដែលខ្ញុំបានដកស្រង់


Buddhism by Richard.A.Goard.
Buddha the Intelligent Heart by Alistair Shearer.
Teaching of the Buddha by Jack Kornfield.
Sermons and Sayings of the Buddha by Sudhakar Dikshit.
Foundation of Buddhist Meditation by Kalu Rinpoche.
Gautama Buddha by Latitha A. Shetty.
What the Buddha Taught. by Walpola Rahula.
The Word of the Buddha. by Nyanatika Mahathera.
The circle of Karma by Joshua Mack.
The power of Mindfulness by Nyanaponika Thera.
Shakyamuni Buddha by Nikkyo Niwano.
Buddhist Meditation and Depth Psychology.

| | |
|---|---|
| បឋមវិបស្សនា មធ្យមវិបស្សនា | ឧត្តមវិបស្សនា ព្រះកេតុធម្មោ សំ-ប៊ុនធឿន |
| ពន្លឺវិបស្សនាកម្មដ្ឋាន | ពុទ្ធសាសនបណ្ឌិត្យ |
| កម្មដ្ឋាននិទ្ទេស | ព្រះគ្រូធម្មបណ្ឌិត គង់-ស៊ីម |
| ប្រស្នាសមថ-វិបស្សនា ភាគ ២-៣ | ភិក្ខុ ងិន-ភេន ឥន្ទបញ្ញោ |
| វិបស្សនាកម្មដ្ឋានសង្ខេប | " |
| សមថកម្មដ្ឋាន និង វិបស្សនាកម្មដ្ឋាន | ព្រះតេជព្រះគុណបណ្ឌិត ហុក-សាវណ្ណ |
| សេចក្តីស្លាប់ ខន្ធមារ | " |
| អត្ថបទព្រះធម៌ ភាគ ១-២-៣ | " |
| ពង្រឹងព្រះពុទ្ធសាសនានៅកម្ពុជា | " |
| ខន្ធ ៥ | ភិក្ខុ ងិន-ភេន ឥន្ទបញ្ញោ |
| ឧបករណ៍ សមថវិបស្សនា | " |
| ព្រះសិរិអារ្យមេត្រីយ៍ | " |
| កម្មផល | " |
| កើតស្លាប់ | " |
| ពុទ្ធសាសន៍ សង្ខេប | សម្តេចព្រះពោធិវង្ស ហួត-តាត វិជិរប្បញ្ញោ |
| ប្រស្នាត្រៃគុណ | អាចារ្យ ឈឹម-ទូច |

| | |
|---|---|
| សាសនសុភាសិត ភាគ ១-២-៣ | ពុទ្ធសាសនបណ្ឌិត្យ |
| អត្ថាធិប្បាយ សាសនសុភាសិត | សែម-សូរ |
| អភិធម្មត្ថាធិប្បាយ | សម្តេចព្រះធម្មលិខិត ល្វី-ឯម |
| អភិធម្មត្ថសង្គហ: | ធម្មាចារ្យ រស់-សុផាត |
| អភិធម្មត្ថសង្គហ: | ធម្មាចារ្យ កែវ-វិមុត |
| ពន្លឺពុទ្ធសាសនា | ឧបាសក សោម-ងន |
| អរិយសច្ច ៤ | ឆឹង-ផាន់សុផុន |
| មហាសតិបដ្ឋានសូត្រ | វិជ្ជាស្ថានស្រាវជ្រាវវិបស្សនាអន្តរជាតិ |
| ឧបនិស្ស័យ | ម៉ិញ-សាវ៉ាន |
| អភិធម្មត្ថសង្គហ: | ព្រះឧត្តមមុនី អ៊ុំ-ស៊ូរ |
| ទ្រឹស្តីកម្មផល | ឈុន-គីមអៀត |
| ព្រះពុទ្ធសាសនាដូចម្តេច? | ព្រះវីរិយបណ្ឌិតោ ប៉ាង-ខាត់ |

## សេចក្តីជូនដំណឹង

បើពុទ្ធបរិស័ទ ត្រូវការសៀវភៅ **ព្រះពុទ្ធដីកា** នេះ ចែកជាធម្មទាន

សូមទាក់ទងជាមួយនឹង

**-ភិក្ខុ យិន-នឿន** វត្តខ្មែរសាន់តាអាណា 2630 N. Grand Ave.
Santa Ana, CA 92705 (714) 744-2834 U.S.A.

**-លោក ង៉ូវ-គា** ផ្ទះលេខ: 256 ក្រុមទី 9 ភូមិទួលតាឯក ឃុំតាទួលឯក
ស្រុកបាត់ដំបង ខេត្តបាត់ដំបង ទូរស័ព្ទ: 012-726-856

**-លោក ហុង-ប៊ូហ៊ីន** ផ្ទះលេខ: 13 FE. ផ្លូវលេខ 146
សង្កាត់វាលវង់ ខណ្ឌ ៧ មករា ភ្នំពេញ
ទូរស័ព្ទ: 012-245-476



## បញ្ជីរាយនាមពុទ្ធបរិស័ទ ដែលមានសទ្ធាជ្រះថ្លា ចូលបច្ច័យបោះពុម្ពផ្សាយ ចែកចាយជាធម្មទាន នៅលើកទី១ នេះ :

| | |
|---|---|
| លោកឈុន-គីមអៀត និង អ្នកស្រី តូ-ប៊ុនឡាំ | ១,០០០ដុ |
| ឯកឧត្តម ហុង-ទូហាយ និង លោកជំទាវ តាន់-គីមស៊ិន | ៣០០ដុ |
| លោក នូ-សំបាន និង អ្នកស្រី នូ-សំបូរ | ៣០០ដុ |
| លោក ធម-គីមហ៊ិន និង អ្នកស្រី ឃី-គីមលាង | ៣០០ដុ |
| លោក ភាត-សុខុម និង អ្នកស្រី កុល-មល្លិកា | ៣០០ដុ |
| លោក ឈុន-សុភាន និង អ្នកស្រី សំ-ផល្លី | ៣០០ដុ |
| ឧបាសិកា ម៉ៅ-កាក់ ព្រមទាំងបុត្រ | ៣០០ដុ |
| លោក ហុង-កុកហ៊្វីរ និង អ្នកស្រី ទឺ-ហុងសាម៉ុន | ២០០ដុ |
| លោក សេង-យន់ និង អ្នកស្រី គីម-ហាន់ | ២០០ដុ |
| លោក ឈួន-ច័ន្ទធាយា និង អ្នកស្រី សេង-សំណាង | ២០០ដុ |
| លោក លឹម-សេប៉ាង និង អ្នកស្រី អ៊ីវ-ប៉ុកនី | ២០០ដុ |
| ឧបាសក ឡូ-ប៊ុនឡេង ឧបាសិកា អៀប-ឆៃគីម | ២០០ដុ |
| លោក ដាញ់-វីរ៉ាវុឌ្ឍ អ្នកស្រី ឡេង-សោភ័ណ និង បុត្រី | ២០០ដុ |
| លោក ខៀវ-ស៊ីណារេត និង អ្នកស្រី ឡាង-រ៉ាន់នីសា | ១២០ដុ |
| អ្នកស្រី កែម-ចាន់ ព្រមទាំងបុត្រ | ១០០ដុ |
| លោក សៅ-សាត អ្នកស្រី ហង្ស-សុខលីន ព្រមទាំងបុត្រី | ១០០ដុ |
| ឧបាសក ទឺ-ពោ និង ឧបាសិកា ជន-ម៉ន | ១០០ដុ |
| អ្នកស្រី ហុង-គីម ហ៊ៅ | ១០០ដុ |

សូមសប្បុរសជន ទទួលនូវផលានិសង្សដែលកើតឡើង ពីធម្មទាននេះ ដោយចិត្តប្រាមោទ្យ ជ្រះថ្លា ប្រាថ្នាយ៉ាងណា សូមឲ្យបានសម្រេចដូចបំណង ។

សូមសេរីសួស្តី ជ័យមង្គល វិបុលសុខ មហាប្រសើរ កើតមានឡើង ដល់អស់លោកអ្នក ជាពុទ្ធបរិស័ទ ជានិច្ចនិរន្តរ៍ រហូតកាលាវសាន ។

**សព្វទានំ ធម្មទានំ ជិនាតិ**

*ធម្មទាន ឈ្នះអស់ទានទាំងពួង ។*

**មនាបទាយី លភតេ មនាបំ**

*អ្នកឲ្យរបស់ដែលគាប់ចិត្ត រមែងបានរបស់ដែលគាប់ចិត្តវិញ ។*

**សេដ្ឋន្ទទោ សេដ្ឋមុបេតិ ឋានំ**

*អ្នកឲ្យទីឋានដ៏ប្រសើរ រមែងចូលទៅដល់ទីឋានដ៏ប្រសើរ ។*

**នត្ថិ ចិត្តេ បសន្នម្ហិ អប្បកា នាម ទក្ខិណា**

*កាលបើចិត្តជ្រះថ្លាហើយ*

*ទក្ខិណាទានមិនឈ្មោះថាតិចតួចឡើយ។*

**វិចេយ្យ ទានំ សុគតប្បសត្ថំ**

*ពិចារណាហើយឲ្យ ព្រះសុគតទ្រង់សរសើរ ។*